ព្រះរាជាណាចក្រកម្ពុជា

— ជាតិ សាសនា ព្រះមហាក្សត្រ —

ក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា

## ការសិក្សាស្តីពី

# ការអនុវត្តការថែទាំជំនួស ចំពោះកុមារ

## តាមសហគមន៍ក្នុងប្រទេសកម្ពុជា



រៀបរៀងដោយ Carolyn Hamilton, Kara Apland, Maurice Dunaiski និង Elizabeth Yarrow

@ Coram Children’s Legal Centre (CCLC) 2017

ឧបត្ថម្ភដោយ ៖
អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា សហការជាមួយ
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ដើម្បីបង្កើនគុណភាពសេវាថែទាំជំនួសចំពោះកុមារនៅសហគមន៍ឱ្យកាន់តែល្អប្រសើរឡើង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) ប្រចាំកម្ពុជា បានប្រគល់ជូនអង្គការ Coram International ឱ្យធ្វើការសិក្សាប៉ាន់ប្រមាណពីការប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ ដោយធៀបទៅនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៨។

ការសិក្សានេះបានផ្តល់នូវរបកគំហើញចំណុចវិជ្ជមាននិងអវិជ្ជមាន និងផ្តល់អនុសាសន៍ល្អៗសម្រាប់ក្រសួង ស.អ.យ និងអង្គការដៃគូពាក់ព័ន្ធ ធ្វើការពិនិត្យ និងកែសម្រួលការថែទាំដោយសាច់ញាតិ និងការថែទាំដោយឪពុកម្តាយធម៌ ការថែទាំតាមវត្តអារាម ផ្ទះស្នាក់នៅជាក្រុម និងអន្តេវាសិកដ្ឋាន។ ទន្ទឹមនឹងនេះក៏មានការស្នើឱ្យបង្កើនចំនួនបុគ្គលិកអាជីពសង្គមកិច្ច និងពាក់កណ្តាលអាជីពក្នុងក្រសួង និងអង្គការដៃគូពាក់ព័ន្ធ ដើម្បីគ្រប់គ្រងករណី និងផ្តល់សេវាគាំទ្រចាំបាច់ដល់កុមារ និងគ្រួសារងាយរងគ្រោះបំផុតនៅតាមសហគមន៍។ បន្ថែមលើនេះទៀតមានការផ្តល់យោបល់លើផែនការសមាហរណកម្មកុមារ ៣០ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារវិញដោយសុវត្ថិភាពពីឆ្នាំ២០១៦-២០១៨ និងការអនុវត្តអនុក្រឹត្យលេខ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ៣៤ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

ក្រសួង ស.អ.យ នឹងយកអនុសាសន៍ទាំងនេះមកសិក្សាបន្ថែម ហើយនឹងសហការជាមួយក្រសួង និងអង្គការដៃគូពាក់ព័ន្ធ និងអនុវត្តជាបន្តបន្ទាប់ទៅតាមលទ្ធភាពជាក់ស្តែងសម្រាប់រយៈពេលខ្លី និងរយៈពេលវែង ដើម្បីទប់ស្កាត់ការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ និងបង្កើនគុណភាពសេវាថែទាំជំនួសចំពោះកុមារផ្សេងគ្នាតាមសហគមន៍ឱ្យកាន់តែប្រសើរឡើង។

ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងទីភ្នាក់អភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) ប្រចាំកម្ពុជា ចំពោះការគាំទ្រដល់ការថែទាំកុមារនៅកម្ពុជា និងសូមសម្តែងនូវការកោតសរសើរដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនរដ្ឋាភិបាលពាក់ព័ន្ធ ដែលបានគាំទ្រ និងផ្តល់ធាតុចូលដល់ការសិក្សានេះឱ្យសម្រេចបានជោគជ័យ។

ថ្ងៃ ព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៨

រដ្ឋមន្ត្រី

វង សូថ

# សេចក្ដីសង្ខេប

## សេចក្ដីផ្ដើម

របាយការណ៍នេះ បង្ហាញអំពីគំហើញនៃការសិក្សាស្ដីពីការអនុវត្ត ការថែទាំជំនួសចំពោះកុមារតាមសហគមន៍ក្នុងប្រទេសកម្ពុជា ដោយរាប់បញ្ចូលការថែទាំតាមវត្តអារាមផងដែរ។ ការសិក្សានេះបានទទួលការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ) និង ត្រូវបានធ្វើឡើងដោយ វិទ្យាស្ថាន កូរ៉ាមអន្តរជាតិ ក្នុងឆ្នាំ២០១៦។ ដោយមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដោយអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា និង USAID។

ការសិក្សានេះ គឺជាការសិក្សាលើកដំបូងអំពីការអនុវត្តការថែទាំជំនួសតាមសហគមន៍ក្នុងប្រទេសកម្ពុជា និងបានធ្វើការប៉ាន់ប្រមាណអំពីការប្រើប្រាស់ទម្រង់ផ្សេងៗគ្នានៃការថែទាំជំនួសចំពោះកុមារ ក្នុងសហគមន៍ ការអនុវត្តបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ឆ្នាំ២០០៨ និងបទដ្ឋានអន្តរជាតិនានា ព្រមទាំងបានរកឃើញ ចំណុចផ្សេងៗទៀតដែលត្រូវការឱ្យមានកិច្ចគាំទ្របន្ត។

គំហើញពីការសិក្សានេះ មានមូលដ្ឋានផ្អែកលើភស្តុតាងបែបគុណភាព និងបរិមាណដែលបានប្រមូលនៅក្នុង រាជធានីខេត្តគោលដៅចំនួន៥ ៖ ភ្នំពេញ សៀមរាប បាត់ដំបង កណ្ដាល និងព្រះសីហនុ។ អ្នកស្រាវជ្រាវបានចុះពិនិត្យមើលការថែទាំដោយសាច់ញាតិ គ្រួសារធម៌ វត្តអារាម ផ្ទះស្នាក់នៅជាក្រុម អន្តេវាសិកដ្ឋាននិងមណ្ឌលថែទាំកុមារមួយចំនួនតូច ដើម្បីស្វែងយល់អំពីការថែទាំជំនួសដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ សរុបមកអ្នកស្រាវជ្រាវបានធ្វើ សម្ភាសន៍ ជាមួយអ្នកថែទាំ និងអ្នកគ្រប់គ្រងកន្លែងថែទាំជំនួសចំនួន ៣៦នាក់បានរៀបចំក្រុមពិភាក្សាចំនួន ២២ក្រុម ជាមួយកុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំជំនួសទាំងនោះហើយបានសម្ភាសន៍កុមារ១៩នាក់ អំពីប្រវត្តិជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់ និងបានសម្ភាសន៍ស៊ីជម្រៅជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់មកពីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលចំនួន ២៨នាក់គំហើញពីកិច្ចសម្ភាសន៍ទាំងនេះរួមមានសេចក្ដីត្រូវការឱ្យធ្វើការពង្រឹង និងធ្វើនិយ័តកម្មទៅលើប្រព័ន្ធការពារកុមារព្រមទាំងបង្កើនសមត្ថភាពរបស់អ្នកដែលកំពុងបម្រើការងារនៅក្នុងប្រព័ន្ធការពារកុមារសេចក្ដីត្រូវការឱ្យមានកិច្ចគាំទ្រកាន់តែខ្លាំងឡើង ចំពោះសាច់ញាតិដែលផ្ដល់ការថែទាំកុមារ និងគ្រួសារធម៌កិច្ចសហការកាន់តែជិតស្និទ្ធរវាងក្រសួង ស.អ.យ និងក្រសួងធម្មការនិងសាសនាទាក់ទងនឹងកុមារដែលរស់នៅតាមវត្តអារាម និងបន្តប្រើប្រាស់ផ្ទះស្នាក់នៅជាក្រុម ជាជម្រើសដោយឡែកជំនួសឱ្យការថែទាំតាមមណ្ឌលសម្រាប់កុមារដែលមិនអាចទុកដាក់នៅក្នុងការថែទាំ ដោយសាច់ញាតិ ឬការថែទាំដោយឪពុកម្ដាយធម៌។ ការសិក្សានេះផ្ដល់នូវព័ត៌មានដ៏ចាំបាច់ដល់ក្រសួង ស.អ.យ ខណៈពេលដែលក្រសួងបោះជំហានឆ្ពោះទៅអនុវត្តផែនការសកម្មភាពជាតិសម្រាប់កែលម្អការថែទាំកុមារក្នុងគោលដៅ សមាហរណកម្មកុមារចំនួន៣០% នៅក្នុងមណ្ឌលថែទាំកុមារឱ្យវិលត្រឡប់ទៅគ្រួសាររបស់ពួកគាត់វិញប្រកបដោយសុវត្ថិភាព ត្រឹមឆ្នាំ២០១៨។

## កត្តាជុំរុញ និង កត្តាអូសទាញដែលបង្កឱ្យមានផលប៉ះពាល់ទៅលើការថែទាំជំនួស

គំហើញពីការស្រាវជ្រាវបានឱ្យដឹងថា បើទោះបីជាភាពក្រីក្រត្រូវបានលើកឡើងថាជាមូលហេតុចម្បងដែលធ្វើឱ្យកុមារធ្លាក់ចូលទៅក្នុងការថែទាំជំនួសក៏ដោយប៉ុន្តែវាក៏មានកត្តាសំខាន់ដទៃទៀត ដែលរួមចំណែកចំពោះសេចក្តីសម្រេចចិត្តនេះផងដែរ។ ក្នុងនោះរួមមាន អំពើហិង្សា ការរំលោភបំពានជម្លោះក្នុងគ្រួសារ ការបោះបង់កុមារ ចំណាកស្រុក មរណភាព ឬ ការមានជម្ងឺនៅក្នុងគ្រួសារ និងការញៀនគ្រឿងញៀន។ សេវាថែទាំកុមារក៏ត្រូវបានមើលឃើញថាជាមធ្យោបាយមួយនៃការផ្តល់ឱ្យកុមារនូវលទ្ធភាពក្នុងការទទួលបានការអប់រំដោយឥតគិតថ្លៃ និងប្រកបដោយគុណភាពខ្ពស់ផងដែរ។ នេះគឺជាកត្តាអូសទាញពុំមានលទ្ធភាពទទួលបានការអប់រំបែបនេះ ព្រមទាំងគ្រួសារដែលគ្មានលទ្ធភាពបង់ថ្លៃ«រៀនគួរ» បន្ថែម ឬ គ្មានលទ្ធភាពលើថ្លៃចំណាយដទៃទៀតដែលពាក់ព័ន្ធនឹងការអប់រំ។

## ប្រព័ន្ធការពារកុមារ និង ការថែទាំជំនួស

នៅក្នុងឯកសារគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារដែលត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានកត់សម្គាល់ថា មានបញ្ហាប្រឈមមួយចំនួនរាំងស្ទះដល់ការអនុវត្តគោលនយោបាយនេះ ដែលបណ្តាលឱ្យមានការប្រើប្រាស់ជំរើសការថែទាំជំនួសកាន់តែច្រើនចំពោះកុមារដែលមិនអាចរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ពួកគេបានដោយសារហេតុផលផ្សេងៗ។ បញ្ហាប្រឈមទាំងនេះនឹងបន្តបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើការបង្ការការបំបែកកុមារពីគ្រួសារ ការផ្តល់កិច្ចគាំទ្រដល់គ្រួសារនិងការប្រើប្រាស់ការថែទាំជំនួសនៅក្នុងសហគមន៍។ បញ្ហាប្រឈមទាំងនោះរួមមានដូចខាងក្រោម ៖

- ការយល់ដឹងមានកម្រិតអំពីសិទ្ធិកុមារ
- ការយល់ដឹងមានកម្រិតអំពីបញ្ហាសង្គមនៅគ្រប់កម្រិតទាំងអស់
- កង្វះធនធានសម្រាប់គ្រប់វិស័យកម្មវិធីទាំងអស់
- ការលំបាកក្នុងការចាត់អាទិភាពបញ្ហានិងកំណត់គោលដៅ និង គោលបំណងដែលអាចសម្រេចបាន
- ក្របខ័ណ្ឌច្បាប់ដែលមិនទាន់បានអភិវឌ្ឍន៍ពេញលេញ
- ការអនុវត្តមិនបានគ្រប់គ្រាន់ចំពោះច្បាប់ជាតិ និង លិខិតុបករណ៍ច្បាប់អន្តរជាតិដែលបានផ្តល់សច្ចាប័ន
- ការសម្របសម្រួលមានកម្រិតក្នុងចំណោមស្ថាប័ន និង ក្រសួងរដ្ឋាភិបាល ព្រមទាំងសង្គមស៊ីវិលដែលធ្វើការងារជាមួយកុមាររងគ្រោះ
- កង្វះប្រព័ន្ធត្រួតពិនិត្យ និងតាមដានរួមបញ្ចូលគ្នានៅគ្រប់កម្រិត និង មិនសូវមានលទ្ធភាពក្នុងការទទួលបានព័ត៌មាន
- ផលវិបាកមួយចំនួននៃទំនើបកម្ម ដូចជាបុគ្គលនិយម ការបាត់បង់គុណតម្លៃជាប្រពៃណី និងសាមគ្គីភាពជាដើម។

ការខកខានក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ មានន័យថា រយៈពេល ១០ឆ្នាំក្រោយមកនៅតែមានកុមារជាច្រើនដែលចូលទៅក្នុងប្រព័ន្ធថែទាំ និងស្នាក់នៅក្នុងមណ្ឌល។ លើសពីនេះក៏មានបញ្ហាប្រឈមមួយចំនួនទៀត ដែលរួមមានដូចជា៖ កង្វះ «សំណាញ់សុវត្ថិភាព» ហិរញ្ញវត្ថុរបស់រដ្ឋសម្រាប់ឪពុកម្តាយដែលគ្មានមធ្យោបាយគ្រប់គ្រាន់ក្នុងការគាំទ្រកូនរបស់ពួកគាត់ កង្វះសេវាគាំទ្រ

គ្រួសារនៅក្នុងសហគមន៍ដើម្បីបង្ការការ បែកបាក់គ្រួសារ និង ថ្លៃចំណាយពាក់ព័ន្ធនឹងការអប់រំកុមារ។ បញ្ហាបន្ថែមមួយចំនួនទៀតរួមមាន កង្វះ «អង្គភាព» ជាក់លាក់ដែលកុមារអាចប្រើប្រាស់ជាយន្តការបណ្តឹងអំពីការថែទាំដែលពួកគេទទួលបាន និង ការយល់ដឹង ជាសាធារណៈអំពីបញ្ហាការពារកុមារនៅមានកម្រិតទាប។

ជារួម ក្រសួង ស.អ.យ និង ដៃគូរដ្ឋាភិបាល ត្រូវធ្វើការពង្រឹងសមត្ថភាពគ្រប់គ្រងករណីរបស់ខ្លួន ព្រមទាំងការផ្តល់សេវានៅតាមបណ្តាស្រុកនានាដោយពិចារណានូវអនុសាសន៍បន្ថែមពីលើផែនការសកម្មភាពជាតិសម្រាប់កែលម្អការថែទាំកុមារនាពេលបច្ចុប្បន្នរបស់ក្រសួង ស.អ.យ ហើយគប្បីបង្កើតផែនការយុទ្ធសាស្ត្រមួយ ដើម្បីអភិវឌ្ឍន៍ និងផ្តល់សេវាគ្រប់គ្រងករណី ការពារកុមារនៅតាមបណ្តាស្រុកនានា ក្នុងរយៈពេល៥ឆ្នាំបន្ទាប់។ យុទ្ធសាស្ត្រនេះគប្បីបញ្ចូលការបង្កើតបទបញ្ញត្តិ និង សេចក្តីណែនាំដែលធ្វើនិយ័តកម្មនិងធ្វើឱ្យមានលក្ខណៈផ្លូវការចំពោះទម្រង់ផ្សេងៗគ្នានៃការថែទាំជំនួសក្នុងនោះរាប់បញ្ចូលការកំណត់អំពីតួនាទី និងការទទួលខុសត្រូវ ព្រមទាំងបទដ្ឋាននៃការថែទាំ ការគ្រប់គ្រង ការធានាគុណភាព និងការត្រួតពិនិត្យគុណភាពនៃសេវាថែទាំតាមសហគមន៍។ ការពិចារណាមិនគួរគ្រាន់តែផ្តោតលើការអភិវឌ្ឍន៍សេវារដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏គួរពិចារណាផងដែរអំពីតួនាទីដែលអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើបានក្នុងការសហការផ្តល់សេវាបែបនេះនៅតាមស្រុកនិងឃុំ។ ធាតុផ្សំមួយដ៏សំខាន់នៃយុទ្ធសាស្ត្រនេះគឺជាការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយមួយទៅលើជំពូក៧ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសដើម្បីធានាឱ្យមានការរៀបចំផែនការសម្រាប់ ការទុកដាក់កុមារជាអចិន្ត្រៃយប្រកបដោយប្រសិទ្ធភាពនិងយន្តការថ្មីៗដើម្បីផ្តល់សេវាចិញ្ចឹមបីបាច់កុមារ និង សេវាសុំកូននៅក្នុងស្រុកនានាប្រកបដោយប្រសិទ្ធភាព។

មានតំរូវការយ៉ាងខ្លាំងនូវបុគ្គលិកសង្គមកិច្ចបន្ថែមទៀតនៅតាមបណ្តាស្រុក ហើយគេក៏បានផ្តល់អនុសាសន៍ថាក្រសួងគប្បីពិចារណាជ្រើសរើសនិងបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ចពាក់កណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការងារជាមួយមន្ទីរស.អ.យ និង ភ្នាក់ងារសង្គមកិច្ច នៅតាមស្រុក គកនក និងរួមផ្សំជាមួយធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់សេវាគាំទ្រគ្រួសារ និងសេវាថែទាំជំនួស។ គំរូគ្រប់គ្រងករណីរួមគ្នារវាងរដ្ឋាភិបាល/អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងនៅប្រទេសមីយ៉ាន់ម៉ាអាចប្រើប្រាស់ជា គំរូមួយដ៏មានសារៈប្រយោជន៍សម្រាប់ប្រទេសកម្ពុជា។



**ការថែទាំដោយសាច់ញាតិ**

ការថែទាំដោយសាច់ញាតិ សំដៅចំពោះការថែទាំតាមគ្រួសារនៅក្នុងសាខាញាតិរបស់កុមារ ឬ ជាមួយមិត្តភក្តិជិតស្និទ្ធរបស់គ្រួសារដែលកុមារស្គាល់ មិនចំពោះថាការថែទាំបែបនេះមានលក្ខណៈផ្លូវការ ឬ មិនផ្លូវការឡើយ។ ការថែទាំដោយសាច់ញាតិ គឺជាការអនុវត្តទូទៅមួយបែបប្រពៃណីនៅក្នុងសហគមន៍កម្ពុជា នៅពេលដែលកុមារមិនអាចទទួលការថែទាំពីឪពុកម្តាយបង្កើតរបស់ពួកគេ។ វាមានគុណសម្បត្តិមួយចំនួនលើសពីការថែទាំជំនួសប្រភេទដទៃទៀតដូចជា កុមារបន្តរស់នៅជាមួយគ្រួសារបង្កើតរបស់ពួកគាត់ ហើយរក្សាទំនាក់ទំនងនិងបណ្តាញសាខាញាតិរបស់ពួកគាត់ព្រមទាំងទទួលបានការថែទាំពីមនុស្សពេញវ័យដែលភាគច្រើនពួកគាត់មានទំនាក់ទំនងជាមួយរួចទៅហើយ។

បើទោះបីជាការរៀបចំថែទាំដោយសាច់ញាតិភាគច្រើនក្នុងប្រទេសកម្ពុជាត្រូវបានធ្វើឡើងក្រៅផ្លូវការដោយគ្មាន ការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ឬ គកនក ឬ មន្ទីរ ស.អ.យ ក៏ដោយ ប៉ុន្តែក្នុងករណីដែលការទុកដាក់ ថែទាំដោយសាច់ញាតិមានការសម្របសម្រួលពីអង្គការមិនមែនរដ្ឋាភិបាល ជាញឹកញាប់

គេរមែងតែងខ្វះការប៉ាន់ប្រមាណប្រកបដោយវិជ្ជាជីវៈទៅលើសមត្ថភាពរបស់សាច់ញាតិក្នុងការផ្តល់ការថែទាំកុមារឱ្យបានគ្រប់គ្រាន់ម្យ៉ាងវិញទៀតភ្នាក់ងារសង្គមកិច្ចកម្រចុះសួរសុខទុក្ខឱ្យបានទៀងទាត់ខ្លាំងណាស់លើកលែងតែក្នុងករណីមួយចំនួនប៉ុណ្ណោះ។

ជាញឹកញាប់ មានសាច់ញាតិសម្រាប់ថែទាំកុមារ ប៉ុន្តែ ពួកគេរមែងតែងមិនអាចផ្តល់ការថែទាំបានដោយសារ ពួកគេគ្មានលទ្ធភាពផ្នែកហិរញ្ញវត្ថុក្នុងការគាំទ្រដល់កុមារ។ ចំនុចនេះបានក្លាយជាបញ្ហាមួយជាក់លាក់ សម្រាប់សាច់ញាតិដែលមានវ័យចំណាស់ ដូចជាជីដូនជីតា និងជាពិសេសគឺជីដូនរស់នៅម្នាក់ឯង ដែលគ្មានប្រភពប្រាក់ចំណូលច្បាស់លាស់។ ក្នុងករណីទាំងនេះការថែទាំដោយសាច់ញាតិគឺជាជម្រើសមួយសមស្រប ប្រសិនបើមានការផ្តល់ប្រាក់ឧបត្ថម្ភ និង មានការចំណាយលើថ្លៃអប់រំ។

**អនុសាសន៍**

- ក្នុងករណីដែលមន្ទីរ ស.អ.យ គកនក ឬ អង្គការមិនមែនរដ្ឋាភិបាលមួយ មានបំណងទុកដាក់កុមារម្នាក់ ឱ្យរស់នៅជាមួយសាច់ញាតិ គេគប្បីធ្វើការប៉ាន់ប្រមាណទៅលើសាច់ញាតិនោះ។
- ការដែលមន្ទីរ ស.អ.យ គកនក ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើការទុកដាក់កុមារឱ្យទទួលការថែទាំពីសាច់ញាតិ គប្បីមានការកត់ត្រាជាផ្លូវការពីមន្ទីរ ស.អ.យ។
- ក្រសួង ស.អ.យ និង មន្ទីរ ស.អ.យ គប្បីធ្វើការពិនិត្យឡើងវិញអំពីរបៀបដែលការថែទាំដោយសាច់ញាតិដែលគួរទទួលបានកិច្ចគាំទ្រហិរញ្ញវត្ថុ និងយន្តការដែលអាចរៀបចំឱ្យមាន (ដោយក្រុមប្រឹក្សាឃុំ) ដើម្បីធានាថាកុមារដែលត្រូវបានទុកដាក់ឱ្យរស់នៅជាមួយសាច់ញាតិមិនតម្រូវឱ្យបង់ប្រាក់ជូនគ្រូបង្រៀន នៅពេលដែលពួកគេទៅរៀននៅឯសាលារដ្ឋ។
- មន្ទីរ ស.អ.យ គប្បីពិនិត្យឡើងវិញទៅលើកម្រិតនៃការត្រួតពិនិត្យ និងកិច្ចគាំទ្រនាពេលបច្ចុប្បន្នរបស់ខ្លួន ទៅលើសាច់ញាតិដែលផ្តល់ការថែទាំកុមារ។



**ការថែទាំដោយឪពុកម្តាយធម៌**

ការថែទាំដោយឪពុកម្តាយធម៌ សំដៅចំពោះស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទុកដាក់ សម្រាប់គោលបំណងថែទាំជំនួសនៅក្នុងបរិយាកាសគ្រួសារក្នុងមូលដ្ឋានមួយដែលត្រូវបានជ្រើសរើសមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួលការឯកភាពនិងមានការត្រួតពិនិត្យតាមដានសម្រាប់ផ្តល់ការថែទាំបែបនេះ។ នាពេលបច្ចុប្បន្ន ឪពុកម្តាយធម៌ត្រូវបានជ្រើសរើស បណ្តុះបណ្តាលផ្តល់បៀវត្សរ៍ និង ទទួលបាន កិច្ចគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។ ពុំមានសេវាថែទាំដោយឪពុកម្តាយធម៌ដែលផ្តល់ជូនដោយរដ្ឋាភិបាលឡើយ។ អង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើការទុកដាក់កុមាររហូតដល់៦នាក់ឱ្យរស់នៅជាមួយឪពុកឬម្តាយធម៌ម្នាក់ដែលទង្វើបែបនេះបង្កឱ្យមានការព្រួយបារម្ភអំពីកម្រិតនៃលទ្ធភាពដែលគេអាចផ្តោតការយកចិត្តទុកដាក់ចំពោះកុមារម្នាក់ៗ។

បើទោះបីជាការទុកដាក់កុមារឱ្យរស់នៅជាមួយឪពុកម្តាយធម៌ភាគច្រើនមានការពាក់ព័ន្ធជាមួយភ្នាក់ងារសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ប៉ុន្តែការកំណត់រកគ្រួសារសមស្រប និងការទុកដាក់កុមារ រមែងតែងធ្វើឡើង ក្នុងស្ថានភាពបន្ទាន់ និង មានការចូលរួមពីរដ្ឋាភិបាល (គកនក និងមន្ទីរស.អ.យ) ក្នុងកម្រិតតិចតួចបំផុត បើធៀបនឹងការថែទាំដោយសាច់ញាតិ គ្រួសារធម៌ទទួលបានការត្រួតពិនិត្យ ប្រសើរជាង។ ប៉ុន្តែ បើទោះជាដូច្នេះក្តីកូនធម៌កម្រត្រូវបានចុះបញ្ជីជាមួយរដ្ឋាភិបាល

ខ្លាំងណាស់ ហើយចំពោះការចុះបញ្ជីនេះភាគច្រើនគឺអាស្រ័យលើការផ្តួចផ្តើមរបស់គ្រួសារធម៌ឬអង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារ។ មានភស្តុតាងបញ្ជាក់ផងដែរថាឳពុកម្តាយធម៌មួយចំនួនបាន «ស្មុំ»កុមារយកទៅចិញ្ចឹមក្នុងលក្ខណៈមិនផ្លូវការដោយប្តូរលិខិតបញ្ជាក់កំណើតរបស់កុមារ។ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានរកឃើញថាផ្តល់ការឧបត្ថម្ភជូនដល់គ្រួសារធម៌ប្រមាណ ៣០-៤០ ដុល្លារអាមេរិក សម្រាប់កុមារ១នាក់ ក្នុង១ខែ និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផ្តល់ «បៀវត្សរ៍» ដល់គ្រួសារធម៌ ដែលអាចមានចំនួនចន្លោះពី ៥០-២០០ ដុល្លារអាមេរិក ក្នុងមួយខែ។ ពុំមានភស្តុតាងបញ្ជាក់អំពីកិច្ចគាំទ្រហិរញ្ញវត្ថុរបស់រដ្ឋាភិបាលសម្រាប់ផ្តល់ជូនដល់គ្រួសារធម៌ឡើយ។

**អនុសាសន៍**

- សេវាថែទាំដោយឳពុកម្តាយធម៌និងសេវាស្មុំកូនក្នុងស្រុករបស់រដ្ឋ ត្រូវអភិវឌ្ឍន៍រួមគ្នាជាមួយក្របខ័ណ្ឌច្បាប់មួយ។ សេវាបែបនេះអាចផ្តល់កិច្ចសន្យាបន្តជូនទៅអង្គការមិនមែនរដ្ឋាភិបាលនៅក្នុង ស្រុក ប៉ុន្តែ ក្រសួង ស.អ.យ គប្បីបន្តរក្សាការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះសេវានេះ។
- មិនគួរទុកដាក់កូនធម៌លើស៣នាក់ នៅក្នុងគ្រួសារមួយឡើយ លើកលែងតែកុមារគឺជាបងប្អូនបង្កើតនឹងគ្នាដែលក្នុងករណីនេះគេគប្បីអនុញ្ញាតឱ្យឳពុកម្តាយធម៌ទទួលយកបងប្អូនបង្កើតរបស់កុមារទាំងអស់។
- ដំណើរការប៉ាន់ប្រមាណគប្បីត្រូវបានពង្រឹងជាពិសេសពាក់ព័ន្ធនឹងភាពសមស្របរបស់ឳពុកម្តាយធម៌។
- ត្រូវពង្រឹងលើការបន្តត្រួតពិនិត្យ និង គាំទ្រ (ការងារគ្រប់គ្រងករណី)។



**ការថែទាំតាមវត្តអារាម**

នៅក្នុងប្រទេសកម្ពុជា វត្តអារាមត្រូវបានមើលឃើញថាជាឋានសួគ៌នៃការអប់រំវិន័យ និងសប្បុរសធម៌ព្រមទាំងមានប្រពៃណីផ្តល់កិច្ចគាំទ្រចំពោះអ្នកដែលត្រូវការផងដែរ។ ការថែទាំតាមវត្តអារាមសំដៅចំពោះការថែទាំដែលផ្តល់ជូនកុមារដោយព្រះសង្ឃ ដូនជី និង អាចារ្យ ដែលជាញឹកញាប់ ការថែទាំបែបនេះធ្វើឡើងនៅក្នុងវត្តអារាម។ ការថែទាំតាមវត្តអារាម អាចរាប់បញ្ចូលការផ្តល់អាហារ ជម្រក ការអប់រំនិងទម្រង់ដទៃទៀត នៃការថែទាំ។ វត្តអារាមត្រូវបានរកឃើញថាផ្តល់ការថែទាំភាគច្រើនចំពោះកុមារាដែលមានអាយុចាប់ពី ១០ឆ្នាំឡើងទៅ។

កុមារមករស់នៅក្នុងវត្តអារាមដោយសារមូលហេតុជាច្រើនផ្សេងៗគ្នា ក្នុងនោះរួមមាន ៖ ដើម្បីបួសជាសង្ឃ ដើម្បីទទួលការអប់រំដែលពុំមាននៅឯកន្លែងកំណើតរបស់ពួកគេ ដោយសារតែត្រូវបានឳពុកម្តាយបោះបង់ ដោយសារតែឳពុកម្តាយរបស់ពួកគេមានប្តី ឬ ប្រពន្ធថ្មី គ្រួសាររបស់ពួកគេគ្មានលទ្ធភាពផ្តល់ការថែទាំឱ្យបាន គ្រប់គ្រាន់ ឬ មានការលំបាកក្នុងការគ្រប់គ្រងលើការប្រព្រឹត្តរបស់កុមារ ឬ ដោយសារតែអ្នកអាណាព្យាបាល របស់ពួកគេរស់នៅ និង/ឬ ធ្វើការងារនៅក្នុងវត្ត។ ការអនុញ្ញាតឱ្យកុមារចូលមករស់នៅក្នុងទីវត្តអារាម រមែងតែងធ្វើឡើងក្នុងលក្ខណៈមិនផ្លូវការ ដោយមានការចូលរួមតិចតួច ឬ គ្មានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ឬ អ្នកតំណាងពីរដ្ឋាភិបាល។

កុមារដែលទទួលការថែទាំតាមវត្តអារាម មានលទ្ធភាពទទួលបានការអប់រំ ដែលជាធម្មតាពួកគេទៅទទួលការអប់រំនៅក្រៅវត្ត និងមានការបំពេញបន្ថែមពីការប្រៀនប្រដៅព្រះពុទ្ធសាសនានៅក្នុងវត្ត។ នៅក្នុងករណីមួយដែលបានបញ្ចូលនៅក្នុងការសិក្សានេះបុគ្គលិកបណ្តុះបណ្តាលរបស់ MoE បានផ្តល់ការអប់រំផ្នែកអាណាចក្រនៅក្នុងវត្ត។លក្ខខណ្ឌសម្ភារៈនៅក្នុងវត្តមានលក្ខណៈខ្សត់ខ្សោយគួរឱ្យកត់សម្គាល់បើធៀបនឹងទម្រង់ដទៃទៀតនៃការថែទាំជំនួសនិងក្នុងករណីមួយចំនួនកុមារបានរាយការណ៍ឱ្យដឹងថាពួកគេមានអាហារទទួលទានមិនគ្រប់គ្រាន់ឬជួនកាលពុំមានអាហារទទួលទាន។ គំហើញពីការស្រាវជ្រាវបានឱ្យដឹងថាការត្រួតពិនិត្យពីខាងក្រៅទៅលើការថែទាំដែលផ្តល់ជូននៅក្នុងវត្តមានកម្រិតតិចតួចយ៉ាងខ្លាំង ឬ គ្មានការត្រួតពិនិត្យពីខាងក្រៅទាល់តែសោះ។

## អនុសាសន៍

- ក្រសួងធម្មការនិងសាសនាដោយមានកិច្ចសហការជាមួយក្រសួងស.អ.យ គប្បីអភិវឌ្ឍន៍គោលនយោបាយមួយស្តីពីការអនុញ្ញាតឱ្យកុមារចូលរស់នៅក្នុងវត្តអារាម។
- ក្រសួងធម្មការនិងសាសនាដោយមានកិច្ចសហការជាមួយក្រសួងស.អ.យគប្បីធ្វើការត្រួតពិនិត្យឡើងវិញដើម្បីកំណត់អំពីកម្រិតវិសាលភាពដែលវត្តអារាមអាចទទួលការថែទាំកុមារ ត្រូវអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំជំនួសចំពោះកុមារនិង បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារនៅក្នុងសហគមន៍ និងអភិវឌ្ឍន៍ផែនការសកម្មភាពមួយដើម្បីឱ្យមានការបន្តផ្លាស់ប្តូរសំដៅសម្រេចឱ្យបាននូវបទដ្ឋានទាំងស្រុង។
- វត្តអារាមគប្បីតម្រូវឱ្យជូនដំណឹងដល់មន្ទីរ ស.អ.យ អំពីការចូលស្នាក់នៅរបស់កុមារ ចំពោះករណីដែល បញ្ហាការពារកុមារគឺជាមូលហេតុទាំងស្រុង ឬ មូលហេតុមួយផ្នែកនៃការចូលស្នាក់នៅនេះ ដែលក្នុងនោះ មូលហេតុអាចរួមមានដូចជា ឪពុកម្តាយធ្វើចំណាកស្រុក ឪពុកម្តាយស្លាប់ ឪពុកម្តាយមានប្តី ឬ ប្រពន្ធថ្មី និងការបដិសេធន៍ថែទាំកុមារ ឬ ទម្រង់ណាមួយនៃការរំលោភបំពានការមិនអើពើ ឬ អំពើហិង្សា។
- ក្នុងករណីដែលវត្តអារាមផ្តល់ការថែទាំកុមារចាប់ពី១០នាក់ឡើងទៅ ក្រសួងធម្មការ និងសាសនា និង ក្រសួង ស.អ.យ គប្បីពិចារណាផ្តល់ការងារជូនបុគ្គលិកពេញម៉ោង១នាក់ ដើម្បីឱ្យទទួលខុសត្រូវថែទាំកុមារនៅក្នុងវត្ត។
- ក្រសួងធម្មការ និងសាសនា គប្បីអភិវឌ្ឍន៍គោលនយោបាយការពារកុមារគំរូមួយសម្រាប់វត្តអារាម និង ពិនិត្យកែសម្រួលឡើងវិញទៅលើក្រមប្រតិបត្តិសម្រាប់វត្តអារាម/ព្រះសង្ឃ។
- ក្រសួងធម្មការ និងសាសនា គប្បីបង្កើតប្រព័ន្ធប្រមូលទិន្នន័យមួយ ដើម្បីស្រង់ស្ថិតិកុមារគ្រប់រូបដែលរស់នៅក្នុងវត្ត។
- ក្រសួងធម្មការ និងសាសនា និង ក្រសួង ស.អ.យ គប្បីអភិវឌ្ឍន៍ពិធីសារការងាររួមគ្នាមួយ ស្តីពីការទទួលខុសត្រូវចំពោះកុមារនៅក្នុងវត្តអារាម។

## ផ្ទះស្នាក់នៅជាក្រុម

ការថែទាំតាមផ្ទះស្នាក់នៅជាក្រុមគឺជាទម្រង់មួយនៃការថែទាំជំនួសដែលកុមារមួយចំនួនតូច( មិនលើសពី ១៥នាក់ដូចមានកំណត់នៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស )ត្រូវបានទុកដាក់ឱ្យរស់នៅក្នុងបរិយាកាសគ្រួសារមួយក្រោមការត្រួតពិនិត្យពីអ្នកថែទាំមួយចំនួនតូចដែលមិនមែនជាសាច់ញាតិរបស់កុមារ។ ផ្ទះស្នាក់នៅជាក្រុមមានទម្រង់ផ្សេងៗគ្នា ៖ ក្នុងករណីមួយចំនួន កុមាររស់នៅជាក្រុមតូចៗជាមួយ "អ្នកថែទាំ ឬ ឪពុកដែលជាអ្នកផ្តល់ការថែទាំ" ដោយឡែកទម្រង់ដទៃទៀតមានលក្ខណៈជា "ការរៀបចំរស់នៅពាក់កណ្តាលឯករាជ្យ" ដោយគ្មានបុគ្គលិកថែទាំនៅក្នុងផ្ទះ។ មានផ្ទះស្នាក់នៅជាក្រុមតិចតួចខ្លាំងណាស់ដែលអ្នកស្រាវជ្រាវបានចុះទៅមើលហើយឃើញថាសមស្របទៅនឹងទំរង់នៃការថែទាំជំនួស "តាមសហគមន៍" ឬការថែទាំជំនួស "មានលក្ខណៈដូចគ្នាទៅនឹងការថែទាំតាមគ្រួសារ" ដែលមានចែងនៅក្នុងបទដ្ឋានអប្បបរមាឆ្នាំ ២០០៨។ ការត្រួតពិនិត្យទៅលើផ្ទះស្នាក់នៅជាក្រុម មានដំណើរការប្រព្រឹត្តទៅបានល្អនៅក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែ ការចូលរួមពីរដ្ឋាភិបាល ( គកនក និង មន្ទីរ ស.អ.យ ) មានកម្រិតតិចតួច។ ការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបង្កើត និង ការប៉ុនប៉ងធ្វើសមាហរណកម្ម ហាក់បីដូចជាមិនទទួលបានការផ្តោតអាទិភាពឡើយ និងត្រូវបានអ្នកថែទាំតាមផ្ទះស្នាក់នៅជាក្រុមមួយចំនួនគិតថាមិនអាចធ្វើបាន។

ការសិក្សាបានរកឃើញថាលក្ខខណ្ឌសម្ភារៈ និង លទ្ធភាពទទួលបានការអប់រំសម្រាប់កុមារដែលកំពុងរស់នៅ ក្នុងផ្ទះស្នាក់នៅជាក្រុមរមែងតែងប្រសើរជាងបរិយាកាសនៅឯផ្ទះរបស់ពួកគេ។ កុមារដែលចូលរួមនៅក្នុងការសិក្សារនេះ មែងតែងរៀបរាប់អំពីបទពិសោធន៍រស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមរបស់ពួកគាត់ថាមានភាពវិជ្ជមាន ដោយសារតែបទដ្ឋានរស់នៅដែលមានលក្ខណៈប្រសើរជាងមុន។ បើទោះជាដូច្នេះក្តី ការសិក្សានេះក៏បានរកឃើញផងដែរថាកុមារដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមកម្រត្រូវបានភ្នាក់ងារសង្គមកិច្ចចុះមកជួបបានទៀងទាត់។

អ្នកថែទាំភាគច្រើនបំផុតនៅក្នុងផ្ទះស្នាក់នៅជាក្រុមបានទទួលការបណ្តុះបណ្តាលក្នុងទម្រង់មួយចំនួន បើទោះបីជាការបណ្តុះបណ្តាលទាំងនោះអាចមានលក្ខណៈមូលដ្ឋាននិង/ឬមិនផ្លូវការក៏ដោយ។ ភស្តុតាងមានកម្រិតអំពីថ្លៃចំណាយរបស់ផ្ទះស្នាក់នៅជាក្រុមបានឱ្យដឹងថាតាមរយៈការយល់ឃើញរបស់អង្គការមិនមែនរដ្ឋាភិបាលនិងរដ្ឋាភិបាលផ្ទះស្នាក់នៅជាក្រុមមានថ្លៃចំណាយខ្ពស់ជាងជម្រើសថែទាំជំនួសតាមគ្រួសារ។

### អនុសាសន៍

- ក្រសួង ស.អ.យ គប្បីធ្វើការត្រួតពិនិត្យឡើងវិញទៅលើថ្លៃចំណាយបច្ចុប្បន្ន ការផ្តល់ហិរញ្ញប្បទាន និង គំរូដែលចំណាយតិចបំផុតសម្រាប់ផ្តល់ការថែទាំនៅក្នុងផ្ទះស្នាក់នៅជាក្រុម។
- ក្រសួង ស.អ.យ គប្បីធានាថាស្រុកនីមួយៗមានផ្ទះស្នាក់នៅជាក្រុមគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កុមារដែល ត្រូវការការថែទាំ ដែលមិនអាចរស់នៅជាមួយសាច់ញាតិ ឬឪពុកម្តាយធម៌បាន។
- គប្បីពិនិត្យកែសម្រួលឡើងវិញទៅលើនិយមន័យនៃផ្ទះស្នាក់នៅជាក្រុមដែលមានកំណត់នៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ដើម្បីឱ្យស្របទៅនឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំជំនួស។

## អន្តេវាសិកដ្ឋាន

អន្តេវាសិកដ្ឋានដើរតួនាទីមួយនៅក្នុងប្រព័ន្ធអប់រំប៉ុន្តែការសិក្សានេះបានបង្ហាញឱ្យដឹងថាមូលហេតុនៃការទុកដាក់កុមារមួយចំនួននៅតាមអន្តេវាសិកដ្ឋានមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងបញ្ហាការពារកុមារក្នុងគ្រួសារ។ ប្រសិនបើគេត្រូវទុកដាក់កុមារនៅក្នុងអន្តេវាសិកដ្ឋានក្នុងលក្ខណៈជាការថែទាំជំនួសជាពិសេសសម្រាប់កុមារដែលមានវ័យជំទង់ដូច្នេះជាថ្មីម្តងទៀតរាល់គ្រប់នីតិវិធីទាំងអស់ដែលមាននៅក្នុងបទប្បញ្ញត្តិនាពេលបច្ចុប្បន្ន គប្បីត្រូវបានយកមកអនុវត្ត។

## អនុសាសន៍

- អន្តេវាសិកដ្ឋាន គប្បីតម្រូវឱ្យផ្តល់ព័ត៌មានជូនដល់មន្ទីរ ស.អ.យអំពីចំនួនកុមារដែលកំពុងស្នាក់នៅក្នុងសាលារៀន។
- ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួង ស.អ.យ គប្បីរៀបចំបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមាររស់នៅក្នុងអន្តេវាសិកដ្ឋាន ។
- ក្រសួងអប់រំ យុវជន និងកីឡា គប្បីអភិវឌ្ឍន៍គោលនយោបាយការពារកុមារគំរូមួយ សម្រាប់អន្តេវាសិកដ្ឋាន ទាក់ទងនឹងបញ្ហាកិច្ចការពារកុមារនៅក្នុងសាលារៀន និង ការបញ្ជូនករណីនៅពេលដែលមានការព្រួយបារម្ភទាក់ទងនឹងកិច្ចការពារកុមារនៅក្នុងគ្រួសារ។
- ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួង ស.អ.យ គប្បីមានពិធីសារការងាររួមគ្នាមួយ ស្តីពីការទទួលខុសត្រូវចំពោះការគាំទ្រកុមារនៅក្នុងអន្តេវាសិកដ្ឋាន ។
- ក្រសួង ស.អ.យ គប្បីទទួលខុសត្រូវចំពោះការត្រួតពិនិត្យ និង ការធ្វើអធិការកិច្ចទៅលើការថែទាំកុមារនៅក្នុងអន្តេវាសិកដ្ឋាន ។

# មាតិកា


សេចក្តីសង្ខេប 4

សេចក្តីផ្តើម 4

កត្តាជំរុញ និង កត្តាអូសទាញដែលបង្កឱ្យមានផលប៉ះពាល់ទៅលើការថែទាំជំនួស 5

ប្រព័ន្ធការពារកុមារ និង ការថែទាំជំនួស 5

ការថែទាំដោយសាច់ញាតិ 6

ការថែទាំដោយឪពុកម្តាយធម៌ 7

ការថែទាំតាមវត្តអារាម 8

ផ្ទះស្នាក់នៅជាក្រុម 10

អន្តេវាសិកដ្ឋាន 11

មាតិកា 12

បញ្ជីអក្សរកាត់ 15

១. សេចក្តីផ្តើម 16

២. ប្រវត្តិ និងបរិបទ 17

គោលនយោបាយ 20

បញ្ញត្តិច្បាប់ 22

៣. និយមន័យសំខាន់ៗ 23

៤. គោលបំណងនៃការស្រាវជ្រាវ 25

៥. វិធីសាស្ត្រ 27

វិធីសាស្ត្រស្រាវជ្រាវ 28

យុទ្ធសាស្ត្រជ្រើសរើសសំណាក 28

ប្រវត្តិនៃអង្កេត 29

ភាពមានកម្រិត 31

ដំណើរការពិនិត្យឡើងវិញ 32

## ៦. ប្រព័ន្ធការពារកុមារ និងការថែទាំជំនួស 33

ការកំណត់អត្តសញ្ញាណ និងការបញ្ជូនកុមារ 35

សេវាគាំទ្រគ្រួសារ- ការបង្ការការបំបែកកុមារពីគ្រួសារ 37

ការបង្រួបបង្រួមគ្រួសារ និងការធ្វើសមាហរណកម្ម 38

## ៧. កត្តារុញច្រាន និងកត្តាអូសទាញដែលប៉ះពាល់ដល់ការថែទាំជំនួស 41

ភាពក្រីក្រ 42

ការអប់រំ 42

ការធ្វើចំណាកស្រុករបស់ឪពុកម្ដាយ 43

មរណៈភាពគ្រួសារ ឬការបែកបាក់ទំនាក់ទំនងគ្រួសារ 44

កុមារដែលមានអាកប្បកិរិយាល្មើស 44

កុមារត្រូវការការថែទាំ និងកិច្ចការពារពិសេស 45

ពហុភាពងាយរងគ្រោះ 45

## ៨. ប្រវត្តិនៃការថែទាំ 47





### ការថែទាំដោយសាច់ញាតិ 49

ប្រវត្តិរបស់កុមារ 50

ការកំណត់អត្តសញ្ញាណ
និងការទុកដាក់កុមារ 50

កុមារមានសេចក្ដីត្រូវការពិសេស 52

ការពិនិត្យតាមដាន 53

ទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើត 54

លក្ខណៈនៃការថែទាំដែលបានផ្ដល់ជូន 55

ការបណ្ដុះបណ្ដាល 56

ការចំណាយ និងការផ្ដល់មូលនិធិ 56





### ការថែទាំដោយឪពុកម្ដាយធម៌ 59

ប្រវត្តិរបស់កុមារ 60

ការកំណត់អត្តសញ្ញាណ
និងការទុកដាក់កុមារ 62

ការត្រួតពិនិត្យតាមដាន 64

ទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើត 65

លក្ខណៈនៃការថែទាំដែលបានផ្ដល់ជូន 65

ការបណ្ដុះបណ្ដាល 66

ការចំណាយ និងការផ្ដល់មូលនិធិ 66

ការថែទាំតាមវត្តអារាម 69

ប្រវត្តិកុមារ 71

ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ 73

ការត្រួតពិនិត្យតាមដាន 74

ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត 75

លក្ខណៈនៃការថែទាំដែលបានផ្តល់ជូន 76

ការបណ្តុះបណ្តាល 80

ការចំណាយ និងការផ្តល់មូលនិធិ 80

កិច្ចការពារកុមារ 82

ផ្ទះស្នាក់នៅជាក្រុម 87

ប្រវត្តិរបស់កុមារ 88

ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ 91

ការត្រួតពិនិត្យតាមដាន 92

ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត 93

លក្ខណៈនៃការថែទាំដែលបានផ្តល់ជូន 94

ការបណ្តុះបណ្តាល 96

ការចំណាយ និងការផ្តល់មូលនិធិ 97

បទពិសោធន៍របស់កុមារ 97

មណ្ឌលថែទាំកុមារ និងអន្តេវាសិកដ្ឋាន 101

ប្រវត្តិរបស់កុមារ 103

ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ 104

ការត្រួតពិនិត្យតាមដាន 105

ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត 106

ការធ្វើសមាហរណកម្មកុមារ 107

ការបណ្តុះបណ្តាល 108

ការចំណាយ និងការផ្តល់មូលនិធិ 108

បទពិសោធន៍របស់កុមារ 109

៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ 111

- ការថែទាំដោយសាច់ញាតិ 113
- ការថែទាំដោយឪពុកម្តាយធម៌ 114
- ការថែទាំតាមវត្តអារាម 115
- ផ្ទះស្នាក់នៅជាក្រុម 116
- អន្តេវាសិកដ្ឋាន 117

១០. ឯកសារយោង 118

ឧបសម្ព័ន្ធ ១ ៖ សំណាកសម្រាប់ការសិក្សា 120

ឧបសម្ព័ន្ធទី ២ ៖ ឧបករណ៍ប្រមូលទិន្នន័យ 130

# បញ្ជីអក្សរកាត់

| | |
|---|---|
| **3PC** | កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ |
| **CBC** | ការថែទាំតាមសហគមន៍ |
| **CBO** | អង្គការសហគមន៍ |
| **CCWC** | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គកនក) |
| **DoSVY** | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្នាក់រាជធានី/ខេត្ត) |
| **FCFC** | ការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង |
| **MoSVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ) (ថ្នាក់ជាតិ) |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **OSVY** | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្នាក់ក្រុង/ស្រុក/ខណ្ឌ) |
| **RCI** | មណ្ឌលថែទាំកុមារ |
| **UNCRC** | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| **UN Guidelines** | គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំជំនួសចំពោះកុមារ |
| **UNICEF** | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **WCCC** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) |

# សេចក្តីផ្តើម

# ១

របាយការណ៍នេះ បង្ហាញអំពីលទ្ធផលគំហើញពីការសិក្សាស្តីពីការប្រើប្រាស់ការថែទាំជំនួសចំពោះកុមារតាម សហគមន៍ ក្នុងប្រទេស កម្ពុជាដោយរាប់បញ្ចូលការថែទាំតាមវត្តអារាមផងដែរ។ ការសិក្សានេះ បានទទួលការ អនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ) និងធ្វើឡើងដោយវិទ្យាស្ថាន កូរ៉ាមអន្តរជាតិ ក្នុងឆ្នាំ២០១៦។ កិច្ចគាំទ្របច្ចេកទេសនិងកិច្ចគាំទ្រហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូន ដោយអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា និង USAID។

គោលបំណងនៃការសិក្សា គឺដើម្បីអភិវឌ្ឍន៍មូលដ្ឋានភស្តុតាងទាក់ទងនឹងទម្រង់ផ្សេងៗ រួមទាំងវិធីសាស្ត្រនៃការថែទាំជំនួសចំពោះកុមារតាមសហគមន៍ក្នុងប្រទេសកម្ពុជាក្នុងនោះរួមមានការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ផ្ទះស្នាក់នៅជាក្រុម និងការថែទាំតាមវត្តអារាម ព្រមទាំងដើម្បីពង្រឹង និងប្រើប្រាស់ជាមូលដ្ឋានព័ត៌មានសម្រាប់ធ្វើការកែទម្រង់វិស័យថែទាំកុមារក្នុងប្រទេសកម្ពុជា។ ជាពិសេស ការសិក្សានេះមានគោលបំណងធ្វើការប៉ាន់ប្រមាណអំពីការប្រើប្រាស់ទម្រង់ថែទាំកុមារដែលមានស្រាប់ និងធ្វើការកំណត់ថាតើទម្រង់ថែទាំកុមារទាំងនេះមានភាពអនុលោមតាមគោលនយោបាយស្តីពីការថែទាំជំនួស បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមាររបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍ណែនាំស្តីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ (គោលការណ៍ណែនាំអង្គការសហប្រជាជាតិ) ដែរឬទេនិងដើម្បីកំណត់រកការគាំទ្រចាំបាច់ដើម្បីធានាថា ទម្រង់ដែលមានស្រាប់នៃការថែទាំជំនួសតាមសហគមន៍ពិតជាបានផ្តល់នូវការថែទាំដ៏សមស្របចំពោះកុមារប្រាកដមែន។[1]

ការសិក្សានេះ រួមមានការប្រមូលទិន្នន័យបែបគុណភាព និងបរិមាណដ៏ស៊ីជម្រៅ អំពីការអនុវត្តថែទាំជំនួសនៅក្នុងប្រទេសកម្ពុជា និង ធ្វើការដកស្រង់ទិន្នន័យបន្ទាប់បន្សំដែលពាក់ព័ន្ធ (ទិន្នន័យបែបគុណភាព និងបរិមាណ)។ ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើងនៅក្នុងរាជធានីខេត្ត "គោលដៅ"ៗ ចំនួន៥ ដែលរួមមានជាអាទិ៍ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តព្រះសីហនុ និង ខេត្តបាត់ដំបង។ គំហើញនេះត្រូវបានដាក់ជូនក្រុមប្រឹក្សាយោបល់ ដែលត្រូវបានបង្កើតឡើងដោយអង្គការយូនីសេហ្វ និងក្រុមស្រាវជ្រាវ និងវាយតម្លៃរបស់អង្គការយូនីសេហ្វ ហើយមតិយោបល់ត្រឡប់ដែលទទួលបានពីក្រុមទាំង ២ នេះត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍នេះផងដែរ។

1 ទោះបីជាការគណនាថ្លៃចំណាយលើការថែទាំជំនួសត្រូវបានបញ្ចូលនៅក្នុងលក្ខខណ្ឌយោងនៃការសិក្សានេះក៏ដោយ ក៏មានការឯកភាពផងដែរថា ដោយសារពេលវេលា និងទិន្នន័យមានកម្រិត ដូច្នេះការសិក្សានេះមិនគួរពាក់ព័ន្ធនៅក្នុងការគណនាថ្លៃចំណាយនោះទេ លើកលែងកម្រិតវិសាលភាពនៃចំនួនទឹកប្រាក់ដែលត្រូវបានចំណាយលើអ្នកថែទាំជំនួស។

# ប្រវត្តិ និងបរិបទ

# ២

ដូចគ្នាទៅនឹងស្ទើរគ្រប់សង្គមទាំងអស់ក្នុងពិភពលោកដែរ គ្រួសារកម្ពុជាហាក់មានប្រពៃណីប្រើប្រាស់បណ្ដាញសាច់ញាតិជិតស្និទ្ធ និង សាខាញាតិ ជាមធ្យោបាយថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះ។ មានការលើកឡើងថា៖ «កន្លងមក បទដ្ឋានសង្គមនៅក្នុងប្រទេសកម្ពុជាកំណត់ថា កុមារកំព្រា និងកុមារដែលត្រូវបានបោះបង់ ដែលលែងទទួលបានការថែទាំពីឪពុកម្ដាយបង្កើត ត្រូវបានទុកដាក់នៅក្នុងការថែទាំដោយ សាខាញាតិ» និង »ការថែទាំតាមវត្តអារាមសម្រាប់កុមារា គឺជាទម្រង់ជាប្រពៃណីមួយនៃការថែទាំតាមសហគមន៍ដែលបានផ្ដល់ដល់កុមារាកំព្រា និងកុមារាទុគ៌ត»[2] ដែលគ្រួសារមិនអាចមើលថែពួកគេបាន។

បើទោះជាដូច្នេះក្ដី វាដូចជាផ្ទុយពីការថែទាំដោយសាច់ញាតិបន្តិច ដោយថា វត្តអារាមរមែងតែងបាន «បំពេញតួនាទីទ្វេដង» គឺតួនាទីផ្ដល់ការថែទាំផង និងតួនាទីផ្ដល់នូវការអប់រំបន្ថែមផងដល់កុមារ។ សូម្បីនៅសម័យមុនអាណានិគមនិយម វត្តអារាមកម្ពុជា«*បានផ្ដល់នូវការអប់រំថ្នាក់បឋមសិក្សាសម្រាប់កុមារាផ្ដល់នូវការថែទាំសម្រាប់កុមារាកំព្រា និងជម្រកសម្រាប់មនុស្សចាស់*»[3]។ តាមពិតនៅយុគសម័យមុនអាណានិគម វត្តអារាមគឺជាជាគ្រឹះស្ថានអប់រំនៅក្នុងប្រទេសកម្ពុជាតែមួយគត់ ប៉ុន្តែការសិក្សារៀនសូត្រតាមវត្តអារាមកន្លងមកនេះមិនបានបើកទ្វារទទួលស្ត្រី និងក្មេងស្រីនោះទេ។[4]

ភស្តុតាងដែលមានស្រាប់មួយចំនួន បានប្រាប់ឲ្យដឹងថា ការថែទាំដោយសាច់ញាតិ និងការថែទាំតាមវត្តអារាមដែលជា «ជាប្រពៃណី» ត្រូវបានកាត់ផ្ដាច់នៅក្នុងយុគសម័យខ្មែរក្រហម ដែលមានផលប៉ះពាល់យ៉ាងខ្លាំងដល់ទំនាក់ទំនងសាច់ញាតិជិតស្និទ្ធ និងសាខាញាតិ៖ «*ឪពុកម្ដាយលែងមានសិទ្ធិអំណាចទៅលើកូនរបស់ខ្លួនទៀតហើយ...របបខ្មែរក្រហមបានពន្លឿនការកំណត់ឡើងវិញអំពីគុណធម៌នៃការឯកភាពគ្រួសារ... និងបានចាប់ផ្ដើមបំបែកចំណងដែលចងភ្ជាប់ទំនាក់ទំនងរវាងកូន គ្រួសារ និងសហគមន៍ជាមួយគ្នា*» ។[5] ក្នុងអំឡុងរបបខ្មែរក្រហម «*បណ្ដាញញាតិទាំងអស់ត្រូវបានបែកបាក់ រួមទាំងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងនាមជាមាតាក៏ត្រូវបានលុបបំបាត់ដោយសារគ្រួសារត្រូវបានបញ្ចូលជាក្រុមសហករណ៍ និងការបង្កើតឲ្យមានសមភាពនិយមនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត*» ។[6]

មានភស្តុតាងខ្លះ ដែលសង្គមកម្ពុជា យល់ឃើញថា ការបាត់បង់ម្ដាយគឺជាការ បាត់បង់ដ៏ធំជាងការបាត់បង់ឪពុក។ ពាក្យស្លោកដ៏មានប្រជាប្រិយរបស់ខ្មែរពោលថា «*ស៊ូស្លាប់បារ កុំឲ្យស្លាប់មេ។ សុខចិត្តលិចទូកកណ្ដាលទន្លេ ជាងភ្លើងឆេះផ្ទះ*»។ ទោះដូច្នេះក្ដី យោងតាមការសិក្សាអំពីមនុស្សសាស្ត្រ[7] ពាក្យថាញាតិជាខ្មែរ »មិនបានបែងចែកដាច់ស្រឡះរវាងបងប្អូនប្រុសខាងម្ដាយ និងបងប្អូនប្រុសខាងឪពុក ឬសាច់ញាតិខាង ម្ដាយ និងសាច់ញាតិខាងឪពុកនោះទេ»។ ការសិក្សានេះបានលើកឡើងនូវអំណះអំណាង

2 Westering, J. (២០១០) ការផ្លាស់ប្ដូរបទដ្ឋានសង្គមទាក់ទងនឹងការថែទាំជំនួសចំពោះកុមារនៅក្នុងប្រទេសកម្ពុជា។ ឯកសារចុងក្រោយរបស់អង្គការយូនីសេហ្វ។

3 Kent, A. (២០០២) ឯកសារស្ដីពីការស្ដារឡើងវិញនូវស្មារតីរួមគ្នា៖ តួនាទីនៃការស្ដារឡើងវិញព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា។

4 Rany, S et al. (២០១២) Cambodia's Higher Education Development in Historical Perspectives (1863-2012). International Journal of Learning & Development. Vol. 2, No. 2.

5 Westering, J. (២០១០) ការផ្លាស់ប្ដូរបទដ្ឋានសង្គមចំពោះការថែទាំជំនួសចំពោះកុមារនៅក្នុងប្រទេសកម្ពុជា។ ឯកសារចុងក្រោយរបស់អង្គការយូនីសេហ្វ។

6 Brickell, K. (2012). 'The 'Stubborn Stain' on Development: Gendered Meanings of Housework (Non)-Participation in Cambodia'. Journal of Development Studies, Taylor & Francis (Routledge), 2011, pp.1

7 Ledgerwood, J. L. (January 01, 1995). Khmer kinship: The matriliny/matriarchy myth. Journal of Anthropological Research, 247-261.

ផ្ទុយថា ប្រព័ន្ធញាតិខ្មែរមានលក្ខណៈទ្វេភាគី ដោយវាមិនមែនផ្តោតចំពោះតែខ្សែខាងឪពុក ឬខ្សែខាងម្តាយដែលផ្តល់ទម្ងន់មិនស្មើចំពោះខ្សែខាងប្រុស ឬជាខ្សែខាងស្រីនោះទេ។ មានន័យថា នៅក្នុងសង្គមខ្មែរការថែទាំដោយសាច់ញាតិ មិនចាំបាច់ត្រូវមានភាព លម្អៀងចំពោះការថែទាំដោយសាច់ញាតិខាងម្តាយជាងសាច់ញាតិខាងឪពុកឡើយ។ ចំណុចនេះក៏បានទទួលការបញ្ជាក់ តាមរយៈអ្នកផ្តល់ព័ត៌មានដ៏សំខាន់ម្នាក់នៅក្នុងកិច្ចសម្ភាសសម្រាប់ការសិក្សានេះផងដែរ ដែលគាត់បានលើកឡើងថា វាមិនសំខាន់ថាកុមារត្រូវបានថែទាំដោយសាច់ញាតិខាងណាឡើយ «វាអាស្រ័យលើឥរិយាបថ និងបុគ្គលិកលក្ខណៈរបស់សាច់ញាតិនោះ» ជាជាងលើខ្សែខាងឪពុក ឬខ្សែខាងម្តាយ។[8] គេមិនបានដឹងអំពីចំនួនកុមារសរុបនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានការថែទាំដោយអ្នកដទៃក្រៅពីឪពុក ឬម្តាយរបស់ពួកគេឡើយ។ លើសពីនេះមានភស្តុតាងតិចតួចអំពីចំនួនកុមារ ដែលស្ថិតនៅក្នុងការថែទាំ ដោយសាច់ញាតិ ឬថែទាំដោយឪពុកម្តាយធម៌ ប៉ុន្តែមានភស្តុតាងបញ្ជាក់អំពីសេវាថែទាំដោយឪពុកម្តាយធម៌ផ្សេងៗគ្នានៅទូទាំងប្រទេសដែលភាគច្រើនសេវាទាំងនោះត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងនោះ មានអង្គការជាច្រើនជាសមាជិករបស់ 3PC។

មានភស្តុតាងច្រើនថែមទៀតអំពីចំនួនកុមារដែលស្ថិតក្នុងទម្រង់ផ្សេងៗនៃការថែទាំតាមមណ្ឌលក្នុងនោះរួមមាន ផ្ទះស្នាក់នៅជាក្រុម និងការថែទាំតាមវត្តអារាម។ របាយការណ៍ស្តីពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារថ្មីៗនេះដែលធ្វើឡើងដោយ ក្រសួង ស.អ.យ ក្នុងឆ្នាំ ២០១៤ និងឆ្នាំ ២០១៥ (ដែលនឹងត្រូវបោះពុម្ពផ្សាយក្នុងខែមីនា ឆ្នាំ ២០១៧) បានរកឃើញកុមាររស់នៅតាមមណ្ឌលចំនួន ២៦.១៨៧ នាក់ (ក្នុងចំណោមកុមារប្រមាណ៥.៥លាននាក់)ក្នុងនោះកុមារចំនួន១១.៧៨៨នាក់ (៧១%នៃចំនួនកុមារសរុបនៅក្នុងមណ្ឌល) រស់នៅក្នុងមណ្ឌលនៅក្នុងរាជធានីខេត្តអាទិភាពទាំង ៥ ដែលការសិក្សានេះបានគ្របដណ្តប់។[9]

ការកំណត់ទីតាំងកន្លែងថែទាំកុមារបានរកឃើញកន្លែងថែទាំកុមារចំនួន ៦៣៩ កន្លែង នៅក្នុងរាជធានីខេត្តចំនួន ២៥ ក្នុងប្រទេសកម្ពុជា ក្នុងនោះ ៧១កន្លែង ត្រូវបានកំណត់ប្រភេទថាជាផ្ទះស្នាក់នៅជាក្រុម (ថែទាំកុមារចំនួន ៦%) និង ៧២ កន្លែង ជាអន្តេវាសិកដ្ឋាន (ថែទាំកុមារចំនួន ២៣%) និង ៦៥ កន្លែង ជាវត្តអារាម ឬ ជាកន្លែងថែទាំរបស់សាសនាដទៃទៀត (ថែទាំកុមារចំនួន ៥%)។

នៅក្នុងរាជធានីខេត្តអាទិភាពទាំង ៥ ដែលការសិក្សានេះគ្របដណ្តប់ ការកំណត់ទីតាំងបានរកឃើញមណ្ឌលថែទាំកុមារចំនួន ៤០០កន្លែង ដែលមានកុមាររស់នៅសរុបចំនួន ១៨.០០៧ នាក់។[10] មានកន្លែងថែទាំកុមារចំនួន ២៦៧កន្លែង ដែលមានលក្ខខណ្ឌស្របតាមនិយមន័យថាជា «មណ្ឌលថែទាំកុមារ» របស់ក្រសួង ស.អ.យ។[11] មានកន្លែងថែទាំកុមារចំនួន ១៩កន្លែង ត្រូវបានចាត់ទុកថាជាផ្ទះស្នាក់នៅបណ្តោះអាសន្ន និងជាកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន និង មានកន្លែងថែទាំកុមារចំនួន ៥៧កន្លែង ត្រូវបានចាត់ប្រភេទថាជាផ្ទះស្នាក់នៅជាក្រុម និង ៤៦កន្លែងជាអន្តេវាសិកដ្ឋាន និង ១១ ផ្សេងទៀតជាវត្តអារាម ឬកន្លែងថែទាំកុមាររបស់សាសនាដទៃទៀត។

របាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារ បានបញ្ជាក់ថា ការថែទាំកុមារនៅក្នុងមណ្ឌលនៅមានចំនួនខ្ពស់នៅឡើយក្នុងប្រទេសកម្ពុជា។ ចំណុចនេះបង្កប់អត្ថន័យមួយចំនួន សម្រាប់អភិវឌ្ឍន៍ការងាររៀបចំថែទាំជំនួសតាមសហគមន៍ អាស្រ័យដោយវាបង្ហាញអំពីចំនួននៃការទុកដាក់កុមារតាម

8 KII ជាមួយតំណាងអង្គការយូនីសេហ្វ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។
9 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា «ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល» ខែកុម្ភៈ ឆ្នាំ ២០១៧។
10 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា «ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល» ខែកុម្ភៈ ឆ្នាំ ២០១៧។
11 មណ្ឌលថែទាំជំនួសត្រូវបានកំណត់និយមន័យនៅក្នុងការសិក្សានេះថាជា៖ មណ្ឌលដែលផ្តល់សេវាដល់កុមារគ្រប់ប្រភេទដែលត្រូវបានបោះបង់ចោល ឬមិនអាចស្នាក់នៅជាមួយគ្រួសារបង្កើត ឬសាច់ញាតិរបស់ពួកគេនៅក្នុងសហគមន៍។

សហគមន៍ដែលគេត្រូវការដើម្បីបំពេញតម្រូវការបច្ចុប្បន្ន។ ផ្អែកលើចំនួនកុមារសរុបក្នុងឆ្នាំ ២០១២ តាមការប៉ាន់ប្រមាណត្រួសៗទំនងថាមានកុមារប្រហែល ០.៤៨% នៅក្នុងប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងទម្រង់មួយចំនួននៃការថែទាំតាមមណ្ឌល[12] ដែលតួលេខនេះ មានចំនួនច្រើនជាង តួលេខនៅប្រទេសអង់គ្លេសរហូតដល់ ៦ដង (កុមារចំនួន ០.០៧៦% រស់នៅក្នុងការថែទាំតាមមណ្ឌលនៅប្រទេសអង់គ្លេស)។ បើទោះបីជាការរៀបចំប្រព័ន្ធការពារកុមារនៅក្នុងប្រទេសមានប្រាក់ចំណូលមធ្យម ដូចជាប្រទេសកម្ពុជា មិនអាចយកមកធ្វើការប្រៀបធៀបបញ្ហានេះជាមួយប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ដូចជាចក្រភពអង់គ្លេសក៏ដោយ ប៉ុន្តែតួលេខនេះមានប្រយោជន៍សម្រាប់បង្ហាញថា មានការប្រើប្រាស់ការថែទាំតាមមណ្ឌលតិចតួចនៅក្នុងប្រព័ន្ធការពារកុមារមួយដែលមានការអភិវឌ្ឍន៍ ដោយត្រូវពិចារណាផងដែរថាចំនួនភាគរយនៃកុមារនៅក្នុងប្រព័ន្ធថែទាំក្នុងចក្រភពអង់គ្លេសជារួម មានចំនួនច្រើនជាងកុមារក្នុងប្រទេសកម្ពុជា។ តួលេខនៃរបាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារបានផ្តល់នូវទិន្នន័យបឋមដ៏មានប្រយោជន៍ ដែលអាចប្រើប្រាស់ជាមូលដ្ឋានព័ត៌មានសម្រាប់កិច្ចខិតខំប្រឹងប្រែងដើម្បីគ្រប់គ្រងការថែទាំតាមមណ្ឌល និងអភិវឌ្ឍន៍ការថែទាំតាមគ្រួសារ ក្នុងលក្ខណៈជាទម្រង់ទូទៅនៃការថែទាំជំនួសចំពោះកុមារ។

ទិន្នន័យដែលមានស្រាប់ពីរដ្ឋាភិបាល បានឲ្យដឹងថា ចំនួនមណ្ឌលថែទាំ និងចំនួនកុមាររស់នៅក្នុងមណ្ឌលក្នុងប្រទេសកម្ពុជា បានថយចុះបន្តិចចាប់តាំងពីឆ្នាំ ២០០៥។ បើទោះដូច្នេះក្តី ចំនួនមណ្ឌលថែទាំនៅតែជាទម្រង់ដ៏សំខាន់នៃការថែទាំជំនួសចំពោះកុមារ។ អង្គការយូនីសេហ្វបានសង្កេតឃើញនៅក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីកិច្ចការពារកុមារនាពេលថ្មីៗនេះថា៖ *«ទោះបីជាមានការធ្វើអន្តរាគមន៍លើកកម្ពស់ការយល់ដឹងជាបន្តបន្ទាប់ រាប់បញ្ចូលទាំងគោលនយោបាយមិនលើកទឹកចិត្តចំពោះការយកកុមារទៅដាក់ក្នុងមណ្ឌលក៏ដោយ ក៏មណ្ឌលថែទាំកុមារនៅតែត្រូវបានគេលើកកម្ពស់ដដែល ក្នុងនោះរួមមានទាំងសមាជិករបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គកនក) មេភូមិ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។*[13]

ការសន្និដ្ឋាននេះ មានសង្គតភាពទៅនឹងលទ្ធផលនៃការសិក្សាឆ្នាំ ២០១១ ស្តីពីឥរិយាបថចំពោះការថែទាំតាមមណ្ឌល ដែលធ្វើឡើងដោយអង្គការយូនីសេហ្វ ក្រោមកិច្ចសហការជាមួយ ក្រសួង ស.អ.យ។ ការសិក្សានេះបានរកឃើញនូវការគាំទ្រដ៏ខ្លាំងក្លាចំពោះការថែទាំតាមមណ្ឌលនៅកម្រិតសហគមន៍។[14] ការសិក្សានោះបានឱ្យដឹងថា ប្រធានភូមិភាគច្រើនគាំទ្រចំពោះការថែទាំតាមមណ្ឌល និងមានមេភូមិមួយចំនួនតូចប៉ុណ្ណោះធ្លាប់បានឮអំពីជម្រើសថែទាំជំនួស ឬជម្រើសថែទាំកុមារតាមសហគមន៍។ ការសិក្សាឆ្នាំ ២០១១ ក៏បានរកឃើញផងដែរថាគ្រួសារក៏គាំទ្រចំពោះការថែទាំកុមារនៅតាមមណ្ឌលផងដែរ ជាពិសេសកុមារទីទ័លក្រ ដែលឪពុកម្តាយមិនអាចបំពេញតាមសេចក្តីត្រូវការមូលដ្ឋានរបស់ពួកគេបាន កុមារដែលឪពុកម្តាយមិនអាចផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ ឬកុមារដែលមិនបានចូលរៀន។ ការសិក្សាបានគូសបញ្ជាក់ថា៖ *«ប្រទេសកម្ពុជាខ្វះបណ្តាញសុខុមាលភាពសង្គមដើម្បីគាំទ្រគ្រួសារក្រីក្រដែលមានតម្រូវការ និងជាញឹកញាប់ការថែទាំតាមមណ្ឌលរមែងតែងបានជួយបំពេញនូវបញ្ហាខ្វះចន្លោះនេះ»។*[15]

12 ជាការល្អប្រសិនបើយើងធ្វើការប្រៀបធៀបចំនួននេះទៅប្រទេសអង់គ្លេសដែលមានកុមារ ៦០នាក់ក្នុងចំណោម ១០០០០នាក់ត្រូវបានរដ្ឋជាអ្នកមើលថែទាំ ដែលក្នុងនោះមាន ៧% មានកុមារស្វែងរកសិទ្ធិជ្រកកោន និងមិនមានអ្នកណានៅជាមួយ។ ក្នុងចំណោមកុមារសរុប ៧០.៤៤០នាក់ មាន ៥១.៨៥៩នាក់ (៧៤%) ស្ថិតនៅក្នុងការថែទាំដោយឪពុកម្តាយធម៌។ មាន ១១%នៃកុមារ ៧៦០០នាក់ស្ថិតនៅក្នុងការថែទាំតាមមណ្ឌល។ ទិន្នន័យពីការសិក្សារបស់សាកលវិទ្យាល័យកូឡុំប៊ីបង្ហាញនូវភាគរយខ្ពស់ជាងគេនៃចំនួនកុមាររស់នៅក្នុងការថែទាំតាមមណ្ឌល។

13 អង្គការយូនីសេហ្វកម្ពុជា «ពង្រឹងប្រព័ន្ធគាំពារកុមារនៅក្នុងប្រទេសកម្ពុជា» របាយការណ៍រីកចម្រើនប្រចាំត្រីមាសរបស់អង្គការយូនីសេហ្វផ្ញើទៅទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ខែមករា ដល់ខែមីនា ឆ្នាំ ២០១៦។

14 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វ «ការសិក្សាអំពីឥរិយាបថចំពោះការថែទាំតាមមណ្ឌលនៅក្នុងប្រទេសកម្ពុជា» ឆ្នាំ ២០១១។

15 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វ «ការសិក្សាអំពីឥរិយាបថចំពោះការថែទាំតាមមណ្ឌលនៅក្នុងប្រទេសកម្ពុជា» ឆ្នាំ ២០១១។

## គោលនយោបាយ

ក្នុងឆ្នាំ២០០៦រាជរដ្ឋាភិបាលបានចេញឯកសារគោលនយោបាយស្តីពីការថែទាំជំនួស[16] សម្រាប់កុមារដែលត្រូវការកិច្ចការពារពិសេសនិងកុមារប្រឈម។ នៅក្នុងឯកសារគោលនយោបាយនេះ រាជរដ្ឋាភិបាលបានចែង នូវកម្រងគោលការណ៍មួយចំនួនសម្រាប់អនុវត្តចំពោះកុមារដែលត្រូវការការថែទាំជំនួស៖

- ការថែទាំដោយគ្រួសារ និងការថែទាំតាមសហគមន៍ គឺជាជម្រើសដ៏ប្រសើរបំផុតម្រាប់ការថែទាំជំនួស។
- ការថែទាំតាមមណ្ឌល គួរជាជម្រើសចុងក្រោយបំផុត និងជាដំណោះស្រាយបណ្តោះអាសន្ន។
- ត្រូវបង្កើតយុទ្ធសាស្ត្រ និងវិធានការជាក់លាក់ដើម្បីគាំទ្រដល់ឪពុកម្តាយក្នុងការចិញ្ចឹមបីបាច់កូនរបស់ពួកគេ និងបញ្ជូនកូនទៅសាលារៀន។
- យុទ្ធសាស្ត្រ និងវិធានការទាំងនេះគួរផ្តោតលើគ្រួសារ សាច់ញាតិ និងសហគមន៍ដែលផ្តល់ ការថែទាំកុមារ ដែលឪពុកម្តាយមិនអាចថែទាំបាន ដើម្បីបញ្ចៀសការយកកុមារទៅដាក់ក្នុងមណ្ឌល។
- នៅពេលដែលមិនអាចចៀសវាងពីការថែទាំតាមមណ្ឌលបាន បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំសម្រាប់ការថែទាំតាមមណ្ឌល ត្រូវយកមកអនុវត្ត ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ស្របតាមគោលការណ៍ដែលមានអធិកភាពនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- ការថែទាំតាមមណ្ឌល និង/ឬសហគមន៍ ឬការថែទាំតាមគ្រួសារត្រូវខិតខំធ្វើយ៉ាងណាឱ្យ ស្របតាមបទដ្ឋានអប្បបរមាដែលបានរៀបចំនៅក្នុងក្របខណ្ឌគោលនយោបាយនេះ។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាថែទាំជំនួសចំពោះកុមារ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួង ស.អ.យ និងត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ។

រដ្ឋាភិបាល បានមើលឃើញឧបស័គ្គដ៏ធំក្នុងការអនុវត្តគោលនយោបាយនេះ ដោយសារតែ៖

- មានការយល់ដឹងនៅមានកម្រិតអំពីសិទ្ធិកុមារ។
- មានការយល់ដឹងដ៏មានកម្រិតអំពីបញ្ហាសង្គមនៅគ្រប់កម្រិតទាំងអស់។
- ខ្វះធនធានសម្រាប់អនុវត្តគ្រប់ផ្នែកនៃកម្មវិធី។
- មានការលំបាកក្នុងការចាត់អាទិភាពបញ្ហា និងកំណត់គោលដៅ និងគោលបំណងដែល អាចសម្រេចបាន។
- ក្របខណ្ឌច្បាប់ត្រូវបានរៀបចំដោយផ្នែក។
- អនុវត្តមិនបានពេញលេញនូវច្បាប់ជាតិ និងលិខិតូករណ៍ច្បាប់អន្តរជាតិដែលបានផ្តល់សច្ចាប័ន។
- ការសម្របសម្រួលក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល ក៏ដូចជា អង្គការសង្គមស៊ីវិលដែលធ្វើការជាមួយ កុមារងាយរងគ្រោះ នៅមានកម្រិត។
- ខ្វះប្រព័ន្ធត្រួតពិនិត្យតាមដាន ដែលមានលក្ខណៈរួមបញ្ចូលនៅគ្រប់កម្រិតទាំងអស់ និងកង្វះលទ្ធភាពក្នុងការទទួលបានព័ត៌មាន។
- ផលវិបាកមួយចំនួននៃទំនើបកម្ម ដូចជាបញ្ហាបុគ្គលនិយម ការបាត់បង់តម្លៃជាប្រពៃណី និងសាមគ្គីភាព។ល។

16 ការថែទាំជំនួសត្រូវបានផ្តល់និយមន័យនៅក្នុងឯកសារគោលនយោបាយត្រង់ទំព័រទី ៩ ថាជាការថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀតដែលមិនស្ថិតនៅក្រោមការថែទាំដោយឪពុកម្តាយបង្កើតរបស់ពួកគេ។

គោលបំណងដ៏ជាក់លាក់មួយ ដែលមានចែងនៅក្នុងគោលនយោបាយនេះ គឺត្រូវរៀបចំក្របខណ្ឌគោលនយោបាយដើម្បីគ្រប់គ្រង និងរៀបចំឱ្យមានលក្ខណៈផ្លូវការចំពោះទម្រង់ផ្សេងៗគ្នានៃការថែទាំជំនួស រួមមានការកំណត់តួនាទី និងការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និងគោលការណ៍ណែនាំ។

រដ្ឋាភិបាល ក៏បានចាត់វិធានការផងដែរដើម្បីរៀបចំឱ្យមានយន្តការ "ត្រួតពិនិត្យ" ដើម្បីកាត់បន្ថយការទទួលកុមារឱ្យចូលស្នាក់នៅក្នុងមណ្ឌលថែទាំ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារដែលចូលជាធរមាន ក្នុងខែកញ្ញា ឆ្នាំ ២០១៥ បានគូសបញ្ជាក់ឡើងវិញថា *"ការអនុញ្ញាតឲ្យកុមារចូល រស់នៅក្នុងមណ្ឌលថែទាំគឺជាជម្រើសចុងក្រោយ និងបណ្តោះអាសន្ន និង អាចធ្វើទៅបាន លុះត្រាណាតែបានខិតខំប្រឹងប្រែងអស់លទ្ធភាពក្នុងការស្វែងរកឪពុកនិងម្តាយ ឬ ឪពុកឬម្តាយ សាច់ញាតិ ឬអ្នកអាណាព្យាបាល ឬឪពុកម្តាយធម៌របស់កុមារ"។*[17]

ចាប់តាំងពីអនុក្រឹត្យស្តីពីការថែទាំតាមមណ្ឌលចូលជាធរមានរួចមក ក្រសួង ស.អ.យ បានកំណត់ជំហានសម្រាប់ការអនុវត្តអនុក្រឹត្យនេះ ព្រមទាំងបានរៀបចំផែនការសកម្មភាពជាតិសម្រាប់កែលំអការថែទាំកុមារ ដោយមានគោលដៅបង្វែរកុមារដោយសុវត្ថិភាពចំនួន ៣០% ពីមណ្ឌល ទៅរកការថែទាំដោយគ្រួសារ និងសហគមន៍វិញត្រឹមឆ្នាំ ២០១៨។ ផែនការសកម្មភាពនេះត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៅក្នុងខែកញ្ញា ឆ្នាំ ២០១៦។ ដូចគ្នានេះដែរ ផែនការប្រតិបត្តិរបស់រាជធានីខេត្តទាំង ៥ដែលមានគោលបំណងដូចគ្នាត្រូវបានរៀបចំឡើងសម្រាប់រាជធានីខេត្តគោលដៅទាំង ៥ (ភ្នំពេញ សៀមរាប បាត់ដំបង កណ្តាល និង ព្រះសីហនុ)។ រដ្ឋាភិបាលកម្ពុជា មិនបានអនុញ្ញាតឱ្យអភិវឌ្ឍន៍មណ្ឌលថែទាំកុមារថ្មីឡើយ ចាប់តាំងពីមានការចេញអនុក្រឹត្យនេះមក។

ចាប់តាំងពីរដ្ឋាភិបាលបានចេញផ្សាយគោលនយោបាយស្តីពីការថែទាំជំនួសក្នុងឆ្នាំ ២០១៦ មក រដ្ឋាភិបាលបានបន្តសង្កត់ធ្ងន់ការគាំទ្រ និង ការចង់បានរបស់ខ្លួន នូវជម្រើសថែទាំតាមគ្រួសារ ចំពោះកុមារដែលត្រូវការការថែទាំជំនួស ជាជាងការថែទាំតាមមណ្ឌល ហើយរដ្ឋាភិបាលបានធ្វើការសហការជាមួយអង្គការផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដើម្បីលើកកម្ពស់គោលនយោបាយរបស់ខ្លួន។ កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ (3PC) គឺជាគម្រោងសហការមួយរវាងអង្គការយូនីសេហ្វ និង ក្រសួង ស.អ.យ ដើម្បីពង្រឹងប្រព័ន្ធការពារកុមារនៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់សេវាសង្គមកិច្ច ការឆ្លើយតបបន្ទាន់ ការធ្វើសមាហរណកម្មដោយសុវត្ថិភាពចំពោះកុមារដែលត្រូវបានបំបែកពីគ្រួសាររបស់ពួកគេ និង ការថែទាំតាមគ្រួសារ។[18] ក្រៅពីនេះ ក៏មានការផ្តល់ជំនួយគាំទ្របន្ថែមទៀតផងដែរពីគម្រោង 'ការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង ដែលទទួលបានមូលនិធិពី USAID ក្នុងគោលបំណងលើកកម្ពស់លទ្ធផលការងារថែទាំកុមារ ដែលមិនរស់នៅក្រោមការថែទាំរបស់គ្រួសារ បង្ការការបំបែកកុមារ ពីគ្រួសារដោយមិនចាំបាច់រួមទាំងជួយឲ្យ មានការទុកដាក់កុមារដែលមិនស្ថិតក្រោមការថែទាំពីគ្រួសារ ទៅក្នុងការថែទាំដោយ គ្រួសារមួយដ៏សមស្រប។

អភិក្រមដែលរដ្ឋាភិបាលបានប្រកាន់យកពុំមានការប្រែប្រួលឡើយក្នុងរយៈពេល ១ទស្សវត្សរ៍កន្លងមកនេះ និងបានទទួលការស្វាគមន៍ តែទន្ទឹមនោះ គេត្រូវទទួលស្គាល់ថា វាមានការប្រឈមជាច្រើននៅក្នុងការ អនុវត្តគោលនយោបាយនោះ។ គោលនយោបាយនេះមានភាពស៊ីសង្វាក់ច្រើនទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និង គោលការណ៍ណែនាំស្តីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ[19] រួមទាំងការ

17 មាត្រា ១១ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (ឆ្នាំ ២០១៥)។

18 មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៩ដែលប្រតិបត្តិដូចជាដៃគូអនុវត្ត មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៦ ដែលជាដៃគូបច្ចេកទេស និងមានអង្គការសហគមន៍ចំនួន ៤០គឺជាដៃគូបណ្តាញ។

19 ឯកសារសហប្រជាជាតិ A/HRC/11/L.13, ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៩។

យល់ដឹងបច្ចុប្បន្នអំពី ការអនុវត្តល្អបំផុត។ គោលនយោបាយនេះក៏ស្របទៅនឹងការអនុវត្តការថែទាំជំនួស បែបប្រពៃណីនៅក្នុងប្រទេសកម្ពុជាផងដែរ ដែលការថែទាំបែបនេះពឹងផ្អែកសំខាន់ទៅលើបណ្តាញ សាច់ញាតិ និង បណ្តាញវត្តអារាម ដើម្បីផ្តល់ការ ថែទាំចំពោះកុមារ ដែលគ្មានការថែទាំពីឪពុកម្តាយ។

## បញ្ញត្តិច្បាប់

ដូចដែលបានលើកឡើងនៅក្នុងឯកសារគោលនយោបាយស្តីពីការថែទាំជំនួស ក្របខណ្ឌច្បាប់ដែល គ្របដណ្តប់លើកិច្ចការពារកុមារ និងការថែទាំជំនួសមានលក្ខណៈមិនប្រមូលផ្តុំ និងរប៉ាត់រប៉ាយ។

### បញ្ញត្តិច្បាប់សំខាន់ៗស្តីពីការថែទាំជំនួសក្នុងប្រទេសកម្ពុជា

**ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩៖**

មាត្រា ១១៩៖ ការដកហូតអំណាចមេបា៖ ត្រូវដកហូតអំណាចមេបា ហើយប្រគល់ទៅឲ្យស្ថាប័នណាមួយ ឬញាតិលោហិតណាមួយ ចំពោះឪពុក-ម្តាយដែលមានកំហុសដូចខាងក្រោម៖

- ឪពុក-ម្តាយដែលខកខានក្នុងការអប់រំកូន
- ឪពុក-ម្តាយប្រើអំណាចមិនសមស្រប ដែលរំលោភបំពានទៅលើសិទ្ធិរបស់កូន ឬ បង្ខំកូនឲ្យប្រព្រឹត្តបទល្មើស ឬអំពើណាមួយប្រឆាំងនឹងសង្គម។
- ឪពុក-ម្តាយវាយធ្វើបាបកូនឥតត្រាប្រណី។
- ឪពុក-ម្តាយប្រព្រឹត្តផ្ទុយពីបទដ្ឋានសីលធម៌ដែលមានឥទ្ធិពលអាក្រក់ចំពោះកូនរបស់ខ្លួន។

មាត្រា ១២០៖ តុលាការប្រជាជន អាចនឹងសម្រេចដកហូតអំណាចមេបាពីឪពុកម្តាយដែលមានកំហុសបាន លុះត្រាតែមានពាក្យប្តឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន ឬញាតិលោហិតណាមួយនៃឪពុកម្តាយនោះ។

**បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស** ដែលបានអនុម័តក្នុងឆ្នាំ ២០០៨ មានចែងអំពីលិខិតូបករណ៍ច្បាប់ ២ដោយឡែកពីគ្នា៖ ប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមារតាមមណ្ឌល និងប្រកាសស្តីពី បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍។ លក្ខខណ្ឌតម្រូវនៅក្នុងបទដ្ឋានអប្បបរមាទាំងនេះ ភាគច្រើនមានសង្គតភាពទៅនឹងលក្ខណៈវិនិច្ឆ័យ ដែលបាន ចែងនៅក្នុងគោលការណ៍ណែនាំរបស់ អង្គការសហប្រជាជាតិ ដោយមានការលើកលែងថា ផ្ទះស្នាក់នៅជាក្រុមត្រូវបានចាត់ទុកថាជាទម្រង់មួយនៃ «ការថែទាំជំនួសនៅក្នុងសហគមន៍» ជាជាងការថែទាំតាមមណ្ឌល។

**ប្រកាស**[20] **ស្តីពីនីតិវិធីអនុវត្តគោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ** ដែលបានចេញផ្សាយដោយ ក្រសួង ស.អ.យ ក្នុងឆ្នាំ ២០១១ មានគោលបំណងលើកកម្ពស់ការអនុវត្តជាក់ស្តែង នូវគោលនយោបាយ ស្តីពីការថែទាំជំនួសឆ្នាំ ២០០៦។ ប្រកាសនេះ ចែងអំពីការណែនាំនីតិវិធីទាក់ទង នឹងការកំណត់អត្តសញ្ញាណ កុមារងាយរងគ្រោះនិងកំណត់តួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋាន និងទីភ្នាក់ងារផ្សេងៗគ្នា។

**អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ** ដែលបានចេញផ្សាយក្នុងឆ្នាំ ២០១៥ មានចែងអំពីលក្ខខណ្ឌតម្រូវដ៏តឹងតែងទាក់ទងនឹងការបង្កើត និងគ្រប់គ្រងទម្រង់នៃការថែទាំកុមារតាមមណ្ឌល និងបានចែងអំពីបរិបទដ៏មានប្រយោជន៍សម្រាប់ឲ្យមានការយល់ដឹងអំពីការផ្លាស់ប្តូរការគ្រប់គ្រងទម្រង់នានា នៃការថែទាំជំនួសចំពោះកុមារនៅក្នុងប្រទេសកម្ពុជា។

20 ប្រកាសមានលក្ខណៈដូចគ្នានឹងលិខិតបទដ្ឋានមួយ (ដូចជាច្បាប់បំពេញបន្ថែម)។

# និយមន័យសំខាន់ៗ

៣

ផ្នែកនេះផ្ដល់និយមន័យនៃពាក្យដែលបានប្រើនៅក្នុងការសិក្សានេះ។ ភាគច្រើន និយមន័យ ទាំងនេះបានដកស្រង់ចេញពីពាក្យទាំងឡាយ ដែលមាននៅក្នុងគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ (២០០៦) របស់រាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែប្រសិនបើពាក្យនៅក្នុងគោលនយោបាយនេះមិនត្រូវបានគេ កំណត់និយមន័យ ឬនិយមន័យមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ពីគោលការណ៍ណែនាំរបស់អង្គការ សហប្រជាជាតិ យើងនឹងយកនិយមន័យដែលមាននៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិជាគោល។

**កុមារ** ត្រូវបានកំណត់ថាជាបុគ្គលដែលមានអាយុក្រោម១៨ឆ្នាំស្របតាមមាត្រា ១៧នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨។

**ការថែទាំជំនួស** ត្រូវបានកំណត់ថាជា «ការថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះដទៃទៀត ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្ដាយបង្កើតរបស់ពួកគេ» (គោលនយោបាយស្ដីពីការថែ ទាំជំនួសចំពោះកុមាររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៦)។

**ការថែទាំតាមសហគមន៍ និងការថែទាំតាមគ្រួសារ** ត្រូវបានកំណត់ថាជា «អភិក្រមមួយដែលបានរៀបចំឡើងដើម្បីជួយកុមារឲ្យមានលទ្ធភាពរស់នៅជាមួយគ្រួសាររបស់ពួកគេ ឬ ទុកដាក់កុមារនៅក្នុងគ្រួសារធម៌ និងប្រសិនជាអាច ត្រូវទុកដាក់កុមារនៅក្នុងសហគមន៍របស់ពួកគេ។ គ្រួសារនៅក្នុងបរិបទនេះរួមមាន សាខាញាតិដែលផ្ដល់ការថែទាំដោយសាច់ញាតិ គ្រួសារដែលមានកុមារជាមេគ្រួសារ និងគ្រួសារធម៌ដែលមិនមាន ទំនាក់ទំនងជាមួយកុមារ» (គោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ ២០០៦)។ ការសិក្សានេះ នឹងមិនបញ្ចូលគ្រួសារ ដែលមានកុមារជាមេគ្រួសារ ទៅក្នុងនិយមន័យរបស់ខ្លួនអំពីការថែទាំតាមគ្រួសារឡើយ។

**ការថែទាំមិនផ្លូវការ** ត្រូវបានកំណត់និយមន័យស្របតាមគោលការណ៍ណែនាំស្ដីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិថាជា «ការរៀបចំលក្ខណៈឯកជនណាមួយនៅក្នុងបរិយាកាសគ្រួសារមួយដែលកុមារត្រូវបានគេមើលថែទាំជាបន្តបន្ទាប់ដោយគ្មានកំណត់ ដោយសាច់ញាតិរបស់មិត្តភក្តិ (ការថែទាំដោយសាច់ញាតិមិនផ្លូវការ) ឬដោយអ្នកដទៃ ដោយប្រើប្រាស់សមាសភាពជាលក្ខណៈបុគ្គលរបស់ពួកគេស្របតាមគំនិតរបស់កុមារ ឪពុកម្ដាយរបស់កុមារ ឬបុគ្គលដទៃ ដោយការរៀបចំបែបនេះមិនមានការបង្គាប់បញ្ជាពីអាជ្ញាធរ រដ្ឋបាល ឬអាជ្ញាធរតុលាការ ឬស្ថាប័នដែលមានការទទួលស្គាល់ជាផ្លូវការណាមួយ»។[21]

**ការថែទាំផ្លូវការ** ត្រូវបានកំណត់និយមន័យស្របតាមគោលការណ៍ណែនាំស្ដីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ ថាជា «ការថែទាំទាំងអស់ដែលត្រូវបាន ផ្ដល់ជូននៅក្នុងបរិយាកាសគ្រួសារ មួយដែលត្រូវបានបង្គាប់បញ្ជាដោយស្ថាប័នរដ្ឋបាលមានសមត្ថកិច្ច ឬអាជ្ញាធរតុលាការ និងរាល់ការថែទាំទាំងអស់ដែលត្រូវបានផ្ដល់ជូននៅក្នុងបរិយាកាសមណ្ឌល រាប់បញ្ចូលមណ្ឌលឯកជន មិនចំពោះថាការថែទាំបែបនេះត្រូវបានធ្វើឡើងដោយសារវិធានការរដ្ឋបាល ឬ វិធានការតុលាការឡើយ»។[22]

21 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្ដីពីការថែទាំជំនួសចំពោះកុមារ សេចក្ដីសម្រេចលេខ ៦៤/១៤២ ឆ្នាំ ២០១០។
22 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្ដីពីការថែទាំជំនួសចំពោះកុមារ សេចក្ដីសម្រេចលេខ ៦៤/១៤២ ឆ្នាំ ២០១០។

**ការថែទាំដោយសាច់ញាតិ** ត្រូវបានកំណត់និយមន័យនៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិថាជា «ការថែទាំតាម គ្រួសារ នៅក្នុងសាខាញាតិរបស់កុមារ ឬ មិត្តភក្តិជិតស្និទ្ធរបស់គ្រួសារដែលកុមារ ស្គាល់ទោះក្នុងលក្ខណៈផ្លូវការក្តី ឬមិនផ្លូវការក្តី»។[23] គោលនយោបាយស្តីពីការថែទាំជំនួស (២០០៦) មិនបានកំណត់និយមន័យច្បាស់លាស់ អំពីការថែទាំដោយសាច់ញាតិនោះទេ ប៉ុន្តែវាស្ថិតនៅក្នុងនិយមន័យនៃ «ការថែទាំតាមសហគមន៍ និងការថែទាំតាមគ្រួសារ» (សូមមើលចំនុចខាងលើ)។

**ការថែទាំដោយឪពុកម្តាយធម៌** ត្រូវបានកំណត់និយមន័យនៅក្នុងគោលការណ៍ណែនាំអង្គការសហប្រជាជាតិ ថាជា «ស្ថានភាពដែលកុមារត្រូវ បានទុកដាក់ដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងផ្តល់ការថែទាំជំនួសនៅក្នុងបរិយាកាសមូលដ្ឋានរបស់គ្រួសារមួយ ជាជាង ក្នុងគ្រួសារផ្ទាល់របស់កុមារដែលត្រូវបានជ្រើសរើស មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលការឯកភាពយល់ព្រម និងមានការត្រួតពិនិត្យដើម្បីផ្តល់ការថែទាំបែបនោះ»។[24] ការថែទាំដោយ ឪពុកម្តាយធម៌មិនត្រូវបានផ្តល់និយមន័យជាក់លាក់នៅក្នុងគោលនយោបាយស្តីពីការថែទាំជំនួស (២០០៦) ឡើយ ប៉ុន្តែវាស្ថិតនៅក្នុងនិយមន័យនៃ «ការថែទាំតាមសហគមន៍ និងការថែទាំតាមគ្រួសារ» (សូមមើល ចំនុចខាងលើ)។

**ការថែទាំតាមផ្ទះស្នាក់នៅជាក្រុម** ត្រូវបានកំណត់និយមន័យថាជា «ទម្រង់មួយនៃការថែទាំជំនួសដែលកុមារមួយចំនួនតូច (មិនលើសពី ១៥នាក់) ស្នាក់នៅក្នុងបរិយាកាសគ្រួសារមួយដែលស្ថិតក្រោម ការគ្រប់គ្រងរបស់អ្នកថែទាំមួយក្រុមតូច ដែលមិនមានទំនាក់ទំនងជាមួយកុមារ។ ផ្ទះស្នាក់នៅជាក្រុម ត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ប៉ុន្តែមិនមែនគ្រប់គ្រងដោយសហគមន៍នោះទេ» (គោលន យោបាយស្តីពីការថែទាំជំនួសឆ្នាំ ២០០៦)។ ចាំបាច់ត្រូវកត់សម្គាល់ថា «ការថែទាំតាមផ្ទះស្នាក់នៅជាក្រុម» ស្ថិតនៅក្រោមនិយមន័យនៃការថែទាំតាមមណ្ឌលរបស់គោលការណ៍ណែនាំអង្គការសហប្រជាជាតិ ប៉ុន្តែត្រូវបានចាត់ទុកថាជាប្រភេទដោយឡែកនៅក្នុងប្រទេសកម្ពុជាទៅវិញ។

**ការថែទាំតាមវត្តអារាម** ត្រូវបានកំណត់និយមន័យថាជាការថែទាំដែលបានផ្តល់ដល់កុមារដោយព្រះសង្ឃ ដូនជី និងអាចារ្យ ដែលជាញឹក ញាប់ធ្វើឡើងនៅតាមវត្តអារាម (គោលនយោបាយស្តីពីការថែទាំជំនួស (២០០៦))។ ការថែទាំតាមវត្តអារាម អាចមានបញ្ចូលការផ្តល់អាហារ ជម្រក ការអប់រំរៀនសូត្រ និងទម្រង់ផ្សេងទៀតនៃការថែទាំ។[25] បើទោះបីជា ការថែទាំតាមវត្តអារាមអាចស្ថិតនៅក្នុងនិយមន័យនៃការថែទាំតាមមណ្ឌលក៏ដោយ ប៉ុន្តែរាល់ការ ថែទាំទាំងអស់ ដែលផ្តល់នៅក្នុងវត្ត ត្រូវបានចាត់ទុកថាជា «ការថែទាំតាមវត្តអារាម» សម្រាប់គោលបំណងនៃការសិក្សានេះ។

**ការថែទាំតាមមណ្ឌល** ត្រូវបានកំណត់និយមន័យថាជា «ការថែទាំដែលផ្តល់ដោយក្រុមគ្រួសារណាមួយដែលមិនមែនជាគ្រួសាររបស់កុមារដូចជា ទីកន្លែងសុវត្ថិភាពសម្រាប់ការថែទាំបន្ទាន់ មណ្ឌលសំចតពេលមានស្ថានភាពអាសន្ន និងមណ្ឌលថែទាំរយៈពេលខ្លី និងរយៈពេលវែងដទៃទៀត»។[26] និយមន័យនេះ ត្រូវបានដកស្រង់ចេញពីគោលការណ៍ណែនាំស្តីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ ហើយវាមាន សង្គតភាពទៅនឹងគោលនយោបាយស្តីពីការថែទាំជំនួសរបស់ប្រទេសកម្ពុជា (ឆ្នាំ ២០០៦)។ បើទោះជាដូច្នេះក្តី ខុសពីគោលនយោបាយ និយមន័យនេះមិនតម្រូវឲ្យបុគ្គលិកទទួលបានបៀវត្សរ៍ឡើយ។

23 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ សេចក្តីសម្រេចលេខ ៦៤/១៤២ ឆ្នាំ ២០១០។
24 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ សេចក្តីសម្រេចលេខ ៦៤/១៤២ ឆ្នាំ ២០១០។
25 រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយនៃការថែទាំជំនួសចំពោះកុមារ ឆ្នាំ ២០០៦ ទំព័រ ១២។
26 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ សេចក្តីសម្រេចលេខ ៦៤/១៤២ ឆ្នាំ ២០១០។

# គោលបំណងនៃការស្រាវជ្រាវ

## ៤

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងបំពេញគោលបំណងរួមចំនួន ៤ ដូចខាងក្រោម៖

១ ធ្វើការប៉ាន់ប្រមាណអំពីទម្រង់ផ្សេងៗគ្នានៃការថែទាំជំនួសចំពោះកុមារនៅក្នុងសហគមន៍។

២ ធ្វើការវិភាគថាតើទម្រង់នៃការថែទាំទាំងនេះ មានភាពអនុលោមទៅនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៨ ដូចម្តេចខ្លះ ហើយតើមានការអនុវត្តជាក់ស្តែង អ្វីខ្លះសម្រាប់ទម្រង់នៃការថែទាំទាំងនេះ។

៣ កំណត់ថ្លៃចំណាយនៃការផ្តល់ការថែទាំក្នុងទម្រង់ផ្សេងៗគ្នាដែលត្រូវបានអនុវត្តនៅសហគមន៍ រួមទាំងប្រភពមូលនិធិ និង

៤ កំណត់អំពីវិស័យដែលត្រូវការឱ្យមានកិច្ចគាំទ្រ ដើម្បីធានាថាទម្រង់ថែទាំជំនួសដែលមានស្រាប់នៅក្នុងសហគមន៍ មានភាពស្របគ្នាទៅនឹងបទដ្ឋានជាតិ និងអន្តរជាតិ។

ការសិក្សាស្រាវជត្រាវ ឆ្លើយតបទៅនឹងគោលបំណងនីមួយៗទាំងនេះដោយឆ្លើយកម្រងសំណួរស្រាវជ្រាវ ដ៏ជាក់លាក់មួយចំនួន ដែលមានដូចខាងក្រោម។ សំណួរសម្រាប់ស្រាវជ្រាវនេះអាចចែកជា៣ក្រុមតូចៗ អាស្រ័យលើថាតើគេចង់ឆ្លើយតបទៅនឹងគោលបំណងណាខ្លះ៖

### គោលបំណងទី ១ និងទី ២- ប៉ាន់ប្រមាណ និងវិភាគអំពីទម្រង់ផ្សេងៗនៃការថែទាំជំនួស

- តើទម្រង់នៃការថែទាំជំនួសនីមួយៗ ដែលបានបញ្ចូលនៅក្នុងការសិក្សានេះមានលក្ខណៈដូចម្តេចខ្លះ?
- តើទម្រង់នីមួយៗមានទំហំដូចម្តេចខ្លះ (ដូចជាចំនួននៃសេវាថែទាំ ចំនួនកុមារស្ថិតនៅក្នុងការថែទាំ ចំនួននៃអ្នកផ្តល់ការថែទាំ។ល។)?
- តើកុមារនៅក្នុងទម្រង់នីមួយៗនៃការថែទាំជំនួសទាំងនោះ មានប្រវត្តិដូចម្តេចខ្លះ?
- តើកុមារត្រូវបានកំណត់អត្តសញ្ញាណ និងធ្វើការទុកដាក់នៅក្នុងកន្លែងថែទាំផ្សេងៗគ្នាយ៉ាងដូចម្តេច? តើដំណើរការធ្វើសេចក្តីសម្រេចចិត្តមានអ្វីខ្លះ? តើមាននរណាខ្លះពាក់ព័ន្ធ និងចាប់ពីកម្រិតណាខ្លះ?
- តើកុមារស្គាល់ឈ្មោះបុគ្គលិកសង្គមកិច្ចដែរឬទេ (ឬអ្នកដែលបំពេញតួនាទីជាបុគ្គលិកសង្គមកិច្ច)? (ប្រសិនបើមាន) តើមានយន្តការត្រួតពិនិត្យអ្វីខ្លះ ដែលគេអាចកំណត់រកបាន? (ប្រសិនបើមាន) តើអាជ្ញាធរមានតួនាទីអ្វីខ្លះ? តើឪពុកម្តាយ និងសាខាញាតិមានតួនាទីអ្វីខ្លះ?
- តើការទុកដាក់កុមារនៅក្នុងទម្រង់នីមួយៗនៃការថែទាំជំនួសទំនងនឹងមានរយៈពេលប៉ុន្មាន? (ប្រសិនបើមាន) តើមានយន្តការអ្វីខ្លះសម្រាប់ធ្វើការពិនិត្យឡើងវិញ?
- តើនរណាជាអ្នកសម្រេចចិត្តអំពីការទាក់ទងជាមួយគ្រួសាររបស់កុមារ (ប្រសិនបើកុមារ ស្ថិតនៅក្នុងការថែទាំដោយអ្នកដទៃ) និងការទាក់ទងជាមួយឪពុកម្តាយបង្កើតរបស់កុមារ (ប្រសិនបើកុមារស្ថិតក្រោមការថែទាំដោយសាច់ញាតិ)? តើមានការគិតគូរពិចារណា ឬលើកកម្ពស់ការធ្វើសមាហរណកម្មដែរឬទេ? តើនរណាជាអ្នកសម្របសម្រួលការធ្វើសមាហរណកម្មនេះ?

- តើទម្រង់នៃការថែទាំជំនួសតាមសហគមន៍ បានផ្តល់ការថែទាំជាក់លាក់ដល់កុមារដែល មានសេចក្តីត្រូវការពិសេស ( កុមារពិការ កុមារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ) កុមារជាជនរងគ្រោះនៃអំពើហិង្សា និងការរំលោភបំពានផ្សេងៗ ) ដែរឬទេ ?
- តើកុមារ និងអ្នកថែទាំកុមារមានទស្សនៈ និងមានបទពិសោធន៍អ្វីខ្លះ (វិជ្ជមាន និងអវិជ្ជមាន ) នៅក្នុងទម្រង់នីមួយៗនៃការថែទាំជំនួស បើប្រៀបធៀបជាមួយការថែទាំតាមមណ្ឌល ?
- ជាទូទៅ តើទម្រង់នីមួយៗនៃការថែទាំជំនួសស្របជាមួយបទដ្ឋានជាតិ និងអន្តរជាតិកម្រិតណា ?
- តើមានកត្តាការពារ និង កត្តាហានិភ័យអ្វីខ្លះ ដែលជួយពង្រឹង ឬ ធ្វើឲ្យប៉ះពាល់ដល់ការសម្រេចបាននូវសិទ្ធិកុមារ ?

## គោលបំណងទី ៣- ផ្តល់ព័ត៌មានអំពីប្រភពមូលនិធិ និង គំរូហិរញ្ញប្បទានសម្រាប់ការថែទាំជំនួស

- តើទម្រង់នីមួយៗនៃការថែទាំជំនួសតាមសហគមន៍ទទួលបានហិរញ្ញប្បទានគាំទ្រយ៉ាងដូចម្តេច ?
- ដើម្បីរក្សាកុមារម្នាក់នៅក្នុងប្រភេទការថែទាំជំនួសនីមួយៗ តើត្រូវចំណាយអស់ប្រហែលប៉ុន្មាន ( ចំណាយសម្រាប់កុមារម្នាក់/ក្នុង១ថ្ងៃ/ក្នុង១ឆ្នាំ ) ?
- បើប្រៀបធៀបរវាងការចំណាយសម្រាប់ទម្រង់នីមួយៗនៃការថែទាំជំនួស តើវាមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ ?
- បើប្រៀបធៀបលើការចំណាយ តើការចំណាយនៅក្នុងទម្រង់នៃការថែទាំតាមសហគមន៍ខុសគ្នាពីទម្រង់ នៃការថែទាំតាមមណ្ឌលដូចម្តេចខ្លះ ?

ដោយសារពេលវេលាដែលបានផ្តល់ជូននៅក្នុងកិច្ចសន្យាមានកម្រិត រួមទាំងកង្វះទិន្នន័យផងនោះ យើងសម្រេចចិត្តថាការសិក្សានេះគួរតែធ្វើការពិនិត្យឡើងវិញទៅលើការចំណាយក្នុងលក្ខណៈមួយដែលមិនស៊ីជម្រៅ តាមរយៈការសាកសួរព័ត៌មានអំពីការចំណាយដោយផ្ទាល់ពីអ្នកថែទាំកុមារ រួមទាំងព័ត៌មានហិរញ្ញវត្ថុដទៃទៀត ទាក់ទងនឹងការចំណាយ ដែលអាចរកបានដោយងាយស្រួល។

## គោលបំណងទី ៤- កំណត់វិស័យដែលត្រូវការការជួយគាំទ្រចាំបាច់

- តើមានតម្រូវការអភិវឌ្ឍន៍សមត្ថភាពអ្វីខ្លះសម្រាប់ប្រភេទផ្សេងៗនៃការថែទាំជំនួស ដើម្បីលើកកម្ពស់ការថែទាំដ៏សមស្របចំពោះកុមារ (ស្របជាមួយបទដ្ឋានជាតិ និងអន្តរជាតិ ) ?
- តើរដ្ឋាភិបាលកម្ពុជា ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍អាចជួយគាំទ្រយ៉ាងដូចម្តេចខ្លះ ចំពោះទម្រង់នៃការថែទាំជំនួស ដើម្បីរួមចំណែកដល់ការធ្វើឲ្យសម្រេចនូវការប្តេជ្ញាចិត្តជាទូទៅរបស់រដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មកុមារចំនួន ៣០% ពីមណ្ឌលនៅឆ្នាំ ២០១៨ ជាពិសេស តាមរយៈការផ្តល់ការថែទាំចំពោះកុមារដែលគ្មានឪពុកម្តាយ ?

# វិធីសាស្ត្រ

# ៥

វិធីសាស្ត្រស្រាវជ្រាវសម្រាប់ការសិក្សានេះ ត្រូវបានរៀបចំឡើងដោយមានគោលបំណងបញ្ចូលទស្សនៈចម្រុះពីរដ្ឋាភិបាលគ្រប់កម្រិត អ្នកផ្ដល់ការថែទាំ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ក៏ដូចជា កុមារ និងគ្រួសារ ដែលបានទទួល (ឬបានផ្ដល់) សេវាថែទាំ។ ជំពូកនេះថែងអំពីភូមិសាស្ត្រ និងប្រធានបទនៃការសិក្សា វិធីសាស្ត្រនៃការប្រមូលទិន្នន័យដែលបានប្រើប្រាស់ និងការជ្រើសរើស សំណាក ដើម្បីកំណត់អ្នកផ្ដល់ចម្លើយនៅក្នុងការសិក្សានេះ។

ការសិក្សានេះគ្របដណ្ដប់លើរាជធានីខេត្តដែលបានជ្រើសរើសជាមុនចំនួន ៥[27] ក្នុងប្រទេសកម្ពុជា៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកណ្ដាល និងខេត្តព្រះសីហនុ។ ទាំងនេះគឺជារាជធានីខេត្តអាទិភាពទាំង ៥ ដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពកម្មវិធីប្រចាំប្រទេសសម្រាប់ឆ្នាំ ២០១៦-២០១៨ ដែលអង្គការយូនីសេហ្វ និងរដ្ឋាភិបាលកម្ពុជាបានឯកភាពលើគោលដៅប្រកបដោយមហិច្ឆតានៃ ការធ្វើសមាហរណកម្មដោយសុវត្ថិភាពនូវកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារទាំងអស់។ រាជធានីខេត្តទាំង៥ នេះត្រូវបានកំណត់អាទិភាពនៅក្នុងការកំណត់ទីតាំងកន្លែងថែទាំកុមារដែល ក្រសួង ស.អ.យ បានធ្វើឡើងនាពេលថ្មីៗនេះ ហើយក៏ជារាជធានីខេត្តអាទិភាពសម្រាប់គម្រោងការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង First ផងដែរ។




27 ភ្នំពេញគឺជារាជធានីមិនមែនជាខេត្តនោះទេ បើនិយាយតាមន័យបច្ចេកទេស។ សម្រាប់គោលបំណងនៃការសិក្សានេះពាក្យថា«ខេត្ត»មានរួមបញ្ចូលទាំងរាជធានីភ្នំពេញផងដែរ។

ការសិក្សាបានធ្វើការប៉ាន់ប្រមាណ និងវិភាគប្រភេទខុសៗគ្នាទាំង ៤នៃការថែទាំជំនួសនៅសហគមន៍៖

- ការថែទាំដោយឪពុកម្តាយធម៌
- ការថែទាំដោយសាច់ញាតិ
- ការចិញ្ចឹមថែទាំតាមវត្តអារាម និង កន្លែងសាសនាដទៃទៀត
- ផ្ទះស្នាក់នៅជាក្រុម

ក្រៅពីនេះ អ្នកស្រាវជ្រាវបានចុះទៅមើលមណ្ឌលថែទាំកុមារចំនួន ៤កន្លែង និងសាលារៀនដែលផ្តល់កន្លែងស្នាក់នៅចំនួន ៣កន្លែង ដើម្បីធ្វើការប្រៀបធៀបឲ្យបានសមស្របរវាងការថែទាំកុមារនៅតាមសហគមន៍ជាមួយការថែទាំកុមារនៅតាមមណ្ឌល។

## វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឆ្លើយសំណួរស្រាវជ្រាវនីមួយៗដែលបានលើកខាងលើ និងដើម្បីធ្វើសម្រេចនូវគោលបំណងជារួម នៃការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រមួយចំនួននៃការប្រមូលទិន្នន័យ រួមផ្សំជាមួយវិធីសាស្ត្រទាំងបែបបរិមាណ និងទាំងវិធីសាស្ត្របែបគុណភាព។ ការសិក្សានេះមានមូលដ្ឋានផ្អែកលើប្រភពទិន្នន័យចំនួន ៦ ដូចខាងក្រោម៖

- ការសម្ភាសជាលក្ខណៈបុគ្គលជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (ពាក់កណ្តាលបទដ្ឋានបែបគុណភាព)។
- ការសម្ភាសជាលក្ខណៈបុគ្គលជាមួយអ្នកផ្តល់ការថែទាំ/អ្នកគ្រប់គ្រង (ពាក់កណ្តាលបទដ្ឋានបែបគុណភាព)។
- សម្ភាសជាលក្ខណៈបុគ្គលជាមួយកុមារនៅក្នុងការថែទាំជំនួស (ពាក់កណ្តាលបទដ្ឋានបែបគុណភាព)។
- ការពិភាក្សាជាក្រុមជាមួយកុមារនៅក្នុងការថែទាំជំនួស (ពាក់កណ្តាលបទដ្ឋានបែបគុណភាព)។
- ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់តាមរយៈការសង្កេត (ពេញបទដ្ឋានបែបគុណភាព)។
- អង្កេតជាមួយអ្នកថែទាំកុមារ/អ្នកគ្រប់គ្រង (ពេញបទដ្ឋានបែបគុណភាព)។

កម្រងឧបករណ៍ប្រមូលទិន្នន័យដ៏ពេញលេញ ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យទាំងទិន្នន័យបែបបរិមាណ និងទិន្នន័យបែបគុណភាព មានភ្ជាប់ជាឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នេះ។

## យុទ្ធសាស្ត្រជ្រើសរើសសំណាក

វិធីសាស្ត្រនៃការជ្រើសរើសសំណាក ដែលបានប្រើប្រាស់សម្រាប់ការសិក្សានេះគឺមានចេតនា និងគោលបំណងដើម្បីសិក្សាអំពីពិពិធភាពនៃការថែទាំជំនួសតាមសហគមន៍នៅក្នុងប្រទេសកម្ពុជាក៏ដូចជាភាពខុសគ្នានៃទស្សនៈ បទពិសោធន៍ និងដំណើរការទាំងឡាយដែលកើតមាន រវាងអ្នកថែទាំកុមារ និងកុមារដែល ស្ថិតនៅក្នុងទម្រង់ផ្សេងៗនៃការរៀបចំការថែទាំជំនួសនេះ។

អ្នកថែទាំកុមារ/អ្នកគ្រប់គ្រង (សម្រាប់ការសម្ភាសលក្ខណៈបុគ្គល និងការអង្កេត) ក៏ដូចជា កុមារដែលស្ថិតក្រោមការថែទាំ (សម្រាប់ការពិភាក្សាជាក្រុម) ត្រូវបានជ្រើសរើសសំណាកចេញមកពីករណីតិចបំផុតចំនួន ៥ នៃទម្រង់ថែទាំកុមារតាមសហគមន៍ទាំង ៥ទម្រង់ (ដូចជា ការថែទាំដោយឪពុកម្ដាយធម៌ ការថែទាំដោយសាច់ញាតិ ការថែទាំតាមវត្តអារាម និងផ្ទះស្នាក់នៅជាក្រុម)។ ក្រៅពីទម្រង់នៃការថែទាំតាមសហគមន៍ទាំងនេះ សំណាកនៃករណីក៏រួមមានមណ្ឌលថែទាំកុមារចំនួន ៤ និងសាលារៀនដែលផ្ដល់កន្លែងស្នាក់នៅចំនួន ៣ ផងដែរ។ ការធ្វើបែបនេះ ជួយឱ្យអ្នកស្រាវជ្រាវអាចធ្វើការប្រៀបធៀបបានគ្រប់ជ្រុងជ្រោយរវាងទម្រង់នៃការថែទាំតាមមណ្ឌល និង ទម្រង់នៃការថែទាំកុមារនៅក្រៅមណ្ឌល។ នៅក្នុងរាជធានីខេត្តនីមួយៗដែលបានជ្រើសរើសទុកជាមុនទាំង ៥ អ្នកស្រាវជ្រាវបានធ្វើការប៉ាន់ប្រមាណយ៉ាងហោចណាស់ករណីចំនួនមួយ (ឬ"ទីតាំងមួយ") នៃទម្រង់ថែទាំខុសៗគ្នាទាំង ៥ ដែលបានបញ្ចូលនៅក្នុងការសិក្សានេះ។ បន្ថែមពីលើការប្រើប្រាស់ជាក្របខ័ណ្ឌជ្រើសរើសសំណាកសម្រាប់អ្នកថែទាំកុមារ/អ្នកគ្រប់គ្រង និងអ្នកផ្ដល់ចម្លើយជាកុមារ "ទីតាំង" ដែលបានជ្រើសរើស ក៏បង្កើតបាននូវសំណាកចុង ក្រោយនៃទី កន្លែងដែលអ្នកស្រាវជ្រាវបានអនុវត្តបញ្ជីផ្ទៀងផ្ទាត់តាមរយៈការសង្កេតផងដែរ។ តារាងលម្អិត ដែលរៀបរាប់អំពីប្រវត្តិរបស់គ្រួសារ និងស្ថាប័នដែលបានចុះទៅមើលសម្រាប់ការសិក្សានេះ មាននៅក្នុងឧបសម្ព័ន្ធ ១ នៃរបាយការណ៍នេះ។

## ប្រវត្តិនៃអង្កេត

កម្រងសំណួរអង្កេតបែបបរិមាណ ត្រូវបានចែកជូនអ្នកថែទាំកុមារ និងអ្នកគ្រប់គ្រងនៅគ្រប់មណ្ឌល និងគ្រួសារទាំងអស់ដែលអ្នកស្រាវជ្រាវបានចុះទៅជួប។ ទោះដូច្នេះក្ដី ដោយសារពេលវេលាមានកំណត់ មិនមែនអ្នកថែទាំកុមារ និង អ្នកគ្រប់គ្រងទាំងអស់ដែលត្រូវបានសម្ភាសសម្រាប់ការសិក្សានេះបានបំពេញកម្រងសំណួរសម្រាប់អង្កេតនេះគ្រប់ៗគ្នានោះទេ។

សរុបមក កម្រងសំណួរសម្រាប់អង្កេតត្រូវបានចែកជូនទៅអ្នកថែទាំកុមារ និងអ្នកគ្រប់គ្រងចំនួន ៤១នាក់។ នៅក្នុងករណីចំនួន ២៦ករណី មានតែអ្នកថែទាំកុមារតែម្នាក់គត់មកពីមណ្ឌល ឬ គ្រួសារដែលអ្នកស្រាវជ្រាវបានចុះទៅជួប បានបំពេញកម្រងសំណួរអង្កេតនេះចប់។ នៅសល់ករណី ២៥ទៀតមានអ្នកថែទាំកុមារ ២នាក់បានបំពេញកម្រងសំណួរអង្កេតនេះ។ ៥៦% នៃអ្នកថែទាំកុមារដែលបានបញ្ចូលទៅក្នុងអង្កេតគឺជាស្ត្រី ហើយមាន ៣៩% គឺជាបុរស។[28] ជាមធ្យម អ្នកថែទាំកុមារមានអាយុ ៤៣ឆ្នាំ ដោយអ្នកក្មេងជាងគេមានអាយុ ២២ឆ្នាំ និងចាស់ជាងគេអាយុ ៧៥ឆ្នាំ។ ២៧% នៃអ្នកថែទាំកុមារដែលបានអង្កេតបញ្ជាក់ថាពួកគេមិនបានរៀនចំសាលាបឋមសិក្សានោះទេ ដែលនេះគឺជាលក្ខខណ្ឌសំខាន់មួយនៅក្នុងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួស (សូមអានប្រការ ៧ នៃប្រកាសស្ដីពីការថែទាំជំនួសតាមសហគមន៍)។[29]

28 ៥%ដែលនៅសល់មិនប្រាប់អំពីយេនឌ័រនោះទេ។

29 ៦៨%នៃអ្នកផ្ដល់ចម្លើយបានប្រាប់ថាពួកគេបានរៀនចប់បឋមសិក្សា និង ៥%ទៀតបដិសេធមិនឆ្លើយ។

រូបភាពទី ១ បង្ហាញអំពីអ្នកផ្តល់ចម្លើយនៅតាមភូមិសាស្ត្រនៃរាជធានីខេត្តទាំង ៥

**រូបភាពទី ១៖** ចំនួនអ្នកផ្តល់ចម្លើយតាមរាជធានីខេត្ត




រូបភាពទី ២ បង្ហាញពីប្រភេទនៃការថែទាំដែលអ្នកឆ្លើយនៅក្នុងអង្កេតបានផ្តល់ឲ្យកុមាររស់នៅក្រោមការថែទាំរបស់ពួកគេ។ ការថែទាំដោយឪពុកម្តាយធម៌និងផ្ទះស្នាក់នៅជាក្រុមគឺជាប្រភេទការថែទាំទូទៅបំផុតដែលអ្នកផ្តល់ចម្លើយនៅក្នុងសំណាកបានផ្តល់ជូន។ អ្នកផ្តល់ចម្លើយខ្លះបានផ្តល់ ( ឬគ្រប់គ្រង ) ការថែទាំច្រើនជាងមួយប្រភេទ។ ឧទាហរណ៍ អ្នកគ្រប់គ្រងការថែទាំនៅសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលដ៏ធំមួយ ទទួលខុសត្រូវចំពោះការថែទាំដោយឪពុកម្តាយធម៌ផង ការថែទាំដោយសាច់ញាតិផង និងផ្ទះស្នាក់នៅជាក្រុមផង។

**រូបភាពទី ២៖** ប្រភេទនៃការថែទាំដែលបានផ្តល់ឲ្យ



## ភាពមានកម្រិត

**ភាពជាតំណាង៖** ដោយសារចរិកលក្ខណៈគិតដល់គុណភាពជាបឋមនៃការប្រមូលទិន្នន័យ រួមទាំងវិធីសាស្ត្រកំណត់សំណាកដោយមានចេតនាដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អ្នកផ្តល់ចម្លើយ វាមានសារៈសំខាន់ក្នុងការបញ្ជាក់ថា លទ្ធផលដែលទទួលបានមិនអាចតំណាងឲ្យការអនុវត្តការថែទាំជំនួសនៅសហគមន៍ទាំងមូលនៅក្នុងប្រទេសកម្ពុជាបាននោះទេ។ ដូចបានលើកឡើងខាងដើម ទីតាំងស្រាវជ្រាវត្រូវបានជ្រើសរើសដើម្បីស្វែងយល់អំពីប្រភេទផ្សេងៗនៃការថែទាំជំនួស នៅក្នុងរាជធានីខេត្តនីមួយៗ ក៏ដូចជាមានទីតាំងខ្លះមានលក្ខណៈស្មុគស្មាញទាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ និងមានទិន្នន័យចម្រុះ និងទិន្នន័យដែលអាចធ្វើការពន្យល់បាន ជាងទិន្នន័យដែលអាចធ្វើជាតំណាង និងអាចរាប់ចំនួនបាន។ ខណៈពេលដែលទិន្នន័យបែបបរិមាណដែលមានកំណត់ និងដែលប្រមូលបានសម្រាប់ការសិក្សានេះ អាចយកទៅប្រៀបធៀបជាមួយទម្រង់ផ្សេងៗនៃការថែទាំជំនួស ដែលបានបញ្ចូលនៅក្នុងសំណាកនៃការសិក្សានេះ ទិន្នន័យទាំងនេះ មិនអាចធ្វើជាតំណាងនៃប្រភេទផ្សេងៗនៃទម្រង់ថែទាំកុមារនៅក្នុងរាជធានីខេត្តនីមួយៗបាននោះទេ។

**លទ្ធភាពក្នុងការកំណត់ជាទូទៅ៖** ដោយសារការសិក្សាមានកម្រិតត្រឹមតែរាជធានីខេត្ត «គោលដៅ» ទាំង៥ យើងមិនអាចទាញការសន្និដ្ឋាន អំពីការអនុវត្តការថែទាំជំនួសនៅក្នុងខេត្ត ២០ផ្សេងទៀតនោះទេ ឬ កំណត់ថានេះគឺជាការអនុវត្តទូទៅនៅថ្នាក់ជាតិនោះទេ។ ដោយសារការលំបាកផ្នែកភូមិសាស្ត្រ គំហើញនៃការសិក្សាដែលទទួលបានពីការប្រមូលទិន្នន័យនៅក្នុងប្រទេសមានលក្ខណៈជាការសិក្សាស្រាវជ្រាវមិនមែនមានលក្ខណៈស៊ីជម្រៅ ឬលក្ខណៈប្រាកដប្រជានោះទេ។

**ពេលវេលា និងកង្វះខាតធនធាន៖** ដោយសារពេលវេលាអនុវត្តការសិក្សាស្រាវជ្រាវនេះមានរយៈពេលខ្លី រួមទាំងមូលនិធិមានកម្រិតសម្រាប់ធ្វើការប្រមូលទិន្នន័យនៅក្នុងប្រទេសផងនោះយើងមិនអាចបញ្ចូលអ្នកផ្តល់ចម្លើយ/មណ្ឌលដ៏គួរឲ្យចាប់អារម្មណ៍ខ្លាំងនិងដែលមានការពាក់ព័ន្ធមួយចំនួនទៅក្នុងការសិក្សានេះបាននោះទេ។ អ្នកស្រាវជ្រាវបានចំណាយជាមធ្យមចំនួន៥ថ្ងៃធ្វើការនៅក្នុងរាជធានីខេត្តនីមួយៗ ហើយទោះជាខំប្រឹងប្រែងចុះទៅជួបអ្នកផ្តល់ចម្លើយនៅក្នុងទីកន្លែងដាច់ស្រយាល/ជនបទយ៉ាងណាក៏ដោយ ក៏ភាគច្រើននៃអ្នកផ្តល់ចម្លើយមាននៅទីរួមខេត្ត និងស្រុកជុំវិញ។ ក្នុងករណីខ្លះ អ្នកផ្តល់ចម្លើយមកពីតំបន់ដាច់ស្រយាលត្រូវបានអញ្ជើញមកសម្ភាសនៅទីរួមខេត្ត ហើយបន្ទាប់មកមានការចេញទូទាត់សោហ៊ុយធ្វើដំណើរឲ្យពួកគាត់ថែមទៀតផង។ ធ្វើបែបនេះអ្នកស្រាវជ្រាវអាចជួបអ្នកផ្តល់ចម្លើយក្នុងចំនួនដ៏ច្រើនជាអតិបរមាតាមដែលអាចធ្វើបានទៅតាមលក្ខណៈភូមិសាស្ត្រ ពេលវេលា និងធនធានដ៏មានកម្រិតទាំងនេះ។

**ការចុះជួបជាមួយអ្នកផ្តល់ចម្លើយ៖** អ្នកស្រាវជ្រាវអន្តរជាតិបានពឹងផ្អែកលើអ្នកស្រាវជ្រាវជាតិមួយក្រុមតូច រួមទាំងការិយាល័យប្រចាំប្រទេសរបស់អង្គការយូនីសេហ្វផងដែរ ដើម្បីកំណត់អត្តសញ្ញាណ និងចូលជួបអ្នកផ្តល់ចម្លើយ និង មណ្ឌលដែលពាក់ព័ន្ធ (ស្របជាមួយវិធីសាស្ត្រនៃការកំណត់សំណាកទុកជាមុន)។ ទោះដូច្នេះក្តី វាសំខាន់ខ្លាំងណាស់ដែលត្រូវបញ្ជាក់ថា ការចុះជួបអ្នកផ្តល់ចម្លើយទាំងនេះត្រូវបានធ្វើតាមរយៈបណ្តាញដែលមានស្រាប់ (ឧ. គម្រោង 3PC គម្រោងការថែទាំកុមារក្នុងគ្រួសារ ជាអាទិភាពចម្បង First ។ល។) និង តាមរយៈអ្នកផ្តល់ សេវាថែទាំជំនួសជាផ្លូវការ។ ជាលទ្ធផល វាហាក់ដូចជាថាបទពិសោធន៍ និងទស្សនៈរបស់កុមាររួមទាំងអ្នកថែទាំកុមារនៅក្នុងកន្លែងថែទាំមិនផ្លូវការ (ដូចជា ការថែទាំដោយគ្មានការចូលរួមពីរដ្ឋាភិបាលឬពីអង្គការមិនមែនរដ្ឋាភិបាល) អាចយកធ្វើជាតំណាងបានបន្តិចបន្តួចនៅក្នុងការសិក្សានេះ។ ក្រៅពីនេះ ចំពោះអ្នកផ្តល់ចម្លើយដែលបណ្តាញបានណែនាំ វាអាចថាសំណាកនេះមាន «គុណភាព» ខ្ពស់ជាង (ដោយសារអ្នកទាំងនោះទទួលបាននូវការគាំទ្រ និងការតាមដាន)

ជាងកម្រិតមធ្យម។ លើសពីនេះ គួរឲ្យកត់សម្គាល់ផងដែរនោះគឺថា ទោះបីជាមានការអនុម័តយល់ព្រមជាផ្លូវការពី ក្រសួង ស.អ.យ និងអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជាក៏ដោយក៏មណ្ឌលថែទាំកុមារខ្លះ និងតំណាងជាន់ខ្ពស់រដ្ឋាភិបាលខ្លះមិនអាច ឬមិនមានបំណងចូលរួមនៅក្នុងការសិក្សានេះផងដែរ។

**ឧបសគ្គទាក់ទងនឹងភាសា៖** ខណៈពេលដែលអ្នកស្រាវជ្រាវអន្តរជាតិប្រើប្រាស់អ្នកបកប្រែដែលមានវិជ្ជាជីវៈ ខ្ពស់នៅក្នុងការប្រមូលទិន្នន័យក្នុងប្រទេសក្តី វាអាចថា ឧបសគ្គផ្នែកភាសាអាចធ្វើឲ្យមានការបាត់បង់ព័ត៌មានជាក់ស្តែង និងសំខាន់ៗខ្លះ រួមទាំងចម្លើយរបស់អ្នកផ្តល់ចម្លើយដែលមានន័យខុសគ្នាបន្តិចបន្តួចគួបផ្សំផង។

**ការរាយការណ៍៖** ដើម្បីឲ្យបានជាក់ស្តែង និងគោរពតាមក្រមសីលធម៌ និងផ្អែកលើភស្តុតាង ភស្តុតាងដែលដែលប្រមូលបានដែលបង្ហាញពីបញ្ហា/កង្វល់ពាក់ព័ន្ធជាមួយកិច្ចការពារកុមារ គឺផ្អែកលើទិន្នន័យដែលបានរាយការណ៍ជាជាងទិន្នន័យដែលប្រមូលបានតាមការសង្កេត។ នេះវានាំទៅរកភាពមានកម្រិតដែលមិនអាចចៀសផុតដែលថា ទិន្នន័យដែលបានប្រមូលអាចជាទិន្នន័យដែលគេរាយការណ៍មិនគ្រប់គ្រាន់ ឬត្រូវបានគេរាយការណ៍លើសហួសហេតុអំពីការរំលោភបំពាន ការមិនអើពើជាក់ស្តែង និងការប៉ះទង្គិចផ្លូវអារម្មណ៍ផ្សេងៗ។ ឧទាហរណ៍ កុមារជាជនរងគ្រោះពីការរំលោភបំពានអាចមានការអល់ឯកមិនចង់រាយការណ៍ដោយមានការភ័យខ្លាចថាជាប់ស្លាកស្នាមមិនល្អ ឬទទួលរងការបាក់ស្មារតីឡើងវិញ ចំណែកជនល្មើសអាចមានការអល់ឯកមិនរាយការណ៍អំពីការប្រព្រឹត្តរបស់ពួកគេដោយភ័យខ្លាចមានការដាក់ទោសជាដើម។

**ការអនុវត្តត្រីកោណវិធាន (Triangulation)៖** អ្នកស្រាវជ្រាវមែងតែងចង់សម្ភាសទាំងកុមារ ក៏ដូចជាអ្នកថែទាំកុមារនៅក្នុងកន្លែងថែទាំនីមួយៗ។ ទោះដូច្នេះក្តី អ្នកស្រាវជ្រាវមិនអាចប្រើប្រាស់អ្នកទី៣ ដើម្បីជជីកសួរអំពីប្រវត្តិជីវិតរបស់កុមារម្នាក់ៗ ដោយប្រើប្រាស់សាច់រឿងដែលបាននិទានប្រាប់ពីមនុស្សធំពេញវ័យ/ អ្នកថែទាំ/ មន្ត្រីដែលពាក់ព័ន្ធក្នុងករណីរបស់ពួកគេទាំងអស់នោះបានទេ។ សាច់រឿងផ្ទាល់ខ្លួនរបស់កុមារទាក់ទងនឹងរបៀបដែលពួកគេបានមករស់នៅក្នុងកន្លែងថែទាំជំនួស អាចទទួលរងឥទ្ធិពលពីភាពលម្អៀងចេញមកពីការរំលឹករឿងចាស់ឡើងវិញ ភាពលម្អៀងនៅក្នុងការរាយការណ៍ និង/ឬ ការយល់ដឹងនៅមានកម្រិតអំពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងតួអង្គដែលពាក់ព័ន្ធផ្សេងៗទៀត។

## ដំណើរការពិនិត្យឡើងវិញ

ក្រុមប្រឹក្សាយោបល់ខាងក្រៅមួយ ត្រូវបានបង្កើតឡើងដោយអង្គការយូនីសេហ្វនៅកម្ពុជាដើម្បីជួយផ្តល់យោបល់បន្ថែមដល់ការសិក្សានេះ។ ក្រុមប្រឹក្សាយោបល់នេះរួមមានសមាជិកជាអ្នកជំនាញនៅក្នុងវិស័យថែទាំជំនួសចំពោះកុមារជាទូទៅ និងអ្នកជំនាញមានការយល់ដឹង ជាពិសេសអំពីបរិបទនៃប្រទេសកម្ពុជា។ សមាជិកនៃក្រុមនេះ បានផ្តល់ការណែនាំដល់ក្រុមទីប្រឹក្សាក្នុងការរៀបចំវិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ប្រមូលទិន្នន័យ ជួយពិនិត្យឡើងវិញនូវរបាយការណ៍ទស្សនាទានសម្រាប់ការសិក្សានេះ និងផ្តល់យោបល់បន្ថែមទៀតលើរបាយការណ៍ពង្រាងនៃការសិក្សានេះ។ កិច្ចប្រជុំផ្តល់សុពលភាពទៅលើលទ្ធផលដែលបានរកឃើញត្រូវបានរៀបចំធ្វើឡើងដោយមានអ្នកពាក់ព័ន្ធ និងអ្នកចូលរួមសំខាន់ៗនៅក្នុងការសិក្សាដើម្បីផ្តល់សុពលភាពទៅលើគំហើញ និងអនុសាសន៍ដែលបាននៅក្នុងរបាយការណ៍នេះ។[30]

30 កិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធត្រូវបានរៀបចំធ្វើនៅថ្ងៃទី ៩ និងថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១៧។ ក្រៅពីក្រុមផ្តល់ប្រឹក្សាផ្តល់យោបល់ អង្គការយូនីសេហ្វកម្ពុជាបានបង្កើតនូវគណៈកម្មការដឹកនាំការស្រាវជ្រាវ និងវាយតម្លៃមួយ ដែលជាយន្តការមួយដើម្បីធានាថារាល់ការសិក្សា ការស្រាវជ្រាវ និងការវាយតម្លៃដោយទីប្រឹក្សាដែលផ្តល់ដោយអង្គការយូនីសេហ្វឲ្យចុះធ្វើការសិក្សាស្រាវជ្រាវ ពិតជាបានបំពេញតាមលក្ខខណ្ឌដែលមានចែងនៅក្នុងនីតិវិធីរបស់អង្គការ រួមទាំងគោរពតាមក្រមសីលធម៌ និងការងារប្រតិបត្តិ និងបច្ចេកទេសដែលពាក់ព័ន្ធផ្សេងទៀត។

# ប្រព័ន្ធការពារកុមារ និងការថែទាំជំនួស

# ៦

ខណៈពេលដែលការសិក្សានេះ មិនត្រូវបានរៀបចំឡើងដើម្បីធ្វើការវាយតម្លៃលម្អិត និងស៊ីជម្រៅអំពីប្រព័ន្ធការពារកុមារនៅក្នុងប្រទេសកម្ពុជា វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតការយល់ដឹងអំពីទិដ្ឋភាពខ្លះនៃប្រព័ន្ធនេះ ដែលមានការពាក់ព័ន្ធយ៉ាងច្រើនជាមួយនឹងការថែទាំជំនួស។ ជាពិសេសរដ្ឋទាំងឡាយតម្រូវឲ្យមានប្រព័ន្ធកំណត់អត្តសញ្ញាណ វាយតម្លៃ និងបញ្ជូនកុមារដ៏រឹងមាំមួយដើម្បីធានាថាកុមារត្រូវបានទុកដាក់តែនៅក្នុងការថែទាំជំនួសប៉ុណ្ណោះ នៅពេលដែលគ្រួសារមិនអាចជួយគាំទ្រ និងការពារកុមារបានពេញលេញ ហើយប្រសិនបើកុមារត្រូវបានទុកដាក់នៅក្នុងការថែទាំជំនួសហើយការថែទាំជំនួសនេះត្រូវតែមានលក្ខណៈសមស្រប និងស្របតាមតម្រូវការរបស់កុមារ។

ច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់ថា វាគឺជាការទទួលខុសត្រូវរបស់រដ្ឋក្នុងការត្រួតពិនិត្យតាមដានចំពោះអ្នកផ្តល់សេវាថែទាំជំនួស ព្រមទាំងត្រួតពិនិត្យជាប្រចាំទៅលើការទុកដាក់កុមារនៅក្នុងការថែទាំជំនួស ព្រមទាំងធ្វើការទប់ស្កាត់ និងធ្វើសមាហរណកម្មកុមារ។ ការទទួលខុសត្រូវទាំងនេះមានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ដែលរំលេចនូវសេចក្តីណែនាំប្រតិបត្តិដើម្បីអនុវត្តបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារនៅក្នុង សហគមន៍។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ) គឺជាទីភ្នាក់រដ្ឋាភិបាលដែលមានការទទួលខុសត្រូវដ៏ចម្បងនេះ ក្នុងការការពារកុមារ ផ្តល់សេវាសង្គមកិច្ច និងការថែទាំជំនួសចំពោះកុមារ។ ការទទួលខុសត្រូវសម្រាប់ការងារគ្រប់គ្រង ក៏ជាបន្ទុករបស់អាជ្ញាធរមូលដ្ឋាន ឬ “ក្រុមប្រឹក្សា” ផងដែរ។ ខាងក្រោមគឺជាការទទួលខុសត្រូវរបស់ទីភ្នាក់ងាររដ្ឋាភិបាលនីមួយៗ។

| ទីភ្នាក់ងាររដ្ឋាភិបាលទទួលបន្ទុកការងារថែទាំជំនួសចំពោះកុមារ | | |
|---|---|---|
| ថ្នាក់ជាតិ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ)៖ ការទទួលខុសត្រូវរបស់ក្រសួង មានចែងនៅក្នុងប្រការ ១២ នៃប្រកាសស្តីពីនីតិវិធីសម្រាប់អនុវត្តគោលនយោបាយស្តីពី ការថែទាំជំនួសចំពោះកុមារ និងមានបញ្ចូលទាំងការងារគ្រប់គ្រង និងត្រួតពិនិត្យតាមដាន ការអនុវត្តគោលនយោបាយច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធីផ្លូវច្បាប់ពាក់ព័ន្ធជាមួយការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ការរក្សាប្រព័ន្ធទិន្នន័យថ្នាក់ជាតិស្តីពីកុមារដែលត្រូវការការថែទាំ និងការទុកដាក់កុមារនៅក្រៅគ្រួសារ រួមទាំងការងារលើកកម្ពស់ ការយល់ដឹងទាក់ទងនឹងការការពារកុមារ។ | ក្រសួងមហាផ្ទៃ (មិនមានការទទួលខុសត្រូវដោយផ្ទាល់នោះទេ តែក្រុមប្រឹក្សាមានតួនាទីត្រួតពិនិត្យ និងតាមដាន) |

| ទីភ្នាក់ងាររដ្ឋាភិបាលទទួលបន្ទុកការងារថែទាំជំនួសចំពោះកុមារ | | |
|---|---|---|
| ថ្នាក់រាជធានី/ខេត្ត | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (DoSVY)៖ ការទទួលខុសត្រូវរបស់មន្ទីរ មានចែងនៅក្នុងប្រការ ១០នៃប្រកាសស្តីពីនីតិវិធីសម្រាប់អនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារនិងមានបញ្ចូលភារកិច្ចធ្វើផែនការអចិន្ត្រៃយ៍សម្រាប់កុមារទាំងអស់នៅក្នុងរាជធានីខេត្ត ផ្តល់ការគាំទ្រនិងតម្រង់ទិសការងាររបស់ បុគ្គលិកការិយាល័យសង្គមកិច្ច ពង្រីកធនធាន ដើម្បីពង្រឹងការថែទាំ តាមគ្រួសារ ធ្វើការប្រមូលទិន្នន័យ និងតាមដានការអនុវត្តបទដ្ឋានអប្បបរមា។ | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) (ក្រុមប្រឹក្សាខេត្ត)៖ ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានេះ មានចែងនៅក្នុងប្រការ ១១ នៃប្រកាស ស្តីពីនីតិវិធីសម្រាប់អនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ និងមាន បញ្ចូលការសហការជាមួយមន្ទីរសង្គមកិច្ច និងការិយាល័យក្រុង/ស្រុក/ខណ្ឌ និង គកសក ដើម្បីធ្វើផែនការ និងតស៊ូមតិឲ្យមានការផ្តល់សេវាដែលចាំបាច់ចំពោះកុមារ និងគ្រួសារ និងដើម្បីជួយមន្ទីរសង្គមកិច្ចឲ្យអាចអនុវត្តបាននូវភារកិច្ចដែលមានចែងនៅក្នុងប្រការ ១០។ |
| ថ្នាក់ក្រុង/ស្រុក/ខណ្ឌ | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (OSVY)៖ ការទទួលខុសត្រូវរបស់ការិយាល័យនេះ មានចែងនៅក្នុងប្រការ ៨ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងមានបញ្ចូលការផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងការណែនាំបច្ចេកទេសដល់ គកនក ដោយសហការជាមួយ គកសក និងធ្វើការគ្រប់គ្រងដោយផ្ទាល់នូវករណី ដែលមិនគ្របដណ្តប់ដោយក្រុមប្រឹក្សាឃុំ មានជាអាទិ៍ កុមារស្ថិតក្រោមការថែទាំ ដោយសាច់ញាតិ ឬដោយឪពុកម្តាយធម៌ កុមារត្រូវបានទុកដាក់នៅក្នុងមណ្ឌល និង កុមារ ត្រូវការនូវការធ្វើផែនការអចិន្ត្រៃយ៍។ | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) (ក្រុមប្រឹក្សាថ្នាក់ស្រុក)៖ ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានេះ មានចែងនៅក្នុងប្រការ ៣ ប្រការ ៦ និង ប្រការ ៩ នៃប្រកាសស្តីពីនីតិវិធី សម្រាប់អនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ដោយមានបញ្ចូលការកំណត់អត្តសញ្ញាណ និង ការប៉ាន់ប្រមាណកុមារ និងគ្រួសារដែលជួបប្រទះស្ថានភាពហានិភ័យដែល គកនក មិនអាចមានសមត្ថភាពជួយបាន។ |
| ថ្នាក់ឃុំ/សង្កាត់ | មិនមាន | ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការសុខុមាលភាពកុមារ មានការទទួលខុសត្រូវ ចំពោះការអនុវត្តភារកិច្ច ដែលបានប្រគល់ឲ្យពីក្រសួង អសយ ស្រប តាមប្រកាសស្តីពីនីតិវិធី សម្រាប់អនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ។ ក្រុមប្រឹក្សានេះ ក៏មានភារកិច្ចចុះសួរសុខទុក្ខកុមារ ឬគ្រួសារដែលជួបប្រទះ ការលំបាក ដែលអាចបណ្តាលឲ្យគ្រួសារបោះបង់កុមារចោល និងទទួលខុសត្រូវ ក្នុងការបើកសំណុំរឿងរបស់គ្រួសារ ឬកុមារតាមការចាំបាច់ (ប្រការ ៦)។ ភារកិច្ចផ្សេងទៀតមានចែងនៅក្នុងប្រការ ៧។ |

ការសិក្សានេះ រួមមានការប្រមូលទិន្នន័យបែបគុណភាពពីតួអង្គការពារកុមារសំខាន់ៗនៅថ្នាក់ឃុំ ស្រុក រាជធានីខេត្ត និងថ្នាក់ជាតិ។ ការសម្ភាសទាំងនេះ មានគោលបំណងបង្កើតការយល់ដឹងអំពីបរិបទនៃកិច្ចការពារកុមារនៅក្នុងប្រទេសកម្ពុជា និងតម្រូវការសម្រាប់ការផ្តល់សេវាថែទាំជំនួស ក៏ដូចជាតួនាទីរបស់អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ ទាក់ទងនឹងការថែទាំជំនួសទាំងនៅក្នុងគោលនយោបាយ និងនៅក្នុងការអនុវត្ត។ ផ្នែកនេះ នឹងពិនិត្យមើលជាពិសេស៖ ដំណើរការនៃការកំណត់អត្តសញ្ញាណករណីការពារកុមារ និងការបញ្ជូនកុមារទៅរកសេវាសមស្រប (រួមមានការថែទាំជំនួស) ការធ្វើសមាហរណកម្ម និងការជួបជុំគ្រួសារឡើងវិញ ព្រមទាំងការផ្តល់ការគាំទ្រដល់គ្រួសារ។ ការត្រួតពិនិត្យទៅលើសេវាថែទាំជំនួស និងការត្រួតពិនិត្យទៅលើការរៀបចំថែទាំកុមារ មិនត្រូវបានលើកឡើងនៅក្នុងផ្នែកនេះទេ ដោយសារបញ្ហាទាំងនេះត្រូវបានគ្របដណ្តប់នៅក្នុងផ្នែកស្តីពី “ប្រវត្តិនៃការថែទាំ” សម្រាប់ប្រភេទនីមួយៗនៃការថែទាំ។

## ការកំណត់អត្តសញ្ញាណ និងការបញ្ជូនកុមារ

ដូចបានបង្ហាញនៅក្នុងប្រវត្តិនៃការថែទាំខាងក្រោម ការទុកដាក់កុមារនៅក្នុងការថែទាំជំនួសនៅគ្រប់ទម្រង់ទាំងអស់នៃការថែទាំ និងជាពិសេស ការថែទាំតាមវត្តអារាម និងការថែទាំដោយសាច់ញាតិរមែងតែងត្រូវធ្វើឡើងក្នុងលក្ខណៈមិនផ្លូវការ ដែលជាទូទៅ ត្រូវបានរៀបចំដោយគ្រួសារ និងអ្នកផ្តល់ការថែទាំដោយមិនមានការចូលរួមពីស្ថាប័នរបស់រដ្ឋាភិបាលនោះឡើយ។

យោងតាម*ប្រកាសស្តីពីនីតិវិធី អនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍* (ប្រកាសស្តីពីនីតិវិធី) ក្រុមប្រឹក្សាឃុំ/សង្កាត់មានការទទួលខុសត្រូវចម្បងក្នុងការកំណត់អត្តសញ្ញាណ និងធ្វើការប៉ាន់ប្រមាណកុមារងាយរងគ្រោះ និងគ្រួសារ បង្កើតផែនការសម្រាប់ទទួលសេវាដ៏ចាំបាច់ តាមដានវឌ្ឍនភាពរបស់គ្រួសារដើម្បីរក្សាកុមារនៅក្នុងគ្រួសារ និងធ្វើសេចក្តីសម្រេចចិត្តអំពីការទុកដាក់កុមារនៅក្នុងការថែទាំជំនួសជាមួយសាច់ញាតិនៅក្នុងឃុំតែមួយ (ទោះបីមិនមានកំណត់រយៈពេលដ៏ជាក់លាក់សម្រាប់ការតាមដានវឌ្ឍនភាពនេះក្តី)។ ចំនុចនេះធ្វើឲ្យអាជ្ញាធរឃុំ និងជាពិសេស គកនក ក្លាយជាចំនុចទំនាក់ទំនងដំបូងគេបង្អស់នៅពេលគ្រួសារមួយត្រូវការការជួយគាំទ្រ ឬកុមារអាចត្រូវការការទុកដាក់នៅក្នុងការថែទាំជំនួស។ នៅពេលដែលការទុកដាក់កុមារនៅក្នុងការថែទាំជំនួសមានការពាក់ព័ន្ធជាមួយការថែទាំដោយឪពុកម្តាយធម៌ ដែលមិនមែនដោយសាច់ញាតិឬពាក់ព័ន្ធជាមួយការទុកដាក់កុមារនៅក្នុងមណ្ឌល ឬករណីដ៏លំបាកជាពិសេសមួយ ការិយាល័យ ស.អ.យ ត្រូវចូលរួមនៅក្នុងដំណើរការនេះ។ ការិយាល័យ ស.អ.យ នេះក៏ទទួលបន្ទុកចំពោះការគ្រប់គ្រងករណី ដែលមិនស្ថិតក្រោមឃុំ (គកនក និងត្រូវសហការជាមួយ គកនក ដើម្បីផ្តល់សេវាលើកកម្ពស់ការថែរក្សាគ្រួសារ។

ទាំងអ្នកផ្តល់សេវាមិនមែនរដ្ឋាភិបាល ទាំងតំណាងការិយាល័យ ស.អ.យ ដែលបានសម្ភាសសម្រាប់ការសិក្សានេះ បានរាយការណ៍អំពីការទទួលការបញ្ជូនកុមារពីអាជ្ញាធរឃុំ នៅពេលពួកគេបានកំណត់អត្តសញ្ញាណកុមារត្រូវការការថែទាំ ឬត្រូវការការការពារ។ លើសពីនេះតំណាង គកនក និងបុគ្គលិកសង្គមកិច្ចស្រុក ដែលបានសម្ភាសសម្រាប់ការសិក្សានេះបានរៀបរាប់ការឆ្លើយតបចំពោះករណីដែលពាក់ព័ន្ធជាមួយកុមារត្រូវការការថែទាំ និង កុមារដែលទទួលរងគ្រោះពីអំពើរំលោភបំពាន ដោយធ្វើការសម្របសម្រួលការរៀបចំឲ្យមានការថែទាំដោយសាច់ញាតិ ប្រសិនបើចាំបាច់ និងធ្វើការបញ្ជូនករណីទៅអាជ្ញាធរដែលពាក់ព័ន្ធនៅក្នុងការិយាល័យ និងមន្ទីរ ស.អ.យ ដែលបន្ទាប់មក ការិយាល័យ និងមន្ទីរត្រូវធ្វើការប៉ាន់ប្រមាណ និងរៀបចំឲ្យមានការទុកដាក់កុមារបន្តទៅទៀត នៅពេលដែលការថែទាំដោយសាច់ញាតិមិនអាចធ្វើបាន។

ទោះបីទំនងជាមានការកើនឡើងនូវការចូលរួមពី គកនក ការិយាល័យ ស.អ.យ និងមន្ទីរ ស.អ.យ នៅក្នុងការឆ្លើយតបចំពោះករណីទាំងឡាយក៏ដោយ ក៏មួយផ្នែកនៃការកើនឡើងនេះទំនងកើតចេញពីតម្រូវការរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការទទួលបានរបាយការណ៍ប៉ាន់ប្រមាណដ៏ពេញលេញមួយពី គកនក ឬពីការិយាល័យ ស.អ.យ មុនពួកគេអាចទទួលកុមារមកនៅក្នុងការថែទាំរបស់ពួកគេ ឬធ្វើការទុកដាក់កុមារនៅក្នុងការថែទាំជំនួសបាន។[31]

31 សូមអានប្រការ ១៥នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួស។

*យើងពិតជាបានជម្រាបអាជ្ញាធរថាប្រសិនបើដកហូតកុមារពីគ្រួសាររបស់គេជាដំបូង ត្រូវប្រគល់ឲ្យទៅខាងបុគ្គលិកសង្គមកិច្ចនៅក្នុងទីតាំងនោះដើម្បីស្វែងរកជំនួយនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន។ យើងត្រូវការឲ្យមានការចុះហត្ថលេខាលើឯកសារទាំងអស់រួមទាំងឲ្យមានការទទួលស្គាល់ពីមេភូមិ ប្រសិនបើមិនធ្វើដូច្នោះទេអ្នកអាចមានបញ្ហានៅថ្ងៃណាមួយ។ យើងត្រូវមានអ្វីៗទាំងអស់ដើម្បីបញ្ជាក់ថាមានការឯកភាពយល់ព្រមតាមផ្លូវច្បាប់។ បុគ្គលិកសង្គមកិច្ចមកពីក្រសួង ស.អ.យ ក៏ប៉ុន្តែពួកគេធ្វើការនៅមូលដ្ឋាន...ខ្ញុំតែងចូលរួមជាមួយបុគ្គលិកសង្គមកិច្ចជានិច្ច។ ពួកគេត្រូវពិនិត្យមើលថាយើងកំពុងធ្វើអ្វី ពីព្រោះការងាររបស់យើងវាស្ថិតនៅក្រោមក្រសួង។*[32]

ទស្សនៈរបស់អ្នកផ្តល់ចម្លើយខ្លះចំពោះអង្កេតនេះគឺថាទោះបីជាមានលក្ខខណ្ឌតម្រូវពីប្រកាសស្តីពីនីតិវិធីក៏ដោយក៏ គកនក និងការិយាល័យ ស.អ.យ នៅតែមិនឆ្លើយតបពេញលេញចំពោះករណីការពារកុមារ។ ដូចប្រធានអង្គការមិនមែនរដ្ឋាភិបាលម្នាក់បានពន្យល់ដោយចំៗថា៖ *«រដ្ឋាភិបាលមិនផ្តល់សេវាសង្គមកិច្ច នោះទេ។ ប្រសិនបើយើងចង់ឲ្យពួកគេចុះមកមើលគ្រួសារ យើងត្រូវចេញសោហ៊ុយថ្លៃធ្វើដំណើររបស់ពួកគេ - គោលនយោបាយរបស់ពួកគេមិនត្រូវបានអនុវត្តតាមនោះទេ។*[33] ពិតប្រាកដណាស់ តំណាងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលបានសម្ភាសសម្រាប់ការសិក្សានេះ បានរាយការណ៍ថា ពួកគេតម្រូវឲ្យចេញសោហ៊ុយថ្លៃធ្វើដំណើរអាហារនិងការស្នាក់នៅសម្រាប់បុគ្គលិកមន្ទីរស.អ.យ ដើម្បីធានានូវការចូលរួមរបស់ពួកគេនៅក្នុងការចុះទៅធ្វើការប៉ាន់ប្រមាណនោះ។ វាមិនច្បាស់ថាវាមានផលប៉ះពាល់ប៉ុណ្ណា (ប្រសិនបើមាន) ទៅលើឯករាជ្យភាពរបស់បុគ្គលិកសង្គមកិច្ច និងខ្លឹមសារនៃរបាយការណ៍ប៉ាន់ប្រមាណរបស់ពួកគេឡើយ។

ខណៈពេលដែលអ្នកផ្តល់ចម្លើយរៀបរាប់អំពីកង្វះខាតសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការឆ្លើយតបចំពោះករណីនៃកិច្ចការពារកុមារ លទ្ធផលនៃការស្រាវជ្រាវក៏បង្ហាញអំពីកង្វះសមត្ថភាពជាច្រើនទាក់ទងនឹងចំនួនបុគ្គលិក និងហិរញ្ញវត្ថុ ក៏ដូចជា ចំណេះដឹង និងជំនាញ។ ឧទាហរណ៍នៅក្នុងខេត្តបាត់ដំបង តំណាងមន្ទីរសង្គមកិច្ចបានរាយការណ៍ថាអាជ្ញាធរឃុំមិនសូវដឹងអំពីលក្ខខណ្ឌតម្រូវនៃច្បាប់ទាក់ទងនឹងការទុកដាក់កុមារនៅក្នុងការថែទាំជំនួសនេះ៖

*ការយល់ដឹងរបស់បុគ្គលិកឃុំអំពីកិច្ចការពារកុមារនៅមានកម្រិតខ្លាំងណាស់។ ពួកគេគួរចេះតែខាងទ្រឹស្តីនៃការទប់ស្កាត់ការទុកដាក់កុមារនៅក្នុងមណ្ឌល តែជាក់ស្តែង ពួកគេបែរជាសម្របសម្រួលការទុកដាក់កុមារនៅក្នុងមណ្ឌលទៅវិញ។ ឧទាហរណ៍ ជាញឹកញាប់ខ្ញុំបានជួបមេភូមិដែលបានចុះហត្ថលេខាលើលិខិតបញ្ជូនកុមារទៅខេត្តផ្សេងៗទៅរស់នៅក្នុងមណ្ឌលថែទាំ ដោយមិនបានគិតគូរពីកិច្ចការពារកុមារនោះទេ។ នេះគឺជាបញ្ហាជាក់ស្តែង។ មុនឆ្នាំ ២០១៥ ឃុំមិនត្រូវការ ការឯកភាពយល់ព្រមពីមន្ទីរ ស.អ.យ នោះឡើយ មុននឹងធ្វើការបញ្ជូនកុមារ ក៏ប៉ុន្តែភាគច្រើនពួកគាត់ នៅមិនដឹងអំពីលក្ខខណ្ឌតម្រូវ... ចំនុចនេះពិតជាត្រូវការការបណ្តុះបណ្តាលយ៉ាងច្រើនបន្ថែមទៀតដើម្បីទប់ស្កាត់ «ការទុកដាក់កុមារទៅក្នុងមណ្ឌលថែទាំដោយមិនចាំបាច់»។*[34]

32 សម្ភាសជាក្រុមជាមួយប្រធាន និងម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់ការថែទាំពេលថ្ងៃ និងសេវាគាំពារគ្រួសារផ្សេងទៀត ខេត្តកណ្តាល ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។
33 សម្ភាសប្រធានអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការថែទាំជំនួស និងសេវាសមាហរណកម្ម ខេត្តកណ្តាល ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦។
34 សម្ភាសតំណាងមន្ទីរសង្គមកិច្ច ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។

មានការស្នើឡើងឲ្យមានការចេញសេចក្តីណែនាំងាយៗ ដែលមានចែងអំពីភារកិច្ច និងការទទួលខុសត្រូវរបស់មេភូមិ និងសមាជិក គកនក នៅពេលដែលកុមារម្នាក់ត្រូវការកិច្ចការពារ ហើយសេចក្តីណែនាំនេះគួរត្រូវបានផ្សព្វផ្សាយនៅទូទាំងប្រទេស រួមជាមួយការរៀបចំកញ្ចប់បណ្តុះបណ្តាល ការបណ្តុះបណ្តាលគ្រូបង្គោល និងបើកវគ្គបណ្តុះបណ្តាលនៅតាមស្រុកនីមួយៗ។ វគ្គបណ្តុះបណ្តាលក៏គួរមានតាមប្រព័ន្ធអ៊ីនធឺណែតផងដែរ។

## សេវាគាំទ្រគ្រួសារ- ការបង្ការការបំបែកកុមារពីគ្រួសារ

ប្រកាសស្តីពីនីតិវិធី ចែងថា គកនក បុគ្គលិកសង្គមកិច្ចនៃការិយាល័យ ស.អ.យ និង គកសក ត្រូវទទួលខុសត្រូវចំពោះការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល វត្តអារាម និងមណ្ឌលសាសនាដទៃទៀត ដើម្បីផ្តល់សេវាគាំទ្រដល់គ្រួសារ ដើម្បីបង្ការការបំបែកកុមារពីគ្រួសារ និងលើកកម្ពស់ការធ្វើសមាហរណកម្ម។ ក្រៅពីការបង្កើត «ផែនការសេវា» និងធ្វើការសម្របសម្រួលការបញ្ជូនរវាងកុមារ និងគ្រួសារ និងសេវាដែលពាក់ព័ន្ធការគាំទ្រនេះគួរតែបញ្ចូលការចុះតាមដានដើម្បីធ្វើការប៉ាន់ប្រមាណអំពីតម្រូវការ និងវឌ្ឍនភាពរបស់គ្រួសារ ក៏ដូចជា ផ្តល់ប្រឹក្សា និងសេវាសង្គមកិច្ចតាមការចាំបាច់។

នៅក្នុងការអនុវត្តជាក់ស្តែង វាហាក់ដូចជាថាអាជ្ញាធររដ្ឋាភិបាលបានផ្តល់ការគាំទ្រតិចតួចខ្លាំងណាស់ ដើម្បីទប់ស្កាត់ការបំបែកកុមារពីគ្រួសារ ឬលើកកម្ពស់ការធ្វើសមាហរណកម្ម។ ទាំងសមាជិក គកនក ទាំងបុគ្គលិកនៃការិយាល័យ ស.អ.យ តាមសេចក្តីរាយការណ៍ មិនបានផ្តល់ការប្រឹក្សាយោបល់ ការរៀបចំផែនការករណី ឬផ្តល់ការគាំទ្រផ្នែកសម្ភារៈអ្វីនោះទេ។ អ្នកផ្តល់ចម្លើយបានឆ្លើយដោយស្របគ្នាចំពោះបញ្ហានេះ ដោយដាក់បន្ទុកទៅលើកង្វះពេលវេលា កង្វះថវិកា និងសមត្ថភាព។

*យើងត្រូវការបុគ្គលិកសង្គមកិច្ចជាច្រើននាក់បន្ថែមទៀត យ៉ាងហោចណាស់ម្នាក់ទៀតសម្រាប់ចុះតាមដាន។ ក៏មានការងារធ្វើច្រើនជាមួយអតីតយុទ្ធជន ដូច្នេះខ្ញុំត្រូវបែងចែកពេលវេលារបស់ខ្ញុំរវាងកិច្ចការអតីតយុទ្ធជន និងកិច្ចការកុមារ។*[35]

*នៅក្នុងគណៈកម្មាធិការរបស់យើងមិនមានអ្នកជំនាញខាងប្រឹក្សាយោបល់ ឬអ្នកផ្តល់ប្រឹក្សាយោបល់ដែលបានទទួលការបណ្តុះបណ្តាលនោះទេ...។*[36]

*គកនក មិនដែលផ្តល់អ្វីដល់កុមារនោះឡើយក្នុងអំឡុងពេលនៃការធ្វើសមាហរណកម្ម ក៏ប៉ុន្តែយើងបានជួយរៀបចំឯកសារដើម្បីធានាថាកុមារពិតជាបានទៅដល់ដៃសាច់ញាតិនិងមិនមានបញ្ហាអ្វីទាំងអស់។ ក៏ប៉ុន្តែពាក់ព័ន្ធជាមួយប្រាក់ និងសម្ភារៈ មិនមានទេ មិនមានទាល់តែសោះ។ គណៈកម្មាធិការរបស់យើងមិនដែលមានមូលនិធិណានៅក្នុងដៃ ឬការគាំទ្រជាវត្ថុអ្វីនោះទេ។*[37]

ផ្ទុយទៅវិញ ការិយាល័យ ស.អ.យ និង គកនក ត្រូវបញ្ជូនកុមារទៅរកអង្គការមិនមែនរដ្ឋាភិបាលដែលមានសេវាទៅវិញ។

35 សម្ភាសបុគ្គលិកសង្គមកិច្ចស្រុក ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
36 សម្ភាសតំណាង គកសក ខេត្តកណ្តាល ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦។
37 សម្ភាសតំណាង គកនក ខេត្តព្រះសីហនុ ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៦។

## ការបង្រួបបង្រួមគ្រួសារ និងការធ្វើសមាហរណកម្ម

លទ្ធផលនៃការស្រាវជ្រាវ បង្ហាញថាមានករណីជាច្រើនបច្ចុប្បន្នដែលកំពុងត្រូវបានដោះស្រាយដោយអាជ្ញាធររដ្ឋាភិបាល ជាពិសេស ដោយបុគ្គលិកមន្ទីរ និងការិយាល័យ ស.អ.យ គឺជាករណីរបស់កុមារដែលចាកចេញពីមណ្ឌលថែទាំទៅរកការរៀបចំថែទាំថ្មីដោយគ្រួសារ។ ការខិតខំប្រឹងប្រែងទាំងនេះបានជួយដល់រដ្ឋាភិបាលក្នុងការធ្វើសមាហរណកម្មប្រកបដោយសុវត្ថិភាពនូវកុមារចំនួន ៣០% ពីការថែទាំតាមមណ្ឌលទៅរកការថែទាំដោយគ្រួសារនៅឆ្នាំ ២០១៨ និងវាស្របទៅនឹងការទទួលខុសត្រូវដូចមានចែងនៅក្នុង *ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ*។ ទោះដូច្នេះក្តី ដោយសារកង្វះធនធានបុគ្គលិក ការយកចិត្តទុកដាក់ចំពោះការធ្វើសមាហរណកម្មកុមារ ដែលស្ថិតនៅក្នុងការថែទាំរួចហើយ អាចរារាំងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះករណីការពារកុមារថ្មីៗនៅពេលដែលករណីនេះកើតឡើងនៅក្នុងចំណោមក្រុមប្រជាពលរដ្ឋទូទៅ។

*តាមបទពិសោធន៍របស់អ្នក (នៅក្នុងស្រុកដែលអ្នកធ្វើការងារ) តើបញ្ហាកង្វល់ចម្បងៗទាក់ទងនឹងកិច្ចការពារកុមារ មានអ្វីខ្លះ?*

*ចំពោះកុមាររងាយរងគ្រោះដែលត្រូវបានបញ្ជូនទៅមណ្ឌលថែទាំ និងក្រោយមកធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញ... យើងខំធ្វើការស្វែងរកគ្រួសារបង្កើតរបស់ពួកគេ ឬគ្រួសារធម៌ដើម្បីជួយកុមារ និង ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ប្រសិនបើគ្រួសារឯកភាពយល់ព្រមទទួលពួកគេ យើងនឹងធ្វើសមាហរណកម្មពួកគេ។ ចំពោះញាតិសន្តានញាតិ ឪពុកម្តាយបង្កើត យើងចុះជាប់រៀងរាល់ខែដើម្បីធានាថាកុមារមិនអី និងតើពួកគេត្រូវការកិច្ចគាំទ្រអ្វីទៀត។*[38]

### ការធ្វើសមាហរណកម្មជាក់ស្តែង

អង្គការមិនមែនរដ្ឋាភិបាល ដែលយើងបានចុះជួបសម្រាប់ការសិក្សានេះបានដាក់ចេញនូវវិធីសាស្ត្រខុសៗគ្នាក្នុងការធ្វើសមាហរណកម្មកុមារទៅឪពុកម្តាយបង្កើតរបស់ពួកគេ ឬទៅក្នុងគ្រួសារសាច់ញាតិ។ ខណៈដែលអង្គការមិនមែនរដ្ឋាភិបាលខ្លះអនុវត្តនីតិវិធីប៉ាន់ប្រមាណការទុកដាក់កុមារជាមុនដោយប្រុងប្រយ័ត្ន និងបានចុះតាមដានជាប់រយៈពេលយូរ (រហូតដល់ ៣ឆ្នាំ) ក៏ដោយ ក៏មានអង្គការមិនមែនរដ្ឋាភិបាលផ្សេងបានទុកដាក់កុមារចូលទៅក្នុងការថែទាំដោយគ្រួសារដោយមានការគិតគូរពិចារណាបន្តិចបន្តួចអំពីសមត្ថភាពរបស់គ្រួសារនោះ ឬមានការគិតគូរបន្តិចបន្តួចអំពីបញ្ហាកិច្ចការពារកុមារ។

ខាងក្រោមនេះ គឺជាសម្រង់សំដីចេញពីការសម្ភាសជាមួយបុគ្គលិកសង្គមកិច្ចនៅក្នុងមណ្ឌលថែទាំកុមារដែលវាបានបង្ហាញយ៉ាងច្បាស់ពីរបៀបដែលអង្គការមិនមែនរដ្ឋាភិបាលបានតម្កល់ឧត្តមប្រយោជន៍របស់កុមារមុនការធ្វើសមាហរណកម្មពួកគេចូលទៅក្នុងការថែទាំជំនួសដោយគ្រួសារ៖

*ដំណើរការនៃការធ្វើសមាហរណកម្ម មាន ៣ដំណាក់កាល៖ មុនសមាហរណកម្ម សមាហរណកម្ម និងក្រោយសមាហរណកម្ម។ ទី ១ មុនការធ្វើសមាហរណកម្ម យើងត្រូវធ្វើការប៉ាន់ប្រមាណគ្រួសារ និងរៀបចំផែនការធ្វើសមាហរណកម្ម។ នៅដំណាក់កាលនៃការធ្វើសមាហរណកម្ម បន្ទាប់ពីបានទុកដាក់កុមារចូលទៅក្នុងគ្រួសាររួចហើយ យើងត្រូវចុះទៅសួរសុខទុក្ខកុមារចំនួន ៣ដង។ បន្ទាប់មក នៅក្រោយការធ្វើសមាហរណកម្ម យើងត្រូវចុះពិនិត្យមើល ២ ឬ ៣ដងទៀត ក៏ប៉ុន្តែចំនួនចុះជួបនេះវាអាស្រ័យលើថាតើគ្រួសារនោះមានស្ថានភាពដូចម្តេច។ ចំណែកខ្ញុំវិញ ខ្ញុំគិតថា ប្រសិនបើមានផែនការ*

38 សម្ភាសបុគ្គលិកសង្គមកិច្ចស្រុក ខេត្តកណ្តាល ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

*ធ្វើសមាហរណកម្មដ៏ច្បាស់លាស់មួយ នៅពេលនោះវាមិនអីទេក្នុងការកំណត់អាទិភាពនៃការធ្វើសមាហរណកម្ម។ ប្រសិនបើគ្មានផែនការ វាមិនមែនជាការល្អនោះទេ។ វាពិតជាសំខាន់ដែលត្រូវមើលឲ្យហួសពីការគាំទ្រហិរញ្ញវត្ថុសម្រាប់គ្រួសារ និងត្រូវពិនិត្យមើលផងដែរអំពីលទ្ធភាពនៃការផ្តល់ជូនគ្រួសារនូវការគាំទ្រផ្លូវចិត្ត និងផ្លូវកាយ។ ឪពុកម្តាយត្រូវការឱ្យមានការត្រៀមលក្ខណៈមុនពេលធ្វើសមាហរណកម្ម បើពុំដូច្នោះទេ វានឹងពុំមានដំណើរការល្អនោះទេ។*[39]

ផ្ទុយទៅវិញ ការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញឱ្យដឹងផងដែរថា មានអង្គការមិនមែនរដ្ឋាភិបាល មួយចំនួនបានធ្វើសមាហរណកម្មកុមារ «ទោះស្ថិតក្នុងតម្លៃណាក៏ដោយ» ដោយមានការព្រួយបារម្ភតិចតួចថាតើគ្រួសារបង្កើត ឬគ្រួសារដែលជាសាច់ញាតិ បានត្រៀមខ្លួនរួចរាល់ដើម្បីផ្តល់ការថែទាំ ឬ កុមារនឹងប្រឈមទៅនឹង អំពើរំលោភបំពាន ឬយ៉ាងណាឡើយ។ ឧទាហរណ៍ ម្តាយចិញ្ចឹមជាសាច់ញាតិរបស់កុមារ (មីងរបស់កុមារ) ដែលបានសម្ភាសនៅក្នុងខេត្តបាត់ដំបង បានប្រាប់ឲ្យដឹងថាគ្មានអ្នកណាម្នាក់បានចុះមកអង្កេតទ្រព្យសម្បត្តិ ឬពិភាក្សាជាមួយគ្រួសាររបស់គាត់មុនក្មួយប្រុសរបស់គាត់បានមករស់នៅជាមួយគាត់នោះទេ។ នៅពេលដែលអ្នកស្រាវជ្រាវក្រោយមកសួរបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបន្ទុកការទុកដាក់កុមារថា ហេតុអ្វីមិនមានការចុះធ្វើការប៉ាន់ប្រមាណមុនមានការទុកដាក់កុមារនៅក្នុងករណីនេះ គាត់បាននិយាយថា អង្គការមិនមែនរដ្ឋាភិបាលមិនមានមូលនិធិចាំបាច់និងមិនមានសមត្ថភាពដើម្បីចុះធ្វើការងារបែបនោះទេ។[40] វាមិនច្បាស់ថាតើនៅក្នុងករណីនេះកុមារត្រូវបានពិគ្រោះយោបល់អំពីការធ្វើសមាហរណកម្មដែរ ឬយ៉ាងណាឡើយ មុនមានការទុកដាក់ពួកគេ។

នៅក្នុងករណីមួយផ្សេងទៀត មានក្មេងស្រីអាយុ ១៦ឆ្នាំម្នាក់ ដែលត្រូវបានបងប្រុសរបស់នាងរំលោភសេពសន្ថវៈ និងបានសម្រាលកូននៅក្នុងកន្លែងស្នាក់នៅដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលត្រូវបាន «ធ្វើសមាហរណកម្ម» ចូលទៅក្នុងគ្រួសាររបស់នាង ដោយមិនមានការប៉ាន់ប្រមាណអំពីការទុកដាក់ជាមុនដោយអង្គការ ឬដោយបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាលឡើយ។ ក្នុងករណីនេះ នគរបាលគ្រាន់តែពឹងផ្អែកលើម្តាយរបស់ក្មេងស្រីដើម្បីធានានូវសុវត្ថិភាពរបស់ក្មេងស្រី និងកូនរបស់ក្មេងស្រីនោះប៉ុណ្ណោះ។

*នគរបាលបានឱ្យខ្ញុំសន្យាថា មិនឲ្យរឿងនេះកើតឡើងម្តងទៀតឡើយ។ បន្ទាប់ពីការចុះសួរសុខទុក្ខនេះមក ពួកគេបានចុះមកពិនិត្យទ្រព្យសម្បត្តិ និងពិនិត្យមើលថាតើកូនប្រុសរបស់ខ្ញុំពិតជាបានចាកចេញទៅរស់នៅកន្លែងផ្សេងដែរឬទេ។*

*តើពួកគេមានដែលស្រាវជ្រាវរកកូនប្រុសរបស់អ្នកដែរឬទេ ? ទេ ! ពួកគេមិនដែលទៅជួបវានោះទេ។ ខ្ញុំប្រាប់ពួកគេអំពីអ្វីដែលកូនប្រុសរបស់ខ្ញុំបានប្រព្រឹត្តចំពោះកូនស្រីរបស់ខ្ញុំ។ ក៏ប៉ុន្តែខ្ញុំក៏និយាយផងដែរថា ខ្ញុំមិនអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងកូនប្រុសរបស់ខ្ញុំនោះដែរ។ ដូច្នេះនគរបាលក៏យល់ព្រមថា វាជាការល្អដែលមិនប្តឹងកូនរបស់ខ្ញុំ។ នគរបាលបាននិយាយថា អ្នកមិនអាចដាក់សំណុំរឿងនេះប្រឆាំងនឹង «ឈាមខ្លួនឯង» នោះទេ។*[41]

39 សម្ភាសបុគ្គលិកសង្គមកិច្ច មណ្ឌលស្នាក់នៅសម្រាប់ជនរងគ្រោះពីការជួញដូរ ខេត្តសៀមរាប ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

40 សម្ភាសឪពុកម្តាយចិញ្ចឹមដែលជាសាច់ញាតិ ខេត្តបាត់ដំបង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។

41 សម្ភាសក្មេងស្រីដែលបានធ្វើសមាហរណកម្ម និងម្តាយ ខេត្តសៀមរាប ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

អ្នកផ្តល់ចម្លើយមួយចំនួនបានសំដែងអំពីកង្វល់ថាការដាក់សម្ពាធពីរដ្ឋាភិបាលឲ្យធ្វើសមាហរណកម្មកុមារចូលទៅក្នុងគ្រួសារក្នុងករណីខ្លះអាចឲ្យកុមារជួបជុំជាមួយគ្រួសារឡើងវិញ តែសុខុមាលភាពរបស់គ្រួសារនោះនៅមានបញ្ហានៅឡើយ ដូច្នេះការធ្វើបែបនេះហាក់ដូចជាយកឧត្តមប្រយោជន៍របស់កុមារទៅធ្វើការប្រថុយប្រថាន៖ ដូចប្រធានអង្គការមិនមែនរដ្ឋាភិបាលម្នាក់ដែលផ្តល់ការគាំទ្រដល់ការធ្វើសមាហរណកម្មនៅខេត្ត ព្រះសីហនុបានពន្យល់ដូច្នេះថា៖

*និយាយដោយស្មោះត្រង់ឥឡូវនេះយើងកំពុងប្រឹងប្រែងយ៉ាងលំបាក។ យើងបានចាត់តាំងបុគ្គលិកយើង ២នាក់ឲ្យធ្វើការនៅក្នុងក្រុមធ្វើសមាហរណកម្ម។ ពួកគេត្រៀមខ្លួនជួយដល់ ក្រសួង ស.អ.យ ក្នុងការចាប់ផ្តើមដំណើរការសមាហរណកម្មកុមារ ក៏ប៉ុន្តែនៅពេលយើងនិយាយអំពីការធ្វើសមាហរណកម្មយើងមិនត្រូវនិយាយច្រើនពេកអំពីបរិមាណនោះទេយើងត្រូវនិយាយអំពីគុណភាព។ យើងមានការព្រួយបារម្ភខ្លាំងណាស់ថាប្រសិនបើយើងជម្រុញខ្លាំងពេក [ចុងបញ្ចប់កុមារនោះនឹងជួប ហានិភ័យ]។*

ពិតណាស់ អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀតបានរាយការណ៍ថា ជានិច្ចកាល វាមិនមានសុវត្ថិភាពចំពោះកុមារក្នុងការវិលត្រឡប់ទៅបរិយាកាសគ្រួសាររបស់ពួកគេវិញនោះទេ ហើយនេះវាបង្កការប្រឈមជាពិសេសនៅពេលដែលមណ្ឌលថែទាំកុមារត្រូវបិទទ្វារ៖

*ការប្រឈមដ៏ធំមួយ ដែលយើងកំពុងជួបប្រទះនៅក្នុងអំឡុងពេលធ្វើការគ្រប់គ្រងករណី និងការធ្វើសមាហរណកម្មកុមារនោះគឺកុមារដែលទទួលរងអំពើរំលោភបំពាន។ ការធ្វើសមាហរណកម្មកុមារនឹងបរាជ័យ ដោយសារតែការប្រើប្រាស់បំពានគ្រឿងស្រវឹង និងអំពើហិង្សាក្នុងគ្រួសារ ដូច្នេះហើយបានជាយើងបានចំណាយពេលជាច្រើនធ្វើការប៉ាន់ប្រមាណគ្រួសារ និង ធ្វើការផ្តល់ប្រឹក្សាដល់គ្រួសារ។ ពេលខ្លះយើងត្រូវយកកុមារត្រឡប់មកវិញ ហើយបញ្ជូនពួកគេទៅវិញ ពេលខ្លះយើងមានការលំបាកជាមួយកុមារ ពីព្រោះឪពុកម្តាយរបស់ពួកគេចង់ប្រើប្រាស់កុមារសម្រាប់គោលបំណងផ្សេងទៀត។*[42]

ដូច្នេះវាសំខាន់ខ្លាំងណាស់សម្រាប់បុគ្គលិកសង្គមកិច្ច និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធជាមួយការធ្វើសមាហរណកម្ម ត្រូវចេះកំណត់អំពីករណីគ្រោះថ្នាក់ ដោយការទុកដាក់កុមារនៅក្នុងបរិយាកាសគ្រួសារខ្លះវាបង្កនូវហានិភ័យធំពេក ឬគ្រោះថ្នាក់ធំពេកចំពោះកុមារ។ មន្ទីរដែលទទួលបន្ទុកចំពោះការ ការពារកុមារក៏ត្រូវធានាថាការដាក់សម្ពាធឲ្យបំពេញតាមគោលដៅ និងកូតាមិនត្រូវធ្វើឲ្យសុខុមាលភាពរបស់កុមារជួបនូវហានិភ័យ ហើយត្រូវធានាថារាល់ការធ្វើសមាហរណកម្មទាំងអស់ជាការធ្វើសមាហរណកម្ម “ប្រកបដោយសុវត្ថិភាព” ផងដែរ។

42 សម្ភាសអង្គការយូនីសេហ្វ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។

# កត្តារុញច្រាន និងកត្តាអូសទាញដែលប៉ះពាល់ដល់ការថែទាំជំនួស

# ៧

ផ្នែកនៃរបាយការណ៍នេះ ពន្យល់អំពីកម្លាំងជម្រុញដ៏សំខាន់ដែលមានឥទ្ធិពលទៅលើការទុកដាក់កុមារកម្ពុជានៅក្នុងទម្រង់ផ្សេងៗនៃការថែទាំជំនួស។ ខណៈពេលដែលការសិក្សាមិនត្រូវបានរៀបចំដើម្បីប្រមូលទិន្នន័យដ៏រឹងមាំ ឬទិន្នន័យជាតំណាងអំពីហេតុផលដែលធ្វើឱ្យកុមារត្រូវគេទុកដាក់នៅក្នុងការថែទាំ ការសិក្សានេះពិតជាបានធ្វើការប្រមូលទិន្នន័យបែបគុណភាពស៊ីជម្រៅទាក់ទងនឹងកត្តារុញច្រាន និងកត្តាអូសទាញដែលមានឥទ្ធិពលទៅលើការទុកដាក់កុមារនៅក្នុងការថែទាំជំនួសពិតប្រាកដមែន។

ភាគច្រើននៃកុមារ រួមទាំងអ្នកថែទាំរបស់កុមារដែលចូលរួមនៅក្នុងការសិក្សានេះបានលើកឡើងថា ភាពក្រីក្រ គឺជាហេតុផលដ៏សំខាន់សម្រាប់រុញច្រានកុមារឲ្យធ្លាក់ចូលទៅក្នុងការថែទាំដោយអ្នកដទៃ។ បើទោះបីជា ភាពក្រីក្រគឺជាបញ្ហាមួយយ៉ាងច្បាស់ចំពោះគ្រួសារមួយចំនួនធំនៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែ ការស៊ើបអង្កេតបន្ថែមទៀតទៅក្នុងករណីដ៏ជាក់លាក់ខ្លះ បានបង្ហាញថា វាមានកត្តាផ្សេងទៀតដែលមានឥទ្ធិពលខ្លាំងទៅលើការសម្រេចចិត្តប្រគល់កុមារទៅឲ្យគេថែទាំជំនួស។ អាស្រ័យដោយមានការមាក់ងាយ ពាក់ព័ន្ធនឹងកុមារដែលមានប្រភពពីគ្រួសារដែលមានប្រវត្តិប្រើហិង្សា មានប្រវត្តិរំលោភបំពាន និងជម្លោះគ្រួសារនៅក្នុងប្រទេសកម្ពុជារួមទាំងកត្តាវប្បធម៌ចាក់ស្រេះដ៏រឹងមាំដូចជាខ្លាចបាក់មុខមាត់ «ភាពក្រីក្រ» អាចគ្រាន់តែជាអ្វីដែលគេប្រើដើម្បីផ្ទេរកុមារទៅរស់នៅជាមួយអ្នកផ្សេងតែប៉ុណ្ណោះ ខណៈពេលដែលបុគ្គលនោះខំបញ្ចៀសមិនបង្ហើបពីមូលហេតុឫសគល់ដ៏ពិតប្រាកដ។[43] កុមារមួយចំនួនដែលបានបញ្ចូលនៅក្នុងការសិក្សានេះ សុទ្ធតែធ្លាប់ទទួលរងការរំលោភបំពាន ឬ មិនអើពើធ្ងន់ធ្ងរ ហើយមើលទៅពួកគេដូចជាបានទទួលរងអំពើហិង្សាលើរាងកាយផ្លូវភេទ ឬផ្លូវចិត្ត។ កុមារដទៃទៀតត្រូវបានឪពុកម្ដាយបោះបង់ចោល ឬបដិសេធ ជាពិសេស ឪពុក ឬម្ដាយដែលបានរៀបការជាមួយដៃគូថ្មី។ កុមារខ្លះត្រូវបានគេយកទៅថែទាំជំនួស ពីព្រោះឪពុកម្ដាយរបស់ពួកគេបានធ្វើចំណាកស្រុក ហើយមិនបានយកកូនទៅតាម។ ហើយទោះអ្នកផ្សេងទៀតមានឪពុកម្ដាយរស់នៅជួបជុំ តែឪពុកម្ដាយនោះបែរជាសេពគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងញៀន ដូច្នេះពួកគេមិនអាចមើលថែទាំកូនរបស់ពួកគេបាននោះទេ។ ជាចុងក្រោយ កុមារផ្សេងទៀតត្រូវបានទុកដាក់ ដោយសារតែលក្ខខណ្ឌសម្ភារៈ និង ការអប់រំ ដែលអាចផ្ដល់ជូនដល់ពួកគេបាននៅឯផ្ទះមានកម្រិតតិចតួចខ្លាំងពេក ហើយវត្តអារាម អន្តេវាសិកដ្ឋាន ឬមណ្ឌលថែទាំកុមារ ត្រូវបានគេមើលឃើញថាជាកន្លែងផ្ដល់ឱកាសរៀនសូត្របានកាន់តែច្រើនដល់កុមារ។

គេប្រហែលជាអាចនិយាយឲ្យកាន់តែសុក្រិតជាងនេះថា កុមារភាគច្រើនបានធ្លាក់ខ្លួនទៅរស់នៅក្នុងការថែទាំជំនួសដោយសារតែមូលហេតុដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកមួយចំនួន។ មូលហេតុទាំងនោះអាចមានដូចជាបញ្ហាសេដ្ឋកិច្ច បញ្ហាគ្រួសារ ការបំបែកកុមារពីគ្រួសារ ជម្ងឺ និងមរណភាពរបស់ឪពុក/ម្ដាយ ដែលទាំងអស់នេះសុទ្ធតែបានរួមចំណែកដល់ការរុញច្រានកុមារចូលទៅក្នុងការថែទាំជំនួស។ ក្រៅពីនេះ វាមានកត្តាទាក់ទងនឹងប្រពៃណីនៅក្នុងសង្គមខ្មែរ ដែលជីដូនជីតាមានភារៈមើលថែទាំចៅរបស់ខ្លួន ហើយក៏កត្តាពាក់ព័ន្ធជាមួយឪពុកម្ដាយចុងដែលពួកគេមានការអល់អែកក្នុងការមើលថែទាំកូនចុងផងដែរ។

---

43 គួរកត់សម្គាល់ថា យើងមិនដឹងច្បាស់លាស់ថាកុមារពិតជាបានដឹងច្រើនប៉ុណ្ណាអំពីមូលហេតុដែលពួកគេត្រូវបានទទួលយកមករស់នៅក្នុងការថែទាំជំនួស ជាពិសេស កុមារដែលបានចូលមករស់នៅក្រោមការថែទាំជំនួសចាប់តាំងពីវ័យតូច។ លើសពីនេះ យើងក៏មិនអាចដឹងថាតើកុមារមានអារម្មណ៍ខ្មាស់អៀនកម្រិតប៉ុណ្ណាអំពីកាលៈទេសៈ ឬការភ័យខ្លាចរបស់ពួកគេចំពោះសហគមន៍ ប្រសិនបើមូលហេតុពិតប្រាកដត្រូវបានគេដឹង ជាពិសេស អ្នកដែលទទួលរងការបំពានផ្លូវកាយ និងផ្លូវភេទ។ ដូចគ្នានេះផងដែរ យើងមិនដឹងថាតើអ្នកថែទាំពិតជាបានប្រាប់យើងដោយស្មោះអំពីមូលហេតុពិតប្រាកដទាក់ទងនឹងមូលហេតុដែលកុមារចូលមករស់នៅក្នុងការថែទាំរបស់ពួកគេ ឬមួយពួកគេមានបំណងរក្សាសេចក្ដីថ្លៃថ្នូរ និងឯកជនភាពរបស់កុមារ ជាពិសេស តើនឹងមានអ្វីកើតឡើង ប្រសិនបើកុមារបានស្ដាប់ឮនូវអ្វីដែលយើងកំពុងសាកសួរ។

## ភាពក្រីក្រ

ដូចបានលើកពីខាងដើម ភាពក្រីក្រគឺជាមូលហេតុចម្បងដែលបានលើកឡើងដោយអ្នកថែទាំកុមារនៅក្នុងរាជធានីខេត្តទាំងអស់ និង នៅក្នុងទម្រង់នៃការថែទាំផ្សេងៗគ្នា ប៉ុន្តែបើទោះជាដូច្នេះក្តី ការប្រើប្រាស់ពាក្យ «ក្រីក្រ» នេះ មានភាពទូលំទូលាយ និងប្រើប្រាស់ដើម្បីលាក់បាំងបញ្ហាហិរញ្ញវត្ថុជាច្រើន ពីអ្នកដែលមិនមានមធ្យោបាយដើម្បីគាំទ្រកូនរបស់ខ្លួន រហូតដល់អ្នកដែលមិនចាត់ទុកខ្លួនឯងថា មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីផ្តល់ការគាំទ្រដែលពួកគេចង់ឲ្យកូនរបស់ពួកគេទទួលបាន។ ចំពោះគ្រួសារកម្ពុជាខ្លះការទុកដាក់កុមារទៅក្នុងការថែទាំជំនួស គឺជាវិធីដោះស្រាយបញ្ហាមួយ នៅពេលដែលគ្រួសារមិនមានប្រាក់គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់អាហារដល់កូន ទិញសម្លៀកបំពាក់ និងផ្តល់ជម្រកដល់កូន។ ចំពោះគ្រួសារខ្មែរមួយចំនួន ការទុកដាក់កុមារនៅក្នុងការថែទាំជំនួសគឺជាមធ្យោបាយមួយក្នុងការធ្វើឲ្យកុមារទទួលបាននូវការថែទាំមួយដែលមានលក្ខណៈប្រកបដោយបទដ្ឋាន ទទួលបានការអប់រំរៀនសូត្រ និងមានឱកាសការងារ និងមុខរបរ ដែលគ្រួសារនោះខ្លួនឯងមិនអាចផ្តល់ឲ្យបាន និង ដើម្បីឱ្យគ្រួសារនោះមានឱកាសធ្វើចំណាកស្រុកទៅរកការងារធ្វើសម្រាប់ខ្លួនឯង។

អ្នកផ្តល់ចម្លើយ បានរៀបរាប់អំពីទស្សនៈយល់ឃើញដ៏ច្បាស់លាស់របស់សហគមន៍ជាច្រើនដែលថាការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំកុមារ គឺជាជម្រើសដ៏ល្អបំផុតសម្រាប់កុមារមកពីគ្រួសារក្រីក្រ ដោយមិនគិតថាតើកុមារនោះមានគ្រួសារដែលចង់ឲ្យសាច់ញាតិមើលថែទាំជំនួសវិញនោះទេ។ ដូចតំណាងមន្ទីរសង្គមកិច្ចម្នាក់នៅខេត្តបាត់ដំបងបានពន្យល់ដូច្នេះថា៖

*មណ្ឌលថែទាំកុមារ គឺជាជម្រើសទី ១ ក្នុងចំណោមប្រជាពលរដ្ឋធម្មតាដែលខ្ញុំបានជួបនៅពេលខ្ញុំចុះទៅសហគមន៍។ ខ្ញុំគិតថានេះដោយសារតែអត្ថប្រយោជន៍សម្ភារៈដែលមណ្ឌលអាចផ្តល់ឲ្យ។ ប្រជាពលរដ្ឋធម្មតាមានគំនិតជាទូទៅថា «កូនរបស់យើងអាចមានជីវិតល្អប្រសើរនៅក្នុងមណ្ឌលថែទាំ»។ វាមានការពិបាកខ្លាំងណាស់ក្នុងការអូសទាញពួកគាត់ឲ្យយល់ថា មណ្ឌលថែទាំកុមារគួរតែជាជម្រើសចុងក្រោយ។*[44]

## ការអប់រំ

ក្រៅពីការផ្តល់ដំណោះស្រាយថែទាំកុមារសម្រាប់គ្រួសារក្រីក្រ និងការដកចេញនូវបន្ទុកផ្នែកសេដ្ឋកិច្ចទាក់ទងនឹងការថែទាំកុមារ សេវាថែទាំជំនួស ជាពិសេស ការថែទាំតាមវត្តអារាម ការថែទាំកុមារតាមមណ្ឌលនិងអន្តេវាសិកដ្ឋានត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយនៃការផ្តល់ឱ្យកុមារនូវការអប់រំរៀនសូត្រដោយឥតគិតថ្លៃ និងមានគុណភាពខ្ពស់។ អ្នកផ្តល់ចម្លើយបានរៀបរាប់ពីប្រតិកម្មរបស់ពួកគេចំពោះប្រព័ន្ធអប់រំរបស់រដ្ឋដែលមានគុណភាពមិនល្អនៅក្នុងប្រទេសកម្ពុជាថា៖

*មូលហេតុទី ២ [ដែលទីបំផុត កុមារត្រូវរស់នៅក្រោមការថែទាំជំនួស] គឺដើម្បីពួកគេទទួលបានការអប់រំ។ គ្រួសារទាំងអស់បានចាត់ទុកមណ្ឌលថែទាំដូចជាអន្តេវាសិកដ្ឋាន ដូច្នេះពួកគេប្រើប្រាស់មណ្ឌលដូចជាសាលារៀនអន្តេវាសិកដ្ឋាន។ ពួកគេមានការជឿជាក់ទៅលើការអប់រំរៀនសូត្រនៅក្នុងសាលារៀននោះច្រើនជាងអ្វី ដែលពួកគេបានទទួលពីសាលារៀនរបស់រដ្ឋាភិបាលនៅក្នុងស្រុកទៅទៀត។*[45]

*មូលហេតុចម្បងដែលកុមារមកទីនេះ គឺដើម្បីបានរៀនសូត្រដល់មធ្យមសិក្សា។ ឱកាសអប់រំរៀនសូត្របែបនេះមិនមាននៅក្នុងភូមិកំណើតរបស់កុមារនោះទេ...។*[46]

44 សម្ភាសតំណាងមន្ទីរសង្គមកិច្ច ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
45 សម្ភាសតំណាងអង្គការ Community Care First តាម skype ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។
46 សម្ភាសព្រះសង្ឃអ្នកថែទាំនៅវត្ត ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

ដូចទស្សនៈទី ២នេះលើកឡើង សម្រាប់គ្រួសារដែលរស់នៅក្នុងតំបន់ជនបទដែលការទទួលបាននូវការអប់រំរៀនសូត្រជារូបវ័ន្តគឺជាបញ្ហាប្រឈមសម្រាប់ពួកគេ សេវាថែទាំជំនួសអាចជួយសម្រួលដល់ការទទួលបានការរៀនសូត្រសម្រាប់កុមារ។ បើទោះបីជាសេវាថែទាំជំនួសមិនផ្ដល់នូវការអប់រំរៀនសូត្រដោយខ្លួនឯងក៏ដោយ ក៏ពួកគេជាញឹកញាប់ចេញថ្លៃសិក្សារៀនសូត្របន្ថែម ឬចេញថ្លៃ "រៀនគួរ" ដែលកុមារមិនអាចទទួលបាននៅពេលពួកគេរស់នៅក្នុងផ្ទះជាមួយគ្រួសារ ហើយអ្នកផ្ដល់ចម្លើយជាច្រើនបានចាត់ទុកថាចំនុចនេះមាន សារៈសំខាន់ខ្លាំងណាស់សម្រាប់កុមារទទួលបានភាពជោគជ័យនៃការរៀនសូត្ររបស់ពួកគេ ដូចប្រធានមណ្ឌលថែទាំម្នាក់នៅក្នុងខេត្តកណ្ដាលបានពន្យល់ថា៖

*បើគ្មានការរៀនគួរបន្ថែមទេនោះ គ្មានកុមារណាម្នាក់រៀនបានពូកែនោះទេ។ ពួកគេត្រូវរៀន ២ដង! ការសិក្សាមិនគិតថ្លៃ តែបើអ្នកចង់ប្រឡងជាប់អ្នកត្រូវរៀនគួរបន្ថែម។ សូម្បីឪពុកម្ដាយកុមារក៏និយាយដូច្នេះដែរ។ រៀនគួរត្រូវចំណាយ ៣០ដុល្លាក្នុង ១ខែ។ បើអ្នកបញ្ជូនកូនទៅផ្ទះ ពួកគេមិនមានប្រាក់ឲ្យកូនរៀនបន្ថែមនោះទេ... ក្មេងជាច្រើនរបស់យើងរៀនបានពិន្ទុខ្ពស់នៅក្នុងសាលាពីព្រោះមានការជួយគាំទ្រដល់ការសិក្សារបស់ពួកគេ។ នោះគឺជាការប្រឈមដ៏ធំ។ ប្រសិនបើពួកគេវិលទៅគ្រួសារ តើនឹងមានអ្វីកើតឡើងចំពោះការសិក្សារបស់ពួកគេ?*[47]

ការចំណាយលើការសិក្សាសម្រាប់កុមារម្នាក់ គឺជាបន្ទុកដ៏ធំចំពោះឪពុកម្ដាយដែលមានប្រាក់ចំណូលទាប ដូច្នេះការផ្ដល់ការអប់រំនៅក្នុងមណ្ឌលថែទាំ (ក្រៅពីការថែទាំដោយសាច់ញាតិ) គឺជាកម្លាំងជម្រុញដ៏ធំមួយជាពិសេសសម្រាប់វត្តអារាម និងមណ្ឌលថែទាំកុមារ។ ទោះបីជាច្បាប់ចែងថា ការអប់រំនៅសាលារដ្ឋមិនគិតថ្លៃក៏ដោយ ប៉ុន្តែ អ្នកផ្ដល់ចម្លើយនៅរក្សាជំហរថា នៅក្នុងការអនុវត្តជាក់ស្ដែង គ្រូបង្រៀនបានតម្រូវឲ្យកុមារម្នាក់ៗបង់ប្រាក់។ ជានិច្ចកាល មណ្ឌលថែទាំជំនួសមិនមែនត្រូវបង់ប្រាក់តាមការតម្រូវរបស់គ្រូបង្រៀននៅសាលារដ្ឋដែលកុមារចូលរៀនប៉ុណ្ណោះទេ តែពួកគេក៏"ត្រូវបង់ថ្លៃរៀនគួរ ថ្លៃគ្រូបង្រៀន និងសម្ភារៈសិក្សាក៏ដូចជា ការបន្តទៅសិក្សានៅសាកលវិទ្យាល័យ និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈផងដែរ"។"[48]

## ការធ្វើចំណាកស្រុករបស់ឪពុកម្ដាយ

លទ្ធផលចេញពីការសិក្សា បង្ហាញថាជាញឹកញាប់ដែលកុមារត្រូវបានទុកដាក់នៅក្នុងការថែទាំជំនួស នោះគឺដោយសារឪពុកម្ដាយរបស់ពួកគេបានធ្វើចំណាកស្រុកទៅរកការងារធ្វើ។ អ្នកផ្ដល់ចម្លើយបានពន្យល់ថា ការធ្វើចំណាកស្រុកដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ (បណ្ដោះអាសន្ន) មានការកើនឡើងនៅក្នុងប្រទេសកម្ពុជាដោយសារមានតម្រូវការច្រើនឡើងនៃពលកម្មថោក នៅក្នុងតំបន់ឧស្សាហកម្មក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសជិតខាង ជាពិសេស ប្រទេសថៃ។

នៅក្នុងខេត្តសៀមរាប កុមារដែលត្រូវបានបោះបង់ គឺជាករណីទូទៅបំផុតមួយដែលត្រូវការនូវការថែទាំជំនួស។ ពួកគេចេញមកពីគ្រួសារងាយរងគ្រោះ។ ឧទាហរណ៍ ឪពុកម្ដាយធ្វើចំណាកស្រុកទៅប្រទេសថៃ ហើយបានទុកកូនចោលនៅជាមួយគ្រួសារសាខាញាតិ។ នៅក្នុងគ្រួសារសាខាញាតិពួកគេខ្វះភាពកក់ក្ដៅ និងការថែទាំ។ ពួកគេអាចទទួលបានការគាំទ្រពីសហគមន៍ ឬទៅវត្តអារាម។[49]

---

47 សម្ភាសប្រធាន មណ្ឌលថែទាំ ខេត្តកណ្ដាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

48 ការរក្សាកុមារនៅផ្ទះ៖ ការវាយតម្លៃតាមបែបគុណភាពអំពីការឆ្លើយតបជាប្រពៃណីរបស់សហគមន៍ចំពោះកុមារត្រូវការការថែទាំជំនួស (អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយមិនស្គាល់) ឆ្នាំ២០០៨។

49 សម្ភាសតំណាង គកសក (ថ្នាក់ខេត្ត) ខេត្តសៀមរាប ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

គ្រួសារទាំងឡាយ មានទំនោរប្រើប្រាស់ការថែទាំដោយសាច់ញាតិ នៅពេលពួកគេធ្វើចំណាកស្រុក ដូចជា ទុកកូនឲ្យជីដូនជីតាជាអ្នកមើលថែ។ ទោះដូច្នេះក៏ដោយវាបានបង្ហាញឱ្យឃើញថាឪពុកម្តាយធ្វើចំណាកស្រុកយូរពេក រហូតដល់រាប់ឆ្នាំ ហើយជីដូនជីតាកាន់តែជរា មិនអាចធ្វើការ និងមិនអាចមើលការថែទាំ និងមិនអាចផ្គត់ផ្គង់លុយកាក់ឲ្យចៅបានជាពិសេសលុយកាក់សម្រាប់ការសិក្សារៀនសូត្រ។ មានភស្តុតាងតែបន្តិចបន្តួចប៉ុណ្ណោះទាក់ទងនឹងឪពុកម្តាយបានផ្ញើប្រាក់មកជួយគាំទ្រឪពុកម្តាយរបស់ពួកគាត់ ឬសាច់ញាតិដែលមើលថែទាំកូនរបស់គាត់។ ជាលទ្ធផល ការថែទាំដោយសាច់ញាតិអាចនឹងមិនធ្វើទៅបាន ដូច្នេះជាចុងក្រោយត្រូវទុកដាក់កុមារនោះនៅក្នុងទម្រង់ដទៃទៀតនៃការថែទាំជំនួស ជាពិសេស នៅពេលដែលរដ្ឋមិនមានលទ្ធភាពផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ។

## មរណៈភាពគ្រួសារ ឬការបែកបាក់ទំនាក់ទំនងគ្រួសារ

អ្នកផ្តល់ចម្លើយ បានឆ្លើយថាកុមារអាចចូលទៅរស់នៅក្នុងការថែទាំជំនួស នៅពេលដែលឪពុកម្តាយរបស់ពួកគេចែកផ្លូវគ្នា ឬដោយសារទម្រង់ណាមួយនៃការបែកបាក់គ្រួសារ។ នេះគឺជារឿងពិត ជាពិសេសចំពោះគ្រួសារក្រីក្រ ដែលឪពុក ឬ ម្តាយ មិនអាចផ្តល់ការគាំទ្រដល់កូន និងមានសម្ពាធសេដ្ឋកិច្ច ហើយត្រូវបង្ខំចិត្តទៅរកការងារធ្វើ៖ *"ម្តាយម្នាក់មានកូន ២នាក់។ ប្តីរបស់គាត់បានចាកចោលគាត់ ហើយគាត់បានក្លាយជាស្ត្រីមេម៉ាយ។ គាត់មិនអាចធ្វើអ្វីបានដើម្បីធ្វើឲ្យជីវិតរបស់គាត់បានប្រសើរជាងនេះដូច្នេះមានតែគាត់បញ្ជូនកូនរបស់គាត់ទៅអង្គការ"*។[50] នៅក្នុងករណីផ្សេងទៀត គេបានរាយការណ៍ថាកុមារត្រូវទុកដាក់នៅក្នុងការថែទាំជំនួស ដោយសារពួកគេត្រូវបានបដិសេធដោយឪពុក ឬម្តាយចុង ឬដោយសារមានអំពើរំលោភបំពាន ការរើសអើង ឬ ការធ្វើបាបដោយឪពុក ឬម្តាយចុង៖ *"ខ្ញុំមិនសប្បាយចិត្តក្នុងការរស់នៅជាមួយម្តាយចុងរបស់ខ្ញុំនោះទេ។ ខ្ញុំមិនបានទៅរៀន ហើយខ្ញុំត្រូវទៅធ្វើស្រែ... ខ្ញុំមិនចង់គិតពីវានោះទេ"*។[51] ប្រការដែលគួរឲ្យចាប់អារម្មណ៍នោះគឺ អ្នកផ្តល់ចម្លើយលើកឡើងថា កុមារកម្ររស់នៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត បន្ទាប់ពីពួកគេបានចែកផ្លូវគ្នាណាស់។ បញ្ហានេះ អាចមួយផ្នែកបណ្តាលពីសម្ពាធសេដ្ឋកិច្ចដែលប្រឈមដោយឪពុក ឬម្តាយនោះ ប៉ុន្តែមួយផ្នែកទៀត វាក៏អាចឆ្លុះបញ្ចាំងពីការមាក់ងាយការបដិសេធន៍ និង ការរំលោភបំពានមកលើកូនចុងផងដែរ រួមផ្សំជាមួយនិយាមសង្គមដែលមិនទទួលយកការបែកបាក់គ្រួសារ ឬការផ្តល់ការថែទាំ និងគាំទ្រដល់កុមារដែលមិនមែនជាកូនបង្កើតរបស់ខ្លួនផង។[52]

## កុមារដែលមានអាកប្បកិរិយាល្មើស

ការថែទាំជំនួស ជាពិសេស ការថែទាំតាមវត្តអារាម ត្រូវបានរាយការណ៍ថា ត្រូវបានគេប្រើប្រាស់ជាដំណោះស្រាយមួយសម្រាប់កុមារដែលមានអាកប្បកិរិយាពិបាក ឬអាកប្បកិរិយាល្មើស៖

*មានក្មេងប្រុសខ្លះនៅទីនេះមិនមែនដោយសារភាពក្រីក្ររបស់គ្រួសារនោះទេ តែដោយសារពួកគេប្រព្រឹត្តមិនល្អ ពួកគេច្រឡើសបើស ឬ មិនស្តាប់បង្គាប់។ ដូច្នេះដើម្បីទប់ស្កាត់បញ្ហានេះមិនឲ្យវាកាន់តែអាក្រក់ ឪពុកម្តាយបានបញ្ជូនពួកគេមកទីនេះដោយមានគោលបំណងថាពួកគេនឹងបួសធ្វើជាព្រះសង្ឃនៅទីនេះក្នុងពេលឆាប់ៗខាងមុខ។*[53]

50 សម្ភាសតំណាង គកនក ខេត្តកណ្តាល ថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦។

51 សម្ភាសក្មេងប្រុសអាយុ ១៨ឆ្នាំនៅសាលារៀនផ្តល់ការស្នាក់នៅ ខេត្តព្រះសីហនុ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។

52 "ការរក្សាកុមារនៅផ្ទះ" ការឆ្លើយតបជាប្រពៃណីរបស់សហគមន៍ចំពោះកុមារត្រូវការការថែទាំជំនួសនៅប្រទេសកម្ពុជា ឆ្នាំ ២០០៨ (បោះពុម្ពផ្សាយ មិនដឹង) របាយការណ៍បង្ហាញថា កុមារបានបាត់បង់ម្តាយងាយនឹងត្រូវគេទុកដាក់ជាងគេនៅក្នុងការថែទាំជំនួសជាងកុមារដែលបាត់បង់ឪពុក៖ ៧០%នៃកុមារដែលបានសម្ភាសសម្រាប់ការសិក្សានេះគឺជាកុមារកំព្រាម្តាយ និង ៣០%ជាកុមារកំព្រាឪពុក។

53 សម្ភាសព្រះចៅអធិការវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។

ហើយដូចបុគ្គលិកមន្ទីរ ស.អ.យ ម្នាក់បានប្រាប់អ្នកស្រាវជ្រាវយើងថា៖

*មានក្មេងប្រុសម្នាក់ត្រូវបានទុកដាក់នៅជាមួយជីដូនជីតារបស់គាត់ តែក្មេងនោះជាក្មេងមិនស្តាប់បង្គាប់ ដូច្នេះ វាមានការពិបាកចំពោះជីដូនជីតា និងចំពោះពួកយើងក្នុងនាមជាមន្ត្រីក្នុងការដោះស្រាយបញ្ហានេះ... ក្រោយមកជីដូនជីតារបស់ក្មេងនោះបានស្នើឲ្យពួកយើងនៅថ្នាក់ស្រុក និងថ្នាក់ខេត្តថា៖ «សូមជួយពួកយើងផងពីព្រោះចៅប្រុសរបស់យើងមិនចេះស្តាប់ចាស់ទុំប្រដៅនោះទេ ហើយថែមទាំងលួចអីវ៉ាន់របស់អ្នកស្រុកទៀតផង!»។ យើងក៏បានដកហូតក្មេងនោះចេញពីជីដូនជីតារបស់គាត់ហើយទុកដាក់ឱ្យរស់នៅក្នុងមណ្ឌលទៅ...។*[54]

## កុមារត្រូវការការថែទាំ និងកិច្ចការពារពិសេស

ជាចុងក្រោយ លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា កុមារដែលចុងក្រោយត្រូវទៅរស់នៅក្នុងការថែទាំជំនួសគឺដោយសារពួកគេទទួលរង ឬ ងាយរងគ្រោះពីអំពើហិង្សា ការរំលោភបំពាន ឬការមិនអើពើនៅក្នុងបរិយាកាសគ្រួសាររបស់ពួកគេ។ បើទោះបីជាញឹកញាប់ នេះគឺជាកត្តាមួយដ៏ចម្បងក៏ដោយ អ្នកថែទាំកុមារដែលយើងបានសម្ភាសសម្រាប់ការសិក្សានេះ មិនសូវបានលើកបញ្ហានេះជាហេតុផលសម្រាប់ការយកកុមារទៅរស់នៅក្នុងការថែទាំជំនួសនោះទេ។ វាហាក់ដូចជាថា ក្នុងករណីខ្លះ ការរំលោភបំពានមិនអាចរកឃើញ ឬមិនត្រូវបានរាយការណ៍ ឬវាអាចថា មាន ឬមិនមានការជូនព័ត៌មានដ៏ពេញលេញដល់អ្នកផ្តល់ការថែទាំអំពីការរំលោភបំពាននោះ។ កុមារមួយចំនួននៅក្នុងការថែទាំដែលយើងបានសម្ភាសសម្រាប់ការសិក្សានេះបានរៀបរាប់ថាពួកគេបានទទួលរងទម្រង់ផ្សេងៗនៃការរំលោភបំពាន រួមមាន អំពើរំលោភបំពានដែលពួកគេមិនបានរាយការណ៍ទៅអាជ្ញាធរ ឬទៅអ្នកថែទាំ៖ *«គ្មានអ្នកណាដឹងអំពីប្រវត្តិរបស់ខ្ញុំនោះទេ។ ពួកគេគិតថាខ្ញុំមកទីនេះដើម្បីទទួលបានការបណ្តុះបណ្តាលជំនាញ... គ្មានអ្នកណាសួរខ្ញុំ ចឹងខ្ញុំក៏មិនដែលប្រាប់ពួកគេដែរ»។*[55]

## ពហុភាពងាយរងគ្រោះ

ដូចដែលបានរៀបរាប់ខាងលើ មូលហេតុដែលកុមារត្រូវបានទុកដាក់នៅក្នុងការថែទាំជំនួសគឺមានអន្តរទំនាក់ទំនងគ្នា និងមានភាពត្រួតគ្នា។ ភាពក្រីក្រ និងកង្វះឱកាសការងារ និងមុខរបរ នាំឱ្យឪពុកម្តាយធ្វើចំណាកស្រុក និងបន្ថែមទម្ងន់ទៅលើភាពងាយរងគ្រោះទ្វេឡើងនៃការបែកបាក់គ្រួសារ។ លើសពីនេះ នៅក្នុងបរិបទដែលគ្មានសំណាញ់សុវត្ថិភាពសង្គម ហើយក្នុងពេលដែលសេវាសាធារណៈមានសភាពទន់ខ្សោយខ្លាំង[56] គ្រួសារដែលខ្វះធនធានក្នុងការផ្តល់ដល់កូនរបស់ខ្លួនត្រូវពឹងផ្អែកលើការថែទាំជំនួសដើម្បីធានាថាតម្រូវការមូលដ្ឋានរបស់កូនពួកគាត់ត្រូវបានបំពេញ។ ការបាត់បង់សេដ្ឋកិច្ចនេះក៏រួមចំណែកដល់ទម្រង់ផ្សេងៗនៃអំពើរំលោភបំពាន និងភាពមិនអើពើផងដែរ ដូចជា គ្រួសារដែលប្រើប្រាស់កុមារធ្វើជាប្រភពពលកម្ម។ ក្នុងករណីជាច្រើន ការប្រើប្រាស់បំពាន គ្រឿងស្រវឹង និង គ្រឿងញៀននៅក្នុងគ្រួសារ ត្រូវបានរកឃើញថានាំឱ្យមានអំពើហិង្សាក្នុងគ្រួសារ និងការ រំលោភបំពានលើរាងកាយ ហើយជាចុងក្រោយគឺកុមារត្រូវបានទុកដាក់ឱ្យរស់នៅក្រោមការថែទាំជំនួស។

ករណីសិក្សាចេញពីការស្រាវជ្រាវ បង្ហាញថាតើមូលហេតុលើកឡើងខាងលើបានរួមចំណែកក្នុងការជម្រុញកុមារឲ្យធ្លាក់ចូលទៅក្នុងការថែទាំជំនួស និងបានរារាំងការធ្វើសមាហរណកម្មពួកគេត្រឡប់ទៅគ្រួសាររបស់ពួកគេវិញដូចម្តេចខ្លះ។

54 សម្ភាសតំណាងមន្ទីរសង្គមកិច្ចខេត្តកណ្តាល ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។

55 សម្ភាសក្មេងប្រុសរស់នៅជាលក្ខណៈឯករាជ្យ មានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។

56 ជាក់ស្តែង សេវាសាធារណៈក៏ថ្លៃផងដែរ- អ្នកផ្តល់ចម្លើយមួយចំនួនបានឆ្លើយថាទោះ បីជាសេវាអប់រំមិនគិតថ្លៃតែនេះគឺគ្រាន់តែ ជាគោលការណ៍តែជាក់ស្តែងវាមានអំពើពុករលួយនៅក្នុងប្រព័ន្ធអប់រំ និងការចំណាយបន្ថែមលើសម្ភារៈ ថ្លៃគ្រូបង្រៀន ។ល។

**ករណីសិក្សា៖ ការថែទាំដោយគ្រួសារសាច់ញាតិនៅក្នុងខេត្តព្រះសីហនុ**

*តើមាននរណាខ្លះរស់នៅទីនេះជាមួយអ្នក ?* យើងមានគ្នា ៤នាក់រស់នៅទីនេះ... ក្មេងស្រីម្នាក់អាយុ ១១ឆ្នាំ។ នាងជាចៅស្រីរបស់ខ្ញុំ។ ម្តាយរបស់នាងមានគ្រោះថ្នាក់ឆក់ខ្សែភ្លើងស្លាប់។ នាងមានអាយុ ៩ឆ្នាំនៅពេល ម្តាយរបស់នាងបានស្លាប់ចោល។

*តើចៅស្រីនេះមានបងប្អូនបង្កើតដែរឬទេ ?* មានចៅស្រី ២នាក់ និងចៅប្រុសម្នាក់ - ២នាក់រស់នៅមណ្ឌល ឈ្មោះ "មណ្ឌលនៃក្តីសង្ឃឹម" ហើយចៅស្រីម្នាក់ទៀតនៅជាមួយឪពុករបស់នាង។ ឪពុករបស់នាងធ្វើជា កម្មករសំណង់នៅភ្នំពេញ។

*តើអ្នកអាចប្រាប់ខ្ញុំអំពីសេចក្តីសម្រេចចិត្តយកចៅទៅរស់នៅក្នុងមណ្ឌលបានដែរឬទេ ? អ្នកណាជាអ្នកធ្វើសេចក្តីសម្រេចចិត្ត និងតើគេបានសម្រេចចិត្តដូចម្តេចខ្លះ ?* ចៅប្រុសរស់នៅជាមួយជីដូនខាងឪពុក មុន ពេលម្តាយវាស្លាប់។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាវាទៅនៅមណ្ឌលដែលវាកំពុងរស់នៅឥឡូវនេះទេ។ នេះគឺជាការសម្រេចចិត្តរបស់ឪពុករបស់វា ជីដូនរបស់វា ឬទាំង ២ហ្នឹង។ នៅពេលនោះឪពុកម្តាយវានៅ រស់ទាំង ២នាក់ហ្នឹង តែមិនមានលទ្ធភាពចិញ្ចឹមកូនបាន។

*តើម្តាយមានទស្សនៈបែបណាដែរ ?* នៅពេលដែលម្តាយវានៅរស់ ឪពុកវាមិនដែលមករំខានខ្ញុំនោះទេ។ ក្រោយម្តាយវាស្លាប់ ឪពុកវាផឹកស្រា ហើយខ្ញុំមិនអាចឃាត់វាបាន ដូច្នេះវាក៏យកកូនស្រីទៅ។ នៅពេលចៅស្រីមកលេងខ្ញុំឃើញវាទ្បើងស្គម!

*តើនាងរស់នៅជាមួយឪពុកបានយូរប៉ុណ្ណា ?* ប្រហែល ១០ថ្ងៃ។ តើឪពុកនាំនាងត្រឡប់មកវិញមែនទេ ? នាងមកដោយខ្លួនឯង។ ម្តាយធំរបស់វាបានហៅវាត្រឡប់មកវិញ។ វាមិនហ៊ានមកដោយខ្លួនឯង នោះទេពី ព្រោះវាខ្លាចម្តាយធំវាយធ្វើបាបវា។

*តើនាងមានបាននិយាយអំពីការសម្រេចចិត្តត្រឡប់មកវិញដែរឬទេ ?* វានិយាយថាវាមិនមានអាហារហូបគ្រប់គ្រាន់ ហើយថាឪពុករបស់វាស្រវឹងជានិច្ច។

*តើអាជ្ញាធរនៅក្នុងសហគមន៍របស់អ្នកមានបានចូលរួមដោះស្រាយករណីនេះក្នុងដំណាក់កាលណាមួយដែរឬទេ?* គ្មានអាជ្ញាធរមូលដ្ឋានណាមួយបានចូលរួមដោះស្រាយនោះទេ។ ខ្ញុំដោះស្រាយបញ្ហាទាំងនេះ ដោយខ្លួនខ្ញុំផ្ទាល់។ ឪពុកវាជាកូនប្រសាររបស់ខ្ញុំ។ ខ្ញុំសួរវា "ហេតុអ្វីឯងមកទីនេះមកយកកូនស្រីត្រឡប់ទៅវិញ ? ឯងជាមនុស្សប្រមឹកឯងមិនអាចមើលថែទាំវាបានទេ! វាចេះតែនិយាយ និយាយឥតឈប់ តែបើគ្មានអ្នកនិយាយតបតវិញ វាក៏ត្រឡប់ទៅផ្ទះវិញទៅ!"។

*តើគាត់ធ្លាប់បង្កគ្រោះថ្នាក់ដល់រាងកាយរបស់អ្នក ឬចៅរបស់អ្នកដែរឬទេ ?* វាគម្រាមថានឹងដុតផ្ទះ។ ឥឡូវនេះវាប្រើគ្រឿងញៀន។ វានិយាយថា "ប្រសិនបើខ្ញុំមិនប្រគល់កូនស្រីទៅឲ្យវា វានឹងដុតផ្ទះខ្ញុំចោល"។[57]

57 សម្ភាសជាក្រុម ការថែទាំដោយសាច់ញាតិ ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។

# ប្រវត្តិនៃការថែទាំ

# ៨

ជំពូកនេះ ពន្យល់សង្ខេបអំពីលក្ខណៈទូទៅនៃទម្រង់នៃការថែទាំជំនួសនីមួយៗដែលបានបញ្ចូលនៅក្នុងការសិក្សានេះ៖ ការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ផ្ទះស្នាក់នៅជាក្រុម ការថែទាំតាមវត្តអារាម និងការថែទាំតាមមណ្ឌល។ នៅក្រោម "ប្រវត្តិនៃការថែទាំ" នីមួយៗ មានការពិនិត្យមើលទិដ្ឋភាពដ៏ទូលំទូលាយនៃការថែទាំទាំង ៧ប្រភេទនេះ

ក. ប្រវត្តិរបស់កុមារ

ខ. ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

គ. ការត្រួតពិនិត្យតាមដាន

ឃ. ការធ្វើទំនាក់ទំនងទៅឪពុកម្តាយបង្កើត (រួមទាំងការពន្យល់អំពីការធ្វើសមាហរណកម្មផងប្រសិនបើមាន )

ង. លក្ខណៈនៃការថែទាំដែលបានផ្តល់ឲ្យ

ច. ការបណ្តុះបណ្តាល

ញ. ការចំណាយ និងការផ្តល់មូលនិធិ។

រចនាសម្ព័ន្ធដ៏ពិតប្រាកដនៃ "ប្រវត្តិនៃការថែទាំ" នីមួយៗ ត្រូវបានកែសម្រួលដើម្បីធានានូវភាពពាក់ព័ន្ធរបស់វាជាមួយប្រភេទនៃការថែទាំនីមួយៗ។ ឧទាហរណ៍ ចំពោះ "ប្រវត្តិនៃការថែទាំ" ដោយសាច់ញាតិ និងដោយ គ្រួសារធម៌ វាពុំមានភាពសមស្របឡើយប្រសិនបើយើងប្រើពាក្យថា "ការគ្រប់គ្រង"។





©UNICEFCambodia2016/Patricia Chourio



# ការថែទាំដោយសាច់ញាតិ

**លទ្ធផលសំខាន់ៗ៖ ការថែទាំដោយសាច់ញាតិ**

១. ការថែទាំដោយសាច់ញាតិ បានក្លាយជាទម្លាប់មួយនៅក្នុងសហគមន៍ខ្មែរនៅពេលដែល ឪពុកម្តាយ របស់កុមារមិនអាចផ្តល់ការថែទាំបាន។

២. បច្ចុប្បន្ន ភាគច្រើននៃការថែទាំដោយសាច់ញាតិត្រូវបានរៀបចំដោយមិនផ្លូវការ។ ប្រសិនបើមាន អ្នកពីខាងក្រៅចូលរួមសម្របសម្រួលការទុកដាក់កុមារនៅក្នុងការថែទាំដោយសាច់ញាតិ អ្នកទី ៣នោះភាគច្រើនគឺជាអង្គការមិនមែនរដ្ឋាភិបាល។

៣. ក្នុងករណីភាគច្រើន ប្រសិនបើមានអ្នកពីខាងក្រៅចូលរួមនៅក្នុងការទុកដាក់កុមារក្នុងការថែទាំ ដោយញាតិ គេតែងខ្វះខាតការប៉ាន់ប្រមាណប្រកបដោយវិជ្ជាជីវៈទៅលើសមត្ថភាពរបស់ សាច់ញាតិដែលផ្តល់ការថែទាំដល់កុមារ។

៤. សូម្បីនៅក្នុងគ្រួសារ ដែលមានអង្គការមិនមែនរដ្ឋាភិបាលចូលរួមទុកដាក់កុមារនៅក្នុងការ ថែទាំ ដោយសាច់ញាតិក៏ដោយក៏តាមសេចក្តីរាយការណ៍បានឱ្យដឹងថា កម្រមានការចុះទៅ ពិនិត្យមើល ជាទៀងទាត់ពីសំណាក់បុគ្គលិកសង្គមកិច្ចណាស់ តែអាចមានករណីលើកលែងខ្លះ ដែលបុគ្គលិក សង្គមកិច្ចបានចុះត្រួតពិនិត្យ។

៥. គ្រួសារសាច់ញាតិ ដែលបានបញ្ចូលនៅក្នុងការសិក្សានេះបានទទួលការគាំទ្រផ្នែកសម្ភារៈ មួយចំនួន តែមិនបានទទួលប្រាក់ជាទៀងទាត់សម្រាប់ចំណាយលើកុមារនោះឡើយ។

៦. មានតែសាច់ញាតិដែលផ្តល់ការថែទាំប្រមាណ ២០%ប៉ុណ្ណោះ ដែលបានរាយការណ៍ថា បានទទួលការបណ្តុះបណ្តាលអំពីការថែទាំកុមារដោយសាច់ញាតិ។

៧. រាល់កត្តាទាំងអស់នេះ បានរួមចំណែកដល់លទ្ធភាពនៃការទុកដាក់កុមារដែលបាក់បែក គ្រួសារ និងកុមារដែលបានបោះបង់ការសិក្សា។

## ប្រវត្តិរបស់កុមារ

យើងមិនមានទិន្នន័យជាតំណាងថ្នាក់ជាតិដ៏រឹងមាំអំពីចំនួនកុមារ ដែលរស់នៅក្រោមការថែទាំដោយញាតិក្នុងប្រទេសកម្ពុជានោះទេ។ ទោះដូច្នេះក៏ដោយ ភស្តុតាងមិនផ្លូវការមួយចំនួនដែលអ្នកផ្តល់ចម្លើយបានផ្តល់ឲ្យ បានបង្ហាញថា នៅក្នុងប្រទេសកម្ពុជាមានប្រពៃណីយូរលង់មកហើយក្នុងការថែទាំកុមារដោយសាច់ញាតិនេះ ដែលនេះគឺជាទម្រង់ដ៏ធំនៃការថែទាំជំនួសដែលបានអនុវត្តនៅក្នុងសហគមន៍។ បណ្តាញគ្រួសារសាខាញាតិ ជាបណ្តាញដ៏រឹងមាំ និងសំខាន់នៅក្នុងវប្បធម៌នៃប្រទេសកម្ពុជា ហើយវាជាប្រពៃណីដែលគ្រួសារសាខាញាតិជួយមើលថែរក្សាក្មួយប្រុស ក្មួយស្រីរបស់ពួកគេ។ ឧទាហរណ៍បុគ្គលិក សង្គមកិច្ចនៃមន្ទីរសង្គមកិច្ចមកពីស្រុកគាស់ក្រឡក្នុងខេត្តបាត់ដំបង បានលើកឡើងថា ការថែទាំដោយសាច់ញាតិត្រូវបានប្រើប្រាស់ញឹកញាប់បំផុតជាការថែទាំជំនួសនៅក្នុងស្រុករបស់គាត់។

*ភាគច្រើននៃការថែទាំជំនួសនៅក្នុងស្រុករបស់ខ្ញុំ គឺការថែទាំដោយសាច់ញាតិ។ កូនរបស់ឪពុកម្តាយដែលបានចែកផ្លូវគ្នា ក្មេងដែលកំព្រាឪពុកម្តាយ ឬកំព្រាតែឪពុក ឬកំព្រាតែម្តាយ កូនដែលមានឪពុកម្តាយធ្វើចំណាកស្រុក ក្មេងកំព្រាមានផ្ទុកមេរោគ អេដស៍/ជំងឺអេដស៍ ក្មេងកំព្រាដោយសារសង្គ្រាម អ្នកទាំងអស់នេះចុងក្រោយ ត្រូវបានសាច់ញាតិរើសយកទៅចិញ្ចឹមបីបាច់! នៅក្នុងស្រុករបស់ខ្ញុំមិន មានមណ្ឌលកុមារកំព្រានោះទេ ហើយក៏មិនមានគ្រួសារធម៌ណាមួយដែលខ្ញុំបានស្គាល់ដែរ។*[58]

វាជាទម្លាប់សម្រាប់ឪពុកម្តាយនៅក្នុងប្រទេសកម្ពុជា ដែលត្រូវមានការព្រមព្រៀងជា លក្ខណៈ ឯកជន និងមិនផ្លូវការជាមួយសមាជិកគ្រួសាររបស់ពួកគេដើម្បីយកក្មេងមកចិញ្ចឹម ជាពិសេសក្នុងរយៈពេលខ្លី។ ក្នុងករណីភាគច្រើន មិនមានបញ្ហាពាក់ព័ន្ធជាមួយកិច្ចការពារកុមារនោះទេ ហើយក៏មិនមានហេតុផលដែលរដ្ឋត្រូវធ្វើអន្តរាគមន៍ ឬចូលរួមពាក់ព័ន្ធនៅក្នុងរឿងនេះផងដែរ។ សាច់ញាតិគ្រាន់តែមកយកកុមារទៅរស់នៅជាមួយពួកគេ ដើម្បីដកហូតកុមារនោះចេញពីស្ថាន ភាពរំលោភបំពានការមិនអើពើ ឬការប្រើអំពើហិង្សា។ ប្រសិនបើសាច់ញាតិអាចការពារកុមារដោយសមស្រប វាមិនទំនងថារដ្ឋអំណាចនឹងត្រូវបានទាក់ទងឱ្យផ្តល់អន្តរាគមន៍ឡើយ។

## ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

នៅក្នុងករណីថែទាំដោយសាច់ញាតិចំនួន ៨ករណី ដែលបានបញ្ចូលនៅក្នុងការសិក្សានេះ សុទ្ធតែមានការជាប់ពាក់ព័ន្ធពីការជួយពីខាងក្រៅ គឺមានខាងអង្គការមិនមែនរដ្ឋាភិបាល ឬពីរដ្ឋ ឬ ទាំង ២ ក្នុងទម្រង់ជាការជួយទុកដាក់កុមារ ឬ គ្រាន់តែផ្តល់ការគាំទ្របន្ទាប់ពីមានការទុកដាក់មិនផ្លូវការរួចមក។ កុមារខ្លះត្រូវបានទុកដាក់ដោយគ្រួសាររបស់ពួកគេ ដោយមានការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ក្រោយការទុកដាក់កុមារ ហើយខ្លះទៀតត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងការថែទាំដោយសាច់ញាតិ បន្ទាប់ពីបានបញ្ជូនទៅរស់នៅក្នុងមណ្ឌលថែទាំកុមារ។

58 សម្ភាសបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។

*តើអ្នកចូលរួមយ៉ាងដូចម្ដេចខ្លះនៅក្នុងការផ្ដល់ការថែទាំដោយសាច់ញាតិ?*

*ខ្ញុំបានមើលថែទាំក្មេងនេះ តាំងពីម្ដាយវានៅរស់ម្ល៉េះ។ ម្ដាយរបស់វាមានជម្ងឺរបេងហើយបានស្លាប់កាលពី ៥ឆ្នាំមុន។ ក្មេងប្រុសនេះបានរស់នៅក្នុងមណ្ឌលកុមារកំព្រាប្រហែល ៣ឆ្នាំ មុនវាមករស់នៅជាមួយពួកយើង។ វាបានសុំមករស់នៅជាមួយពួកយើង។ ខ្ញុំបានសម្រេចចិត្តយកវាពីព្រោះវាជាក្មួយប្រុសរបស់ខ្ញុំ ហើយវាមិនមានអ្នកណាផ្សេងដែលវាអាចពឹងពាក់បាននោះទេ។*[59]

តាមរយៈការសម្ភាស បានបង្ហាញយ៉ាងច្បាស់ថានៅពេលដែលកុមារត្រូវបានទុកដាក់នៅក្នុងការថែទាំដោយសាច់ញាតិ ដោយអង្គការមិនមែនរដ្ឋាភិបាល ដោយមន្ទីរ ស.អ.យ ឬ ដោយ គកនក នេះមិនមានន័យ ថាគ្រួសារ សាច់ញាតិដែលពាក់ព័ន្ធក្នុងរឿងនេះ ត្រូវបានធ្វើការប៉ាន់ប្រមាណជាមុនអំពីការទុកដាក់កុមារ អំពីភាព សមស្របនៃការទុកដាក់ ឬធ្វើផែនការនៃការទុកដាក់លម្អិត ដូចដែលបានតម្រូវនៅក្រោមជំពូក ២នៃប្រកាសស្ដីពីបទដ្ឋានអប្បបរមានៃការថែទាំជំនួសតាមសហគមន៍ឆ្នាំ ២០០៨ នោះទេ។ ប៉ុន្តែវាមានភស្តុតាងបង្ហាញថាមានការធ្វើការប៉ាន់ប្រមាណប្រកបដោយវិជ្ជាជីវៈ នៅក្នុងករណីតែ ១ គត់នៃករណីទាំង ៨។ សាច់ញាតិម្នាក់ដែលបានផ្ដល់ការថែទាំដល់ក្មួយប្រុសរបស់គាត់ នៅក្នុងតំបន់ជនបទនៃខេត្តបាត់ដំបងបានប្រាប់ឲ្យដឹងថា៖

*អត់ទេ! គ្មានអ្នកណាម្នាក់ចុះមកពិនិត្យទ្រព្យសម្បត្តិ ឬចុះមកសាកសួរខ្ញុំនោះទេ មុនពេលដែលក្មេងប្រុសម្នាក់នេះមករស់នៅទីនេះឡើយ។ គ្មាននរណាម្នាក់បានមកពិភាក្សាជាមួយខ្ញុំ ពីមុនមកនោះទេ។ បងប្រុសច្បងរបស់វាដែលឥឡូវនេះកំពុងនៅប្រទេសថៃ គឺជាអ្នករៀបចំទុកដាក់វាឱ្យរស់នៅជាមួយមណ្ឌលអង្គការ។*[60]

ជីដូនជីតាមួយគូទៀតដែលយកចៅមកចិញ្ចឹមដែរនោះ បាននិយាយថា បុគ្គលិកសង្គមកិច្ចរបស់ CWCC បានចុះមកជួបពួកគាត់ មុនគេយកក្មេងនោះមករស់នៅជាមួយពួកគាត់។ ជីដូនជីតាទាំង ២នាក់សុទ្ធតែចាស់ ហើយជីដូនពិការ និងមិនអាចដើរបាន។ ពួកគាត់ទាំង ២មិនមានប្រាក់ចំណូល ហើយបានពឹងផ្អែកលើការជួយគាំទ្រពីកូនប្រុសរបស់ពួកគាត់។ នៅពេលដែលសួរទៅកាន់ជីដូន ថាតើគាត់បានប្រាប់ទៅបុគ្គលិកសង្គមកិច្ចថាពួកគាត់មិនអាចមើលថែទាំក្មេងប្រុសអាយុ ១៥ឆ្នាំនេះបានទេ គាត់ឆ្លើយថាគាត់មិនហ៊ានប្រាប់បុគ្គលិកសង្គមកិច្ចបែបនោះទេ តែគាត់បាននិយាយថា គាត់មាន ការលំបាកដោយសារគាត់គ្មានប្រាក់ចំណូល។ មន្ត្រីសង្គមកិច្ចបានឆ្លើយថា៖ *"ពួកគេគ្មានអ្វីសម្រាប់ជួយគាំទ្រកុមារនោះទេ មានតែគ្រួសារនេះហើយដែលត្រូវរកវិធីដោយខ្លួនឯង"* ។

ស្ទើរតែគ្រប់កុមារទាំងអស់ ដែលបានទុកដាក់នៅក្នុងការថែទាំដោយសាច់ញាតិបានទទួលរងការបាត់បង់ យ៉ាងច្រើននៅក្នុងជីវិតរបស់ពួកគេ ដោយសារការទុកដាក់កុមារមិនបានត្រឹមត្រូវតាំងពីកុមារភាព និងមានការផ្លាស់ប្ដូរកន្លែងស្នាក់នៅច្រើនពេក។ តម្រូវការឱ្យមានការជួយគាំទ្រផ្នែកផ្លូវចិត្តសម្រាប់ពួកគេដើម្បីដោះស្រាយបញ្ហាកំហឹង ទុក្ខសោក និងដើម្បីបន្សាំទៅជីវិតថ្មី និងកាលៈទេសៈថ្មីវាតម្រូវឲ្យមានការយល់ដឹងអំពីផលប៉ះពាល់នៃ ព្រឹត្តិការណ៍ទាំងនេះទៅលើកុមារ និងឆន្ទៈក្នុងការផ្ដល់កិច្ចគាំទ្រដែលកុមារត្រូវការ។ មិនមានភស្តុតាង ថាមានការផ្ដល់ប្រឹក្សាសម្រាប់កុមារ ឬ មានបុគ្គលិកសង្គមកិច្ចបានចុះមកជួបគ្រួសារដើម្បីជួយឱ្យកុមារអាចរស់នៅជាមួយសាច់ញាតិរបស់ពួកគេឡើយ។

59 សម្ភាសអ្នកថែទាំដោយសាច់ញាតិ ខេត្តបាត់ដំបង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។
60 សម្ភាសអ្នកថែទាំដោយសាច់ញាតិ ខេត្តបាត់ដំបង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។

សាច់ញាតិដែលបានផ្តល់ការថែទាំ និង កុមារដែលបានសម្ភាសសម្រាប់ការសិក្សានេះ ទាំងអស់គ្នាបានចាត់ទុកការទុកដាក់កុមារនេះថាមាន «លក្ខណៈអចិន្ត្រៃយ៍» មិនមែនជាវិធានការរយៈពេលខ្លី ឬ បណ្តោះអាសន្ននោះទេ ហើយកុមារភាគច្រើនមានការរីករាយដោយបានមករស់នៅជា មួយសាច់ញាតិដែល ជាគ្រួសាររបស់ពួកគេ ទោះបីជាគ្រួសារសាច់ញាតិខ្លះមើលឃើញថាក្នុងដំណាក់កាលអន្តរកាលនេះ ការថែទាំបែបនេះវាមានការលំបាកពីដំបូងក៏ដោយ។ មានការបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីគ្រួសារទាំង ៨ ថាទោះបីជាក្មេងខ្លះមានឪពុកម្តាយនៅរស់ក៏ដោយ ដោយហេតុផលផ្សេងៗ និង/ឬ ដើម្បីឧត្តមប្រយោជន៍របស់កុមារគេមិនអាចធ្វើសមាហរណកម្មកុមារមករស់នៅជាមួយពួកគេដែលជាសាច់ញាតិបានឡើយ។

## កុមារមានសេចក្តីត្រូវការពិសេស

ក្នុងចំណោមសាច់ញាតិដែលបានមើលថែទាំកុមារទាំង ៨ ដែលបានបញ្ចូលនៅក្នុងការសិក្សានេះ មានម្នាក់បានរាយការណ៍ថា គាត់បានចិញ្ចឹមកុមារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ម្នាក់ និងមានសាច់ញាតិម្នាក់ទៀតនិយាយថាបានចិញ្ចឹមកុមារពិការម្នាក់។ ភស្តុតាងដែលប្រមូលបានពីការប្រាស្រ័យទាក់ទង បែបគុណវិស័យបានឲ្យដឹងថា គ្រួសារសាច់ញាតិអាចត្រូវការការជួយគាំទ្រជាពិសេសដើម្បីឱ្យពួកគាត់អាចផ្តល់ការថែទាំគ្រប់ជ្រុងជ្រោយដល់កុមារដែលមានសេចក្តីត្រូវការពិសេស។ នេះគឺដោយសារគ្រួសារសាច់ ញាតិភាគច្រើនមានធនធានហិរញ្ញវត្ថុមានកម្រិត និងខ្វះការបណ្តុះបណ្តាលឯកទេសក្នុងការមើល ថែទាំកុមារដែលមានសេចក្តីត្រូវការពិសេស។ ករណីសិក្សាខាងក្រោមអំពីគ្រួសារសាច់ញាតិនៅក្នុងតំបន់ជនបទនៃខេត្តសៀមរាប បានបញ្ជាក់ យ៉ាងច្បាស់អំពីចំណុចខាងលើនេះ។

### ករណីសិក្សា៖ គ្រួសារសាច់ញាតិនៅតំបន់ជនបទនៃខេត្តសៀមរាប

កុមារកំព្រា ៣នាក់ (ក្មេងស្រី ២នាក់ និងក្មេងប្រុសពិការម្នាក់) និងបងស្រីរបស់ពួកគេរស់នៅជាមួយម្តាយមីងនៅក្បែរក្រុងសៀមរាប។ ម្តាយមីងមិនមានសុខភាពល្អ ហើយមិនអាចជួយបានច្រើននោះទេ។ បងស្រី (អាយុ ២១ឆ្នាំ) គឺជាមេគ្រួសារចម្បងនៃគ្រួសារនេះ។ កន្លែងរស់នៅរបស់ពួកគេមានសភាពមិនល្អខ្លាំងណាស់។

ក្មេងប្រុសដែលពិការសតិបញ្ញា និងរាងកាយមានកៅអីកង់រទេះមួយធ្វើអំពីឈើ។ នៅពេលថ្ងៃមិនមានអ្នកនៅមើលថែទាំគាត់នោះទេ។ នៅពេលព្រឹក មុនបងស្រីចាកចេញទៅធ្វើការ គេបីគាត់ដាក់នៅលើគ្រែនៅក្រោមផ្ទះ។ នៅទីនោះគាត់ត្រូវរង់ចាំរហូតដល់ព្រលប់ ដោយមិនអាចទៅបន្ទប់ទឹកបាន។ នៅពេលបងស្រីមកពីធ្វើការវិញនៅពេលល្ងាច ទើបនាងងូតទឹកសម្អាតខ្លួនឲ្យគាត់។

សម្រង់ខាងក្រោមនេះចេញពីការសម្ភាសជាមួយបងស្រីអាយុ ២១ឆ្នាំរបស់វា បង្ហាញពីកង្វះសមត្ថភាពរបស់គ្រួសារសាច់ញាតិនេះក្នុងការផ្តល់នូវការថែទាំដ៏ពេញលេញដល់កុមារពិការ៖

*តើអ្នកផ្តល់នូវការគាំទ្រដល់ប្អូនរបស់អ្នកដូចម្តេចខ្លះ?*
ជាទូទៅ ខ្ញុំមានប្រាក់ប្រហែល ១៦០ដុល្លាអាមេរិកដើម្បីចំណាយក្នុង ១ខែទៅការថែទាំប្អូនៗរបស់ខ្ញុំ។

*តើក្មេងៗទាំងអស់បានទៅរៀនដែរឬទេ ?*

អត់ទេ! ប្អូនប្រុសពិការមិនបានទៅរៀនទេ... ហើយអាមួយតូចជាងគេ (១២ឆ្នាំ) បានឈប់រៀនបន្ទាប់ពីបានត្រួតថ្នាក់នៅថ្នាក់ទី ១ចំនួន ៤ឆ្នាំជាប់ៗគ្នា។ ប្អូនកណ្តាល (អាយុ ១៧ឆ្នាំ) នៅរៀននៅឡើយ។ ខ្ញុំវិញបានឈប់រៀននៅពេលខ្ញុំរៀនបានថ្នាក់ទី ៦ នៅពេលដែលឪពុករបស់ពួកយើងបានស្លាប់។

*ហេតុអ្វីបានជាអ្នកត្រូវមានការទទួលខុសត្រូវជួយដល់ប្អូនៗរបស់អ្នក ?*

ខ្ញុំត្រូវរកប្រាក់ដើម្បីជួយប្អូនៗរបស់ខ្ញុំ ពីព្រោះបងប្រុសៗរបស់ខ្ញុំមិនជួយពួកគេនោះទេ។ បងប្រុសៗរបស់ខ្ញុំគាត់មានគ្រួសាររបស់គាត់។ បងប្រុសខ្ញុំម្នាក់ជាកម្មករចំណាកស្រុកទៅប្រទេសថៃ។ គាត់មិនខ្វល់ខ្វាយរឿងផ្ញើប្រាក់មកជួយពួកយើងឡើយ។ ម្តាយមីងខ្ញុំមានជម្ងឺឈឺសន្លាក់ ដូច្នេះគាត់ ធ្វើការងារមិនកើតនោះទេ។

## ការពិនិត្យតាមដាន

អ្នកផ្តល់ការថែទាំដោយសាច់ញាតិ ចំនួន៣នាក់ ក្នុងចំណោម ៨នាក់ ដែលបានបញ្ចូលក្នុងការសិក្សានេះបានប្រាប់ឲ្យដឹងថា «មិនដែល» មានមន្ត្រីពីខាងក្រៅ (មកពីមន្ទីរ ស.អ.យ គកនក និងអង្គការមិនមែនរដ្ឋាភិបាល) ចុះមកសួរសុខទុក្ខ ដើម្បីពិនិត្យតាមដាននោះទេ។ តាមរយៈសំណាកដ៏តិចតួចរបស់យើងបង្ហាញថា ការទុកដាក់កុមារនៅក្នុងគ្រួសារសាច់ញាតិដោយគ្មានការ ចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលអាចនឹងមិនត្រូវបានត្រួតពិនិត្យតាមដាន។ សូម្បី តែមានអង្គការមិន មែនរដ្ឋាភិបាល ចុះត្រួតពិនិត្យតាមដានការទុកដាក់នេះក៏ដោយ ក៏វាហាក់ដូចជាការធ្វើបែបចំពោះកិច្ច ដោយវាអាស្រ័យលើធនធានរបស់អង្គការនោះក្នុងការចុះទៅពិនិត្យតាមដានបែបនេះ។ តំណាងមន្ទីរ ស.អ.យ និង គកនក ទំនងដូចជាកម្រចូលរួមនៅក្នុងការពិនិត្យតាមដានកុមារដែលរស់នៅក្នុងការថែទាំ ដោយសាច់ញាតិណាស់។ តួនាទីពីខាងក្រៅរបស់រដ្ឋាភិបាលនៅក្នុងរយៈពេលតាមដាន និងការប្រឈមនានា ត្រូវបានបង្ហើបឲ្យដឹងដោយអ្នកផ្តល់ព័ត៌មានដ៏សំខាន់ម្នាក់នៅក្នុងខេត្តសៀមរាប៖

*តើអ្នកធ្វើការជាមួយរដ្ឋាភិបាលយ៉ាងដូចម្តេចខ្លះ នៅពេលអ្នកធ្វើសមាហរណកម្មកុមារ ? តើរដ្ឋាភិបាល បានចូលរួមអ្វីខ្លះនៅក្នុងការចុះទៅធ្វើការប៉ាន់ប្រមាណមុនការទុកដាក់កុមារ និងធ្វើការប៉ាន់ប្រមាណក្រោយទុកដាក់កុមារ ?*

*ភាគច្រើន យើងជម្រុញឱ្យពួកគេចូលរួមនៅក្នុងការប៉ាន់ប្រមាណមុនទុកដាក់កុមារ។ ការទៅជម្រុញឱ្យពួកគេចូលរួមមានការពិបាក អាស្រ័យដោយយើងត្រូវចេញសោហ៊ុយ ចំណាយទាំង អស់ ហើយវាពិបាកបញ្ជាក់អំពីការចំណាយទាំងនេះជាមួយម្ចាស់ជំនួយ។ ឥឡូវនេះជាមួយបុគ្គលិកសង្គមកិច្ចនៃមន្ទីរ ស.អ.យ វាបានប្រសើរបន្តិចហើយ។ កាលពី ២ ឬ ៣ឆ្នាំមុន គ្មានអ្នកណាដឹងពីរបៀបបំពេញទម្រង់នោះទេ ដូច្នេះយើងជាអ្នកបំពេញ ហើយឲ្យរដ្ឋាភិបាលជាអ្នកចុះហត្ថលេខា។ ចំពោះ គកនក មិនមានការរីកចម្រើននោះទេ ពួកគេមិនយល់ អំពីតួនាទីរបស់ពួកគេ ពួកគេមិនដែលចុះត្រួតពិនិត្យ។ ចំពោះក្រោយការទុកដាក់កុមារវិញ គឺពុំមានតួនាទីរបស់ពួកគេឡើយ។*[61]

61 សម្ភាសតាម Skype ទីក្រុងឡុងដ៍ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។

ប្រសិនបើតំណាងមន្ទីរ ស.អ.យ ឬ គកនក មានការចូលរួមនៅក្នុងការប៉ាន់ប្រមាណ និងតាមដានចំពោះគ្រួសារសាច់ញាតិមែននោះ ការធ្វើបានបែបនេះដោយសារមានការផ្តួចផ្តើមគំនិត ពីអង្គការមិនមែនរដ្ឋាភិបាល។ ទោះដូច្នេះក៏ដោយ ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាល បានធ្វើការទុកដាក់កុមារមែននោះ មន្ទីរ ស.អ.យ ទំនងជាទុកឲ្យអង្គការនោះធ្វើការតាមដានដោយខ្លួនពួកគេ និងសូម្បីអង្គការមិនមែនរដ្ឋាភិបាលនោះអស់មូលនិធិ និង មិនអាចធ្វើការពិនិត្យតាមដានក៏ដោយ ក៏មិនមានភស្តុតាងបញ្ជាក់ថា មន្ទីរ ស.អ.យ ឬ គកនក មានការទទួលខុសត្រូវធ្វើការពិនិត្យតាមដាននោះដែរ។ នេះហាក់ដូចជាមានន័យថា ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលមួយទទួលខុសត្រូវសម្រាប់ករណីមួយ អង្គការនោះត្រូវនៅទទួលខុសត្រូវចំពោះកុមារជាបន្តទៀតនៅក្នុងអំឡុងពេលកុមារភាពមិនមែនរដ្ឋនោះទេ។

*តំណាងមន្ទីរ ស.អ.យ ម្នាក់នៅខេត្តបាត់ដំបងបានធ្វើការកត់សម្គាល់ដូច្នេះថាៈ*

*ពេលខ្លះ យើងបានចុះទៅមើលគ្រួសារដែលបានបង្រួបបង្រួម ដែលយើងបានស្គាល់ក្នុង លក្ខណៈមិនផ្លូវការ ប្រហែល ២ដងក្នុង១ឆ្នាំ។ ក៏ប៉ុន្តែទាល់តែយើងមានការអញ្ជើញពីអង្គការមិនមែនរដ្ឋាភិបាល ដែលបានធ្វើការ ទុកដាក់កុមារ។ យើងមិនចង់រំខាននូវអ្វីដែលអង្គការកំពុងធ្វើនោះទេ។*[62]

មានករណីខ្លះ នៅពេលដែលមានការចុះពិនិត្យតាមដាន គេហាក់ដូចជាផ្តោតជាសំខាន់តែលើបញ្ហាសុខភាព ហើយវាមានភស្តុតាងតិចតួចដែលបង្ហាញថាបុគ្គលិកសង្គមកិច្ចបានចុះទៅបង្កើតទំនាក់ទំនងជាមួយកុមារ ឬទៅពិភាក្សាជាមួយកុមារ។ កង្វះការគាំទ្រក្រោយការទុកដាក់កុមារ ហាក់បីដូចជាទុកកុមារនិងអ្នកថែទាំកុមារចោលដោយមិនមានជំនួយគាំទ្រអ្វីទាំងអស់ ជាពិសេសនៅក្នុង ពេលលំបាកដែលចំនុចនេះ អាចបង្កហានិភ័យខ្ពស់នៃការបែកបាក់ទៅវិញចំពោះការទុកដាក់នេះ ។

នៅពេលដែលការទុកដាក់កុមារធ្វើឡើងក្នុងលក្ខណៈមិនផ្លូវការ វាទំនងថាអ្វីៗទាំងអស់ត្រូវទុកជាភារៈរបស់គ្រួសារសាច់ញាតិជាអ្នកសម្រេចថាតើ ត្រូវចុះឈ្មោះអ្នកចំណូលថ្មីជាមួយអាជ្ញាធរមូលដ្ឋានឬយ៉ាងណា។

*តើអ្នកបានចូលរួមដូចម្តេចខ្លះក្នុងការផ្តល់ការថែទាំដោយសាច់ញាតិ ?*

*ម្តាយរបស់ក្មួយស្រីរបស់ខ្ញុំរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ ក្មួយស្រីខ្ញុំរស់នៅជាមួយជីដូនវា តែជីដូនបានស្លាប់ទៅហើយ។ បន្ទាប់មកខ្ញុំបានប្រាប់ឪពុកវាឲ្យទៅយកវាពីជនបទមក នេះគឺជា គំនិតរបស់ខ្ញុំ។*

*តើអ្នកមានជម្រាបដល់អាជ្ញាធរមូលដ្ឋានដែរឬទេ ?*

*ខ្ញុំមិនដឹងច្បាស់ថាតើឪពុកវាបានធ្វើអ្វីខ្លះនោះទេនៅទីនោះ [នៅជនបទ] – នៅទីនេះ ខ្ញុំចុះឈ្មោះវានៅក្នុងសៀវភៅស្នាក់នៅ។ នៅក្នុងសៀវភៅនោះមានឈ្មោះខ្ញុំ ប្រពន្ធខ្ញុំ និងក្មួយស្រីខ្ញុំ។*[63]

## ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត

ក្នុងករណីជាច្រើន កុមារដែលរស់នៅជាមួយសាច់ញាតិ អាចនៅមានឪពុក ឬម្តាយ ឬ ទាំងឪពុក និងម្តាយបង្កើត តែដោយសារពួកគេបានធ្វើចំណាកស្រុក ឬរៀបការជាថ្មី និង/ឬបោះបង់ពួកគេចោល។ មានភស្តុតាងតិចតួចបង្ហាញថាកុមារដែលគ្រួសារសាច់ញាតិទាំង៨ យកទៅចិញ្ចឹម បានធ្វើការទាក់ទង

62 សម្ភាសតំណាងមន្ទីរ សអយ ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
63 សម្ភាសអ្នកថែទាំដោយសាច់ញាតិ ខេត្តកណ្តាល ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។

ជាមួយឪពុកម្ដាយរបស់ពួកគេ។ មិនមានភស្តុតាងបញ្ជាក់ថា មន្ទីរ ស.អ.យ គកនក ឬ អង្គការមិនមែនរដ្ឋាភិបាលដែលបានធ្វើការទុកដាក់កុមារ បានមើលឃើញថាជាតួនាទីរបស់ពួកគេ ក្នុងការ ជួយកុមារឲ្យរក្សាទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើតរបស់ពួកគេ ឬ ក៏ធ្វើការរារាំងការធ្វើទំនាក់ទំនង ដែលអាចបង្កហានិភ័យដល់កុមារឡើយ។ ទិន្នន័យបែបគុណភាពដែលយើងប្រមូលបាន បង្ហាញថា កុមារកម្រពាក់ព័ន្ធនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តណាស់ ហើយពួកគេក៏គ្មានសិទ្ធិអំណាច ដើម្បីកំណត់ថាអាចទាក់ទងទៅឪពុកម្ដាយបង្កើតឬ ទាក់ទងបាននៅពេលណាដែរ។

## លក្ខណៈនៃការថែទាំដែលបានផ្ដល់ជូន

គុណភាព និងលក្ខណៈនៃការថែទាំដែលបានផ្ដល់ដល់កុមារនៅក្នុងគ្រួសារសាច់ញាតិ មិនដូចគ្នានោះទេ។ ជាទូទៅ គុណភាព និងលក្ខណៈនៃការថែទាំនេះ អាស្រ័យលើស្ថានភាព សេដ្ឋកិច្ចសង្គមរបស់គ្រួសារនោះ និងលទ្ធភាពដែលអាចជួយគាំទ្រដែលគ្រួសារទទួល ពីអង្គការមិន មែនរដ្ឋាភិបាល។

*លក្ខខណ្ឌសម្ភារៈ៖*

ទិន្នន័យបែបបរិមាណដែលទទួលបានពីបញ្ជីផ្ទៀងផ្ទាត់តាមរយៈការសង្កេតបង្ហាញថា គ្រួសារសាច់ញាតិជាញឹកញាប់ រស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ និង មិនមានសម្ភារៈអ្វីទាំងអស់។ ឧទាហរណ៍ គ្រួសារចំនួន ៧ ក្នុងចំណោមគ្រួសារសាច់ញាតិទាំង ៨ ដែលយើងបានជួបសម្រាប់ការសិក្សានេះ មិនមានសូម្បីតែ ប្រព័ន្ធលូបង្ហូរទឹកមួយដែលមានដំណើរការ។ កុមារ ៤នាក់ មិនមានកន្ទេល ឬ ពូកសម្រាប់គេង និង មានកុមារ ៣នាក់ មិនមានបង្គន់មួយដែលមានដំណើរការសម្រាប់ប្រើប្រាស់។

*ការទទួលបានការអប់រំ ៖*

កុមារនៅក្នុងគ្រួសារសាច់ញាតិបានទៅរៀនទាំងអស់គ្នានៅសាលាបឋមសិក្សា ឬនៅមធ្យមសិក្សា។ បើទោះជាដូច្នេះក្ដី នៅក្នុងគ្រួសារមួយដែលអ្នកស្រាវជ្រាវរបស់យើងបានជួប មានកុមារម្នាក់ត្រូវទៅធ្វើការដើម្បីបានប្រាក់បង់ថ្លៃសាលារៀន ដោយសារសាច់ញាតិជាអ្នកថែទាំនោះមិនអាចរ៉ាប់រងការចំណាយទៅលើការរៀនសូត្ររបស់កុមារនោះបាន។[64] អង្គការមិនមែនរដ្ឋាភិបាលដែលបានធ្វើសមាហរណកម្មកុមារនោះ មិនបានផ្ដល់ដល់គ្រួសារសាច់ញាតិនោះនូវមូលនិធិ ដើម្បីអាចឲ្យកុមារបន្តការរៀនសូត្ររបស់គេតទៅទៀតនោះទេ។

ដោយសារអ្នកស្រាវជ្រាវ បានជួបតែគ្រួសារសាច់ញាតិនៅតំបន់ប្រជុំជន វាពិបាកក្នុងការនិយាយថាកុមារនៅក្នុងគ្រួសារសាច់ញាតិ ដែលរស់នៅទីជនបទអាចមានលទ្ធភាពទៅរៀនក្នុងកម្រិតសិក្សាដូចគ្នាដូចកុមារនៅទីប្រជុំជនណាស់។ ភស្តុតាងពីការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗបានបង្ហាញថា កុមារនៅក្នុងគ្រួសារសាច់ញាតិនៅក្នុងទីជនបទ មានការលំបាកក្នុងការទទួលបានការសិក្សារៀនសូត្រ ដោយសារតែមានបន្ទុកហិរញ្ញវត្ថុបន្ថែម (បង់ថ្លៃសាលាមិនផ្លូវការ ចំណាយលើការធ្វើដំណើរ ។ល។) ដែលចំនុចនេះរារាំង និងកាត់បន្ថយឱកាសសម្រាប់អ្នកថែទាំ និងកុមារក្នុងការរកប្រាក់។

64 សម្ភាសអ្នកថែទាំដោយសាច់ញាតិ រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦។

*ការទទួលបានការថែទាំសុខភាព៖*

ក្រៅពីលទ្ធភាពទទួលបានការសិក្សារៀនសូត្រ ការទទួលបានការថែទាំសុខភាពរបស់កុមារ អាស្រ័យយ៉ាងខ្លាំងទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ គ្រួសារសាច់ញាតិនោះ។ ខណៈពេលដែលគ្រួសារខ្លះដែលអ្នកស្រាវជ្រាវបានជួបមិនអាចមានលទ្ធភាពបញ្ជូនកូនរបស់ខ្លួនទៅរកពេទ្យឯកជន គ្រួសារដទៃទៀតត្រូវពឹងលើប្រព័ន្ធថែទាំសុខភាពសាធារណៈ។ ក្នុងករណីខ្លះ អ្នកផ្ដល់ការថែទាំកុមារបានបង្ហាញថា អង្គការមិនមែនរដ្ឋាភិបាលដែល «ទុកដាក់» កុមារនៅក្នុងការថែទាំរបស់ពួកគេ នឹងរ៉ាប់រងចំណាយពាក់ព័ន្ធជាមួយការថែទាំសុខភាពនេះ។[65]

*ការទទួលបានការចុះជួបពីបុគ្គលិកសង្គមកិច្ច៖*

ភស្តុតាងពីការពិភាក្សាបែបគុណភាពបង្ហាញថា កុមារដែលរស់នៅជាមួយគ្រួសារសាច់ញាតិកម្រទទួលបានការចុះសួរសុខទុក្ខពីបុគ្គលិកសង្គមកិច្ចណាស់ (មិនចំពោះថាបុគ្គលិកសង្គមកិច្ចមកពីអង្គការមិនមែនរដ្ឋាភិបាល ឬ មកពីរដ្ឋាភិបាល) ហើយអ្នកថែទាំមានទំនាក់ទំនងតិចណាស់ ឬ គ្មានទំនាក់ទំនងទាល់តែសោះជាមួយបុគ្គលិកសង្គមកិច្ច ទោះមកពីអង្គការមិនមែនរដ្ឋាភិបាល ឬមកពីមន្ទីរ ស.អ.យ ក៏ដោយ។ បញ្ហានេះត្រូវបានបញ្ជាក់ផងដែរដោយកុមារដែលរស់នៅក្រោមការថែទាំដោយសាច់ញាតិដែលបានបញ្ជាក់ថា ពួកគេមិនអាចពឹងអ្នកណាផ្សេង «ក្រៅពីគ្រួសារ» ឡើយ នៅពេលដែលពួកគេមានបញ្ហាណាមួយ។[66]

## ការបណ្ដុះបណ្ដាល

ប្រការ ៧ នៃប្រកាសស្ដីពីការថែទាំជំនួសតាមសហគមន៍ចែងថា រាល់អ្នកផ្ដល់ការថែទាំទាំងអស់ «ត្រូវចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលដែលផ្ដល់ដោយមន្ទីរ ស.អ.យ ឬ អ្នកផ្ដល់សេវាថែទាំជំនួសផ្សេងទៀត» ដែលការបណ្ដុះបណ្ដាលមានមេរៀនដូចជា ការថែទាំកុមារ ការប្រឹក្សាយោបល់ និងការរំលោភបំពាន កុមារជាដើម។ ភស្តុតាងពីការអង្កេតបែបបរិមាណបង្ហាញថា មានតែអ្នកថែទាំដោយសាច់ញាតិ ២នាក់ ប៉ុណ្ណោះដែលបានបញ្ចូលនៅក្នុងការសិក្សានេះបានទទួលការបណ្ដុះបណ្ដាល។ ពួកគេបានរៀនសូត្រអំពីការកំណត់អត្តសញ្ញាណកុមាររងការរំលោភបំពាន ដែលរៀបចំដោយអង្គការ មិនមែនរដ្ឋាភិបាលមួយ។ គ្មានអ្នកថែទាំជាសាច់ញាតិណាម្នាក់បានទទួលការបណ្ដុះបណ្ដាលអំពីផលប៉ះពាល់នៃការធ្វើសមាហរណកម្មកុមារ របៀបដោះស្រាយបញ្ហាទាក់ទងនឹងអាកប្បកិរិយា ឬ ការចិញ្ចឹមកូនបែបវិជ្ជមានឡើយ។

## ការចំណាយ និងការផ្ដល់មូលនិធិ

ដោយសារកង្វះទិន្នន័យជាតំណាង និងមានភាពរឹងមាំ វាមានការលំបាកក្នុងការប៉ាន់ស្មានអំពីការចំណាយទៅលើការផ្ដល់ការថែទាំដោយសាច់ញាតិ។ លើសពីនេះ ការចំណាយទាំងនេះទំនង ខុសគ្នាយ៉ាងទូលំទូលាយ អាស្រ័យលើអាយុរបស់កុមារ តម្រូវការជាក់ស្ដែងរបស់កុមារ និងគ្រួសារដែលផ្ដល់ការថែទាំដល់កុមារនោះ។ ជាងនេះទៀត ការចំណាយលើការរស់នៅក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផង

65 សម្ភាសអ្នកថែទាំដោយសាច់ញាតិ ខេត្តកណ្ដាល ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦។
66 សម្ភាសជាមួយកុមារនៅក្នុងការថែទាំដោយឪពុកម្ដាយធម៌ ខេត្តសៀមរាប ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៦។

ដែរនៅទូទាំងប្រទេស។ ទោះដូច្នេះក្តី យោងតាមទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងរដ្ឋាភិបាល ការថែទាំដោយសាច់ ញាតិអាចចាត់ទុកថាមានការចំណាយទាបបំផុតនៃទម្រង់ថែទាំជំនួសក្នុងប្រទេសកម្ពុជា។ នេះដោយសារតែការចំណាយដែលផ្តល់ដល់ការថែទាំ «ត្រូវបានបង្គ្រប់» ទាំងស្រុង ឬ ដោយផ្នែក ដោយគ្រួសារខ្លួនឯង។

នៅពេលដែលមានអង្គការមិនមែនរដ្ឋាភិបាលចូលរួមនៅក្នុងការទុកដាក់កុមារក្រោមការថែទាំដោយសាច់ញាតិ ពួកគេរមែងតែងគាំទ្រចំពោះកុមារម្នាក់ប្រហែល ៣០ដុល្លាអាមេរិកក្នុង ១ខែ សម្រាប់រយៈពេលដ៏មានកម្រិតមួយ ដោយចំនួនជាក់ស្តែងវាអាស្រ័យលើតម្រូវការជាក់លាក់របស់កុមារ និង គ្រួសារចិញ្ចឹមនោះ។

*ចំនួននៃការជួយគាំទ្រដែលយើងបានផ្តល់សម្រាប់ការធ្វើសមាហរណកម្មកុមារ វាអាស្រ័យលើតម្រូវការរបស់កុមារ។ ឧទាហរណ៍ យើងនឹងផ្តល់ការគាំទ្រច្រើនជាងប្រសិនបើពួកគេពិការ ឬមានផ្ទុកមេរោគអេដស៍។ ចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍ យើងផ្តល់ការគាំទ្រផ្នែកអាហារ និងចេញថ្លៃ ធ្វើដំណើរទៅមន្ទីរពេទ្យ។ ថវិកាដ៏មានកម្រិតរបស់យើងក្នុង១ខែសម្រាប់កុមារម្នាក់គឺ ៣០-៣៥ ដុល្លាអាមេរិក។ ក៏ប៉ុន្តែចំណាយនេះមិនរាប់បញ្ចូលថវិកាជួយពេលមានអាសន្នដែលយើងមានសម្រាប់ករណីលើកលែងខ្លះនោះទេ។[67]*

*អង្គការមិនមែនរដ្ឋាភិបាលដែលទុកដាក់ក្មេងប្រុសជាមួយយើង បានជួយគាំទ្រយើងនូវទឹកប្រាក់ ២០ដុល្លាអាមេរិកក្នុង១ខែ អង្ករ ៥០គីឡូក្រាមរាល់២សប្តាហ៍ សាប៊ូកក់សក់ ផលិតផល អនាម័យ និងលុយហោប៉ៅ ៣.៥ ដុល្លា សម្រាប់ក្មេងប្រុសម្នាក់។[68]*

ចំពោះគ្រួសារសាច់ញាតិ ការចំណាយបឋមមានទៅលើអាហារ និងការសិក្សារៀនសូត្រ។[69] សម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារនៅក្នុងការ ថែទាំដោយសាច់ញាតិ ការចំណាយភាគច្រើនពាក់ព័ន្ធទៅនឹងការប៉ាន់ប្រមាណក្រោយការទុកដាក់ និងការធ្វើដំណើរ។[70]

អ្នកផ្តល់ការថែទាំដោយសាច់ញាតិភាគច្រើនដែលបានធ្វើការអង្កេត គឺជាជនក្រីក្រ និងតស៊ូដើម្បីរកប្រាក់ឲ្យបានគ្រប់គ្រាន់ សម្រាប់ចំណាយលើរបស់ចាំបាច់ជាមូលដ្ឋាន និងការរៀនសូត្ររបស់កុមារ។ បុគ្គលិកសង្គមកិច្ចនៃមន្ទីរ ស.អ.យ ទំនងមិនមានការទទួលបានមូលនិធិណាមួយដែលពួកគេអាច ប្រើប្រាស់ដើម្បីគាំទ្រដល់ការទុកដាក់កុមារជាមួយសាច់ញាតិនោះទេ។ បុគ្គលិកសង្គមកិច្ចនៃមន្ទីរ ស.អ.យ នៅខេត្តបាត់ដំបងម្នាក់ នៅពេលសួរថាតើមន្ទីរ ស.អ.យ បានផ្តល់ការគាំទ្រណាមួយដែរឬទេ ចំពោះសាច់ញាតិជាអ្នកថែទាំ ដែលកំពុងជួបការលំបាកក្នុងការស្វែងរកជំនួយជួយដល់កុមារ គាត់បានឆ្លើយថា៖

*ការិយាល័យ ស.អ.យ ស្រុក មិនអាចផ្តល់ការជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រួសារ សាច់ញាតិបាននោះទេ។ យើងមិនមានថវិកាសម្រាប់គោលបំណងនេះឡើយ ក៏ប៉ុន្តែ [អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិធំមួយ] មានការិយាល័យនៅក្នុងស្រុករបស់ខ្ញុំ ហើយពួកគេអាចជួយដល់គ្រួសារសាច់ញាតិដោយផ្តល់នូវស្បៀង សៀវភៅ និងគ្រាប់ពូជបន្លែ។[71]*

67 សម្ភាសតាម Skype ទីក្រុងឡុងដ៍ ថ្ងៃទី ១៩ខែធ្នូ ឆ្នាំ ២០១៦។
68 អ្នកថែទាំដោយសាច់ញាតិ ខេត្តបាត់ដំបង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។
69 អ្នកថែទាំដោយសាច់ញាតិ ខេត្តសៀមរាប ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៦។
70 សម្ភាសតាម Skype ទីក្រុងឡុងដ៍ ថ្ងៃទី ១៩ខែធ្នូ ឆ្នាំ ២០១៦។
71 សម្ភាសបុគ្គលិកសង្គមកិច្ចស្រុក នៃមន្ទីរ សអយ ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។





© UNICEF Cambodia2015Antoine Raab

# ការថែទាំដោយឪពុកម្តាយធម៌

## គំហើញសំខាន់ៗ៖ ការថែទាំដោយឪពុកម្តាយធម៌

១. ចំនួនគ្រួសារធម៌ «មិនផ្លូវការ» មានចំនួនតិច។

២. ឪពុកម្តាយធម៌ បានយល់យ៉ាងច្រើនអំពីការទុកដាក់កុមារថា «មានលក្ខណៈអចិន្ត្រៃយ៍» ខណៈពេលដែលអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងគាំទ្រគ្រួសារធម៌ ចាត់ទុកការ ទុកដាក់កុមារថា «មានលក្ខណៈបណ្តោះអាសន្ន»។ ក្នុងករណីខ្លះ ការទុកដាក់កុមារ មានពីរយៈពេលខ្លី ទៅរយៈពេលវែង។

៣. គ្រួសារធម៌ខ្លះ ទំនងជាបានយកកុមារជាច្រើនមកចិញ្ចឹមធ្វើជាកូនធម៌ (នៅក្នុងសំណាកនៃការសិក្សានេះមានគ្រួសារដែលមានកូនធម៌រហូតដល់ ៦នាក់)។

៤. ភាគច្រើននៃការទុកដាក់កុមារនៅក្នុងគ្រួសារធម៌ មានការចូលរួមពីបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល តែការកំណត់អត្តសញ្ញាណគ្រួសារដ៏សមស្រប និងការទុកដាក់កុមារជាញឹកញាប់កើតឡើងចោះៗតែប៉ុណ្ណោះ ដោយសារការចូលរួមពីរដ្ឋាភិបាលនៅមានកម្រិត។

៥. បើប្រៀបធៀបជាមួយគ្រួសារសាច់ញាតិ គ្រួសារធម៌ដូចជាមានការត្រួតពិនិត្យតាមដានបានល្អជាង។

៦. កូនធម៌កម្របានចុះបញ្ជីជាមួយរដ្ឋាភិបាលខ្លាំងណាស់ និង ចំពោះថាតើពួកគេបាន ឬ មិនបានចុះបញ្ជីនោះ ភាគច្រើនវាអាស្រ័យទៅលើការផ្តួចផ្តើមរបស់គ្រួសារធម៌ ឬ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារនោះ។

៧. ពេលខ្លះគ្រួសារធម៌ ផ្លាស់ប្តូរសំបុត្រកំណើត និងដាក់ឈ្មោះកុមារយកត្រកូលខ្លួន ដែលនេះគឺជាការសុំកូនមកចិញ្ចឹមដោយមិនធ្វើតាមផ្លូវច្បាប់។

៨. កុមារនៅក្នុងគ្រួសារធម៌ បានទទួលការសិក្សារៀនសូត្រ និងទទួលបានបុគ្គលិកសង្គមកិច្ចពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែបើទោះជាដូច្នេះក្តី បុគ្គលិកសង្គមកិច្ចនេះកម្រជាបុគ្គលិកដែលត្រូវបាន «ចាត់តាំង» ឱ្យទទួលបន្ទុកជាក់លាក់ណាស់។

៩. ធៀបទៅនឹងការចំណាយរបស់មណ្ឌលថែទាំ ការថែទាំដោយឪពុកម្តាយធម៌ទំនងមិនសូវចំណាយច្រើន។ អង្គការដែលជួយដល់គ្រួសារធម៌ចំណាយពី ៣០-៤០ដុល្លា ១ខែសម្រាប់ក្មេងម្នាក់។

១០. អង្គការមិនមែនរដ្ឋាភិបាលខ្លះ «ផ្តល់បៀវត្សរ៍» ដល់ឪពុកម្តាយធម៌ចាប់ពី ៥០ ដល់ ២០០ ដុល្លាក្នុង១ខែ។

## ប្រវត្តិរបស់កុមារ

ការថែទាំដោយឪពុកម្តាយធម៌ ជាទូទៅ ត្រូវបានកំណត់និយមន័យថាជា «ស្ថានភាពមួយដែលកុមារត្រូវបានទុកដាក់ដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបានការថែទាំជំនួស នៅក្នុងបរិយាកាសគ្រួសារមួយក្រៅពីគ្រួសារផ្ទាល់ខ្លួនរបស់កុមារ ដែលត្រូវបានជ្រើសរើស មានសមត្ថភាព មានការយល់ព្រម មានការឃ្លាំមើលសម្រាប់ការផ្តល់ការថែទាំបែបនោះ»។[72]

ការថែទាំដោយឪពុកម្តាយធម៌មិនផ្លូវការ សំដៅលើស្ថានភាពមួយដែលគ្រួសារមានការទទួលខុសត្រូវ និងមើលថែទាំកុមារ ដែលដោយហេតុផលខ្លះ មិនអាចត្រូវបានឪពុក ឬម្តាយរបស់គេមើលថែទាំ និងដោយគ្មានការចូលរួមពីស្ថាប័នរដ្ឋ ឬពីអង្គការមិនមែនរដ្ឋាភិបាលឡើយ។ ក្នុងន័យបច្ចេកទេស ការទុកដាក់កុមារមិនផ្លូវការ មិនស្ថិតនៅក្នុងនិយមន័យនៃ «ការថែទាំដោយឪពុកម្តាយធម៌» នោះឡើយ ក៏ប៉ុន្តែគ្រួសារខ្លះស្វែងរកជំនួយពី គកនក ពីមន្ទីរ ស.អ.យ ឬ ពីអង្គការក្នុងស្រុក នៅពេលពួកគេបានទទួលកុមារមកចិញ្ចឹម។

មិនមានភស្តុតាងបែបបរិមាណអំពីចំនួនគ្រួសារដែលបាន «សុំកូនគេមកចិញ្ចឹមជាកូនធម៌» មិនផ្លូវការនោះទេ ក៏ប៉ុន្តែយោងតាមភស្តុតាងមិនផ្លូវការ ចំនួននេះមានមិនច្រើននោះទេ។[73]

ទោះបីជាការថែទាំដោយឪពុកម្តាយធម៌ ត្រូវបានរៀបចំ និងគាំទ្រដោយ ក្រសួង ស.អ.យ តាមរយៈមន្ទីរ ស.អ.យ ឬ ការិយាល័យ ស.អ.យ ក៏ដោយ ក៏ភាគច្រើននៃសេវាថែទាំដោយឪពុកម្តាយធម៌ផ្លូវការបច្ចុប្បន្នកំពុងត្រូវបានផ្តល់ឲ្យ គ្រប់គ្រង និងផ្តល់មូលនិធិតាមរយៈអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ជាលទ្ធផល ទម្រង់លក្ខណៈ និងទីតាំងភូមិសាស្ត្រនៃការចិញ្ចឹមកូនធម៌ មានភាពខុសគ្នាទៅតាមវិធានជាក់លាក់របស់អង្គការដែលធ្វើការគ្រប់គ្រង។

ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលនីមួយៗមានទិន្នន័យអំពីអ្នកថែទាំជាឪពុកម្តាយធម៌ និងចំនួននៃកុមារដែលត្រូវបានសុំយកទៅចិញ្ចឹមជាកូនធម៌ក៏ដោយ ប៉ុន្តែពុំមានទិន្នន័យថ្នាក់ជាតិអំពីចំនួន កុមារស្ថិតក្នុងការថែទាំដោយឪពុកម្តាយធម៌នៅក្នុងប្រទេសកម្ពុជាឡើយ។ លើសពីនេះ មិនមានការ កំណត់ផែនទីគ្រប់ជ្រុងជ្រោយដើម្បីកំណត់សេវាថែទាំដោយឪពុកម្តាយធម៌នោះទេ។ ការទទួលបានទិន្នន័យដ៏គួរឲ្យជឿជាក់ពិតជាមានការពិបាកដោយហេតុថា មិនមែនរាល់អ្នកថែទាំជា ឪពុកម្តាយធម៌ទាំងអស់សុទ្ធសឹងតែមានអាជ្ញាប័ណ្ណនោះទេ។[74]

មានគ្រួសារធម៌ចំនួន ១០ គ្រួសារ ដែលយើងបានជួបនៅក្នុងការសិក្សានេះ។ បើទោះបីជាមានអ្នកថែទាំជាឪពុកម្តាយធម៌ខ្លះ និង អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ ព័ន្ធក្នុងការទុក ដាក់កុមារ ដែលយើងបានជួបយល់ថាការទុកដាក់នេះមាន »លក្ខណៈអចិន្ត្រៃយ៍» ក៏ដោយ ប៉ុន្តែខ្លះទៀតជឿថា “មានលក្ខណៈបណ្តោះអាសន្ន” ឬ រយៈពេលខ្លីដោយយល់ថាគោលដៅ គឺចង់ ធ្វើសមាហរណកម្មកុមារចូលទៅក្នុងគ្រួសារកំណើតរបស់ពួកគេ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ អ្នកថែទាំជាឪពុកម្តាយធម៌ និងអង្គការដែលទុកដាក់កុមារមានទស្សនៈខុសៗ គ្នាអំពីលក្ខណៈនៃការទុក ដាក់នេះ។ ឪពុកម្តាយធម៌ទាំងអស់ លើកលែងតែម្នាក់ដែល

72 មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ សេចក្តីសម្រេចលេខ ៦៤/១៤២ ២០១០។
73 សម្ភាសតំណាងមន្ទីរ សអយ ខេត្តសៀមរាប ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។
74 សូមអានសេចក្តីព្រាងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់គាំទ្រគ្រួសារ ការថែទាំដោយឪពុកម្តាយធម៌ និងសុំកូននៅក្នុងប្រទេសកម្ពុជា ២០១៧-២០២៣ ក្រសួង សអយ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៦។

យើងបានសម្ភាសបានប្រាប់ថា កុមារដែលរស់ នៅជាមួយពួកគេនោះគឺរស់នៅ «ជាអចិន្ត្រៃយ៍» មិនមែនរយៈពេលខ្លីនោះទេ។ បើទោះជាដូច្នេះក្តី ភាគច្រើននៃអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ដែលយើងបានសម្ភាសសម្រាប់ការ សិក្សានេះបាន និយាយថា "ការទុកដាក់នេះមានមានលក្ខណៈបណ្តោះអាសន្ន" មានន័យថាកុមារត្រូវយក មកចិញ្ចឹម រហូតដល់ពួកគេត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារកំណើតរបស់ពួកគេ ឬរហូតដល់ពួកគេអាច ផ្លាស់ទៅក្នុងការរៀបចំរស់នៅថែទាំជំនួសណាមួយទៀត។

ការរៀបចំថែទាំដោយឪពុកម្តាយធម៌ខ្លះ ពិតជាបានវិវឌ្ឍន៍ពីការថែទាំរយៈពេលខ្លីទៅរកការថែទាំអចិន្ត្រៃយ៍ ដោយសារកាលៈទេសៈមានការផ្លាស់ប្តូរ៖

*«ដំបូងកុមារគ្រាន់តែមករស់នៅជាមួយយើងបណ្តោះអាសន្នប៉ុណ្ណោះ តែក្រោយពីម្តាយរបស់ពួកគេស្លាប់ [ដោយសារមេរោគអេដស៍/ជំងឺអេដស៍] ពួកគេចង់រស់នៅជាអចិន្ត្រៃយ៍»។*[75]

យើងមិនអាចពិនិត្យមើលកំណត់ហេតុរបស់កុមារបានស៊ីជម្រៅនោះទេ ប៉ុន្តែភាគច្រើននៃ កុមារដែលចិញ្ចឹមដោយឪពុកម្តាយធម៌នៅក្នុងការសិក្សានេះ ទំនងមានការពិតតិចតួចណាស់ដែលកុមារបានរួមរស់ឡើងវិញជាមួយឪពុកម្តាយរបស់ពួកគេនោះ៖ ដោយសារឪពុកម្តាយរបស់ពួកគេបានស្លាប់ ឬដោយសារឪពុក ឬ ម្តាយបានរៀបការជាថ្មី និង ឪពុក ឬម្តាយចុងបានបដិសេធ មិនព្រមទទួលកុមារត្រឡប់មកវិញ ឬដោយសារកាលៈទេសៈគ្រួសារ ដែលការវិលត្រឡប់របស់កុមារអាចធ្វើឱ្យកុមារ ប្រឈម ហានិភ័យនៃការធ្វើបាបជាដើម។

មានភស្តុតាងបន្តិចបន្តួចអំពីការធ្វើផែនការអចិន្ត្រៃយ៍ សម្រាប់កុមារនៅក្នុងការថែទាំដោយឪពុកម្តាយធម៌ សូម្បីនៅក្នុងករណីកុមារតូចៗក៏ដោយ។ បញ្ហានេះវាបង្កើតនូវភាពមិនច្បាស់លាស់សម្រាប់អនាគតរបស់ពួកគេ។ កុមារដែលយើងបានសម្ភាស សម្រាប់ការសិក្សានេះ មានការយល់ដឹងមិនច្បាស់លាស់ថាពួកគេនឹងត្រូវត្រឡប់ទៅរស់នៅជាមួយ គ្រួសារ របស់ពួកគេឬយ៉ាងណា ប៉ុន្តែ កុមារភាគច្រើនជឿថាហេតុការណ៍នេះអាចនឹងកើតឡើង បើទោះបីជាពួកគេ បានចាកចេញពីគ្រួសារជាច្រើនឆ្នាំ និងមានទំនាក់ទំនងជាមួយគ្រួសារតិចតួចក៏ដោយ។

ក្នុងករណីខ្លះ ការទុកដាក់កុមារការថែទាំដោយឪពុកម្តាយធម៌ មានលក្ខណៈស្រដៀងច្រើននឹងការសុំកូនមិនផ្លូវការ ដោយឪពុកម្តាយធម៌មានការប្តេជ្ញាចិញ្ចឹមកុមាររយៈពេលវែង។ មានភស្តុតាងអំពីឪពុកម្តាយធម៌ខ្លះបានធ្វើការផ្លាស់ប្តូរសំបុត្រកំណើតរបស់កុមារ និងប្តូរឈ្មោះកុមារ ដោយដាក់ឈ្មោះខ្លួនឯងចូលដូចជាឪពុកម្តាយបង្កើតនៅក្នុងសៀវភៅគ្រួសារ។ ក្នុងករណីផ្សេងទៀត ឪពុកម្តាយធម៌គឺជា «អ្នកអាជីព» ដែលរកប្រាក់ចំណូលពីការថែទាំកុមារ។

យោងតាមទិន្នន័យនៃការសិក្សាបានបង្ហាញឲ្យដឹងថា ចំនួនកុមារជាអតិបរមាដែលកំពុង រស់នៅជាមួយគ្រួសារធម៌មួយ មានចំនួន ៩នាក់។[76] ទិន្នន័យបែបគុណភាពបង្ហាញថាគ្រួសារធម៌ខ្លះបានយកកុមារច្រើននាក់មកចិញ្ចឹមបីបាច់ថែរក្សា។

*ឪពុកម្តាយធម៌នីមួយៗរបស់យើង ចិញ្ចឹមក្មេងជាមធ្យម ចំនួន៦នាក់។ ពិតណាស់ ពួកគេក៏មានកូនផ្ទាល់ខ្លួនរបស់ពួកគេដែរ។ ដូច្នេះឪពុកម្តាយធម៌អាចចិញ្ចឹមក្មេងសរុបប្រមាណ ១០នាក់។*[77]

75 សម្ភាសឪពុក/ម្តាយធម៌ ខេត្តសៀមរាប ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៦។

76 ស្ថិតិអំពីការថែទាំដោយឪពុកម្តាយធម៌មិនរាប់បញ្ចូលនូវចម្លើយពីអ្នកគ្រប់គ្រង/បុគ្គលិកសង្គមកិច្ច/គ្រូបង្រៀន ទទួលបន្ទុកត្រួតពិនិត្យគ្រួសារធម៌មួយចំនួន។

77 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។

វត្តមាននៃកូនធម៌ច្រើននៅក្នុងផ្ទះតែមួយ បង្កើតជាសំណួរទាក់ទងនឹងសមត្ថភាពក្នុងការយកចិត្តទុកដាក់ពេញលេញ ការគាំទ្រផ្នែកផ្លូវចិត្ត និងពេលវេលាដែលមានសម្រាប់កុមារ។ នេះគឺអាចជាបញ្ហាជាក់ស្តែងសម្រាប់កុមារដែលធ្លាប់បាត់បង់គ្រួសាររបស់ពួកគេ និងកុមារដែល អាចបាត់បង់កុមារដទៃ និងបុគ្គលិកដែលពួកគេធ្លាប់មានទំនាក់ទំនងជាមួយ នៅពេលពួកគេ ត្រូវបានគេទុកដាក់ដំបូង។ វាក៏បង្ហាញឱ្យឃើញច្បាស់ផងដែរថានៅក្នុងករណីខ្លះ កុមារដ៏ច្រើន នៅក្នុងគ្រួសារវាបង្កភាពតានតឹងទៅលើអ្នកថែទាំកុមារទាំងនោះផងដែរ។

កុមាររស់នៅក្នុងគ្រួសារធម៌ ដែលបានចូលរួមនៅក្នុងការសិក្សានេះ ភាគច្រើនគឺជាក្រុមកុមារតូចៗ។ អ្នកផ្តល់ចម្លើយដ៏សំខាន់ម្នាក់ដែលធ្វើការឲ្យអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការថែទាំនៅ សហគមន៍ក្នុងរាជធានីភ្នំពេញបានធ្វើការកត់សម្គាល់ថា កុមារអាយុពី ៤-១០ឆ្នាំ គឺជាប្រភេទក្រុមអាយុ «ធំបំផុត» ដែលចូលទៅក្នុងគ្រួសារធម៌។[78]

ការសិក្សាបានរកឃើញកុមារវ័យជំទង់ដែលមានវ័យច្រើនមួយចំនួនតូចនៅក្នុងការថែទាំដោយឪពុកម្តាយធម៌។ អង្គការ មិនមែនរដ្ឋាភិបាល បាននិយាយថា វាមានការលំបាកក្នុងការទុកដាក់កុមារធំៗដោយកុមារ ទាំង នេះមានការពិបាកខ្លាំងជាងក្នុងការសម្របខ្លួនរស់នៅក្នុងគ្រួសារថ្មី។ អង្គការមួយធ្លាប់បានដកហូត កុមារពីការថែទាំដោយឪពុកម្តាយធម៌ នៅពេលដែលពួកគេចូលដល់ពាក់កណ្តាលវ័យជំទង់ និងបានបញ្ជូន ពួកគេត្រឡប់ទៅរស់នៅក្នុងមណ្ឌលថែទាំវិញ ឬទៅរស់នៅរបៀបពាក់កណ្តាលឯករាជ្យ។ នេះគឺជាបញ្ហាគួរឲ្យព្រួយបារម្ភដោយសារកុមារត្រូវគេផ្ទេរម្តងហើយម្តងទៀត ដែលនាំឱ្យរំខានដល់កុមារ និងមិនស្របតាមឧត្តមប្រយោជន៍របស់កុមារថែមទៀតផង។ គេមិនច្បាស់ថាហេតុអ្វីបានជាអង្គការ មិនមែនរដ្ឋាភិបាលរក្សាគោលនយោបាយបែបនេះ ជាពិសេសនៅពេលកុមារបានរស់នៅជាមួយឪពុកម្តាយធម៌ជាច្រើនឆ្នាំហើយ និងបានកសាងទំនាក់ទំនងជិតស្និទ្ធរួចទៅហើយ។

គ្រួសារធម៌ខ្លះ មានគោលបំណងច្បាស់លាស់ចំពោះកុមារដែលពួកគេចង់យក មកចិញ្ចឹម ជាកូនធម៌។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ អ្នកគ្រប់គ្រងអង្គការថែទាំតាមសហគមន៍មួយនៅ ខេត្តសៀមរាបបាននិយាយប្រាប់អ្នកស្រាវជ្រាវយើងថា៖

*ឪពុកម្តាយធម៌ រមែងតែងចង់បានកូនកំព្រាទាំងឪពុកនិងម្តាយ។ ពួកគេភ័យខ្លាចថាឪពុកម្តាយបង្កើតរបស់កុមារនឹងត្រឡប់មកយកកូនរបស់ពួកគេវិញ។ ឪពុកម្តាយធម៌ មានការពេញចិត្តចំពោះកុមារតូចៗជាងកុមារធំៗ ហើយក៏មានការពេញចិត្តក្មេងស្រីជាងក្មេងប្រុសដែរ ដោយពួកគេយល់ថាក្មេងស្រីងាយ អប់រំជាង។[79]*

នេះបង្ហាញថា យ៉ាងហោចណាស់ឪពុកម្តាយធម៌ខ្លះទំនងស្វែងរកការទុកដាក់កុមាររយៈពេលវែងដែលវាមានលក្ខណៈស្រដៀងគ្នាទៅនឹងសុំកូន។

## ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

ទោះបីជាការទុកដាក់កុមារនៅក្នុងគ្រួសារធម៌ មានការជាប់ពាក់ព័ន្ធជាមួយបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ឬ តំណាងរដ្ឋាភិបាលក៏ដោយ ក៏ដំណើរការនៃការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារជាញឹកញាប់កើតឡើងក្នុងលក្ខណៈចំពោះកិច្ច ឬកើតឡើងទៅតាម «ឱកាស» ហុចឲ្យតែប៉ុណ្ណោះ។ ឧទាហរណ៍ គ្រួសារធម៌មួយដែលអ្នកស្រាវជ្រាវបានជួបនៅក្នុងខេត្តសៀមរាប មានកូនស្រីបង្កើតម្នាក់ដែល

78 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។
79 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។

កំពុងធ្វើការជាមួយអង្គការថែទាំតាមសហគមន៍មូលដ្ឋានមួយ។ កូនស្រីនោះបានកំណត់គ្រួសាររបស់នាងថាជាគ្រួសារធម៌ដ៏មានសក្តានុពលដែលអាចចិញ្ចឹមក្មេងកំព្រា ៣នាក់ ដែលនៅពេលនោះក្មេងទាំង៣កំពុងនៅរៀន និងទទួលការជួយគាំទ្រស្បៀងអាហារពី [អង្គការមិនមែនរដ្ឋាភិបាល]។[80] នៅក្នុងករណីមួយទៀត អាជ្ញាធរមូលដ្ឋានត្រូវបានជូនដំណឹង *ក្រោយពេលដែល* កុមារត្រូវឪពុកម្តាយបោះបង់ចោលម្នាក់ត្រូវបានគ្រួសារធម៌ «មិនផ្លូវការ» មួយយកទៅចិញ្ចឹមធ្វើជាកូនធម៌។

*នាងត្រូវបានគេបោះបង់ចោលនៅក្បែរធុងសម្រាម នៅប៉ុន្មានផ្លូវឆ្ងាយពីទីនេះ។ នៅពេលដែលប្រពន្ធរបស់ខ្ញុំបានឃើញទារិកានោះ គាត់ក៏បីនាងទៅមន្ទីរពេទ្យ។ ទារិកានោះមានអាយុទើបតែបាន ១ខែនៅពេលយើងឃើញនាង។ ម្នាក់ៗចេះតែដើររំលងធុងសម្រាមនោះ តែប្រពន្ធរបស់ខ្ញុំមិនដាច់ចិត្តដើរចេញពី ទារិកាដ៏តូចនេះទេ។*

*តើមានតួអង្គណាផ្សេងទៀតបានចូលពាក់ព័ន្ធដែរឬទេ ?*

*បាទ! យើងបានជម្រាបប្រធានភូមិ និងតំណាងឃុំ។ យើងមិនចង់ឲ្យមានការចោទប្រកាន់ថាយើងបានលួចកូនរបស់គេយកមកនោះទេ។*[81]

ក្នុងករណីខ្លះ អង្គការមិនមែនរដ្ឋាភិបាល ធ្វើការសហការជាមួយមន្ត្រីអាជ្ញាធរមូលដ្ឋានដើម្បីកំណត់រកគ្រួសារធម៌ដ៏សមស្រប។ ឧទាហរណ៍ បុគ្គលិកសង្គមកិច្ចម្នាក់នៃអង្គការថែទាំសហគមន៍មួយបានលើកឡើងថា គាត់អាចនឹង«*ទៅជួប គកនក មេភូមិ មេឃុំ ដើម្បីរៀបចំយកកុមារមកចិញ្ចឹមជាកូនធម៌។ អ្នកទាំងអស់នេះស្គាល់គ្រួសារធម៌ ហើយគ្រួសារធម៌អាចដាក់ពាក្យសុំចិញ្ចឹមជាកូនធម៌បាន*»។[82] បុគ្គលិកសង្គមកិច្ចផ្សេងទៀតនៃអង្គការមិនមែនរដ្ឋាភិបាល ដែលបានសម្ភាសសម្រាប់ការសិក្សានេះ បានធ្វើកម្មវិធីផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ឪពុកម្តាយធម៌ដែលមានសក្តានុពល។[83]

អង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់គ្រួសារធម៌ដ៏សមស្របដែលលក្ខខណ្ឌនោះផ្តោតលើលក្ខណៈសម្បត្តិ ជាជាងការផ្តោតលើភាពសមស្រប បើទោះបីជាប្រការ ៦(១) នៃប្រកាសស្តីពីការថែទាំជំនួសតាមសហគមន៍ចែងថា «*នៅក្នុងគ្រប់ករណីទាំងអស់ បុគ្គលិកសង្គមកិច្ចនៃក្រសួង ស.អ.យ ឬ អ្នកផ្តល់ការថែទាំជំនួស [អង្គការមិនមែនរដ្ឋាភិបាល] ត្រូវធ្វើការប៉ាន់ប្រមាណមួយដើម្បីធានានូវភាពសមស្របនៃគ្រួសារធម៌ប្រកបដោយសក្តានុពល*» (ទំព័រទី ៦) ក៏ដោយ។ ឧទាហរណ៍ បុគ្គលិកសង្គមកិច្ចម្នាក់នៃអង្គការមិនមែនរដ្ឋាភិបាលមួយនៅខេត្តកណ្តាលបាននិយាយថាលក្ខណៈវិនិច្ឆ័យនោះចែងថា៖ «*ឪពុកម្តាយធម៌ដែលមានសក្តានុពលត្រូវមានអាយុយ៉ាងតិច ៣៥ឆ្នាំ។ គ្រួសារនេះមិនត្រូវមានកូនលើសពី ៤ ឬ៥នាក់ឡើយ។ ឪពុកម្តាយនេះមិនត្រូវជាអតីតទណ្ឌិត ឬធ្លាប់បានប្រព្រឹត្តអំពើហិង្សាឡើយ។ ពួកគេត្រូវមានសុខភាពល្អទាំងរាងកាយ និងសតិបញ្ញា មិនមានជម្ងឺលោកថ្លើម ឬជម្ងឺរបេង*»។[84]

ភស្តុតាងបែបគុណភាពបង្ហាញថា ការធ្វើការប៉ាន់ប្រមាណមុនការទុកដាក់កុមារទៅលើគ្រួសារធម៌ដែលមានសក្តានុពល ត្រូវបានធ្វើជាបឋម ដោយបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាលជាជាងដោយបុគ្គលិក សង្គមកិច្ចរបស់រដ្ឋាភិបាល។[85] ទោះដូច្នេះក៏ដោយ នៅក្នុងកន្លែងខ្លះអ្នកស្រាវជ្រាវត្រូវបានគេប្រាប់ថាអាជ្ញាធរមូលដ្ឋានបានធ្វើការប៉ាន់ប្រមាណមុនការទុកដាក់កុមារ។ ឧទាហរណ៍ តំណាងមន្ទីរ ស.អ.យ ម្នាក់នៅខេត្តសៀមរាប បាននិយាយថា «*មុនទុកដាក់កុមារ [ចូលទៅក្នុងគ្រួសារធម៌] យើងធ្វើ*

80 សម្ភាសឪពុក/ម្តាយធម៌ ខេត្តសៀមរាប ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៦។
81 សម្ភាសឪពុក/ម្តាយធម៌ ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
82 បុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ខេត្តកណ្តាល ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។
83 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តព្រះសីហនុ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៦។
84 បុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ខេត្តកណ្តាល ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។
85 បញ្ហានេះត្រូវបានបញ្ជាក់ដោយតំណាង គកនក ខេត្តកណ្តាល។ សម្ភាស គកនក ខេត្តកណ្តាល ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

*ការប៉ាន់ប្រមាណមួយលើក ឬ ពីរលើកទៅលើគ្រួសារ។ ជាធម្មតា គឺបុគ្គលិកសង្គមកិច្ចមកពីមន្ទីរ ស.អ.យ តំណាងមកពី គកនក និង មេភូមិ។ ពេលខ្លះ មានតែបុគ្គលិកសង្គមកិច្ចមកពីមន្ទីរ ស.អ.យ ប៉ុណ្ណោះ»។*[86] ជាអកុសល្យ យើងមិនអាចអនុវត្តត្រីកោណវិធានដើម្បីបញ្ជាក់បញ្ហានេះបាន ដោយវាអាចជាការអនុវត្តមានភាពប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រផ្សេងគ្នា ឬ អ្នកផ្តល់ចម្លើយដែលជាមន្ត្រីអាជ្ញាធរមូលដ្ឋាន និយាយបន្លើសអំពីការចូលរួមរបស់ពួកគេនៅក្នុងការប៉ាន់ប្រមាណមុនការទុកដាក់កុមារនេះ។

## ការត្រួតពិនិត្យតាមដាន

ផ្ទុយពីការថែទាំដោយសាច់ញាតិ ការរៀបចំថែទាំដោយឳពុកម្តាយធម៌ទំនងជាត្រូវបានត្រួតពិនិត្យតាមដានបានល្អជាង។ រាល់អ្នកថែទាំកូនធម៌ទាំងអស់ដែលបានបញ្ចូលនៅក្នុងការសិក្សានេះបានបង្ហាញថាមានមន្ត្រីមកពីខាងក្រៅ (មកពីមន្ទីរ ស.អ.យ គកនក ឬអង្គការមិនមែនរដ្ឋាភិបាល) បានចុះមកជួបពួកគេក្នុងគោលបំណងពិនិត្យតាមដាន។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថា គ្រួសារធម៌ដែលបានបញ្ចូលនៅក្នុងការសិក្សានេះមិនតំណាងឲ្យគ្រួសារធម៌ទាំងអស់នៅក្នុងប្រទេសកម្ពុជានោះទេ។ ទិន្នន័យបែបបរិមាណមិនបានបង្ហាញថាតើអង្គការមិនមែនរដ្ឋាភិបាល ឬ តួអង្គរដ្ឋាភិបាល ជាអ្នកចូលរួមញឹកញាប់នៅក្នុងការចុះទៅពិនិត្យតាមដានក្រោយពេលទុកដាក់កុមារឡើយ។

យោងតាមតំណាងជាន់ខ្ពស់នៃមន្ទីរ ស.អ.យ ក្នុងខេត្តសៀមរាបបានឲ្យដឹងថា មន្ត្រីមន្ទីរ ស.អ.យ (ជាទ្រឹស្តី) ត្រូវបានណែនាំឲ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការធ្វើផែនការអចិន្ត្រៃយ៍របស់ ក្រសួង ស.អ.យ សម្រាប់ចុះបញ្ជីគ្រួសារធម៌។[87] បើទោះជាដូច្នេះក្តី ជាក់ស្តែង ការធ្វើផែនការអចិន្ត្រៃយ៍ពិតជាមិនកើតមាននោះទេ ហើយការចុះបញ្ជីការថែទាំដោយឳពុកម្តាយធម៌ក៏ទំនងត្រូវបានធ្វើក្នុង លក្ខណៈចំពោះកិច្ច៖ *«បន្ទាប់ពីខ្ញុំបានដឹងថាម្តាយ [របស់កុមារត្រូវគេបោះបង់ចោល] មិនមកបង្ហាញខ្លួន ខ្ញុំបានចុះទៅជួបមេភូមិ ហើយប្រាប់គាត់អំពីរឿងនេះ គាត់និយាយថា - មិនអីទេ! អ្នកអាចមើលថែទាំកុមារនេះបាន»។*[88]

ចំពោះការដែលកូនធម៌ បានចុះឈ្មោះ ឬ ក៏មិនបានចុះឈ្មោះជាមួយរដ្ឋាភិបាល ភាគច្រើនគឺ អាស្រ័យលើគំនិតផ្តួចផ្តើមរបស់ឳពុកម្តាយធម៌ និង/ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលរួមនៅ ក្នុងការទុកដាក់កុមារក្នុងការថែទាំដោយឳពុកម្តាយធម៌នេះ។ ឧទាហរណ៍ សូមពិចារណាសម្រង់សំដីពីការ សម្ភាសជាមួយឳពុកម្តាយធម៌នៅក្នុងខេត្តបាត់ដំបង ព្រះសីហនុ និងសៀមរាបដូចខាងក្រោម៖

*ឥឡូវកុមារកំពុងប្រើត្រកូលរបស់ខ្ញុំ ហើយនាងមានសំបុត្រកំណើតទៀត។ ហើយយើងក៏បានបញ្ចូលឈ្មោះរបស់នាងទៅក្នុងសៀវភៅគ្រួសារ ដូច្នេះនាងមាន សិទ្ធិទទួលមរតក។*[89]

*តើឈ្មោះរបស់កុមារមាននៅក្នុងសៀវភៅគ្រួសាររបស់អ្នកដែរឬទេ? ទេ! ខ្ញុំមិនដែលមានសៀវភៅគ្រួសារនោះទេ ក៏ប៉ុន្តែកូនប្រុសនេះមានសំបុត្រកំណើត ហើយវាប្រើ ត្រកូលគ្រួសារខ្ញុំ។*[90]

*តើកុមារមានបានចុះបញ្ជីជាកូនធម៌ដែរឬទេ? ខ្ញុំមិនបានធ្វើដោយខ្លួនខ្ញុំនោះទេ។ អង្គការមិនមែនរដ្ឋាភិបាលបានចុះឈ្មោះកុមារជាមួយ គកនក មេភូមិ និងមន្ទីរ ស.អ.យ។ យើងមិនដែលមានទំនាក់ទំនងដោយផ្ទាល់ ជាមួយរដ្ឋាភិបាលនោះឡើយ។*[91]

86 សម្ភាសតំណាងមន្ទីរ សអយ ខេត្តសៀមរាប ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។
87 សម្ភាសតំណាងមន្ទីរសង្គមកិច្ច ខេត្តសៀមរាប ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។
88 សម្ភាសម្តាយធម៌ ខេត្តព្រះសីហនុ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
89 សម្ភាសឳពុក/ម្តាយធម៌ ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
90 សម្ភាសម្តាយធម៌ ខេត្តព្រះសីហនុ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
91 សម្ភាសឳពុក/ម្តាយធម៌ ខេត្តសៀមរាប ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦។

បើធ្វើការប្រៀបធៀបរវាងការរៀបចំចិញ្ចឹមកូនដោយឪពុកម្តាយធម៌ដែលបានចុះបញ្ជី និង មិនបានចុះបញ្ជី អ្នកផ្តល់ចម្លើយជាន់ខ្ពស់ម្នាក់ពីរដ្ឋាភិបាលខេត្តសៀមរាបបានមានប្រសាសន៍ឱ្យដឹងថា *"ភាគច្រើននៃការថែទាំដោយគ្រួសារធម៌ធ្វើឡើងនៅក្រោមតុ ដោយគ្មានការចុះបញ្ជីណាមួយនោះទេ"។*[92] ជាអកុសល្យពុំមានទិន្នន័យបែបបរិមាណដែលអាចប្រើប្រាស់បានជាតំណាង ដើម្បីបញ្ជាក់លើការ អះអាងនេះឡើយ។

## ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត

បើប្រៀបធៀបជាមួយកុមារថែទាំដោយសាច់ញាតិ កុមាររស់នៅជាមួយគ្រួសារធម៌ រមែងតែងនៅមានឪពុក ឬ ម្តាយបង្កើត ឬ ឪពុកនិងម្តាយបង្កើតដែលនៅរស់។ ភាពញឹកញាប់នៃទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និង ការប៉ុនប៉ងធ្វើសមាហរណកម្មកុមារ មានភាពខុសគ្នាពីករណីមួយទៅករណីមួយទៀត។ ក្នុងករណីខ្លះ ដោយសារតែស្ថានភាពរបស់គ្រួសារ ធ្វើឱ្យទំនាក់ទំនងទៅគ្រួសារបង្កើតរបស់កុមារ អាចបង្កហានិភ័យដល់កុមារ។ ចំពោះករណីផ្សេង ទៀត ធនធានគឺជាកត្តាចម្បងដែលកំណត់ទៅលើទំនាក់ទំនងទៅគ្រួសារកំណើត និង កម្រិតនៃទំនាក់ ទំនងបែបនេះ។

*<u>តើមានការប្រាស្រ័យទាក់ទងទៅឪពុកបង្កើតរបស់កុមារ ដែរឬទេ ?</u>*

*បាទ! ឪពុកបង្កើតបានមកលេងកុមារប្រហែល ២ដងដែរក្នុង១ឆ្នាំ ក៏ប៉ុន្តែទាល់តែ [បុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល] បើកឡានជូនគាត់មកទីនេះ។ គាត់រស់នៅចម្ងាយ ១៥គីឡូម៉ែត្រ។ តើអ្នកគិតដូចម្តេចចំពោះការមកលេងនេះ ? យើងមានការភ័យខ្លាចបន្តិច ថាឪពុក [ដែលជាអ្នកញៀនថ្នាំ] នឹងមានឥទ្ធិពលអាក្រក់មកលើកុមារនៅពេលនាងធំដឹងក្តី។ តើមានការប្រឹងប្រែងដើម្បីធ្វើសមាហរកម្មកុមារជាមួយឪពុក ឬម្តាយបង្កើតដែលនៅ រស់ដែរ ឬទេ ? [បុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល] ធ្វើការប៉ាន់ប្រមាណជាទៀងទាត់ នូវស្ថានភាពរបស់ឪពុកបង្កើត ក៏ប៉ុន្តែមកដល់ពេលនេះស្ថានភាពរបស់គាត់មិន បានប្រសើរសោះ។*

## លក្ខណៈនៃការថែទាំដែលបានផ្តល់ជូន

លក្ខណៈនៃការថែទាំដែលបានផ្តល់ដល់កុមាររស់នៅក្នុងគ្រួសារធម៌ អាស្រ័យលើស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារធម៌នោះ ក៏ដូចជាកម្រិតនៃការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារផងដែរ។

*<u>លក្ខខណ្ឌសម្ភារៈ</u>*

ទិន្នន័យបែបបរិមាណពីបញ្ជីផ្ទៀងផ្ទាត់តាមរយៈការអង្កេតបង្ហាញថាគ្រួសារធម៌មានជីវភាពល្អប្រសើរជាងគ្រួសារសាច់ញាតិ។ នេះប្រហែលមកពីគ្រួសារនោះជាគ្រួសារមានធនធានច្រើន ហើយបានស្ម័គ្រចិត្តធ្វើជាឪពុកម្តាយធម៌ និង/ឬ ជំនួយគាំទ្រហិរញ្ញវត្ថុដែលបានផ្តល់ដល់ឪពុកម្តាយធម៌អាចឲ្យពួកគេមានជីវភាពរស់នៅបានល្អប្រសើរ។ គ្រួសារធម៌ចំនួន ៩ ក្នុងចំណោមគ្រួសារធម៌ទាំង ១០មានប្រព័ន្ធលូបង្ហូរទឹកមួយដែលមានដំណើរការ ដែលផ្ទុយពីគ្រួសារសាច់ញាតិដែលមានតែ ១គ្រួសារក្នុងចំណោម ៨គ្រួសារ ប៉ុណ្ណោះដែលមានប្រព័ន្ធ លូបង្ហូរទឹកបែបនេះ។ គ្រប់គ្រួសារធម៌ដែលអ្នកស្រាវជ្រាវបានជួបកុមារមានបង្គន់មួយដែល

92 សម្ភាសតំណាងជាន់ខ្ពស់រដ្ឋាភិបាល ខេត្តសៀមរាប ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦។

មានដំណើរ ការសម្រាប់ប្រើប្រាស់។ បើទោះបីជា គំហើញទាំងនេះគ្រាន់តែជាការប្រាប់ឲ្យដឹងក៏ដោយ ប៉ុន្តែដោយសារ តែវិធីសាស្ត្រជ្រើសរើសសំណាកសម្រាប់គោលបំណងជាក់លាក់លទ្ធផលនេះបង្ហាញថា ជាទូទៅគ្រួសារធម៌មានស្ថានភាពសេដ្ឋកិច្ចរឹងមាំជាង។

*ការទទួលបានការសិក្សារៀនសូត្រ៖*

កុមាររស់នៅក្នុងគ្រួសារធម៌ទាំង ១០គ្រួសារដែលអ្នកស្រាវជ្រាវបានជួបទាំងអស់គ្នាសុទ្ធតែបានចូលរៀន តែកម្រិតនៃការរៀនសូត្ររបស់ពួកគេវាអាស្រ័យលើការជួយ គាំទ្រហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល។ ទោះដូច្នេះក្តី នៅក្នុងគ្រួសារធម៌ខ្លះ អ្នកថែទាំកូនធម៌មានការលំបាកក្នុងការចុះឈ្មោះកូនធម៌ចូលរៀននៅក្នុងសាលារដ្ឋ ដោយសារមិនមានលិខិតបញ្ជាក់កំណើត។

*ការទទួលបានបុគ្គលិកសង្គមកិច្ច៖*

ភស្តុតាងបែបគុណភាពបង្ហាញថា គ្រួសារធម៌ជាធម្មតា បានទទួល បុគ្គលិកសង្គមកិច្ច តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមនៅក្នុងការទុកដាក់ កុមារនៅក្នុងគ្រួសារធម៌ ប៉ុន្តែមានភស្តុតាងបញ្ជាក់ថា មិនមែនមានបុគ្គលិកសង្គមកិច្ចជាក់លាក់ណា តែមួយដែលត្រូវបានកំណត់ឱ្យទទួលខុសត្រូវលើករណីឡើយ គឺមានបុគ្គលិកសង្គមកិច្ចជា ច្រើនផ្សេងៗ គ្នាដែលបានចុះមកជួប។ ការចុះមកជួបនេះគឺដើម្បីពិនិត្យមើលថាតើអ្វីៗគ្រប់យ៉ាងមានដំណើរការប្រព្រឹត្ត ទៅបានល្អ ដែរឬទេ នៅក្នុងការទុកដាក់នេះ។ ចម្លើយខាងក្រោមពីកុមារាម្នាក់រស់នៅជាមួយគ្រួសារធម៌ក្នុងខេត្តសៀមរាបបង្ហាញអំពីបញ្ហានេះយ៉ាងច្បាស់។

*តើមាន "បុគ្គលិកសង្គមកិច្ច" ឬ នរណាម្នាក់ត្រូវបានគេចាត់តាំងជាពិសេសឱ្យមកជួយអ្នក ដែរឬទេ ?*

*បាទ! មានបុគ្គលិកសង្គមកិច្ច ៤នាក់បានចុះមកជួបពួកយើងជាបន្តបន្ទាប់។ ខ្ញុំស្គាល់ពួកគេទាំងនោះ។ ក៏ប៉ុន្តែពួកគេមិននិយាយជាមួយយើងនោះទេ។ ពួកគេគ្រាន់តែនិយាយជាមួយមីង និងពូ។ ភាគច្រើន នៅពេលពួកគេមក យើងខ្ញុំនៅឯសាលារៀន"។*[93]

## ការបណ្តុះបណ្តាល

ឪពុកម្តាយធម៌មួយចំនួនដែលបានសម្ភាសសម្រាប់ការសិក្សានេះបង្ហាញថា ពួកគេបានទទួលការបណ្តុះបណ្តាលអំពីការថែទាំកុមារ និង កិច្ចការពារកុមារ ពីអង្គការពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារ។ ក្នុងចំណោមអ្នកថែទាំកូនធម៌ចំនួន ១០នាក់ ដែលបានធ្វើអង្កេតបែបបរិមាណ បានបង្ហាញថាមាន ៨នាក់ បានប្រាប់ឲ្យដឹងថា អង្គការមិនមែនរដ្ឋាភិបាល បានផ្តល់ការបណ្តុះបណ្តាលដល់ពួកគេ ហើយមានម្នាក់បានបង្ហាញថាតំណាងមកពីមន្ទីរ ស.អ.យ បានផ្តល់ការបណ្តុះបណ្តាល។[94]

## ការចំណាយ និងការផ្តល់មូលនិធិ

យើងមានការលំបាក ក្នុងការប៉ាន់ប្រមាណអំពីការចំណាយសរុបទៅលើការថែទាំដោយឪពុកម្តាយធម៌ ហើយការសិក្សានេះក៏គ្មានគោលបំណងធ្វើការប៉ាន់ប្រមាណទៅលើការចំណាយនេះដែរ។ បើប្រៀបធៀបជាមួយការថែទាំដោយសាច់ញាតិ ការសិក្សានេះមិនបានពិនិត្យមើលការ ចំណាយទៅ លើការត្រួតពិនិត្យ

93 សម្ភាសកុមាររស់នៅក្នុងការថែទាំដោយឪពុកម្តាយធម៌ ខេត្តសៀមរាប ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៦។

94 ត្រូវចងចាំថាសំណាកនេះមិនតំណាងឲ្យគ្រួសារធម៌នៅក្នុងប្រទេសកម្ពុជាទាំងអស់នោះទេ ហើយអ្នកផ្តល់ចម្លើយចំពោះការអង្កេតនេះត្រូវបានជ្រើសរើសជាសំណាកសម្រាប់គោលបំណងជាក់លាក់។

តាមដាននោះទេ ប៉ុន្តែ វាគ្រាន់តែពិនិត្យមើលទៅលើការចំណាយដោយផ្ទាល់ទៅ លើអ្នកថែទាំកូនធម៌តែប៉ុណ្ណោះ។ បើទោះបីជាការថែទាំដោយឪពុកម្តាយធម៌អាចចាត់ទុកថាជាទម្រង់ថែទាំជំនួសមួយដែលមិនសូវចំណាយច្រើន នៅក្នុងប្រទេសកម្ពុជា និង មានតម្លៃទាបជាងជាងការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំក៏ដោយ ប៉ុន្តែវាក៏នៅតែត្រូវចំណាយច្រើន និងត្រូវបន្តផ្តល់ការគាំទ្រ ដរាបណាកុមារនៅតែស្ថិតក្នុងការថែទាំដោយឪពុកម្តាយធម៌។ ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការទុកដាក់កូនធម៌នេះ បានមកពីអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ ប៉ុន្តែពុំមានភស្តុតាងនៅក្នុងការអង្កេតនេះបញ្ជាក់ថា មានការរួមចំណែកហិរញ្ញវត្ថុពីរដ្ឋាភិបាលកម្ពុជាឡើយ។ ការឧបត្ថម្ភប្រចាំខែ មានការប្រែប្រួលចាប់ពីគ្មានអ្វីសោះ រហូតដល់៧៥ដុល្លាសម្រាប់កុមារ១នាក់ ក្នុង១ខែ។

*ជាធម្មតាមិនមានការជួយគាំទ្រដល់គ្រួសារធម៌នោះទេ។ មានករណីតិចណាស់ដែលយើងបានជួយឧបត្ថម្ភដល់គ្រួសារធម៌នូវទឹកប្រាក់ពី ៣០-៤០ដុល្លាក្នុង១ខែ។*[95]

*ប្រសិនបើអ្នកទុកដាក់កុមារក្រោមការថែទាំដោយឪពុកម្តាយធម៌ តើអ្នកជួយឧបត្ថម្ភគាំទ្រអ្វីខ្លះ ដល់គ្រួសារធម៌ ? វាអាស្រ័យលើករណីនីមួយៗ។ ពេលខ្លះ ប្រសិនបើកុមារពិការ យើងផ្តល់ ប្រាក់ពី ៥០ ទៅ៧០ដុល្លា [ក្នុង១ខែ] និងផលិតផលអនាម័យខ្លួនប្រាណ ខោទឹកនោមក្មេង សាប៊ូកក់សក់ សម្លៀកបំពាក់ កញ្ចក់ឆ្លុះមុខ អង្ករ និងអាហារសម្រន់ខ្លះ។*[96]

ផ្ទុយពីការថែទាំដោយសាច់ញាតិ អង្គការមិនមែនរដ្ឋាភិបាលខ្លះផ្តល់ «បៀវត្សរ៍» ជូនឪពុកម្តាយធម៌សម្រាប់ការថែទាំកូនធម៌ បន្ថែមពីលើការឧបត្ថម្ភដែលផ្តល់ជូនដោយផ្ទាល់ដល់កុមារ។ ឧទាហរណ៍ អ្នកផ្តល់ចម្លើយសំខាន់ម្នាក់មកពីគម្រោង ការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង First បាននិយាយថា អង្គការមិនមែនរដ្ឋាភិបាលខ្លះបានផ្តល់ប្រាក់បៀវត្សរ៍ដល់អ្នកថែទាំកូនធម៌ ចាប់ពី ៥០ដុល្លា សម្រាប់ក្មេងម្នាក់ រហូតដល់ទឹកប្រាក់សរុបចំនួន ២០០ដុល្លាក្នុង១ខែ។[97]

មានហេតុផលដ៏ត្រឹមត្រូវក្នុងការផ្តល់ប្រាក់ខែដល់ឪពុកម្តាយធម៌៖ វាគឺជាការទទួលស្គាល់ តម្លៃនៃការងារដែលឪពុកម្តាយធម៌កំពុងធ្វើ នៅពេលមើលថែទាំកូនមិនមែនជាកូនបង្កើតរបស់ខ្លួន និងការមើលថែទាំប្រកបដោយវិជ្ជាជីវៈជាអ្នកថែទាំ។ លើសពីនេះ ឪពុកម្តាយធម៌ដែលទទួល បាននូវការ គាំទ្រ និង ប្រាក់ខែខ្ពស់អាចបន្តធ្វើការជូនអង្គការរយៈពេលវែង ដែលធ្វើឲ្យការវិនិយោគទៅលើការបណ្តុះបណ្តាល បន្ថែមទៀតទៅលើឪពុកម្តាយធម៌ក្លាយជាសកម្មភាពដែលមានតម្លៃ ដែលបង្កើននូវជំនាញ និងបទ ពិសោធន៍របស់ពួកគេក្នុងការចិញ្ចឹមកុមារ។ ការផ្តល់បៀវត្សរ៍ដល់អ្នកថែទាំ ក៏ធានាថាពួកគេអាចចំណាយ ពេលវេលាជាមួយកុមារ និង ពុំមានពួកគេណាម្នាក់ត្រូវបានបង្ខំឲ្យទៅរកការងារធ្វើនៅខាងក្រៅបន្ថែម ដើម្បីរកប្រាក់ឲ្យបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសាររបស់ពួកគេឡើយ។ ប៉ុន្តែ ក៏តែងមានការភ័យខ្លាចថា ការផ្តល់បៀវត្សរ៍បែបនេះនឹងលើកទឹកចិត្តមនុស្សឲ្យធ្វើអ្វីមួយខុសដោយដាក់ពាក្យសុំធ្វើជាឪពុកម្តាយធម៌។ ទោះដូច្នេះក៏ដោយ នេះគឺជាបញ្ហាមួយដែលអាចដោះស្រាយបាននៅក្នុងការប៉ាន់ប្រមាណអំពីឪពុកម្តាយធម៌និងនៅក្នុងការបណ្តុះបណ្តាល។

95 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
96 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តព្រះសីហនុ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
97 សម្ភាសតំណាងគម្រោង Family Care First រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។


Furby



© UNICEF Cambodia2015Antoine Raab

# ការថែទាំតាមវត្តអារាម

## លទ្ធផលរកឃើញសំខាន់ៗៈ ការថែទាំតាមវត្តអារាម

១. វត្តអារាម ផ្តល់ការថែទាំដល់ក្មេងប្រុស តែមានវត្តអារាមតិចតួចណាស់ ដែលផ្តល់ការថែទាំដល់ក្មេងស្រី។

២. វត្តអារាម ផ្តល់ការថែទាំដល់កុមារធំៗ ជាធម្មតាមានអាយុលើសពី ១០ឆ្នាំ។

៣. កុមារមករស់នៅតាមវត្តអារាម មានមូលហេតុចម្រុះ មានដូចជា ចង់បួសធ្វើជាព្រះសង្ឃ ដើម្បីបានរៀនសូត្រដោយសារនៅភូមិមិនមានសាលារៀន ឬមិនមានប្រាក់រៀន ដោយសារឪពុក ឬ ម្តាយរៀបការថ្មីឬដោយសារចំណាកស្រុកដោយសារគ្រួសារមិនមាន លទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ដោយសារឪពុកម្តាយ/គ្រួសាររបស់ពួកគេ មិនអាចគ្រប់ គ្រងលើអាកប្បកិរិយារបស់ពួកគេបាន ឬ ដោយសារអ្នកអាណាព្យាបាលរបស់ពួកគេរស់នៅ និង/ឬ ធ្វើការនៅក្នុងវត្តស្រាប់។

៤. ការកំណត់អត្តសញ្ញា និងការទុកដាក់កុមារនៅក្នុងវត្តអារាមមាន «លក្ខណៈមិនផ្លូវការ» ដោយមានការចូលរួមតិចតួចពីអង្គការមិនមែនរដ្ឋាភិបាល ឬពីតំណាងរដ្ឋាភិបាល។

៥. កុមារភាគច្រើននៅក្នុងការថែទាំដោយវត្តអារាម បានទទួលការសិក្សារៀនសូត្រ (ភាគច្រើននៅខាងក្រៅវត្ត)។

៦. ក្នុងវត្តខ្លះដែលយើងបានចុះទៅមើល កុមារមានអាហារហូបមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ ហើយត្រូវហូបអាហារសល់ពីព្រះសង្ឃ និង/ឬដូនជី។

៧. លក្ខខណ្ឌសម្ភារៈនៅក្នុងវត្ត មានសភាពមិនល្អ បើធៀបទៅនឹងប្រភេទនៃការថែទាំដទៃទៀត។

៨. ការត្រួតពិនិត្យតាមដានពីខាងក្រៅចំពោះវត្តអារាម នៅមានកម្រិតហើយពេលខ្លះមិនមានផង។

៩. កម្រិតនៃការពិនិត្យតាមដាន និងការថែទាំលក្ខណៈផ្ទាល់ខ្លួនដែលកុមារទទួលបាននៅក្នុងវត្ត រមែងតែងមានកម្រិតតិចតួចខ្លាំងណាស់។

១០. កុមាររស់នៅក្នុងវត្ត មិនបានទទួលការចុះមកជួបពីបុគ្គលិកសង្គមកិច្ចនោះទេ។

១១. ការថែទាំតាមវត្តអារាម ទទួលមូលនិធិពីការបរិច្ចាគរបស់ពុទ្ធសាសនិក នេះមានន័យថា ការផ្តល់មូលនិធិនេះមានសភាពមិនស្ថិតស្ថេរ។

១២. ភស្តុតាងបែបគុណភាពបង្ហាញថា មានការរំលោភបំពានលើរាងកាយ និងផ្លូវភេទ លើកុមារនៅក្នុងវត្តដែលនេះជាបញ្ហាដែលត្រូវតែធ្វើការដោះស្រាយ។

១៣. ពុំមានទំនាក់ទំនងការងារ រវាងវត្តអារាមដែលផ្តល់ការថែទាំដល់កុមារ និងមន្ទីរ ស.អ.យ ឡើយ។

យើងបានចុះទៅពិនិត្យមើលវត្តចំនួន ៧ នៅក្នុងរាជធានីខេត្តទាំង៥ សម្រាប់ការអង្កេតនេះ។ វាមានការពិបាកដើម្បីដឹងឲ្យប្រាកដនូវចំនួនកុមារដែលកំពុងរស់នៅក្នុងវត្ត បើទោះបីជាមានជំនួយមួយចំនួនពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារនៅក្នុង ២៥ រាជធានីខេត្ត ទូទាំងប្រទេសកម្ពុជា ដែលធ្វើឡើងដោយក្រសួង ស.អ.យ នាពេលថ្មីៗនេះក៏ដោយ។ ការសិក្សានេះបានកំណត់រកឃើញថាមានវត្តចំនួន ៦៥ និងមណ្ឌលអង្គការសាសនាដទៃទៀតដែលមានក្មេងស្រីចំនួន ៦៧៣នាក់ និងក្មេងប្រុសចំនួន ៦៧៦នាក់កំពុងស្នាក់នៅទីនោះ។[98] វាអាចថាចំនួនប៉ាន់ស្មាននៃកុមាររស់នៅតាមវត្តអារាមមានចំនួនទាបពេកដោយសារតែការថែទាំតាម វត្តអារាមភាគច្រើនមានលក្ខណៈមិនផ្លូវការ ដោយគ្មានការឃ្លាំមើលពីរដ្ឋាភិបាល។ ឧទាហរណ៍ នៅក្នុងរាជធានីខេត្តមួយចំនួនដែលយើងបានបញ្ចូលទៅក្នុងការសិក្សានេះបង្ហាញថា តួលេខអំពីចំនួន កុមាររស់នៅក្នុងវត្ត ដែលផ្តល់ការថែទាំដោយមន្ទីរធម្មការ និងសាសនាខេត្ត មានចំនួនទាបជាងចំនួនដែល បានរាយការណ៍ដោយព្រះសង្ឃគង់នៅក្នុងវត្ត។ បន្ថែមពីនេះទៀត ចំនួនក្មេងស្រីដែលស្ទើរស្មើនឹងចំនួនក្មេងប្រុស គឺជារឿងដ៏គួរឲ្យភ្ញាក់ផ្អើល។ កុមារដែលស្ថិតក្រោមការថែទាំតាមវត្តអារាមភាគច្រើនជាក្មេងប្រុស៖ មានតែវត្ត ៣ក្នុងចំណោមវត្តទាំង ៧ ដែលអ្នកស្រាវជ្រាវបានចុះសិក្សាប៉ុណ្ណោះ បានរាយការណ៍ថាពួកគេបានផ្តល់ការថែទាំដល់ក្មេងស្រី ក៏ដូចជា ក្មេងប្រុស ហើយវត្តទាំងនេះផ្តល់ការថែទាំដល់ក្មេងស្រីតិចជាងក្មេងប្រុស។ មានវត្តមួយក្នុងចំណោមវត្តទាំង ៤ បានផ្តល់ការរៀនសូត្រដល់ក្មេងស្រី និង បានពន្យល់ថា៖ *«ជាប្រពៃណីនៅក្នុងព្រះពុទ្ធសាសនា យើងមិនអាចប៉ះពាល់នារីភេទឡើយ ដូច្នេះយើងមិនមានកន្លែងសម្រាប់ក្មេងស្រីស្នាក់នៅនោះទេ។ ក្មេងស្រីទទួលបានការជួយគាំទ្រនូវអ្វីៗទាំងអស់លើកលែងតែកន្លែងស្នាក់នៅ ដូច្នេះពួកគេត្រូវទៅ គេងនៅឯផ្ទះវិញ»។*[99] ការដែលវត្តអារាម និង មណ្ឌលសាសនាដទៃទៀតត្រូវបានធ្វើការកំណត់ទីតាំងរួម បញ្ចូលគ្នាជាក្រុមតែមួយយ៉ាងដូច្នេះ ទំនងនឹងធ្វើឱ្យទិន្នន័យមិនអាចយកមកតំណាងឱ្យវត្តអារាមបាន អាស្រ័យដោយអង្គការសាសនាគ្រីស្តដែលត្រូវបានរាប់បញ្ចូលផងដែរ ពុំមានគោលនយោបាយ ដូចគ្នាសម្រាប់ ការអនុញ្ញាតឱ្យកុមារចូលស្នាក់នៅក្នុងកន្លែងសាសានាឡើយ។

វត្តដែលបានបញ្ចូលនៅក្នុងការសិក្សានេះ មានលក្ខណៈចម្រុះ ទំហំមិនដូចគ្នា និងផ្តល់ការថែទាំដល់កុមារចាប់ពីពី ៥នាក់រហូតដល់ ២០០នាក់។ ទោះបីអ្នកផ្តល់ចម្លើយដ៏សំខាន់ម្នាក់បានប្រាប់អ្នកស្រាវជ្រាវយើងថាកុមារទាំងអស់ដែលនៅក្នុងវត្តពួកគេកំពុងរស់នៅជាមួយព្រះសង្ឃដែលជាសាច់ញាតិរបស់ពួកគេក៏ដោយ ប៉ុន្តែជាក់ស្តែងករណីនេះពុំមែនយ៉ាងដូច្នេះឡើយ។ វត្តអារាមផ្តល់ការថែទាំដល់កុមារគ្រប់រូប តែជាវិធានទូទៅគឺមិនទទួលកុមារតូចពេកនោះទេ។ មានតែវត្តមួយប៉ុណ្ណោះដែលបានបញ្ចូលនៅក្នុងការសិក្សានេះ ថ្លែងថាខ្លួនបានផ្តល់ការថែទាំ ដល់កុមារអាយុចន្លោះ ៣-៦ឆ្នាំ ហើយជាងពាក់កណ្តាល នៃវត្តដែលមាននៅក្នុងការសិក្សានេះ បានរាយការណ៍ថា ពួកគេបានផ្តល់ការថែទាំដល់កុមារអាយុចាប់ពី ១០ឆ្នាំ។ ទោះជាដូច្នេះក៏ដោយ នេះមិនមែនជាគោលនយោបាយផ្លូវការឡើយ។ យោងតាមព្រះសង្ឃមួយអង្គដែលយើងបានសម្ភាសសម្រាប់ការសិក្សានេះបានមានសង្ឃដីកាថា៖ *«គ្មានការកំណត់អាយុសម្រាប់ការទទួលយកកុមារនោះទេ»។*[100]

98 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា «ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល» ខែមីនា ឆ្នាំ ២០១៦។ ចំនុចនេះប្រហែលមិនត្រូវបានអនុវត្តចំពោះជីដូន ឬកុមារជាសាច់ញាតិផ្សេងទៀតដែលត្រូវបានដូនជីថែទាំនោះទេ។

99 សម្ភាសព្រះចៅអធិការវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។

100 សម្ភាសព្រះចៅអធិការវត្ត រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៦។

អ្នកផ្តល់ចម្លើយមួយចំនួននៅក្នុងការសិក្សានេះ បានពន្យល់ថា ជាប្រពៃណី វត្តអារាមត្រូវបាន គេចាត់ទុកថាជាឋានសួគ៌នៃចំណេះវិជ្ជា វិន័យ និងសប្បុរសធម៌ ហើយមានប្រពៃណីជួយដល់អ្នកដែលមានតម្រូវការ៖

*គ្រួសារក្រីក្រ បញ្ជូនកូនរបស់ពួកគេមកវត្ត ពីព្រោះពួកគេជាពុទ្ធសាសនិក ហើយពួកគេយល់ ថាព្រះពុទ្ធសាសនាគឺជាឆ័ត្រដ៏ធំមួយ ឬជាជម្រកសម្រាប់មនុស្សគ្រប់គ្នា - ជាប្រពៃណី នេះគឺជាទំនៀមទម្លាប់របស់សហគមន៍យើង ក្នុងការផ្តល់ការជួយគាំទ្រដល់អ្នកដែលមានតម្រូវការ... ថ្នាក់ដឹកនាំ របស់យើងមួយចំនួន រួមទាំងនាយករដ្ឋមន្ត្រីផង ក៏ធ្លាប់ជាក្មេងវត្តដែរ។ នេះគឺជាវប្បធម៌ និងប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរយើង។*[101]

វត្តជាច្រើនដែលយើងបានចុះទៅសិក្សាសម្រាប់ការអង្កេតនេះ បានទទួលកុមារឱ្យស្នាក់នៅលើសពីសមត្ថភាពទទួលយករបស់ខ្លួន ហើយព្រះសង្ឃបានពន្យល់ថានៅក្នុង ដំណើរការនៃការទទួលក្មេងមកស្នាក់នៅ (មានលំអិតនៅខាងក្រោម) ក្មេងទាំងនោះកម្រត្រូវបានបដិសេធការសុំមកស្នាក់នៅក្នុងវត្តណាស់៖ *"យើងមិនដែលបដិសេធក្មេងៗនោះទេ....អាត្មាមិនដែលមានសង្ឃដីកាថាកន្លែងរបស់យើងពេញអស់នោះទេ ពីព្រោះបើអាត្មាមានសង្ឃដីកាបែបនេះ ក្មេងនឹងតូចចិត្ត និងអស់សង្ឃឹមចំពោះអនាគតរបស់វា។ ទោះកន្លែងចង្អៀតប៉ុណ្ណា ពួកគេត្រូវចែករំលែកជាមួយគ្នា"។*

## ប្រវត្តិកុមារ

លទ្ធផលដែលបានរកឃើញពីការសិក្សា បង្ហាញថាកុមារដែលរស់នៅក្នុងវត្តគឺដោយសារមូលហេតុមួយចំនួន។ ឧទាហរណ៍ ក្នុងករណីខ្លះ កុមារចង់បួសធ្វើជាកូននេនហើយក៏ទៅ ស្នាក់នៅក្នុងវត្តសម្រាប់គោលបំណងជាក់លាក់នេះ។ កុមារទាំងនេះចូលទៅដោយមានការអនុញ្ញាតពីឪពុកម្តាយរបស់ពួកគេ គឺពួកគេចូលទៅសិក្សាអំពីព្រះធម៌ និងប្រតិបត្តិតាមព្រះធម៌។ ពួកគេអាចស្នាក់នៅទីនោះ ២សប្តាហ៍ ឬ ២ ឬ ៣ខែ ឬ ជាអចិន្ត្រៃយ៍ ប្រសិនបើពួកគេចង់នៅធ្វើជាសង្ឃ។ ទោះបីជាពួកគេមិនមានតម្រូវការការថែទាំជំនួសក៏ដោយ ក៏ពួកគេស្ថិតនៅក្រោមការមើលថែទាំពីវត្ត ហើយការធ្វើបែបនេះ វាស្ថិតនៅក្នុងនិយមន័យដែលមាននៅក្នុងប្រកាសស្តី ពីបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍។

ក្រុមកុមារទី២ តាមការរាយការណ៍បានឱ្យដឹងថា ពួកគេមករស់នៅក្នុងវត្តដើម្បីបានរៀនសូត្រ ភាគច្រើនរៀនថ្នាក់មធ្យមសិក្សា។ មានកុមារជាច្រើន បើមិនស្ទើរទាំងអស់ទេនោះ បានមកពីតំបន់ជនបទដែលមិនមានសាលាវិទ្យាល័យ ឬ ក៏មានដែរ តែគុណភាពមិនល្អ។ ភាគច្រើននៃកុមារទាំងនេះគឺជាកុមារមកពីគ្រួសារ "ក្រីក្រ"។[102] យើងមិនច្បាស់អំពីកុមារទាំងនេះទេថាតើឪពុកម្តាយមិនមានប្រាក់ឲ្យកុមារបង់ថ្លៃសិក្សាថ្នាក់មធ្យមសិក្សា ឬ ឪពុកម្តាយយល់ថាការសិក្សា ថ្នាក់មធ្យមសិក្សា នៅតំបន់ទីក្រុង (ដែលវត្តតាំងនៅ) វាផ្តល់អត្ថប្រយោជន៍ច្រើនជាងដល់កុមារ ប៉ុន្តែគ្រួសារទាំងនោះមិនអាចរ៉ាប់រងបង់ថ្លៃសិក្សា ថ្លៃស្នាក់នៅ និងថ្លៃថែទាំសម្រាប់កូនរបស់ពួក គេនៅទីក្រុង។

កុមារដែលរស់នៅក្នុងវត្ត មិនបង់ថ្លៃសិក្សា ឬបង់ថ្លៃស្នាក់របស់ពួកគេនោះទេ។ ក្នុងករណីដ៏កម្រប្រសិនបើកុមាររៀនពូកែ ហើយចង់បន្តចូលសាកលវិទ្យាល័យ តាមការរាយការណ៍ថា វត្តខ្លះបន្តផ្តល់កន្លែងស្នាក់នៅ និង អាហារដោយឥតយកកម្រៃ ព្រមទាំងស្វែងរកការគាំទ្រ ដើម្បីជួយ បង់ថ្លៃសិក្សានៅសាកលវិទ្យាល័យទៀតផង។ លើសពីនេះ គ្រួសារពួកគេជឿថាតាមរយៈការស្នាក់ នៅជាមួយព្រះសង្ឃនៅក្នុងវត្ត កូនរបស់ពួកគេ

101 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
102 ដូចបានរៀបរាប់ខាងលើ ពាក្យថា "ក្រីក្រ" ត្រូវបានប្រើប្រាស់ដើម្បីពណ៌នាអំពីស្ថានភាពហិរញ្ញវត្ថុមួយដ៏ទូលំទូលាយ។

នឹងរៀនធ្វើអាកប្បកិរិយាល្អ និង មិនទទួលរងឥទ្ធិពល មិនល្អនៅក្នុងវ័យជំទង់របស់ពួកគេឡើយ។ ចំពោះក្រុមកុមារនេះ វត្តអារាមហាក់ដូចជាដើរ តួនាទីពាក់ កណ្តាលជាសាលារៀនផ្តល់កន្លែងស្នាក់នៅ (ទោះបីជាកុមាររៀននៅសាលាក្រៅវត្តក៏ដោយ) និងជាលំនៅដ្ឋានគាំទ្រមួយដល់កុមារ។

ក្រុមកុមារទី ៣ មករស់នៅក្នុងវត្តដោយមូលហេតុស្រដៀគ្នាទៅនឹងក្រុមទី ២ ដែរ តែកុមារទាំងនេះមានទំនាក់ទំនងជាមួយព្រះសង្ឃដែលគង់នៅក្នុងវត្តនោះ។ ជាញឹកញាប់ ព្រះសង្ឃ មានទស្សនៈថា វាមានប្រយោជន៍ខ្លាំងណាស់សម្រាប់ក្មេងប្រុស ជាសាច់ញាតិរបស់ពួកគេមក រស់នៅ ក្នុងវត្តនៅពេលពួកគេមានវ័យជំទង់ ដូច្នេះ ពីព្រោះការសិក្សារៀនសូត្រ រួមទាំងបរិយាកាស នៅក្នុងវត្តមានលក្ខណៈអំណោយផលច្រើនសម្រាប់ការរៀនសូត្រ ព្រមទាំងអាចជួយដល់ឪពុកម្តាយ ដែលរមែងតែងមានកូនផ្សេងទៀតសម្រាប់អបរំផងដែរ។

ក្រុមកុមារទី ៤ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងកុមារដែលស្ថិតនៅក្នុងការថែទាំដោយសាច់ញាតិ និងការថែទាំដោយ ឪពុកម្តាយធម៌។ កុមារទាំងនេះគឺជាកុមារដែលឪពុកម្តាយរបស់ពួកគេបានធ្វើចំណាកស្រុក ឬរៀបការម្តង ទៀត (ហើយកុមារត្រូវបានបដិសេធមិនឲ្យរួមរស់នៅជាមួយ) ឬ កុមារដែលឪពុកម្តាយមានជំងឺធ្ងន់ធ្ងរពុំមាន លទ្ធភាពមើលថែពួកគេបាន  កុមារដែលឪពុកម្តាយបានស្លាប់ចោល ឬកុមារងាយរងគ្រោះពីគ្រោះថ្នាក់ ផ្សេងៗ (ពេលខ្លះក៏មានក្មេងស្រីដែរ) ប្រសិនបើពួកគេរស់នៅជាមួយគ្រួសារ។ ពួកគេអាចត្រូវបានសាច់ញាតិនាំទៅវត្ត ដែលជាញឹកញាប់គឺជីដូន នៅពេលដែលឪពុកម្តាយបានធ្វើចំណាកស្រុក ឬត្រូវបានមេភូមិយកទៅប្រគល់ឲ្យវត្ត។ កុមារជាច្រើនដែលយើងបានសម្ភាស សម្រាប់ការសិក្សានេះដែលស្ថិតនៅក្នុងទម្រង់ផ្សេងទៀតនៃការថែទាំ ធ្លាប់បានរស់នៅក្នុងវត្ត ឬមានបងប្អូនបង្កើតស្នាក់នៅក្នុងវត្ត។

ក្រុមកុមារទី ៥ គឺជាកុមារដែលរស់នៅជាមួយដូនជីនៅក្នុងវត្ត។ មានតែវត្តចំនួន ២ប៉ុណ្ណោះ ដែលយើងបានចុះជួបមានដូនជី ហើយមានដូនជីនៅក្នុងវត្តមួយនៃវត្តទាំង ២ ត្រូវបានសម្ភាស។ នៅក្នុងវត្តនេះដូនជីភាគច្រើនជាស្ត្រីចំណាស់ និងមេម៉ាយ។ វត្តអនុញ្ញាតឲ្យពួកគេយកចៅ ឬសាច់ញាតិ ជិតដិត (មានទាំងក្មេងប្រុស និងក្មេងស្រី) មករស់នៅជាមួយពួកគេ។ កុមារចូលរៀននៅសាលារដ្ឋខាង ក្រៅវត្តហើយមានទំនាក់ទំនងតិចតួចជាមួយទិដ្ឋភាពដទៃទៀតនៃជីវិតក្នុងវត្ត។ មានករណីមួយចំនួនតូចដែលកុមាររស់នៅក្នុងវត្តដើម្បីមើលថែទាំជីដូនដែលជាដូនជី តែក្នុងករណី ផ្សេងទៀត ជីដូនដែលជាដូនជី គឺជាអ្នកមើលថែទាំចៅ។ ក្រុមកុមារចុងក្រោយនេះ  ជាក់ស្តែងណាស់  គឺពួកគេស្ថិតនៅក្នុងក្រុមកុមារទទួលបានការថែទាំជំនួសអាស្រ័យដោយវាមាន លក្ខណៈជា ការថែទាំ ដោយសាច់ញាតិ ជាជាងការថែទាំដោយវត្តអារាម។ ទោះដូច្នេះក្តី កុមារទាំងនេះកំពុង រស់នៅក្នុង បរិវេណវត្ត និងស្ថិតក្រោមនិយមន័យនៃកុមារដែលស្ថិតក្នុងការថែទាំជំនួស ដូចមានចែងនៅក្នុង ប្រកាស ស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍។

ដូច្នេះ ទោះបីជាវត្តអារាមគឺជាកន្លែងស្នាក់នៅសម្រាប់ក្រុមកុមារផ្សេងៗក៏ដោយ ក៏វត្តទាំងនេះត្រូវបានគ្របដណ្តប់ដោយប្រការ ២ នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ដែរ បើទោះបីជាកុមារមករស់នៅក្នុងវត្ត ក្នុងគោលបំណងដើម្បីសិក្សារៀនសូត្រ ឬរស់នៅជាមួយជីដូនដែលជាដូនជីក៏ដោយ។

*ប្រការ ២៖ ការថែទាំតាមវត្តអារាម និងកន្លែងសាសនាដទៃទៀត គឺជាការថែទាំដែលផ្តល់ជូនកុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងអង្គការសាសន៍នានា ដែលផ្តល់ឱ្យកុមារ នូវតម្រូវការមូលដ្ឋានរបស់ពួកគេនៅក្នុងវត្ត និងកន្លែងសាសនាដទៃទៀត។*

## ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

លទ្ធផលនៃការស្រាវជ្រាវនៅក្នុងរាជធានីខេត្តទាំង ៥ បង្ហាញថាដំណើរការបញ្ជូនកុមារទៅរក ការថែទាំនៅក្នុងវត្តអារាមត្រូវបានធ្វើឡើងក្នុងលក្ខណៈមិនផ្លូវការ។ គ្រួសារស្គាល់អំពីវត្តតាមរយៈការនិយាយតៗគ្នា ហើយកុមារត្រូវបានបញ្ជូនទៅរស់នៅក្នុងវត្តតាមរយៈ ឪពុកម្តាយ ឬសាច់ញាតិ ឬអ្នកជិតខាង ឬអាជ្ញាធរភូមិ៖

*ភាគច្រើននៃកុមារទាំងនេះ មកពីខេត្តជិតខាង ជាខេត្តនៅទីជនបទ។ ការទទួលកុមារឱ្យចូលស្នាក់នៅក្នុងវត្តមានលក្ខណៈមិនផ្លូវការ ដោយត្រូវបានធ្វើឡើងក្នុង លក្ខណៈចំពោះកិច្ច។ ភាគច្រើនឪពុកម្តាយ ឬ សាច់ញាតិបានមកជួបអាត្មា ហើយសួរថាតើ អាត្មាអាចទទួលយកកូនរបស់ពួកគេបានដែរឬទេ។*[103]

*មិនមានការធ្វើការប៉ាន់ប្រមាណ ឬការចុះមកពិនិត្យជាក់ស្តែងនោះទេ។ កុមារភាគច្រើនត្រូវបានជីដូនទាំមកបន្ទាប់ពីឪពុកម្តាយរបស់កុមារធ្វើចំណាកស្រុកទៅរកការងារធ្វើ។ ពេលខ្លះអាត្មាបានទៅខេត្តផ្សេង តែពេលត្រឡប់មកវិញឃើញកុមារចូលថ្មីមករស់នៅពេញវត្ត!*[104]

ព្រះសង្ឃគង់នៅវត្ត បានពន្យល់ថាព្រះអង្គគ្រាន់តែជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន អំពីការទុកដាក់កុមារក្នុងករណីដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាលកុមារមិនមានវត្តមាន។ ចំនុចនេះផ្ទុយពីប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ដែលចែងថា *"គប្បីជូនដំណឹងទៅអាជ្ញាធរឃុំ នៅពេលមានកុមារមករស់នៅក្នុងការថែទាំឯកន្លែងណាមួយ"*។[105]

ក្រៅពីការទទួលកុមារដែលត្រូវគេបញ្ជូនមក ព្រះសង្ឃខ្លះនៅក្នុងវត្តបានមានសង្ឃដីកាថាម្តងម្កាលព្រះអង្គបានជ្រើសរើសកុមារមករស់នៅក្នុងវត្តដោយអង្គឯង។ ព្រះសង្ឃមួយអង្គមានសង្ឃដីកា ប្រាប់អ្នកស្រាវជ្រាវថា៖ *"ពេលខ្លះអាត្មាធ្វើដំណើរទៅភូមិនៅទីជនបទ។ នៅពេលទៅដល់ទីនោះ អាត្មាជ្រើសរើសកុមារនៅធ្វើការនៅចម្ការកៅស៊ូឱ្យមករស់នៅក្នុងវត្ត។"*[106]

ជាចុងក្រោយ បើទោះបីកុមារភាគច្រើននិយាយថា ការសម្រេចចិត្តទុកដាក់ពួកគេនៅ ក្នុងវត្តគឺជាការសម្រេចចិត្តរបស់ឪពុក ឬម្តាយ ឬសាច់ញាតិក៏ដោយ ប៉ុន្តែក្នុងករណីខ្លះ កុមារបានរាយការណ៍ឱ្យដឹងផងដែរថាពួកគេស្ម័គ្រចិត្តមករស់នៅក្នុងវត្តដោយខ្លួនឯង។

*តើអ្នកបានជ្រើសរើសមករស់នៅក្នុងវត្តនេះ យ៉ាងដូចម្តេច?*

*មានការប្រកាសថាវត្តនេះត្រូវការព្រះសង្ឃច្រើនអង្គបន្ថែមទៀត។ នៅពេលនោះមានព្រះសង្ឃនិមន្ត មកពីប្រទេសថៃមកធ្វើទស្សនកិច្ច ហើយចង់ធ្វើជាអធិបតីនៅក្នុងពិធីបំបួសនាគ។ [នៅពេលអាត្មាសួរឪពុកម្តាយរបស់អាត្មា] ពួកគាត់សប្បាយចិត្តហើយបានលើកទឹកចិត្តឲ្យអាត្មានៅធ្វើជាសង្ឃជាច្រើនឆ្នាំតាមដែលអាត្មាអាចធ្វើបាន។ ពួកគាត់ចង់ឲ្យអាត្មារៀនព្រះធម៌ឲ្យបានច្រើនតាមដែលអាចធ្វើបាន។*[107]

---

103 សម្ភាសព្រះសង្ឃ/អ្នកថែទាំជាក្រុមនៅវត្ត ខេត្តបាត់ដំបង ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦។
104 សម្ភាសព្រះចៅអធិការវត្ត ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៦។
105 បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស។ ប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសតាមសហគមន៍ ការទទួលខុសត្រូវរបស់អ្នកផ្តល់ការថែទាំជំនួស ឆ្នាំ ២០០៨ ប្រការ ៦.២។
106 សម្ភាសព្រះសង្ឃ/អ្នកថែទាំជាក្រុមនៅវត្ត ខេត្តបាត់ដំបង ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦។
107 សម្ភាសនេននៅវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។

តំណាងមកពីវត្តនៃរាជធានីខេត្តទាំង ៥បានរាយការណ៍ថា មិនមានការធ្វើការប៉ាន់ប្រមាណអំពីស្ថានភាពកុមារនៅផ្ទះ ឬមុនមានការទទួលកុមារចូលស្នាក់នៅក្នុងវត្តនោះទេ។ អ្នកផ្តល់ចម្លើយបានរៀបរាប់ដំណើរការនៃការទទួលកុមារចូលស្នាក់នៅក្នុងវត្តថាជាដំណើរការដ៏សាមញ្ញ៖

*តើមានដំណើរការដូចម្តេចខ្លះ ដើម្បីទទួលបានការយល់ព្រមឲ្យស្នាក់នៅទីនេះ ?*

*ឪពុកម្តាយរបស់ខ្ញុំ បាននាំខ្ញុំមកទីនេះហើយបាននិយាយជាមួយចៅអធិការវត្ត ហើយគេក៏ទទួលយកខ្ញុំទៅ។*

*តើមានលក្ខខណ្ឌអ្វីខ្លះទេ ?*

*យើងត្រូវចូលរៀន បើមិនដូច្នេះទេវត្តនឹងដេញយើងចេញ។*[108]

*តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលអ្នកប្រើសម្រាប់ទទួល ឬបដិសេធកុមារ ?*

*កុមារត្រូវមកពីទីជនបទ ឬតំបន់ឆ្ងាយដាច់ស្រយាល។ សំខាន់កុមារត្រូវមានចិត្តចង់រៀនសូត្រ។*[109]

ដូចដែលមានបញ្ជាក់នៅក្នុងសម្រង់សំដីខាងលើ លក្ខណៈវិនិច្ឆ័យទទួលកុមាររបស់វត្តមាន ទំនោរផ្អែកលើតម្រូវការផ្អែកសម្ភារៈរបស់កុមារ និងការតាំងចិត្តរៀនសូត្រ និងអាកប្បកិរិយាមាយាទ ល្អរបស់កុមារ។ វត្តអារាម ហាក់ដូចជាប្រកាន់យកវិធីសាស្ត្រចិត្តសប្បុរសធម៌ក្នុងការទទួលកុមារ ហើយកម្រមានការបដិសេធចំពោះសំណើសុំស្នាក់នៅខ្លាំងណាស់។

## ការត្រួតពិនិត្យតាមដាន

ជាក់ស្តែង ការត្រួតពិនិត្យតាមដានការថែទាំដែលផ្តល់នៅក្នុងវត្តអារាមមិនសូវមាន ឬ គ្មានការត្រួតពិនិត្យតាមដានទាល់តែសោះ។ អ្នកថែទាំ (នៅក្នុងវត្ត) ដែលបានសម្ភាស សម្រាប់ការ សិក្សានេះ គ្មាននរណាម្នាក់បានរាយការណ៍ថាវត្តរបស់ពួកគេ ត្រូវបានមន្ត្រី ពីខាងក្រៅចុះមក មើល ឬ ត្រួតពិនិត្យតាមដាននោះទេ។ មន្ទីធម្មការ និង សាសនារាជធានីខេត្ត គឺជាស្ថាប័នរដ្ឋាភិបាល ដែលមានការ ទទួលខុសត្រូវពិនិត្យតាមដានលើវត្តអារាម។ បើទោះជាដូច្នេះក្តី យោងតាមតំណាងមន្ទីរធម្មការ និងសាសនា បានឲ្យដឹងថា ការចុះមកជាទៀតទាត់មិនបានធ្វើគ្រប់វត្តនោះទេ ហើយក៏មិនមានការបង្កើតយន្តការពិនិត្យតាមដានលើការងារថែទាំកុមារដែលផ្តល់ដោយវត្តដែរ៖

*ខ្ញុំជាអនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត។ យើងត្រួតពិនិត្យមើលវត្តអារាម ព្រមទាំងអង្គការសាសនាដទៃទៀត។ មន្ទីររបស់យើងមិនមានការងារធ្វើទាក់ទងនឹង ការថែទាំកុមារនោះទេ។ ប៉ុន្តែថ្មីៗនេះមន្ទីរបានចាប់ផ្តើមលើកទឹកចិត្តវត្តឲ្យផ្តល់ជម្រកអាហារ និងការអប់រំរៀនសូត្រដល់ កុមារងាយរងគ្រោះ។*[110]

ជាក់ស្តែងលទ្ធផលដែលបានរកឃើញពីការសិក្សា ក៏បានបញ្ជាក់ថាក្រសួង ស.អ.យ មិនបានធ្វើការត្រួតពិនិត្យ

108 សម្ភាសនេននៅវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
109 សម្ភាសព្រះសង្ឃ/អ្នកថែទាំជាក្រុមនៅវត្ត ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
110 សម្ភាសតំណាងមន្ទីរធម្មការ រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។

ឬ ផ្តល់ការជួយគាំទ្រដល់សេវាថែទាំតាមវត្តអារាមនោះទេ។ សម្រង់សំដីខាងក្រោមពីតំណាងមន្ទីរ ស.អ.យ ក្នុងខេត្តបាត់ដំបង មានភាពស្របគ្នាជាមួយលទ្ធផល ដែលបានរកឃើញពីខេត្តដទៃទៀត៖

*តើអ្នកធ្លាប់ទុកដាក់កុមារនៅក្នុងវត្ត ដែរឬទេ ?*

*ទេ ! ខ្ញុំមិនដែលពាក់ព័ន្ធជាមួយការទុកដាក់កុមារនៅក្នុងវត្តអារាមនោះទេ។ ខ្ញុំក៏មិនដែលចុះធ្វើអធិការកិច្ចក្នុងវត្តផងដែរ។ មានតែមន្ទីរធម្មការប៉ុណ្ណោះដែលដឹងថាតើកុមាររស់នៅក្នុងវត្តមានសុខទុក្ខដូចម្តេចនោះ។*[111]

កង្វះការត្រួតពិនិត្យតាមដាននេះ ពុំមានភាពស្របគ្នាទៅនឹងខ្លឹមសារនៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ ដែលតម្រូវឲ្យអ្នកផ្តល់សេវាថែទាំជំនួស *«ទទួលខុសត្រូវចំពោះការចុះតាមដានជាប្រចាំ និងជាបន្តបន្ទាប់ ទៅលើការទុកដាក់កុមារនៅក្នុងវត្តអារាម និងនៅក្នុងការថែទាំដោយអង្គការសាសនាផ្សេងទៀត រួមទាំងផ្ទះស្នាក់នៅជាក្រុមផងដែរ ដើម្បីធានាថាទីកន្លែងទាំងនោះគោរពតាមបទដ្ឋានអប្បបរមា»* ( ប្រការ ៦ )។

## ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត

ទាំងព្រះសង្ឃ និង មន្ទីរ ស.អ.យ មិនបានចូលរួមនៅក្នុងការរក្សាទំនាក់ទំនង ឬធ្វើការសម្របសម្រួលទំនាក់ទំនងរវាងកុមារ និងគ្រួសាររបស់ពួកគេ ក្នុងអំឡុងពេលកុមារស្នាក់នៅក្នុងវត្តនោះទេ។ លើសពីនេះ ទាំងព្រះសង្ឃ និង មន្ទីរ ស.អ.យ ក៏មិនបានរាយការណ៍ថា ពួកគេបានចូលរួមនៅក្នុងការបង្រួបបង្រួមកុមារជាមួយគ្រួសារ នៅពេលដែលកុមារ សម្រេចចិត្ត ចាកចេញពីវត្ត ឬបានបញ្ចប់ការសិក្សាដែរ។

វត្តខ្លះរាយការណ៍ថាបានផ្តល់ព័ត៌មានដល់មន្ទីរធម្មការ និងសាសនា អំពីចំនួនកុមារដែលរស់នៅក្នុងវត្ត។ ប៉ុន្តែ បើទោះជាដូច្នេះក្តី ព័ត៌មាននេះទំនងមានភាពសុក្រិតតិចតួចណាស់ និងមានការផ្តល់ព័ត៌មានបែបនេះក្នុងលក្ខណៈចំពោះកិច្ចប៉ុណ្ណោះ៖

*កិច្ចសម្ភាសជាមួយមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ៖*

*ពេលខ្លះយើងមិនអាចធ្វើអធិការកិច្ចលើវត្តបាននោះទេ ពីព្រោះពួកគេមិនប្រាប់យើងថាពួក គេមានក្មេងមករស់នៅទីនោះ។ ពេលខ្លះក្មេងទាំងនោះជាសាច់ញាតិរបស់ព្រះសង្ឃ ដូច្នេះយើងមិនបានរាប់បញ្ចូលពួកគេនោះទេ។*

*កិច្ចសម្ភាសជាមួយមន្ទីរធម្មការ និង សាសនា ខេត្តបាត់ដំបង៖*

*ជាធម្មតា ព្រះចៅអធិការវត្ត រាយការណ៍អំពីកុមារម្នាក់ៗដែលរស់នៅក្នុងវត្តដល់ការិយាល័យ ធម្មការ និងសាសនាស្រុក។ ប៉ុន្តែ យើងនៅតែមិនដឹងថា តើមានកុមារប៉ុន្មាននាក់កំពុង រស់នៅក្នុងវត្តនៅខេត្តបាត់ដំបង... នេះដោយសារតែការរាយការណ៍មកមន្ទីរធម្មការ និងសាសនា មិនមែនជាលក្ខខណ្ឌតម្រូវជាកាតព្វកិច្ច។ ព្រះចៅអធិការខ្លះ រាយការណ៍អំពីចំនួនកុមារខ្លះទៀតក៏មិនបានរាយការណ៍។ ខ្លះរាយការណ៍ដោយផ្ទែក។ បញ្ហាគឺថាកុមារក៏ផ្លាស់ពីវត្តមួយ ទៅវត្តមួយទៀតផងដែរ ជាពិសេសអ្នកដែលចង់បួសធ្វើជាព្រះសង្ឃ។*[112]

111 សម្ភាសតំណាងមន្ទីរ សអយ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
112 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។

## លក្ខណៈនៃការថែទាំដែលបានផ្ដល់ជូន

### *លក្ខខណ្ឌសម្ភារៈនៅក្នុងវត្តៈ*

បើទោះបីជាលក្ខខណ្ឌនៅក្នុងវត្តពុំដូចគ្នាក៏ដោយ ជាទូទៅ លក្ខខណ្ឌទាំងនោះមិនសូវល្អឡើយ បើធៀបទៅនឹងលក្ខខណ្ឌនៅក្នុងការថែទាំដោយឪពុកម្ដាយធម៌ ផ្ទះស្នាក់នៅជាក្រុម និងមណ្ឌលថែទាំកុមារ។ វត្តជាច្រើនដែលយើងបានចុះជួបនៅក្នុងការសិក្សានេះ មិនមានអនាម័យ មានគំនរសម្រាមជុំវិញអគារ និងនៅលើដី។ វត្តជាច្រើនមិនមានប្រព័ន្ធលូបង្ហូរទឹក ហើយបន្ទប់ទឹកមិនដំណើរការ ឬស្ថិតក្នុងលក្ខខណ្ឌដែលមិនអាចទទួលយកបាន។

អ្នកថែទាំនៅក្នុងវត្ត ទទួលស្គាល់ថាមិនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ហើយចង់បាន មូលនិធិដើម្បីកែលំអ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ។ កុមារគេងនៅក្នុងបន្ទប់រួមគ្នា ហើយជាញឹកញាប់ គេងជាមួយព្រះសង្ឃ ឬ ជាមួយកុមារផ្សេងទៀតដែលរស់នៅក្នុងវត្ត។ ចំនួនមនុស្សនៅក្នុងបន្ទប់នៅក្នុងវត្តដែលយើងបានចូលមើលគឺមានមនុស្សចាប់ពី២នាក់ដល់ ១៥នាក់។ មានតែវត្តមួយប៉ុណ្ណោះដែលផ្ដល់ពូកសម្រាប់កុមារគេង ប៉ុន្តែពូកនេះចាស់ និង កខ្វក់ណាស់ទៅហើយ។ នៅក្នុងវត្តផ្សេងទៀត កុមារគេងលើកន្ទេល ឬ លើកម្រាលឥដ្ឋផ្ទាល់។ នៅក្នុងវត្តដែលមានកុមាររស់នៅជាមួយដូនជី លក្ខខណ្ឌរស់នៅរបស់ដូនជីពិតជាយ៉ាប់យ៉ឺនខ្លាំងណាស់។

នៅពេលសួរអំពីស្ថានភាពនៅក្នុងវត្ត កុមារភាគច្រើននិយាយថាគេពេញចិត្ត ឬ និយាយថាវាគ្រាន់បើជាងនៅផ្ទះ ដែលនេះប្រហែលជាដោយសារនៅផ្ទះរបស់ពួកគេ វាមានលក្ខខណ្ឌអន់ជាងវត្ត ជាពិសេសអ្នកដែលមកពីទីជនបទ។[113]

### *ការអប់រំរៀនសូត្រនៅក្នុងវត្តៈ*

ការអប់រំរៀនសូត្រមានសារៈសំខាន់ណាស់សម្រាប់ជីវិតរបស់កុមារនៅក្នុងវត្ត។[114] រាល់កុមារទាំងអស់ដែលស្ថិតក្រោមការថែទាំដោយវត្តអារាម ដែលត្រូវបានបញ្ចូលនៅក្នុងការសិក្សានេះ បាននិយាយថា ពួកគេបានទទួលការសិក្សារៀនសូត្រក្នុងកម្រិតផ្សេងៗគ្នា ដែលចំនុចនេះស្របទៅនឹងប្រការ ៥ នៃបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស ចំពោះកុមារតាម សហគមន៍។ ព្រះសង្ឃដែលមើលថែទាំកុមារទាំងអស់លើកលែងតែវត្តមួយដែលបានសម្ភាស នៅក្នុងការសិក្សា បានមានសង្ឃដីកាថាកុមារបានចូលរៀននៅសាលារដ្ឋ។ វត្តដែលលើកលែងនេះគឺនៅខេត្តកណ្ដាល វត្តនេះទំនងមានករណីដោយឡែកពីគេក្នុងការ ផ្ដល់ការអប់រំ អំពីផ្លូវលោកនៅក្នុងវត្ត ដែលបង្រៀនដោយគ្រូបង្រៀនរដ្ឋ ហើយទាំងកុមារនៅក្នុងវត្ត និងកូនសិស្ស ដែលរៀនសូត្រនៅពេលថ្ងៃផ្សេងទៀតអាចចូលរៀនបាន។ ក្នុងអំឡុងពេលសម្ភាស វត្តបានរាយការណ៍ថាមានកុមារចំនួន ៦៩៧នាក់បានចូលរៀននៅក្នុងសាលាក្នុង ១ថ្ងៃៗ តែមានកុមារតែ ២០០នាក់ប៉ុណ្ណោះដែលស្នាក់នៅក្នុងវត្ត ឯកុមារផ្សេងទៀតត្រឡប់ទៅរស់នៅក្នុងភូមិវិញ។

ក្រៅពីរៀននៅឯសាលា កុមារនៅក្នុងវត្តមួយចំនួនដែលបានសម្ភាសសម្រាប់ការសិក្សានេះ បានប្រាប់ថាពួកគេបានទទួលការគាំទ្រពីព្រះសង្ឃក្នុងវត្តឲ្យរៀនគួរបន្ថែម ដែលពួកគេយល់ថាមានសារៈប្រយោជន៍យ៉ាងខ្លាំង។[115]

113 សម្ភាសនេន (បួស) នៅវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។
114 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៦។
115 សម្ភាសជាក្រុមជាមួយកុមារស្នាក់នៅក្នុងវត្ត ខេត្តកណ្ដាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

### *អាហារក្នុងវត្ត៖*

វត្តផ្តល់នូវម្ហូបអាហារដល់កុមាររស់នៅក្នុងវត្ត។ បើទោះជាដូច្នេះក្តី គុណភាព និងបរិមាណនៃអាហារពីវត្តមួយទៅវត្តមួយដែលយើងបានសម្ភាស មានលក្ខណៈមិនដូចគ្នាឡើយ។ នៅក្នុងវត្តខ្លះ កុមារហូបអាហារសល់ពីព្រះសង្ឃ។ ប្រសិនបើអាហារមិនគ្រប់គ្រាន់ ពួកគេត្រូវដោះ ស្រាយខ្លួនឯង។ ហេតុការណ៍នេះក៏ជាការពិតផងដែរចំពោះវត្តដែលកុមារចូលទៅរស់នៅដើម្បីទទួលបានការសិក្សា៖

*វត្តផ្តល់កន្លែងស្នាក់នៅ។ យើងមិនចេញថ្លៃអាហារនោះទេ។ នៅពេលណាព្រះសង្ឃឆាន់មិនអស់ នៅពេលនោះកុមារអាចយកអាហារសល់ទៅហូបបានដោយសេរី។*[116]

*តើអាហារនៅទីនេះមានគុណភាព ដូចម្តេចដែរ ? តើអ្នកហូបប៉ុន្មានដងក្នុង១ថ្ងៃ ?*

*វាមិនទៀងនោះទេ ពេលខ្លះតិចជាង ៣ដងក្នុង១ថ្ងៃ។ ជាញឹកញាប់ យើងមិនហូបអាហារពេលព្រឹក។ នៅពេលចុងភៅរៀបចំអាហារសម្រាប់ព្រះសង្ឃ អាហារដែលសល់គឺសម្រាប់កុមារហើយ។*[117]

បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ តម្រូវឱ្យកុមារទទួលបាន "អាហារយ៉ាងហោចណាស់ ៣ពេលក្នុង១ថ្ងៃ" និងត្រូវមាន "គុណភាពអាហារូបត្ថម្ភ ជាមួយប្រូតេអ៊ីន"។ យើងមិនច្បាស់ថាតើវត្តបានបំពេញតាមលក្ខខណ្ឌនេះដែរឬទេ។ ហេតុការណ៍បែបនេះមិនត្រឹមតែកើតឡើងចំពោះ ក្មេងប្រុសនោះទេ តែវាក៏កើតឡើងច្រើនផងដែរចំពោះ ក្មេងស្រីដែលរស់នៅជាមួយដូនជី។ នៅក្នុងវត្តនៅរាជធានីភ្នំពេញ ដែលដូនជីអាចយកចៅមករស់ នៅជាមួយ ដូនជីជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ ម្ហូបអាហារដល់ចៅរបស់ខ្លួនមិនមែនវត្តនោះទេ។

នៅវត្តផ្សេងទៀត ការផ្តល់អាហារត្រូវបានឃើញថាមានភាពស្របគ្នាទៅនឹងប្រកាស។ កុមាររាយការណ៍ថាពួកគេទទួលបានអាហារពេញ ៣ពេលក្នុង១ថ្ងៃ ហើយពួកគេរីករាយ នឹងអាហារ ទាំងនោះ។[118]

### *បញ្ហាសុខភាពនៅក្នុងវត្ត៖*

វត្តដែលបានសម្ភាសនៅក្នុងការសិក្សានេះបានផ្តល់ការទំនុកបម្រុងដល់កុមារទាក់ទងនឹងការទទួលបានសេវាសុខភាពមិនដូចគ្នាទេ ពីវត្តមួយទៅវត្តមួយ។ មានវត្តមួយដែលព្រះសង្ឃមានសង្ឃដីកាថា វត្តបានផ្តល់មូលនិធិដល់កុមារឲ្យទៅរកសេវាថែទាំសុខភាព ដោយមានការចំណាយប្រហែល ១៥០០ដុល្លាក្នុងមួយឆ្នាំលើការធ្វើដំណើររបស់កុមារទៅរកសេវាថែទាំសុខភាព ហើយក៏មានកុមារខ្លះនិយាយថាពួកគេទៅរកសេវាសុខភាពដោយខ្លួនឯង ៖ "[បើយើងឈឺ] យើងអាចទៅឱសថស្ថាននៅក្បែរនេះ"។[119]

ក្នុងចំណោមវត្តដែលយើងបានសម្ភាសនៅក្នុងការសិក្សានេះ មិនមានវត្តណាមួយមាន កន្លែងផ្តល់ការថែទាំសុខភាពនៅក្នុងបរិវេណវត្តឡើយ។ បើទោះជាដូច្នេះក្តី ព្រះសង្ឃនៅវត្តមួយ ចំនួនបានពន្យល់ថាព្រះអង្គបានផ្តល់ការព្យាបាលផ្នែករាងកាយ និងផ្លូវចិត្ត និងការព្យាបាលដោយចលនានៅក្នុងវត្ត។[120]

---

116 សម្ភាសព្រះសង្ឃ (អ្នកថែទាំ) នៅវត្ត ខេត្តបាត់ដំបង ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។
117 សម្ភាសជាក្រុមជាមួយកុមារស្នាក់នៅក្នុងវត្ត ខេត្តសៀមរាប ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
118 សម្ភាសជាក្រុមជាមួយកុមារស្នាក់នៅក្នុងវត្ត ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
119 សម្ភាសជាក្រុមជាមួយកុមារស្នាក់នៅក្នុងវត្ត ខេត្តសៀមរាប ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
120 សម្ភាសព្រះចៅអធិការវត្ត ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

បើទោះបីជាវត្តព្យាយាមផ្តល់ការទំនុកបម្រុងលើការថែទាំសុខភាពដល់កុមារក៏ដោយ ប៉ុន្តែក្នុងករណីភាគច្រើន ជំនួយនេះវាមិនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការឡើយ ៖ «កុមារដែលទទួលការថែទាំជំនួសតាមសហគមន៍ ត្រូវទទួលបានការថែទាំសុខភាព និងធ្មេញដ៏សមស្រប និងពេញលេញ ការចាក់ថ្នាំបង្ការ និងព្យាបាល»។ ដូចមានចែងនៅក្នុងប្រការ ៤ នៃបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាម សហគមន៍ផងដែរ។

*អ្នកផ្តល់ការថែទាំតាមវត្តអារាមៈ*

បញ្ហាដ៏សំខាន់មួយដែលត្រូវពិចារណាទាក់ទងនឹងការថែទាំនៅតាមវត្តអារាមគឺកង្វះសេវាថែទាំជាលក្ខណៈបុគ្គលដែលផ្តល់ឲ្យនៅក្នុងវត្ត ជាពិសេស បើប្រៀបធៀបទៅនឹងទម្រង់ផ្សេងទៀតនៃការថែទាំជំនួស។ បើទោះបីជាកុមារស្នាក់នៅក្នុងវត្តចាប់ផ្តើមបង្កើតនូវទំនាក់ទំនងជាមួយព្រះសង្ឃ ហើយជាញឹកញាប់តាមការរាយការណ៍ថា ពួកគេត្រូវបានចាត់តាំងឲ្យរស់នៅ និង បម្រើព្រះសង្ឃអង្គណាមួយដូចជា «គ្រូ» របស់ពួកគេក៏ដោយ (ក្នុងករណីជាច្រើន ព្រះសង្ឃអង្គនេះសឹង្ហជាមួយកុមារនៅក្នុងបន្ទប់ ឬ អគារតែមួយ) ប៉ុន្តែកម្រិតនៃការពិនិត្យតាមដាន និង ការថែទាំជាលក្ខណៈបុគ្គលដែលកុមារម្នាក់ៗ បានទទួលមាន ចំនួនតិចតួចខ្លាំងណាស់។ ដូចអ្នកផ្តល់ចម្លើយម្នាក់បានពន្យល់ថា៖ «វត្តមិនទទួលខុសត្រូវចំពោះការផ្តល់ច្រើនជាងនេះដល់កុមារនោះទេ។ កុដិនីមួយៗទទួលខុសត្រូវចំពោះ ការសិក្សារៀនសូត្ររបស់កុមារ - នៅពេលដែលព្រះសង្ឃអង្គណាព្រមទទួលកុមារហើយ អង្គនោះត្រូវ ទទួលខុសត្រូវ និងត្រូវថែទាំនៅពេលកុមារឈឺ និងនាំកុមារទៅមន្ទីរពេទ្យ។ល។»[121]

*បើទោះបីជាវត្តយល់ថា៖*

*«ការទទួលខុសត្រូវចំពោះការថែទាំធ្លាក់ទាំងស្រុងមកលើពួកយើងជាព្រះសង្ឃក៏ដោយ[122] ប៉ុន្តែព្រះសង្ឃមិនមែនមានការទទួលខុសត្រូវដូចឪពុកម្តាយធម៌នោះទេ។ ព្រះសង្ឃមានភារកិច្ចតាមសាសនារបស់ព្រះអង្គ។ ចំនុចនេះត្រូវបានទទួលស្គាល់ ដូចព្រះចៅអធិការនៅក្នុងវត្តមួយមានសង្ឃដីកាថា៖*

*«និយាយដោយស្មោះត្រង់ចុះ យើងនៅទីនេះជាព្រះសង្ឃ - យើងទទួលយកក្មេងប្រុសមកស្នាក់នៅ ហូបចុក តែយើងមិនមែនជាឪពុកម្តាយរបស់គេនោះទេ។ យើងមិនអាចយកចិត្តទុកដាក់ចំពោះ គេដូចឪពុកម្តាយរបស់គេឡើយ។ ក្មេងប្រុសក្នុងវ័យនេះអាចទទួលបានការទំនុកបម្រុង និងសេចក្តីស្រឡាញ់ប្រសើរជាងពីឪពុកម្តាយបង្កើតរបស់ពួកគេ។*

*តើមានសង្ឃពេញវ័យប៉ុន្មានអង្គត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវលើកុមារ ?*

*មកដល់ពេលនេះ អាត្មាមិនអាចប្រាប់ថាមានព្រះសង្ឃពេញវ័យប៉ុន្មានអង្គត្រូវបានចាត់តាំង ឲ្យមើលការខុសត្រូវលើក្មេងប្រុសៗឡើយវាអាស្រ័យលើស្ថានភាព និងបរិយាកាសផ្សេងៗគ្នា... គណៈគ្រប់គ្រងមានការរវល់ខ្លាំង។ ពួកគេមិនអាចលះបង់ពេលវេលាម្នាក់ៗដើម្បីមើលថែក្មេងនោះទេ។[123]*

ទោះដូច្នេះក្តី សូមចងចាំថា កុមារស្នាក់នៅតាមវត្តអារាមបានរាយការណ៍ថាពួកគេបានទៅលេងផ្ទះម្តង ឬ ២ដង ប៉ុណ្ណោះក្នុង ១ឆ្នាំ ហើយគ្មានអ្នកណាម្នាក់មានទំនាក់ទំនងជាមួយបុគ្គលិកសង្គមកិច្ច ឬអ្នកផ្តល់ប្រឹក្សាយោបល់មកពីក្រៅ វត្តឡើយ (រួមទាំងវត្តដែលបានបញ្ចូលនៅក្នុងការសិក្សានេះ) ព្រះសង្ឃភាគច្រើនមានចំណងទាក់ទងយ៉ាងសំខាន់ នៅក្នុងជីវិតរបស់កុមារដែលរស់នៅក្នុងវត្ត ដែលកុមារខ្លះនៅតូចៗមុនឈានដល់វ័យជំទង់នៅឡើយ។

121 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៦។
122 សម្ភាសព្រះសង្ឃគង់នៅវត្ត ខេត្តបាត់ដំបង ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
123 សម្ភាសជាមួយគ្រូសូត្រវត្ត ខេត្តព្រះសីហនុ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦។

លក្ខណៈសម្បត្តិនៃការថែទាំតាមវត្តអារាម បានធ្វើឲ្យអ្នកផ្តល់ចម្លើយសំខាន់ៗខ្លះសំដែងនូវភាពសង្ស័យថា តើវត្តពិតជាផ្តល់នូវបរិយាកាសថែទាំជំនួសដ៏សមស្របចំពោះកុមារដែរឬយ៉ាងណា។ នៅពេលសួរអំពីប្រភេទនៃការថែទាំណាដែលពិបាកបំផុត ឬមានការប្រឈមបំផុត អ្នកផ្តល់ចម្លើយដ៏សំខាន់ម្នាក់បានឆ្លើយថា៖ *"គឺការថែទាំនៅតាមវត្តអារាម ពីព្រោះព្រះសង្ឃមិនមើល ថែទាំកុមារជាអាទិភាពដ៏សំខាន់របស់ ព្រះអង្គឡើយ ដោយឡែកអ្វីដែលជាអាទិភាពដ៏សំខាន់របស់ព្រះអង្គ គឺសាសនា"*។[124]

មានបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធជាមួយកុមាររស់នៅជាមួយដូនជី។ ក្នុងករណីវត្តអារាមដែលមានដូនជីត្រូវបានសម្ភាសសម្រាប់ការសិក្សានេះ កុមារ និងដូនជីរស់នៅក្នុងស្ថានភាពដែល មិនល្អក្នុង កម្រិតមធ្យមទៅស្ថានភាពដែលមិនល្អខ្លាំង ដោយគ្មានការជួយគាំទ្រច្បាស់លាស់។ ដូនជីមិនមានប្រភពចំណូលណាក្រៅពីពុទ្ធបរិស័ទដែលមកគោរពបូជានៅក្នុងវត្ត ដែលពួកគាត់បានចូលរួម បំពេញធម៌ឲ្យអ្នកទាំងនោះឡើយ។ កុមារដែលរស់នៅជាមួយដូនជីនៅក្នុងវត្តនេះ បាននិយាយថា ពួកគាត់ មិនមានសាច់ញាតិផ្សេងដែលពួកគាត់អាចរស់នៅជាមួយនោះទេ ហើយអនាគតរបស់ពួកគេគឺជា បញ្ហាមួយដ៏គួរឱ្យព្រួយបារម្ភ ជាពិសេសនៅពេលដែលជីដូនរបស់ពួកគេស្លាប់។[125] លក្ខខណ្ឌ និងសមត្ថភាពរបស់ដូនជីក្នុងការថែទាំកុមារបង្កើតបានជាសំណួរថាតើនឹងមានស្ថាប័នមួយណា គប្បីទទួលខុសត្រូវចំពោះការជួយទំនុកបម្រុងដល់គ្រួសារដែលមានតម្រូវការចាំបាច់៖ តើជាវត្តអារាម ឬ មន្ទីរ ស.អ.យ ?

អ្នកពាក់ព័ន្ធសំខាន់ៗ បានសំដែងនូវទស្សនៈចម្រុះអំពីអត្ថប្រយោជន៍ ព្រមទាំងបញ្ហានៃការថែទាំតាមវត្តអារាម នៅពេលធ្វើការប្រៀបធៀបជាមួយទម្រង់ផ្សេងទៀតនៃការថែទាំជំនួស។ អ្នកផ្តល់ចម្លើយខ្លះសង្កត់ធ្ងន់អំពីអត្ថប្រយោជន៍ជាពិសេសរបស់ការថែទាំតាមវត្តអារាមថាបានអនុញ្ញាត ឲ្យកុមាររក្សាចំណងទាក់ទងដ៏រឹងមាំជាមួយសហគមន៍របស់ពួកគេ ជាងទម្រង់ផ្សេងទៀតនៃការថែទាំតាមមណ្ឌល៖

*ប្រសិនបើអ្នកពិនិត្យមើលរបៀបដែលការថែទាំតាមវត្តអារាមដំណើរការ វាពិតជាមានការ ខុសគ្នាពីការថែទាំតាមមណ្ឌល - ពួកគេចេញទៅបិណ្ឌបាត ឬទៅរៀននៅសាលារដ្ឋពីមួយថ្ងៃ ទៅមួយថ្ងៃ ប៉ុន្តែពេលយប់ពួកគេស្នាក់នៅក្នុងវត្តក្នុងស្បង់ចីវរជាព្រះសង្ឃ។ នៅពេលកុមារគ្រងស្បង់សូម្បីតែខ្ញុំៗក៏ត្រូវគោរពពួកគេដែរ ពីព្រោះក្នុងចិត្តរបស់ខ្ញុំពួកគេ តំណាងឲ្យព្រះសម្មាសម្ពុទ្ធ... កុមារនៅក្នុងមណ្ឌល មិនទទួលបានការគោរព ឬមានទំនាក់ទំនងបែបនោះជាមួយសហគមន៍នោះទេ*។[126]

ផ្ទុយមកវិញ អ្នកផ្តល់ចម្លើយផ្សេងទៀតបានចាត់ទុកការថែទាំនៅវត្តអារាមថាជាការថែទាំមិនពេញលេញ ដោយសារតែអាហារមិនគ្រប់គ្រាន់ ស្ថានភាពរស់នៅមិនល្អ និងខ្វះការថែទាំជាលក្ខណៈបុគ្គលដែលផ្តល់ដោយព្រះសង្ឃ។ ដោយសារបញ្ហានេះយោងតាមតំណាងមន្ទីរ ស.អ.យ វត្តអារាម គួរជាជម្រើសចុងក្រោយសម្រាប់កុមារដែលគ្មានសាច់ញាតិក្នុងការថែទាំពួកគេ៖ *"កុមារនៅក្នុងវត្តមាន ស្ថានភាពមិនល្អជាងកុមារដែលរស់នៅក្រោមការថែទាំដោយសាច់ញាតិ។ ពួកគេចេញមកពីគ្រួសារក្រីក្រខ្លាំង ឬគ្រួសារដែលមានម្តាយជាស្ត្រីមេម៉ាយ"*។[127]

124 សម្ភាសប្រធានអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាថែទាំជំនួស ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
125 គួរកត់សម្គាល់ថាព្រះចៅអធិការវត្តកំពុងធ្វើការរៃអង្គាសបច្ច័យដើម្បីកសាងអគារថ្មីមួយដែលមានបំពាក់ឧបករណ៍ទំនើបសម្រាប់ដូនជី និងកុមាររស់នៅជាមួយដូន។
126 សម្ភាសតំណាងអង្គការយូនីសេហ្វ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។
127 សម្ភាសតំណាងមន្ទីរ សអយ ខេត្តបាត់ដំបង ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៦។

## ការបណ្តុះបណ្តាល

មានការចាត់តាំងព្រះសង្ឃឲ្យទទួលបន្ទុក សម្រាប់គ្រប់គ្រងបញ្ហាពាក់ព័ន្ធជាមួយកុមាររស់ នៅក្នុងវត្តនិងការសិក្សារបស់កុមារ។ ជាទូទៅគឺគ្រូសូត្រជាអ្នកទទួលខុសត្រូវ ឬក្នុងករណីដ៏កម្រគឺចៅអធិការវត្ត។ គ្មានវត្តអារាមណាមួយដែលផ្តល់ប្រាក់ខែឲ្យបុគ្គលិកផ្តល់ការថែទាំដល់កុមារនោះទេ ទោះបីជាវត្តភាគច្រើនមានព្រះសង្ឃអង្គខ្លះត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើកុមារក៏ដោយ។ អ្នកផ្តល់ចម្លើយមួយចំនួនបាននិយាយថានៅក្នុងវត្តខ្លះ មានអង្គការមិនមែនរដ្ឋាភិបាល បង្កើតកម្មវិធីថែទាំ កុមារប្រកបដោយវិជ្ជាជីវៈ ព្រមទាំងមានបុគ្គលិកបម្រើការងារដែលទទួលបានបៀវត្សរ៍៖ «វត្តអារាមអាចចែកចេញជា ២ក្រុម។ ទី១ គឺវត្តដែលមានកម្មវិធីថែទាំកុមារប្រកបដោយវិជ្ជាជីវៈ និង មានបុគ្គលិក និង អ្នកមើលថែទាំកុមារមានបៀវត្សរ៍ត្រឹមត្រូវ។ កម្មវិធីទាំងនេះជាធម្មតាត្រូវបានដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងបរិវេណវត្ត។ ទី ២ មានវត្តខ្លះផ្តល់ការថែទាំជាលក្ខណៈប្រពៃណីដោយផ្អែកការធ្វើទានរបស់ព្រះសង្ឃ»។[128]

យើងមិនច្បាស់ថា តើព្រះសង្ឃគង់នៅក្នុងវត្តដែលទទួលបន្ទុកលើកុមារបានទទួលការបណ្តុះបណ្តាលកម្រិតណាទ្បើយ។ ព្រះសង្ឃទាំងអស់លើកលែងតែមួយអង្គបានមានសង្ឃដីកាថា ព្រះអង្គបានទទួលការបណ្តុះបណ្តាលអំពីការផ្តល់ប្រឹក្សា និងការកំណត់អត្តសញ្ញាណកុមារ ទទួលរងការរំលោភបំពានពីអង្គការមិនមែនរដ្ឋាភិបាលមួយ តែការបណ្តុះបណ្តាលនេះទំនងមានរយៈពេលខ្លី ហើយធ្វើតែម្តងគត់ មិនមានវគ្គបន្តទៀតនោះទេ។ មិនមានកម្មវិធីបណ្តុះបណ្តាលប្រកបដោយបទដ្ឋាន អំពីកិច្ចការពារកុមារ សម្រាប់អ្នកទទួលបន្ទុកកុមារនៅក្នុងវត្តនោះទេ ហើយក៏គ្មានការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារការអភិវឌ្ឍកុមារការអនុវត្តវិន័យបែបវិជ្ជមាន។ល។ ដែរ។

*<u>តើព្រះសង្ឃបានទទួលការអប់រំពិសេស ឬការបណ្តុះបណ្តាលអំពីការថែទាំកុមារ ដែរឬទេ ?</u>*

*អាត្មានឹងចេញថ្លៃការបណ្តុះបណ្តាល ដើម្បីទទួលបានការបណ្តុះបណ្តាលឯក ទេសស្តីពីការថែទាំកុមារ។ អាត្មាទទួលបានការបណ្តុះបណ្តាលនៅទីនេះក្នុងវត្តជាមួយគ្រូដែលបានជួលពីខាងក្រៅ ហើយអាត្មាក៏បានបញ្ជូនព្រះសង្ឃទៅរៀននៅមហាវិទ្យាល័យពុទ្ធកសិក្សានៅរាជធានីភ្នំពេញ។*

*សម្រាប់ករណីទាំងនេះ អាត្មាបានចូលវគ្គសិក្ខាសាលាដែលរៀបចំ និងផ្តល់មូលនិធិដោយអង្គការយូនីសេហ្វ។[129]*

រាល់អ្នកថែទាំទាំងអស់ ដែលបានសម្ភាសសម្រាប់ការសិក្សានេះបានឆ្លើយ ថាបានរៀនចប់បឋមសិក្សាដែលចំនុចនេះស្របទៅនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍។

## ការចំណាយ និងការផ្តល់មូលនិធិ

ការថែទាំតាមវត្តអារាម ភាគច្រើនទទួលមូលនិធិពីការបរិច្ចាគដែលព្រះសង្ឃបានប្រមូលតាមរយៈការបិណ្ឌបាតប្រចាំថ្ងៃ ក៏ដូចជា ការបរិច្ចាគដែលព្រះសង្ឃបានទទួលពេលរៀបចំពិធីបុណ្យសាសនា ផ្សេងៗផងដែរ៖

*វត្តពឹងផ្អែកទាំងស្រុងលើពុទ្ធបរិស័ទ។ ដើម្បីសាងសង់អគារមួយយើងត្រូវការពុទ្ធបរិស័ទជួយផ្តល់បច្ច័យសម្រាប់សាងសង់។ យើងមិនពឹងលើរដ្ឋនោះទេ ព្រោះឱកាសគឺសូន្យ។[130]*

--

128 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
129 សម្ភាសព្រះចៅអធិការវត្ត ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
130 សម្ភាសព្រះចៅអធិការវត្ត រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៦។

*តើព្រះតេជគុណទទួលបានមូលនិធិដើម្បីថែទាំកុមារពីខាងណា?*

*ទទួលបានពីវិភាគទានពីពុទ្ធបរិស័ទ។ អាត្មាក៏បានបច្ច័យតាមរយៈការសូត្រធម៌នៅក្នុងពិធីផ្សេងៗ។ បន្ទាប់មក ម្ចាស់កម្មវិធីក៏ផ្ដល់បច្ច័យជាប្រាក់ជូនអាត្មា។*[131]

អ្នកថែទាំកុមារនៅក្នុងវត្តចំនួន ៤ ដែលបានសម្ភាសបាននិយាយថាពួកគេបានទទួលមូលនិធិពីខាងក្រៅខ្លះៗដែរ៖ ពីអង្គការអន្តរជាតិ ពីអង្គការក្នុងស្រុក ពីអង្គការសាសនាក្នុងស្រុក និងពីក្រសួងធម្មការ និង សាសនា។ បើទោះជាដូច្នេះក្ដី មូលនិធិទាំងនេះមិនច្រើននោះទេ៖ នៅពេលសួរថាតើវត្តរបស់ព្រះតេជគុណបានទទួលអ្វីខ្លះពីក្រសួងធម្មការ និងសាសនា ព្រះសង្ឃមួយអង្គបានពន្យល់ថា «មានតែសម្ភារៈរៀនសូត្រសម្រាប់សាលាពុទ្ធិកសិក្សា និងសៀវភៅអានជាដើម»[132]។ កុមារខ្លះដែលស្នាក់នៅក្នុងវត្តបាននិយាយថាពួកគេបានទទួលប្រាក់តិចតួចពីគ្រួសាររបស់ពួកគេជារៀងរាល់ខែ ដើម្បីបំពេញកង្វះខាតនៅក្នុងវត្ត តែក៏មាន កុមារខ្លះមិនបានទទួលអ្វីទាល់តែសោះផងដែរ។

ការចំណាយនៅក្នុងវត្ត មានការប្រែប្រួល អាស្រ័យទៅលើអ្វីដែលមាន និងមានតំណាងវត្ត ជាច្រើនបានពន្យល់ថា ពួកគេមិនបានរក្សាថវិកាឱ្យមានជាទៀងទាត់នោះទេ។ លើសពីនេះ ដូចបាន លើកខាងដើមវត្តអារាមជាច្រើនបានរាយការណ៍ថាពួកគេមិនបដិសេធការសុំស្នាក់នៅ របស់កុមារ នោះឡើយ ដូច្នេះហើយបានជាវត្តត្រូវចាយវាយជាមួយថវិកាដែលមានចំនួនតិចជាងតម្រូវការ ដែលត្រូវផ្ដល់សម្រាប់ការថែទាំដែលមានបទដ្ឋានសមរម្យ។

វាមានការពិបាកក្នុងការកំណត់ជាទូទៅដោយផ្អែកលើការចំណាយលើកុមារម្នាក់ៗ ដែលបានរាយការណ៍ដោយវត្តអារាមនៅក្នុងការសិក្សានេះ ពីព្រោះជំនួយគាំទ្រផ្នែកសម្ភារៈ និង សេវាដែលបានផ្ដល់ ដល់កុមារ គឺមិនដូចគ្នាឡើយពីវត្តមួយទៅវត្តមួយទៀត និង នៅក្នុងវត្ត វាក៏អាស្រ័យលើមូលនិធិដែលមានផងដែរ។ នៅពេលសាកសួរអំពីការចំណាយប្រហាក់ប្រហែលសម្រាប់កុមារម្នាក់ ( គិតទាំងរបស់របរប្រើប្រាស់ និងម្ហូបអាហារ ) វត្តបានរាយការណ៍ថាបានចំណាយចន្លោះពី ៣០ ទៅ៥០ដុល្លារអាមេរិកក្នុង១ខែជាមធ្យម។ តម្លៃនេះមិនអាចយកជាបទដ្ឋានបាននោះទេ ម៉្យាងវិញទៀត ព្រះសង្ឃទាំងអស់ដែលបានសម្ភាសបានបញ្ជាក់ថាការចំណាយនេះមិនបានគិតបញ្ចូលតម្រូវការរបស់កុមារឱ្យបានគ្រប់ជ្រុងជ្រោយឡើយ។ មានវត្តមួយដែលបានបញ្ចូលនៅក្នុងការសិក្សានេះបានរាយការណ៍អំពីការចំណាយប្រចាំខែដ៏ជាក់លាក់ទៅលើសុខភាព និងការសិក្សា ( ថ្នាក់រៀនគួរ ) សម្រាប់កុមារ៖ *«កាលពីខែកញ្ញាមុន អាត្មាបានចំណាយ ១.៧៥០ បញ្ជូនក្មេងទៅពេទ្យដើម្បីទទួលការថែទាំសុខភាព... យើងចំណាយ ៣៥.០០០ សម្រាប់បង់ឱ្យ គ្រូបង្រៀនក្នុង១ខែ លើមុខវិជ្ជាភាសាខ្មែរ និងកុំព្យូទ័រ»*។[133]

កង្វះលំហូមូលនិធិជានិរន្ដ គឺជាឧបសគ្គសម្រាប់វត្តក្នុងការផ្ដល់ការថែទាំដ៏គួរឲ្យទុកចិត្ត និងមាននិរន្តរភាពសម្រាប់កុមារ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ អ្នកផ្ដល់ព័ត៌មានបាននិយាយ ថាការថែទាំនៅតាមវត្តអារាមលែងសូវមាននិរន្តរភាពនៅក្នុងប្រទេសកម្ពុជានាសម័យបច្ចុប្បន្នដោយសារតែការបាត់បង់ការគោរពរបស់សហគមន៍ចំពោះវត្តអារាម និង ការថមថយការតាំងចិត្តជួយដល់វត្ត៖ *«ប្រជាជនបាត់ជំនឿចំពោះព្រះសង្ឃ ពួកគេមិនបានផ្ដល់វិភាគទានធ្វើបុណ្យដូចដែលពួក គេធ្លាប់ធ្វើកាល ពីអតីតកាលនោះទេ... ពីមុនក្នុង ១ ឃុំមានវត្តមួយ ប៉ុន្តែឥឡូវមានវត្ត ៤ ឬ៥ ដូច្នេះការផ្ដល់មូល និធិពិតជា មានកម្រិតខ្លាំងណាស់»*។[134]

131 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។
132 សម្ភាសព្រះសង្ឃ/អ្នកថែទាំនៅវត្ត ខេត្តបាត់ដំបង ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦។
133 សម្ភាសព្រះចៅអធិការវត្ត ខេត្តកណ្ដាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
134 សម្ភាសបុគ្គលិកអង្គការយូនីសេហ្វ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។

## កិច្ចការពារកុមារ

បើទោះបីជាមិនសូវមានទិន្នន័យស៊ីជម្រៅ និង រឹងមាំអំពីបញ្ហាការពារកុមារតាមវត្តអារាមក៏ដោយ ប៉ុន្តែភស្តុតាងមិនផ្លូវការ បានឲ្យដឹងថាការរំលោភបំពានកុមារគឺជាបញ្ហាមួយនៅក្នុងវត្តអារាមនៃប្រទេសកម្ពុជា និងជាពិសេស ការរំលោភបំពានផ្លូវភេទទៅលើក្មេងប្រុសដោយព្រះសង្ឃ។ បញ្ហានេះត្រូវបានលើកឡើងដោយអ្នកផ្តល់ចម្លើយសំខាន់ៗជាច្រើននាក់ នៅក្នុងការសិក្សានេះ៖

*វត្តអារាមត្រូវការរៀបចំឲ្យបានត្រឹមត្រូវ - វត្តត្រូវមានគោលនយោបាយការពារកុមារដើម្បីធានា ថាមិនមានការកេងប្រវ័ញ្ច ឬ បំពានលើកុមារនៅក្នុងវត្ត។ មានឪពុកម្តាយដែលជឿថាវត្តគឺជាទី កន្លែងដ៏ល្អសម្រាប់កូនរបស់ពួកគេ។[135]*

*បញ្ហាមួយដែលយើងមិនត្រូវព្រងើយកន្តើយនោះគឺ ការរំលោភបំពានដោយអ្នកផ្តល់ការ ថែទាំនៅក្នុងមណ្ឌល។ ពេលខ្លះបញ្ហានេះក៏កើតឡើងនៅក្នុងវត្តអារាមផងដែរ។[136]*

លទ្ធផលនៃការស្រាវជ្រាវបែបគុណភាព ក៏បានបង្ហាញនូវហេតុការណ៍នៃការរំលោភបំពាន ផ្លូវភេទនៅក្នុងវត្តអារាមផងដែរ ដូចបានបង្ហាញនៅក្នុងកិច្ចសន្ទនាខាងក្រោមជាមួយក្មេងប្រុសម្នាក់ដែល បានស្នាក់នៅក្នុងវត្តមួយនៃខេត្តបាត់ដំបង៖

### ករណីសិក្សា៖ ក្មេងប្រុសរស់នៅក្នុងវត្តមួយនៃខេត្តបាត់ដំបង

*តើធ្លាប់មានអ្នកណាម្នាក់ប្រើប្រាស់ភាសាទាក់ទងនឹងផ្លូវភេទជាមួយអ្នក ដែរឬទេ ?*

*បាទ! មានបុរសម្នាក់មកពីភូមិជិតខាងដែលបានមកវត្តប្រហែល១ខែម្តង។*

*តើគាត់មានបានស្ទាបអ្នក ដែរឬទេ ?*

*ទេ! គ្មានការស្ទាបនោះទេ។*

*តើបុរសដែលប្រើភាសាផ្លូវភេទធ្វើអ្វីខ្លះ នៅពេលគាត់មកវត្តម្តងៗ ?*

*គាត់លេងជាមួយក្មេងៗ និងជជែកលេងជាមួយក្មេងប្រុសៗ។*

*តើហេតុការណ៍នេះកើតឡើងនៅកន្លែងណា ? ខាងក្រៅ ឬខាងក្នុង ?*

*នៅខាងក្រៅ។*

*តើគាត់អាយុប៉ុន្មាន ?*

*ប្រហែល ៣០ឆ្នាំ... គាត់រស់នៅក្បែរៗនេះ។*

135 សម្ភាសប្រធានអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាថែទាំជំនួស ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។

136 សម្ភាសលក្ខណៈបុគ្គលជាមួយបុគ្គលិកអង្គការយូនីសេហ្វ រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦។

*តើគាត់ធ្លាប់ស្ទាបប្រដាប់ភេទក្មេងប្រុសណាម្នាក់ ដែរឬទេ ?*
*ទេ! អត់មានទេ... តែព្រះសង្ឃស្ទាបពងរបស់ខ្ញុំ។*

*នៅពេលណា ?*
*នៅពេលខ្ញុំដេកលក់។ បន្ទាប់មកខ្ញុំភ្ញាក់ ហើយទាញខោរបស់ខ្ញុំឡើង។*

*បន្ទាប់មកយ៉ាងម៉េចទៀត ?*
*ព្រះសង្ឃក៏ឈប់ស្ទាបពងរបស់ខ្ញុំ។*

*តើរឿងនេះវាកើតឡើងញឹកញាប់ប៉ុណ្ណាដែរ ?*
*ប្រហែលមួយឆ្នាំមួយដង... រឿងនេះបានកើតឡើងមួយរយៈមុននេះ។ ប្រហែល១ឆ្នាំហើយ ចាប់តាំងពីពេលនោះមក គាត់ឈប់ធ្វើបែបនេះដាក់ខ្ញុំទៀតហើយ។*

*តើព្រះសង្ឃអង្គនោះនៅគង់វត្តនេះទៀត ដែរឬទេ ?*
*បាទ។*

*តើអ្នកមានបានប្រាប់ឪពុកម្តាយរបស់អ្នកអំពីរឿងនេះដែរឬទេ ?*
*ទេ! ខ្ញុំមិនបានប្រាប់ពួកគាត់ទេ។*

*តើអ្នកបានប្រាប់អ្នកណាម្នាក់ផ្សេងអំពីរឿងនេះទេ ?*
*ទេ! មិនបានប្រាប់អ្នកណាផ្សេងនោះទេ។*[137]

វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា នៅក្នុងវត្តភាគច្រើនដែលបានបញ្ចូលនៅ ក្នុងការសិក្សានេះ កុមាររក្សាសំដីថាពួកគេមិនដែលទទួលរងការ រំលោភបំពានផ្លូវភេទនោះទេនៅក្នុងវត្ត ឬ មិនដែលបានស្តាប់ឮអំពីរឿងនេះថាបានកើតឡើងលើអ្នកផ្សេងឡើយ។ វាទំនងថាមានការរាយការណ៍ខ្វះចន្លោះខ្លះកើតឡើងដោយសារតែបញ្ហានេះ ជាបញ្ហាអំពើហិង្សាផ្លូវភេទ ដែលជាបញ្ហារសើប និងធ្វើឲ្យមានការមាក់ងាយ។

លទ្ធផលនៃការស្រាវជ្រាវក៏បានឲ្យដឹងផងដែរថា មានការដាក់ទណ្ឌកម្មលើរាងកាយកើត ឡើងជាទៀងទាត់នៅក្នុងវត្តអារាម។ តាមពិត អ្នកផ្តល់ចម្លើយខ្លះបានចាត់ទុកការដាក់ទណ្ឌកម្មលើ រាងកាយថាជាវិធីសាស្ត្រមួយដ៏សំខាន់នៃការអនុវត្តវិន័យរបស់វត្តទៅវិញ។ អ្នកផ្តល់ចម្លើយបានរៀបរាប់អំពីការដាក់ទណ្ឌកម្មលើរាងកាយមួយចំនួនដែលបានអនុវត្តនៅវត្ត ដែលអាចមានភាពធ្ងន់ធ្ងរ៖

*ការអនុវត្តវិន័យលើរាងកាយ គឺជាបញ្ហាមួយនៅក្នុងវត្ត។ មានករណីមួយដែលបានកើតឡើងថ្មីៗនេះ ព្រះសង្ឃបានដាក់ទណ្ឌកម្មលើកុមារដោយចាក់ទឹកក្តៅលើកុមារនោះ។*[138]

--

137 សម្ភាសជាលក្ខណៈបុគ្គលជាមួយកុមារនៅក្នុងវត្ត ខេត្តបាត់ដំបង ថ្ងៃទិ ១៨ ខែតុលា ឆ្នាំ ២០១៦។
138 សម្ភាសប្រធានអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាថែទាំជំនួស ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។

*តើនឹងមានអ្វីកើតឡើងបើអ្នកធ្វើខុសវិន័យ ?*

*ព្រះសង្ឃនឹងវាយយើង។*

*យកអ្វីវាយ ?*

*យករំពាត់។*

*តើរឿងបែបនេះកើតឡើងច្រើនដង ដែរឬទេ ?*

*វាកើតឡើងប្រហែល១ខែម្តង។ ជាធម្មតាគាត់វាយយើង ២រំពាត់។ យើងអាចយំបានពីព្រោះវាឈឺពេក។*

*តើមានការដាក់ទណ្ឌកម្មអ្វីផ្សេងទៀតទេ ?*

*អត់ទេ! មានតែវាយ។*[139]

ការប្រើប្រាស់ទណ្ឌកម្ម និង រឿងរ៉ាវពាក់ព័ន្ធនឹងការរំលោភបំពានបង្ហាញថា កុមារ និងបុគ្គលិកនៅក្នុងវត្ត នឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ប្រសិនបើមានគោលនយោបាយការពារកុមារដែលទាំងអស់គ្នាត្រូវតែគោរពតាម ហើយគោលនយោបាយនេះត្រូវចែងអំពីវិធានការ នៅពេលមានការចោទប្រកាន់អំពីការរំលោភបំពាន ដើម្បីការពារកុមារ។ នៅពេលសួរអំពីកិច្ចការពារកុមារនៅក្នុងវត្ត តំណាងមន្ទីរធម្មការ និង សាសនាបញ្ជាក់ថា ត្រូវធ្វើការងារឱ្យបានច្រើនជាងនេះបន្ថែមទៀត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពានកុមារ។ *"ពួកយើងគ្មានអ្នកណាម្នាក់បានជួបប្រទះ ឬរកឃើញអំពីបញ្ហាការពារកុមារនៅក្នុងវត្តនោះទេ។ យើងមានការឯកភាពផ្ទៃក្នុងថា បើមានករណីធ្ងន់ធ្ងរ ករណីនេះត្រូវតែរាយការណ៍ទៅព្រះចៅអធិការវត្ត និងមានបណ្តាញមួយប្រកបដោយសក្តានុពលសម្រាប់រាយការណ៍ទៅមន្ទីរ ស.អ.យ ប៉ុន្តែការជូនដំណឹងបែបនេះមិនដែលបានកើតឡើងឡើយ។"*[140]

វត្តអារាមបង្ហាញឱ្យឃើញនូវលទ្ធភាពពីរផ្ទុយគ្នា។ ទី១ វត្តដែលយើងចុះទៅសិក្សាមិនបានមើលឃើញនូវមុខនាទីជាអ្នកថែទាំយូរអង្វែងដល់កុមារនោះឡើយ។ ពួកគេទទួលស្គាល់ថា អ្នកដែលថែទាំកុមារនៅក្នុងវត្តគឺមានតែព្រះសង្ឃ ( ដូនជីមិនដើរតួនាទីថែទាំក្មេង ប្រុសក្នុងវត្តនោះឡើយ លើកលែងតែក្មេងប្រុសនោះជាសាច់ញាតិរបស់គាត់ និង រស់នៅជាមួយគាត់ )។ ម្យ៉ាងវិញទៀត វត្តចាត់ទុកខ្លួនឯងថាជាអ្នកផ្តល់នូវសំណាញ់សុវត្ថិភាពជូនកុមារដែលឪពុកម្តាយ ឬ គ្រួសាររបស់ពួកគេមិនអាចមើលថែទាំពួកគេបាន (រួមទាំងការផ្តល់នូវការអប់រំផងដែរ ) ឬ ដែលកេងប្រវ័ញ្ចពួកគេ ( ដែលតួនាទីនេះគួរធ្លាក់លើស្មារបស់មន្ទីរ ស.អ.យ និង គកនក វិញ )។

គោលបំណងចម្បងនៃការយកកុមារមករស់នៅក្នុងវត្ត ដូចបានពន្យល់ដល់អ្នកស្រាវជ្រាវយើងថាដើម្បីធានាថាកុមារបានរៀនសូត្រទាំងផ្លូវធម៌ និង ផ្លូវលោក។ គ្មានវត្តមួយណាបានលើកពីប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍នោះទេ ហើយទាំងវត្ត ឬ ក្រសួងធម្មការនិងសាសនាទំនងមិនមានការយល់ដឹងថាប្រកាសនេះអាចយក មកអនុវត្តបាន និង ប្រកាសនេះបានកំណត់អំពីកាតព្វកិច្ចជាក់លាក់មួយចំនួនទៅលើក្រសួងធម្មការ និងសាសនា និងព្រះចៅអធិការវត្ត។

139 សម្ភាសជាក្រុមជាមួយកុមារនៅក្នុងវត្ត ខេត្តបាត់ដំបង ថ្ងៃទិ ១៨ ខែតុលា ឆ្នាំ ២០១៦។
140 សម្ភាសតំណាងមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៦។




© UNICEF Cambodia2015Antoine

# ផ្ទះស្នាក់នៅជាក្រុម

## ផ្ទះស្នាក់នៅជាក្រុម៖ គំហើញសំខាន់ៗ

១. ផ្ទះស្នាក់នៅជាក្រុម គ្របដណ្តប់លើការថែទាំដែលមានលក្ខណៈខុសៗគ្នាយ៉ាងច្រើន ដែលខ្លះវាមានន័យប្រហាក់ប្រហែលនឹងការថែទាំ«ជាប្រពៃណី»ដោយគ្រួសារញាតិ ហើយខ្លះទៀតមានន័យប្រហាក់ប្រហែលនឹង «ការរៀបចំរស់នៅដោយឯករាជ្យ»។

២. អ្នកផ្តល់ការថែទាំភាគច្រើន យល់ថាផ្ទះស្នាក់នៅជាក្រុមមានលក្ខណៈជាការថែទាំ “បណ្តោះអាសន្ន” ដើម្បីរៀបចំធ្វើការបង្រួបបង្រួមគ្រួសារ ឬ រៀបចំកុមារធំពេញវ័យ ឲ្យរស់នៅ ឯករាជ្យ។

៣. ផ្ទះស្នាក់នៅជាក្រុមខ្លះ ស្ថិតនៅដាច់ឆ្ងាយបន្តិចពីសហគមន៍ ហើយជាក់ស្តែង វាប្រហាក់ ប្រហែលនឹងមណ្ឌលថែទាំ «បិទទ្វារ» និង ពុំមានលក្ខខណ្ឌល្អស្របទៅនឹងការរៀបចំថែទាំ »តាមសហគមន៍»ៗ «ដែលស្រដៀងគ្នាទៅនឹងគ្រួសារ» ដូចមានចែងនៅក្នុងប្រកាសឆ្នាំ ២០០៨ឡើយ។

៤. ការទុកដាក់កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុម ពេលខ្លះកើតឡើងមុនពេលបានប្រើប្រាស់អស់លទ្ធភាពនូវជម្រើសថែទាំតាមគ្រួសារ ។

៥. ការត្រួតពិនិត្យតាមដានផ្ទះស្នាក់នៅជាក្រុមមានដំណើរការប្រព្រឹត្តទៅល្អបង្គួរ បើទោះបីជាការចូលរួមពីរដ្ឋាភិបាលនៅមានកម្រិតតិចតួចក៏ដោយ។

៦. ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និងការធ្វើសមាហរណកម្ម មិនត្រូវបានចាត់ទុកថាជាអាទិភាព ហើយត្រូវអ្នកថែទាំនៅផ្ទះស្នាក់នៅជាក្រុមដែលត្រូវបានសម្ភាសសម្រាប់ការសិក្សានេះបង្ហាញពីភាពសង្ស័យ។

៧. ស្ថានភាពសម្ភារៈ និងការទទួលបានការអប់រំ រមែងតែងមានភាពប្រសើរជាងមុនសម្រាប់ កុមាររស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម។

៨. កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុម កម្របានជួបបុគ្គលិកសង្គមកិច្ចដែលត្រូវបានចាត់តាំងសម្រាប់ពួកគេឱ្យបានទៀងទាត់ណាស់។

៩. អ្នកថែទាំភាគច្រើននៅក្នុងផ្ទះស្នាក់នៅជាក្រុម បានទទួលការបណ្តុះបណ្តាលមួយចំនួន ទោះបីជាការបណ្តុះបណ្តាលនេះកម្រិតបឋម និង/ឬ មិនផ្លូវការក៏ដោយ។

១០. ផ្ទះស្នាក់នៅជាក្រុម ត្រូវចំណាយច្រើនជាងការថែទាំជំនួសដោយគ្រួសារ។

១១. ជាញឹកញាប់ កុមារនិយាយថាការរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម មានពន្លឺវិជ្ជមានដោយសារមានការកែលំអជីវភាពរស់នៅ និងការទទួលបានការសិក្សារៀនសូត្រ។ ទោះដូច្នេះក្តី កុមារធំៗនិយាយថាពួកគេចង់បានភាពឯកជនច្រើនជាងនេះ ដែលការស្នាក់ នៅផ្ទះស្នាក់នៅជាក្រុមមិនអាចផ្តល់ឲ្យបានក្នុងពេលបច្ចុប្បន្ន។

## ប្រវត្តិរបស់កុមារ

គោលនយោបាយស្តីពីការថែទាំជំនួសឆ្នាំ២០០៦ និងប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការ ថែទាំជំនួសចំពោះកុមារតាមសហគមន៍ឆ្នាំ២០០៨ បានកំណត់និយមន័យផ្ទះស្នាក់នៅជាក្រុមថាជា ទម្រង់នៃការថែទាំជំនួសដែលមានចំនួនកុមារកំណត់ ( យោងតាមប្រកាសថា មិនលើសពី ១៥ នាក់ ) ស្នាក់នៅក្នុងផ្ទះក្រោមការគ្រប់គ្រងពីអ្នកថែទាំមួយក្រុមតូចដែលមិនមែនជាសាច់ញាតិរបស់កុមារ។[141] ការកំណត់ទីតាំងកន្លែងថែទាំកុមារដែលបានធ្វើក្នុងឆ្នាំ២០១៥ នៅគ្រប់រាជធានីខេត្ត ទាំងអស់នៃប្រទេស កម្ពុជា បានរកឃើញថាមានផ្ទះស្នាក់នៅជាក្រុមចំនួន ៧១ ។ កុមារសរុបអាយុក្រោម ១៨ឆ្នាំ ដែលរស់ នៅក្នុងផ្ទះទាំងនេះត្រូវបានរកឃើញថាមានចំនួន ១៥៩២នាក់ ដែលមានក្មេងស្រីច្រើនជាងក្មេងប្រុសបន្តិច គឺក្មេងស្រីមានចំនួន ៨២០នាក់ និង ក្មេងប្រុសចំនួន ៧៧២នាក់។ ក្នុងនោះក៏មានកុមារ អាយុចន្លោះ ១៨-២៤ឆ្នាំ យ៉ាងច្រើនផងដែរ ( ៥៤៤នាក់ ) ដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមដែល បានកំណត់រក ឃើញទាំងនោះ។ ការស្រាវជ្រាវសម្រាប់ការសិក្សានេះបង្ហាញថា កុមារអាយុលើស ១៨ឆ្នាំខ្លះ បានកើនអាយុ ដោយពួកគេបានរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមទាំងនោះ ឬ មណ្ឌលថែទាំកុមារមុនអាយុ ១៨ឆ្នាំ ហើយពួកគេក៏ចេះតែបន្តស្នាក់នៅទីនោះទៀត។ កុមារផ្សេងទៀតជាសិស្សនិស្សិតដែលជួយធ្វើការងារនៅក្នុងផ្ទះដោយមិនយកកម្រៃ ឬកាត់បន្ថយការ ចំណាយលើស្នាក់នៅក្នុងផ្ទះទាំងនោះ។ ការកំណត់ទីតាំងនេះមិនបានផ្តល់នូវការបែងចែកអាយុលម្អិត និងមិនបានស្រង់គ្រប់ ផ្ទះស្នាក់នៅជាក្រុមក្នុងប្រទេសកម្ពុជានោះទេ ដោយសារអ្នកកត់ ត្រាបានពឹងផ្អែក លើអ្នក ផ្តល់ព័ត៌មានសំខាន់ៗ នៅថ្នាក់ឃុំក្នុងការកំណត់អំពីកន្លែងថែទាំដែលពាក់ព័ន្ធ។

ដោយសារពេលវេលា និងធនធានមានកម្រិត អ្នកស្រាវជ្រាវអាចចុះពិនិត្យមើល ផ្ទះស្នាក់នៅ ជាក្រុមចំនួន ៤ ប៉ុណ្ណោះ ដែលនេះជាសំណាកដ៏តូច បើប្រៀបធៀបជាមួយចំនួនផ្ទះស្នាក់នៅជាក្រុម ដែលត្រូវបានគ្របដណ្តប់ដោយក្រុមអ្នកកំណត់ទីតាំងកន្លែងថែទាំកុមារ បានធ្វើក្នុងឆ្នាំ២០១៥ កន្លងទៅនេះ។ តារាងទី ៤នៅក្នុងឧបសម្ព័ន្ធពន្យល់អំពីទិដ្ឋភាពទូទៅនៃ ផ្ទះស្នាក់នៅជាក្រុម ដែលមាន លក្ខណៈខុសៗគ្នា និងការរៀបចំរស់នៅដោយឯករាជ្យដែលអ្នកស្រាវជ្រាវបានចុះជួប រួមទាំងការពណ៌នា អំពីការរៀបចំថែទាំដ៏ជាក់លាក់ទាំងនោះផង។ ចំនួនកុមាររស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម ដែលយើងបាន ជួបសម្រាប់ការសិក្សានេះ មិនដូចគ្នាឡើយ គឺមានចាប់ពី ៣នាក់ រហូតដល់ ១៣នាក់ និង មានអាយុចន្លោះ ពី ៤ ទៅ ២២ឆ្នាំ។ ផ្ទះដែលកុមាររស់នៅដោយឯករាជ្យ ដែលអ្នកស្រាវជ្រាវបាន ចុះជួបនៅក្នុងខេត្តព្រះសីហនុ មានកុមារ២នាក់រស់នៅ ក្នុងនោះម្នាក់អាយុ ១៥ឆ្នាំម្នាក់ និងម្នាក់ទៀតអាយុ ១៧ឆ្នាំ។

ភាគច្រើននៃកុមាររស់នៅផ្ទះស្នាក់នៅជាក្រុម ដែលយើងបានចុះជួប ធ្លាប់រស់នៅក្នុងមណ្ឌល ថែទាំជំនួស ឬមណ្ឌលបណ្តោះអាសន្នមួយរយៈពេល។ ការសិក្សាខាងក្រោមអំពីក្មេងស្រីម្នាក់ រស់នៅ ក្នុងផ្ទះស្នាក់នៅជាក្រុមក្នុងខេត្តសៀមរាប បង្ហាញយ៉ាងច្បាស់ពីរបៀបដែលកុមារត្រូវបានផ្ទេរពីការ ថែទាំមួយទៅការថែទាំមួយទៀត។ ពេលខ្លះការផ្លាស់ប្តូរច្រើនដង ជាការដែលមិនអាចចៀសផុត ក៏ប៉ុន្តែគេគួរតែចៀសវាងប្រសិនបើអាចធ្វើបាន ដោយសាររាំខានដល់កុមារ ហើយអាចបន្ទុចបង្អាក់ទំនាក់ ទំនងដ៏មានអត្ថន័យរបស់ពួកគេជាមួយអ្នកផ្តល់ការថែទាំរបស់ពួកគេ និងអាចបណ្តាលឲ្យពួកគេ ផ្លាស់ប្តូរ សាលារៀន រំខានដល់ការអប់រំទៀតផង។

141 សូមអានប្រការ ២ និងប្រការ ៥។

## ករណីសិក្សា៖ ក្មេងស្រីអាយុ ១៧ឆ្នាំដែលបានសម្ភាសនៅក្នុងផ្ទះស្នាក់នៅជាក្រុមក្នុងខេត្តសៀមរាប

តើអ្នករស់នៅកន្លែងណាមុនមករស់នៅក្នុង [ផ្ទះស្នាក់នៅជាក្រុមនេះ]? ខ្ញុំបានរស់នៅ [ឯមណ្ឌលមួយសម្រាប់ជនរងគ្រោះពីការរំលោភបំពាន និងជួញដូរនៅជាយក្រុងសៀមរាប] មុនខ្ញុំមកនៅទីនេះ។ ខ្ញុំគិតថាខ្ញុំបានរស់នៅ [មណ្ឌល] នោះជិត៤ឆ្នាំ។ តើ [មណ្ឌលនោះ] ធ្វើអ្វីខ្លះ? តើមណ្ឌលនោះមានគោលបំណងអ្វីខ្លះ? [មណ្ឌល] នោះសង្គ្រោះកុមារពីអំពើហិង្សា និងកុមារដែលមិនមានជម្រក។

*ហេតុអ្វីបានជាអ្នកមករស់នៅក្នុង [មណ្ឌល] នេះ?*

*ខ្ញុំធ្លាប់ជាជនរងគ្រោះនៃអំពើហិង្សា។ គ្រួសារមួយដែលខ្ញុំបានរស់នៅជាមួយពីមុនបានធ្វើបាបខ្ញុំ។ ហេតុអ្វីបានជាអ្នករស់នៅជាមួយគ្រួសារនោះ? ឪពុករបស់ខ្ញុំបានបញ្ជូនខ្ញុំទៅរស់នៅក្នុងគ្រួសារនោះដើម្បីខ្ញុំបានសិក្សារៀនសូត្រ។ ហេតុអ្វីគាត់បញ្ជូនអ្នកទៅរស់នៅក្នុងគ្រួសារនោះ? ឪពុករបស់ខ្ញុំជាអ្នកសម្រេចចិត្ត។ គាត់មានបណ្តាញរបស់គាត់។ ពូដែលខ្ញុំនៅជាមួយធ្វើបាបខ្ញុំគាត់បានវាយដំ និងបំពានលើខ្ញុំ។ តើអ្នករួចផុតពីស្ថានភាពបែបនេះដោយរបៀបណា? មន្ត្រីឃុំបានឃើញពូដែលខ្ញុំនៅជាមួយ វាយដំខ្ញុំជាញឹកញាប់។ ពួកគាត់តែងដើរកាត់ផ្ទះដែលខ្ញុំរស់នៅពេលនោះជាញឹកញាប់។*

*បន្ទាប់មកយ៉ាងម៉េចទៀត?*

*បន្ទាប់មកមន្ត្រីឃុំបាននិយាយជាមួយឪពុកម្តាយបង្កើតរបស់ខ្ញុំ ក្រែងពួកគាត់អាចយកខ្ញុំមករស់នៅជាមួយពួកគាត់វិញ។ តែខ្ញុំមិនចង់ទៅរស់នៅជាមួយពួកគាត់នោះទេ។ នៅក្នុងភូមិរបស់ខ្ញុំមិនមានការរៀនសូត្រ។ ដូច្នេះមន្ត្រីឃុំ និងឪពុកម្តាយរបស់ខ្ញុំបានសម្រេចចិត្តថាបញ្ជូនខ្ញុំទៅរស់នៅក្នុង[មណ្ឌល]។*

*ហេតុអ្វីបានជាអ្នកចាកចេញពី [មណ្ឌល] ហើយមករស់នៅទីនេះ?*

*ពីព្រោះ ៤ឆ្នាំក្រោយមក ពួកគាត់សម្រេចចិត្តថាខ្ញុំត្រូវទៅរស់នៅក្នុង [ផ្ទះស្នាក់នៅជាក្រុម] ដើម្បីខ្ញុំបានរៀនសូត្រប្រសើរជាងនេះ។*

ភស្តុតាងពីការសម្ភាសបែបគុណភាព បង្ហាញថាអង្គការមិនមែនរដ្ឋាភិបាល និងតំណាងរដ្ឋាភិបាលបានចូលរួមនៅក្នុងការទុកដាក់កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុម ដោយយល់ថាទម្រង់នៃ ការថែទាំជំនួសនេះជាការថែទាំ«បណ្តោះអាសន្ន» មិនមែនជាការទុកដាក់កុមារក្នុងការថែទាំរយៈពេលវែង ឬអចិន្ត្រៃយ៍ឡើយ។

*ចំពោះកុមារនៃគ្រួសារដែលប្រើអំពើហិង្សា យើងនឹងទុកដាក់ពួកគេនៅក្នុងផ្ទះស្នាក់នៅជាក្រុមបណ្តោះអាសន្ន បន្ទាប់មក យើងនឹងបណ្តុះបណ្តាលឪពុកម្តាយអំពីការចិញ្ចឹមកូនបែបវិជ្ជមាន រហូតដល់ពួកគេមានភាពរួចរាល់សម្រាប់ការបង្រួបបង្រួមគ្រួសារ។*[142]

ការយល់ឃើញរបស់អ្នកផ្តល់ចម្លើយថា «ផ្ទះស្នាក់នៅជាក្រុម» គឺជាការទុកដាក់ថែទាំបណ្តោះអាសន្ន មានភាពស្របគ្នាទៅនឹងប្រការ ២១ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួស ចំពោះកុមារ ដែលបានផ្តល់និយមន័យដល់ «ការថែទាំជាក្រុម» ថាជា «ការថែទាំជំនួសបណ្តោះអាសន្ន» ហើយដែលបង្កើតនូវ «ឋានានុក្រមនៃការថែទាំ» ដ៏តឹងរឹង ចំណែកឯផ្ទះស្នាក់នៅជាក្រុមមិនត្រូវបានចាត់ទុក ថាមានលក្ខណៈសមស្រប ដូចជាការថែទាំដោយគ្រួសារ (ការថែទាំដោយសាច់ញាតិ និងការថែទាំដោយ ឪពុកម្តាយធម៌) នោះទេ។

142 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៦។

ចំណុចគួរឲ្យចាប់អារម្មណ៍នោះគឺ អ្នកផ្ដល់ការថែទាំដែលបានសម្ភាសសម្រាប់ការសិក្សានេះ មានការយល់ដឹងខុសៗគ្នាអំពីធាតុផ្សំនៃ «ផ្ទះស្នាក់នៅជាក្រុម» ដោយអ្នកខ្លះយល់ថាវាស្រដៀងគ្នាទៅនឹង «ការថែទាំបណ្ដោះអាសន្នដោយឪពុកម្ដាយធម៌» ហើយខ្លះទៀតថាវាស្រដៀងគ្នាទៅនឹង «ការរស់នៅដោយឯករាជ្យ»។ ឧទាហរណ៍ អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលម្នាក់ដែល យើងបាន សម្ភាសបានប្រាប់ឲ្យដឹងថាអង្គការរបស់អ្នកស្រីផ្ដល់ការគាំទ្រដល់ *«ផ្ទះស្នាក់នៅជាក្រុមចំនួន ៨ ដែលក្រុមនីមួយៗមានកុមារចំនួន ៤-៥នាក់។ កុមារទាំងនេះនឹងត្រូវបានទុកដាក់ឱ្យរស់នៅជាមួយគ្រួសារដែលមានផ្ទះសម្បែងស្រាប់ ដូច្នេះយើងមិនចាំបាច់បង់ថ្លៃឈ្នួលផ្ទះ។»*[143] បើទោះបីជាអង្គការមិនមែនរដ្ឋាភិបាលអាចផ្ដល់ការទំនុកបម្រុងជាសម្ភារៈដល់កុមារ និងផ្ដល់ «បៀវត្សរ៍» ដល់ឪពុកម្ដាយនៅក្នុងផ្ទះស្នាក់នៅជាក្រុមក៏ដោយ ប៉ុន្តែការដែលកុមារត្រូវបានទុកដាក់នៅក្នុងផ្ទះលក្ខណៈឯកជន ធ្វើឲ្យប្រភេទនៃការថែទាំនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងអ្វីដែលគេតែងចាត់ទុកថាជាគ្រួសារធម៌។

អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលម្នាក់ទៀតដែលយើងបានសម្ភាសបាននិយាយថា «ផ្ទះស្នាក់នៅជាក្រុម» ដែលគាំទ្រដោយអង្គការរបស់អ្នកស្រីនៅក្នុងខេត្តសៀមរាប គឺជា *«កន្លែងទុកដាក់កុមាររយៈពេល ៤-៦ខែ ក្នុងគោលបំណងរៀបចំកុមារឲ្យចេះរស់នៅដោយឯករាជ្យ។ យើងមានបុគ្គលិកសង្គមកិច្ចដែលផ្ដល់ការប្រឹក្សាយោបល់ និង ចុះជួបកុមារ ៨ម៉ោង ក្នុង១ថ្ងៃ តែមិនគេងនៅក្នុងផ្ទះនោះទេ លើកលែងតែមានការស្នើសុំ»។*[144] ក្នុងករណីនេះ វាហាក់ដូចជាថា ការយល់ឃើញរបស់អ្នកផ្ដល់ចម្លើយអំពី «ផ្ទះស្នាក់នៅជាក្រុម» មានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងការរស់នៅដោយឯករាជ្យដែលមានការត្រួតពិនិត្យដោយហេតុថាអ្នកថែទាំមិនស្នាក់នៅទីនោះទេ។

ផ្ទះស្នាក់នៅជាក្រុមចំនួន ២ ដែលយើងបានចុះជួបសម្រាប់ការសិក្សានេះ ស្រដៀងគ្នាទៅនឹងការពន្យល់ខាងលើ ហើយផ្ទះទាំងនេះត្រូវបានគ្រប់គ្រងដូចគ្នានឹងមណ្ឌលថែទាំជំនួសដ៏តូចមួយ ជាជាងការថែទាំដោយគ្រួសារដែលត្រូវធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍។ ឧទាហរណ៍ ផ្ទះស្នាក់នៅជាក្រុម ដែលបានសម្ភាសនៅខេត្តសៀមរាប ត្រូវបានបិទជិតពីខាងក្រៅដោយជញ្ជាំងខ្ពស់ៗ និង មានអ្នកយាម។ ពេលដែលកុមាររស់នៅក្នុងផ្ទះនេះ ត្រូវបានអនុញ្ញាតឲ្យចេញពីបរិវេណ គឺនៅពេលដែលពួកគេត្រូវ បានគេដឹកតាមរថយន្តទៅ និងមកពីសាលារៀនឯកជននៅក្បែរនេះប៉ុណ្ណោះ ឬនៅពេលដែលអ្នកគ្រប់គ្រង នាំពួកគេទៅមើលភាពយន្តនៅក្នុងក្រុងប៉ុណ្ណោះ។[145] កុមារដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមដែលអ្នកស្រាវជ្រាវបានជួបនៅក្នុងរាជធានីភ្នំពេញក៏មានការរឹតបន្តឹងមិនឲ្យទៅលេងនៅក្នុងសហគមន៍ផងដែរ។ *«មិត្តភក្តិខ្លះមកទីនេះតែយើងមិនដែលបានទៅផ្ទះរបស់ពួកគេនោះទេ - គេមិនអនុញ្ញាតឲ្យយើងចេញទៅក្រៅទេ។ គេមិនអនុញ្ញាតិឲ្យយើងទៅលេងអ្នកផ្សេងនោះទេ»។*[146] បើទោះបីជាសុវត្ថិភាពកុមារ ជាបញ្ហាដែលត្រូវគិតគូក៏ដោយ ប៉ុន្តែ ប្រភេទនៃផ្ទះស្នាក់ នៅជាក្រុមបែបនេះមិនស្របតាមចក្ខុវិស័យនៃ «ការថែទាំជំនួសតាមសហគមន៍» ដែលមានចែង នៅក្នុងប្រកាសស្ដីពីបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសតាមសហគមន៍ឡើយ។

143 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៦។
144 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ទីក្រុងឡុងដ៍ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។
145 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
146 សម្ភាសកុមារជាក្រុមនៅផ្ទះស្នាក់នៅជាក្រុម រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។

## ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

ការទុកដាក់កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុម តែងមានការពាក់ព័ន្ធជាមួយតួអង្គពីខាងក្រៅអង្គការមិនមែនរដ្ឋាភិបាល ឬ តំណាងរដ្ឋាភិបាល) ដែលនេះមានន័យថា ចំនួននៃផ្ទះស្នាក់នៅជាក្រុម «មិនផ្លូវការ» ប្រហែលជាមានចំនួនតិចតួច។ ឧទាហរណ៍ នៅក្នុងផ្ទះស្នាក់នៅជាក្រុមដែលបានសម្ភាស ទាំងអស់ដំណើរការនៃការទុកដាក់កុមារ មានជាប់ពាក់ព័ន្ធយ៉ាងហោចណាស់ជាមួយ តួអង្គពីខាងក្រៅ ចំនួនមួយដែរ ដែលនោះអាចជាតំណាងអង្គការមិនមែនរដ្ឋាភិបាល ឬ ជាទីភ្នាក់ងាររដ្ឋាភិបាល (មន្ទីរ ស.អ.យ និង គកនក)។

ការទុកដាក់កុមារតាម «លំដាប់លំដោយ» ដែលមានចែងនៅក្នុងប្រការ ២១នៃ*ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ* គឺដំបូងត្រូវទុកដាក់កុមារ ជាមួយសាច់ញាតិ ទី ២ ជាមួយ ឪពុកម្តាយធម៌ ទី៣ ជាមួយផ្ទះស្នាក់នៅជាក្រុម និងការថែទាំតាមវត្តអារាម និងចុងក្រោយនៅក្នុងមណ្ឌលថែទាំកុមារ។ វិធីសាស្ត្រនេះហាក់ដូចជាមានការគោរពប្រតិបត្តិតាមដោយអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនដែលយើងបានសម្ភាសសម្រាប់ការសិក្សានេះ ៖ កុមារត្រូវបានទុកដាក់នៅក្នុងផ្ទះស្នាក់នៅជាក្រុមបន្ទាប់ពីបានធ្វើសមាហរណកម្មមិនបានជោគជ័យចូលទៅក្នុងការថែទាំដោយគ្រួសារ ឬ មិនអាចបញ្ចូលទៅក្នុងការថែទាំដោយគ្រួសារបាន។ អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលម្នាក់នៅក្នុងខេត្តសៀមរាប បានបញ្ជាក់ថាការថែទាំរបៀប ឋានានុក្រមដ៏តឹងរឹងនេះត្រូវបានអនុវត្ត នៅពេលទុកដាក់កុមារនៅក្នុងការថែទាំជំនួស។

*តើអង្គការរបស់អ្នកបានរៀបចំការធ្វើសមាហរណកម្មកុមារ ដែលកន្លងមកធ្លាប់រស់នៅក្នុង មណ្ឌលដោយរបៀបណា ?*

*«ជាដំបូង យើងទាក់ទងទៅមន្ទីរ ស.អ.យ ដើម្បីឲ្យដឹងថាតើកុមារមានឪពុកម្តាយឬអត់ ឬថាតើពួកគេអាចទៅរស់នៅជាមួយគ្រួសារសាខាញាតិ ដែរឬអត់។ បន្ទាប់មក ប្រសិនបើគ្មានសមាជិកសាខាញាតិទេនោះ កុមារតូចៗនឹងបញ្ជូនទៅរស់នៅជាមួយគ្រួសារធម៌ ហើយកុមារធំៗទៅនៅផ្ទះស្នាក់នៅជាក្រុម។»*

*ហេតុអ្វីបានជាកុមារធំៗទៅរស់នៅផ្ទះស្នាក់នៅជាក្រុម ?*

*កុមារធំៗមានការពិបាកជាង ក្នុងការធ្វើសមាហរណកម្មចូលទៅរស់នៅក្នុងគ្រួសារធម៌។*

*ហេតុអ្វីបានជាអ្នកគិតបែបនេះ ?*

*កុមារធំៗប៉ុន្មាននាក់ ដែលយើងបានទុកដាក់ឱ្យរស់នៅជាមួយគ្រួសារធម៌ រស់នៅមិនចុះសម្រុងជាមួយកូនបង្កើតរបស់ឪពុកម្តាយធម៌។*[147]

ចំពោះកុមារខ្លះ ពុំមានការប៉ុនប៉ងទុកដាក់កុមារនៅក្នុងការថែទាំជំនួសដោយគ្រួសារ មុនការទុកដាក់កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុមនោះទេ។ ឧទាហរណ៍ អ្នកគ្រប់គ្រងផ្ទះស្នាក់នៅជា ក្រុមម្នាក់ដែលបានសម្ភាសនៅក្នុងខេត្តសៀមរាប បានរៀបរាប់អំពីដំណើរ ការកំណត់អត្តសញ្ញាណ និងបញ្ជូនកុមារមករស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមរបស់អ្នកស្រីដូចខាងក្រោម។

147 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ

*តើកុមារមករស់នៅទីនេះយ៉ាងដូចម្តេច ? តើដំណើរការបញ្ជូនកុមារមានលក្ខណៈដូចម្តេចខ្លះ ? តើត្រូវកំណត់អត្តសញ្ញាណពួកគេដូចម្តេចដែរ ?*

*ភាគច្រើន ដំណើរការមានលក្ខណៈមិនផ្លូវការ។ ឧទាហរណ៍ ក្មេងស្រីម្នាក់ត្រូវបានកំណត់ អត្តសញ្ញាណដោយបុរសដឹកជញ្ជូនភីហ្សាម្នាក់របស់យើង។ ពេលខ្លះខ្ញុំក៏បានចុះទៅភូមិជនបទ ក្រីក្រហើយនេះគឺជារបៀបដែលខ្ញុំកំណត់អត្តសញ្ញាណក្មេងស្រីខ្លះដែលកំពុងរស់នៅទីនេះ។ ខ្ញុំចុះធ្វើការពិនិត្យមើលដោយចៃដន្យ ប្រហែល ៣ដង ក្នុង១ឆ្នាំ។ ខ្ញុំពិភាក្សាជាមួយមេភូមិ អ្នកជិតខាង និងថ្នាក់ដឹកនាំសហគមន៍។ វាត្រូវចំណាយច្រើនសម្រាប់ការថែទាំកុមារនៅក្នុងផ្ទះនេះ ដូច្នេះយើងត្រូវជ្រើសរើសឲ្យ បានល្អិតល្អន់ [ដកស្រង់តាមខ្លឹមសារដើម]។*[148]

ដំណើរការកំណត់អត្តសញ្ញាណ និង ទុកដាក់កុមារដូចរៀបរាប់ខាងលើ មិនស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ នោះទេ។ អ្នកផ្តល់ចម្លើយមិនបានប្រាប់ឲ្យដឹងថាបានស្វែងរកជម្រើសថែទាំតាមគ្រួសារផ្សេងទៀត មុនធ្វើការ «ជ្រើសរើស» កុមារទៅរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមឡើយ ហើយតាមរយៈការសម្ភាស ក៏បង្ហាញថាការធ្វើសមាហរណកម្មកុមារចូលទៅក្នុងគ្រួសារ មិនត្រូវបានចាត់ទុកថាជាអាទិភាពឡើយ ដោយឡែក វាត្រូវបានចាត់ទុកថាជា «គ្រោះថ្នាក់» មួយសម្រាប់កុមារទៅវិញ។ បើទោះជាដូច្នេះក្តី កុមារទាំងនេះសុទ្ធសឹងតែត្រូវបានចាត់ទុកថាអាចប្រឈមទៅនឹងគ្រោះថ្នាក់គួរឱ្យកត់សម្គាល់ នៅក្នុងគ្រួសារបង្កើតរបស់ពួកគេ។

*តើកុមារទំនងនឹងស្នាក់នៅក្នុងការថែទាំរបស់អ្នក រយៈពេលប៉ុន្មាន ?*

*យូរតាមតែពួកគេត្រូវការ។ មិនមានការកម្រិតអាយុច្រើនបំផុតនោះទេចំពោះក្មេងស្រីដែលស្នាក់នៅទីនេះ។ ឪពុកម្តាយអាចសម្រេចចិត្តថាចង់ ឬ មិនចង់យកកូនរបស់ពួកគេត្រឡប់ទៅវិញ ឬ យកកូនរបស់ពួកគេត្រឡប់ទៅវិញនៅពេលណា។ ប្រព័ន្ធនេះវាមានចន្លោះប្រហោងធំ! យើងគ្មានសិទ្ធិអំណាចរារាំងឪពុកម្តាយពីការយកកូនរបស់ពួកគេត្រឡប់ទៅវិញនោះទេ។*

*តើអ្នកមានបានប្រឹងប្រែងធ្វើសមាហរណកម្មកុមារដែលស្ថិតនៅក្នុងការថែទាំរបស់អ្នក ដែរឬទេ ?*

*ទេ! គ្មានគ្រួសារណាដែលមានជីវភាពល្អប្រសើរ ហើយអាចយកកូនរបស់ពួកគេត្រឡប់ទៅវិញនោះទេ។*[149]

## ការត្រួតពិនិត្យតាមដាន

ផ្ទះស្នាក់នៅជាក្រុម មានការត្រួតពិនិត្យតាមដានល្អជាង បើប្រៀបធៀបទៅនឹងការថែទាំកុមារដោយគ្រួសារសាច់ញាតិ។ រាល់អ្នកផ្តល់ការថែទាំនៅផ្ទះស្នាក់នៅជាក្រុមទាំងអស់ដែលបានសម្ភាសបានប្រាប់ឲ្យដឹងថាមានស្ថាប័នពីខាងក្រៅចុះមកត្រួតពិនិត្យពួកគេ។ ការអនុវត្តបែបនេះ ស្របទៅនឹងប្រការ១២ នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសតាមសហគមន៍ដែលតម្រូវឲ្យអ្នកផ្តល់ការថែទាំជំនួសនៅផ្ទះស្នាក់នៅជាក្រុម ទទួលខុសត្រូវចំពោះការតាមដានជាប្រចាំ និងជាបន្តបន្ទាប់ ក្រោយពេលទុកដាក់កុមារ ដើម្បីធានានូវភាពអនុលោមតាមបទដ្ឋានអប្បបរមា។

148 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
149 សម្ភាសអ្នកថែទាំផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

ប្រការ ១២ ក៏ចែងផងដែរថាមន្ទីរ ស.អ.យ មានភារកិច្ចចុះត្រួតពិនិត្យផ្ទះស្នាក់នៅជាក្រុមយ៉ាងហោចណាស់ម្តងក្នុង១ឆ្នាំ។ បើទោះជាដូច្នេះក្តី ភស្តុតាងពីទិន្នន័យបែបគុណភាពបង្ហាញថា ការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងការត្រួតពិនិត្យតាមដានផ្ទះស្នាក់នៅជាក្រុម ជាពិសេសផ្ទះស្នាក់នៅជាក្រុមដែលស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹង "គ្រួសារធម៌" នៅមានកម្រិតនៅឡើយ។ ដូចអង្គការមិនមែនរដ្ឋាភិបាលមួយបានកត់សម្គាល់ថា៖

*"ពេលខ្លះ [មន្ទីរ ស.អ.យ និង គកនក] មានការរវល់ខ្លាំងពេក ដូច្នេះយើងចុះទៅពិនិត្យ [ផ្ទះស្នាក់នៅជាក្រុម] តែឯង ហើយពួកគេ [មន្ទីរ ស.អ.យ និង គកនក] គ្រាន់តែចុះហត្ថលេខាលើទម្រង់ដោយមិនបានចុះត្រួតពិនិត្យតាមដានដោយខ្លួនពួកគេ។"*[150]

អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការទុកដាក់កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុម ជាញឹកញាប់ជួបប្រទះបញ្ហាដូចៗគ្នាដូចតំណាងអាជ្ញាធរមូលដ្ឋានដែរ។ *"ចំពោះកុមារដែលរស់នៅក្បែរការិយាល័យរបស់យើង ខ្ញុំអាចនិយាយបានថា [យើងបានចុះមើល] ២-៣ដង ក្នុង១សប្តាហ៍។ សម្រាប់អ្នកដែលរស់នៅឆ្ងាយ យើងចុះទៅ ១-២ដងក្នុង១ខែ"*។[151]

ផ្ទុយទៅវិញ សម្រាប់ផ្ទះស្នាក់នៅជាក្រុមដែលមានរចនាសម្ព័ន្ធ និងទំហំនៃការគ្រប់គ្រង់របស់ពួកគេស្រដៀងទៅនឹងមណ្ឌលថែទាំកុមារខ្នាតតូច មន្ទីរ ស.អ.យ មានការចូលរួមច្រើនជាងគេក្នុងការត្រួតពិនិត្យតាមដាន។ អ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុមម្នាក់ដែលបានផ្តល់ការថែទាំដល់កុមារចំនួន ១៣នាក់ នៅក្នុងក្រុងសៀមរាប និយាយថា៖

*"តំណាងមកពីមន្ទីរ ស.អ.យ ខេត្ត [សៀមរាប] បានចុះមកមើលដោយមិនប្រកាសឲ្យដឹងជាមុន ពួកគេចុះមកបែបនេះ ៣ដងក្នុង១ឆ្នាំ តែចន្លោះពេលខុសៗគ្នា។ ហើយពេលខ្លះ ក្រសួង ស.អ.យ មកពីភ្នំពេញ បញ្ជូន១ក្រុមចុះមកត្រួតពិនិត្យ១ឆ្នាំម្តង។"*[152]

បើទោះបីជាករណីនេះបង្ហាញថា ការចុះត្រួតពិនិត្យជាផ្លូវការទៅលើផ្ទះធំៗសម្រាប់ស្នាក់នៅជាក្រុម មានលក្ខខណ្ឌស្របច្រើនទៅនឹងបទដ្ឋានអប្បបរមាឆ្នាំ ២០០៨ ក៏ដោយ ប៉ុន្តែវាមានសារៈសំខាន់ដែលត្រូវចងចាំថា សំណាកនៃការសិក្សានេះមានទំហំតូចណាស់ ដែលអាចមិនតំណាងឲ្យផ្ទះស្នាក់នៅជាក្រុមទាំងអស់នៅក្នុងប្រទេសកម្ពុជានោះទេ។

## ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត

កុមាររស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម អាចនៅមានឪពុក ឬ ម្តាយ ឬ ទាំងឪពុកនិងម្តាយ បង្កើតដែលនៅរស់។ ភាពញឹកញាប់នៃការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបង្កើត មានមិនដូចគ្នា ឡើយរវាងផ្ទះស្នាក់នៅជាក្រុមផ្សេងៗគ្នាដែលការសិក្សាបានរកឃើញ ដោយមានកុមារ ខ្លះបានធ្វើការ ប្រាស្រ័យទាក់ទងរៀងរាល់សប្តាហ៍ ហើយខ្លះទៀតបានជួបឪពុកម្តាយរបស់ពួកគេ១ឆ្នាំម្តងប៉ុណ្ណោះ។

*តើអ្នកជួបឪពុកម្តាយរបស់អ្នកញឹកញាប់ប៉ុណ្ណា?*

*ពួកគាត់មកលេងខ្ញុំប្រហែល ២-៣ដង រៀងរាល់ឆ្នាំ។ ហើយយើងអាចទូរស័ព្ទទៅជួបគាត់ប្រហែល ៣ដងក្នុង ១ខែ។*[153]

150 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
151 អ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
152 សម្ភាសអ្នកថែទាំ ផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
153 សម្ភាសជាមួយកុមារ ផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៦។

*ចុះឪពុកម្តាយរបស់អ្នក? តើអ្នកដែលជួបពួកគាត់ទេ?*

*ម្តាយរបស់ខ្ញុំមកលេងខ្ញុំប្រហែល១ដង ឬ ២ដង ក្នុងមួយឆ្នាំ។ ភាគច្រើនគាត់មកដោយមិនប្រាប់ឲ្យដឹងមុន។ គាត់ជាអ្នកសុំទាននៅក្នុងប្រទេសថៃ។*[154]

បើទោះបីជាការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ ជាគោលការណ៍ គឺជាចំណុចល្អមួយសម្រាប់កុមារក៏ដោយ ប៉ុន្តែមានអ្នកផ្តល់ការថែទាំមួយចំនួននៅផ្ទះស្នាក់នៅជាក្រុម បាននិយាយថាការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបង្កើតអាចជះឥទ្ធិពលអវិជ្ជមានមកលើកូន។

*តើការប្រឈម និងការលំបាកដ៏ធំដែលអ្នកជួបប្រទះក្នុងនាមជាអ្នកថែទាំកុមារមានអ្វីខ្លះ?*

*វាគឺជាការផ្តល់ដំបូន្មានអវិជ្ជមានរបស់ឪពុកម្តាយ និងឥទ្ធិពលអាក្រក់មកលើកូន។ ពួកគេនិយាយដូចជា៖ "សាលារៀនមិនសំខាន់នោះទេ" ឬ "យើងជាប់បំណុលដែលត្រូវសង"។ ក្មេងស្រីម្នាក់ [ដកស្រង់តាមខ្លឹមសារដើម] នាងទើបអាយុ ១៦ឆ្នាំថ្មីៗនេះបានចាកចេញទៅរកការងារធ្វើជាអ្នកបោសសំអាត ពីព្រោះម្តាយរបស់នាងជំពាក់បំណុលគេ ហើយនាងមានអារម្មណ៍ថាខ្លួននាងមានកាតព្វកិច្ចត្រូវជួយម្តាយរបស់នាង។ តាមវប្បធម៌ខ្មែរ ក្មេងស្រីចង់ជួយគ្រួសាររបស់គេ។*[155]

តាមទស្សនៈរបស់កុមារខ្លួនឯង ជាទូទៅ ការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ ចាត់ទុកថាមានផលវិជ្ជមាន ប៉ុន្តែក៏មានកុមារមួយចំនួនតូចនិយាយថា ពួកគេចង់រស់នៅជាមួយឪពុកម្តាយបង្កើតរបស់ពួកគេជាង។ ក្មេងស្រីមួយក្រុមនៅក្នុងផ្ទះស្នាក់នៅជាក្រុមនៅក្នុងខេត្តសៀមរាបត្រូវបានសួរសំណួរដូចខាងក្រោម៖

*តើអ្នកមានអារម្មណ៍ដូចម្តេចពេលបានជួបឪពុកម្តាយរបស់អ្នក?*

*យើងចូលចិត្តជួបឪពុកម្តាយរបស់យើង!*

*ប្រសិនបើអ្នកអាចសម្រេចចិត្តអំពីទីកន្លែងដែលអ្នកចង់រស់នៅ តើអ្នកចង់រស់នៅជាមួយឪពុកម្តាយរបស់អ្នក ឬ រស់នៅទីនេះ?*

*យើងចូលចិត្តរស់ [ផ្ទះស្នាក់នៅជាក្រុម] ជាង។*[156]

បើទោះជាដូច្នេះក្តី នៅក្នុងករណីផ្សេងទៀត កុមារចាត់ទុកថាការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបង្កើតមានផលជាវិជ្ជមាន។ ឧទាហរណ៍ ក្មេងប្រុសម្នាក់ដែលបានសម្ភាសនៅក្នុងផ្ទះស្នាក់នៅជាក្រុមនៅក្នុងរាជធានីភ្នំពេញបាននិយាយថា គាត់ *"មានការភ័យខ្លាចចំពោះម្តាយរបស់គាត់"* (ម្តាយរបស់គាត់បានសម្លាប់មនុស្សម្នាក់) ហេតុដូច្នេះហើយបានជាគាត់មិនចង់និយាយជាមួយម្តាយ។[157] នៅក្នុងករណីនេះ ការប្រាស្រ័យទាក់ទង (ប្រសិនបើមាន) ត្រូវធ្វើដោយប្រុងប្រយ័ត្ន។

## លក្ខណៈនៃការថែទាំដែលបានផ្តល់ជូន

ប្រការ ៦(៣) នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍តម្រូវថា៖ *"ផ្ទះស្នាក់នៅជាក្រុមនីមួយៗ ត្រូវមានអ្នកថែទាំកុមារ ២នាក់ ធ្វើជាម្តាយ និងជាឪពុក"*។ បើទោះជាដូច្នេះក្តី ជាក់ស្តែង ផ្ទះស្នាក់នៅជាក្រុមកម្រអនុវត្តតាមរចនាសម្ព័ន្ធថែទាំដូចដែលប្រកាសបានតម្រូវណាស់។ ឧទាហរណ៍ ផ្ទះស្នាក់នៅជាក្រុមដែលអ្នកស្រាវជ្រាវបានចុះជួបនៅក្នុងខេត្តបាត់ដំបងមានតែអ្នកថែទាំកុមារ

154 សម្ភាសជាមួយកុមារ ផ្ទះស្នាក់នៅជាក្រុម ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៦។
155 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
156 សម្ភាសក្មេងស្រីជាក្រុមនៅផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
157 សម្ភាសក្មេងប្រុសនៅផ្ទះស្នាក់នៅជាក្រុម រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។

ជាស្ត្រីម្នាក់ប៉ុណ្ណោះ។[158] ផ្ទុយទៅវិញ ផ្ទះស្នាក់នៅជាក្រុមដែលយើងបានចុះជួបនៅក្នុងខេត្តសៀមរាប មានអ្នកថែទាំកុមារច្រើនជាង ៣នាក់ ប៉ុន្តែក្នុងនោះ ពុំមាននរណាម្នាក់ជាបុរសនោះទេ។[159]

លក្ខណៈនៃការថែទាំដែលផ្តល់ដល់កុមាររស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម ភាគច្រើនអាស្រ័យលើថាតើការថែទាំនោះមានលក្ខណៈស្រដៀងទៅនឹង "គ្រួសារធម៌" (ដោយមានអ្នកថែទាំដែលទទួលបានបៀវត្សរ៍ និង/ឬ ផ្ទះជួល) ឬស្រដៀងទៅនឹងមណ្ឌលថែទាំខ្នាតតូច។ ក្រៅពីនេះ លក្ខណៈនៃការថែទាំដែលផ្តល់ឲ្យកុមាររស់នៅផ្ទះស្នាក់នៅជាក្រុម គឺអាស្រ័យលើកម្រិតនៃការទំនុកបម្រុង ពីអង្គការមិនមែនរដ្ឋាភិបាល។ ទោះបីជាពិបាកទាញការសន្និដ្ឋានដ៏រឹងមាំ ដោយសារចំនួនករណីដែលបានសិក្សានេះមានចំនួនតិចពេកក៏ដោយ ប៉ុន្តែវាទំនងថាផ្ទះស្នាក់នៅជាក្រុម ដែលមានទម្រង់ជា "មណ្ឌលស្នាក់នៅ" អាចផ្តល់ជូនកុមារនូវសេវានានា (ការទទួលបានការអប់រំនៅសាលាឯកជន មានបន្ទប់ផ្ទាល់ខ្លួន ។ល។) ដែលកុមារកម្រមានលទ្ធភាពទទួលបាននៅក្នុងការថែទាំដោយគ្រួសារ ដូចជា ការថែទាំដោយសាច់ញាតិ ឬការថែទាំដោយឪពុកម្តាយធម៌។

*លក្ខខណ្ឌសម្ភារៈ*

ទិន្នន័យបែបបរិមាណដែលទទួលបានពីបញ្ជីផ្ទៀងផ្ទាត់តាមរយៈការអង្កេតបង្ហាញថា កុមាររស់នៅផ្ទះស្នាក់នៅជាក្រុម បានទទួលបទដ្ឋានរស់នៅសមរម្យ បើប្រៀបធៀបជាមួយបទដ្ឋានរស់នៅជាទូទៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ ផ្ទះស្នាក់នៅជាក្រុមទាំងអស់ដែលបានបញ្ចូលនៅក្នុងបញ្ជីផ្ទៀងផ្ទាត់តាមរយៈការអង្កេត មានប្រព័ន្ធលូទឹក និង បង្គន់មួយមានដំណើរការ ដែលមានស្ថានភាពអាចទទួលយកបាន។ ក្រៅពីនេះ បញ្ជីផ្ទៀងផ្ទាត់បែបបរិមាណបង្ហាញថា កុមារទាំងអស់រស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមមានលទ្ធភាពទទួលបានទឹកស្អាត និងមានសុវត្ថិភាព សម្រាប់បរិភោគ។

*ការទទួលបានការអប់រំ៖*

កុមាររស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម មានលទ្ធភាពល្អប្រសើរក្នុងការទទួលការអប់រំ។ អង្គការមិនមែនរដ្ឋាភិបាលមួយដែលអ្នកស្រាវជ្រាវបានចុះជួបនៅខេត្តបាត់ដំបងបានកំណត់លក្ខខណ្ឌឲ្យមានការបង្កើតផ្ទះស្នាក់នៅជាក្រុមនៅក្បែរសាលារៀនរបស់រដ្ឋ។[160] នៅក្នុងផ្ទះស្នាក់នៅជាក្រុមមួយទៀតនៅខេត្តសៀមរាប កុមារទាំងអស់ត្រូវបានដឹកតាមរថយន្តក្រុងធន់តូចទៅមកពីសាលាឯកជនអាស្រ័យដោយអ្នកគ្រប់គ្រងយល់ថាការសិក្សានៅសាលារដ្ឋខ្វះគុណភាព ៖

*"ខ្ញុំបានចុះមើលសាលារដ្ឋនៅទីនេះ តែវាមិនល្អ។ គ្រូបង្រៀនខ្លះទារប្រាក់ពីសិស្ស ២៥០០រៀលសម្រាប់មុខវិជ្ជាមួយ ដូច្នេះខ្ញុំគិតថាខ្ញុំសុខចិត្តបញ្ជូនកុមារទៅរៀននៅសាលាឯកជនវិញ"។[161]*

*ការទទួលបានបុគ្គលិកសង្គមកិច្ច៖*

ប្រការ ៦(៣) នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសតាមសហគមន៍ ចែងថា "បុគ្គលិកសង្គមកិច្ច [...] ត្រូវចុះតាមដានកុមារ និងអ្នកថែទាំកុមាររស់នៅតាមផ្ទះស្នាក់នៅជាក្រុមជាប្រចាំ ដើម្បីធានាថាកុមារមានសុវត្ថិភាព"។ បើទោះជាដូច្នេះក្តី គ្មានកុមារណាម្នាក់នៅក្នុងផ្ទះស្នាក់នៅជាក្រុម ដែលយើងបានសម្ភាសនៅក្នុងការសិក្សានេះ បានជួបជាមួយបុគ្គលិកសង្គមកិច្ចជាប្រចាំនោះទេ ដោយនេះមិនទាន់សំដៅចំពោះបុគ្គលិកសង្គមកិច្ចដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកផង។

158 សម្ភាសអ្នកថែទាំផ្ទះស្នាក់នៅជាក្រុម ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
159 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
160 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៦។
161 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

*តើបុគ្គលិកសង្គមកិច្ច បានចុះមកជួបអ្នកជាបន្តបន្ទាប់ ដែរឬទេ ? [ក្មេងស្រីអាយុ ១៣ឆ្នាំ]*

*ចាស! ពេលខ្លះគាត់ចុះមកមើលខ្ញុំ។ [នៅពេលដំបូង កុមារផ្សេងទៀតនៅក្នុងក្រុម មិនច្បាស់ក្នុងចិត្តអំពីរឿងនេះ តែបន្ទាប់បានយល់ស្រប]*

*តើគាត់ចុះមកញឹកញាប់ប៉ុណ្ណា ?*

*ខ្ញុំគិតថាប្រហែល១ឆ្នាំម្តង។*

*តើអ្នកនិយាយអំពីអ្វីខ្លះជាមួយគាត់ ?*

*គាត់សួរក្រែងយើងមានបញ្ហា។ គាត់សួរថាហេតុអីបានជាយើងមករស់នៅទីនេះ។ តើនៅផ្ទះរបស់យើងមានបញ្ហាអ្វីខ្លះ...។*

*តើអ្នកចូលចិត្តនិយាយជាមួយបុគ្គលិកសង្គមកិច្ច ដែរឬទេ ?*

*ចាស! វាជាការល្អ! ក៏ប៉ុន្តែយើងចង់ឲ្យពួកគាត់ចុះមកមើលយើងឲ្យបានញឹកញាប់ជាងនេះ។*

*រាល់ពេលគេចុះមកមើលម្តង តើអ្នកទាំងនោះមិនមែនជាមនុស្សដដែល ទេឬ ?*

*ទេ! រាល់ពេលគាត់ចុះមក មិនមែនមនុស្សដដែលៗនោះទេ។*

*[សួរក្មេងស្រីដែលបានរស់នៅផ្ទះស្នាក់នៅជាក្រុមបាន ១ខែ] តើបុគ្គលិកសង្គមកិច្ចចុះមកមើលអ្នកដែរទេ ?*

*ទេ! ខ្ញុំមិនបានជួបបុគ្គលិកសង្គមកិច្ចណាមួយនោះទេ។*[162]

កង្វះលទ្ធភាពទទួលបានបុគ្គលិកសង្គមកិច្ច ដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកជាក់លាក់លើករណីនីមួយៗ គឺជាបញ្ហាដែលបានកើតឡើងយ៉ាងច្បាស់លាស់ សូម្បីតែនៅក្នុងផ្ទះស្នាក់នៅជាក្រុមដែលមានរចនាសម្ព័ន្ធគ្រប់គ្រង និងដំណើរការដូចមណ្ឌលថែទាំកុមារខ្នាតតូចមួយក៏ដោយ ដូចជា ផ្ទះស្នាក់នៅជាក្រុមដែលយើងបានចុះពិនិត្យមើលនៅខេត្តសៀមរាប។

## ការបណ្តុះបណ្តាល

ប្រការ ៦(៣) នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ចែងថា អ្នកផ្តល់ ការថែទាំជំនួស «ត្រូវផ្តល់ឱ្យអ្នកថែទាំនូវជំនាញដ៏ចាំបាច់ក្នុងការថែទាំកុមារ រួមទាំងកុមារមានសេចក្តីត្រូវការពិសេសផងដែរ»។រាល់អ្នកថែទាំទាំងអស់នៃផ្ទះស្នាក់នៅជាក្រុមដែលបានបញ្ចូលនៅក្នុងការសិក្សានេះ បាននិយាយថា ពួកគេបានទទួលការបណ្តុះបណ្តាលក្នុងទម្រង់មួយចំនួន។ បើទោះជាដូច្នេះក្តី យោងតាមទិន្នន័យ បែបគុណភាពបង្ហាញថា ក្នុងករណីខ្លះ ការបណ្តុះបណ្តាលនេះអាចនៅមានកម្រិតនៅឡើយ ហើយការបណ្តុះបណ្តាលត្រូវបានផ្តល់ដោយបុគ្គលិកជាន់ខ្ពស់ម្នាក់»។[163]

162 សម្ភាសកុមារជាក្រុមនៅផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។
163 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

## ការចំណាយ និងការផ្តល់មូលនិធិ

យោងតាមទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាល និងម្ចាស់ជំនួយ ផ្ទះស្នាក់នៅជាក្រុមត្រូវចំណាយច្រើនជាង ការថែទាំជំនួសដោយគ្រួសារ ដូចជា ការថែទាំដោយសាច់ញាតិ និងការថែទាំដោយឪពុកម្តាយធម៌។ នេះដោយសារអ្នកផ្តល់ការថែទាំនៅក្នុងផ្ទះស្នាក់នៅជាក្រុម ត្រូវជួលផ្ទះ សម្រាប់បង្កើតជាផ្ទះស្នាក់នៅជាក្រុម។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ "បៀវត្សរ៍"ដល់អ្នកថែទាំកុមារ ឬផ្តល់ប្រាក់ដល់កុមារម្នាក់ៗ។ ចំនួនទឹកប្រាក់នេះមិនដូចគ្នាឡើយ គឺមានចំនួនចាប់ពី ២៥ដុល្លារអាមេរិកក្នុងកុមារម្នាក់ ក្នុង១ខែ[164] ទៅ "ច្រើនជាង១០០ដុល្លារ" ឬ "១៤៩ដុល្លារ ក្នុង១ខែ" អាស្រ័យលើធនធានរបស់អង្គការនីមួយៗ។[165]

សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ឱ្យកុមារនូវការរៀនសូត្រនៅសាលាឯកជនវិញ ការចំណាយសម្រាប់កុមារម្នាក់អាចមានចំនួនច្រើនជាង ដោយសារត្រូវបង់ថ្លៃសាលា និង ថ្លៃធ្វើដំណើរ។ ឧទាហរណ៍ ផ្ទះស្នាក់នៅជាក្រុមនៅខេត្តសៀមរាបដែលយើងបានជួប បានចំណាយប្រហែល ២០០ដុល្លារសម្រាប់កុមារម្នាក់ក្នុង១ខែ ដែលក្នុងនោះមានបញ្ចូលថ្លៃឈ្នួលផ្ទះ អាហារ និង ថ្លៃសាលាឯកជន។ *"ការចំណាយដ៏ច្រើនបំផុតរបស់យើងគឺចំណាយលើការសិក្សា បន្ទាប់មកគឺថ្លៃអាហារ។"*[166]

ចំពោះផ្ទះស្នាក់នៅជាក្រុមនៅរាជធានីភ្នំពេញ អ្នកគ្រប់គ្រងបានប៉ាន់ស្មានថា គាត់ត្រូវចំណាយ ១៥០០ដុល្លារ ដើម្បីផ្តល់ការថែទាំកុមារ ៧នាក់ និង យុវជនវ័យក្មេង ២នាក់ (មិនរាប់បញ្ចូលបៀវត្សរ៍សម្រាប់បុគ្គលិក)។ ចំពោះកុមារម្នាក់ត្រូវចំណាយ ១៧០ដុល្លារ ក្នុង១ខែ។ បើគិតទាំងបៀវត្សរ៍ផង តាមការប៉ាន់ស្មានត្រូវចំណាយប្រហែល ៣១៥០ដុល្លារ ក្នុង១ខែ សម្រាប់គ្រប់គ្រងដំណើរការផ្ទះស្នាក់នៅជាក្រុមដែលបានចុះពិនិត្យមើលនៅភ្នំពេញ។[167]

ដោយសារសំណាកនៃផ្ទះស្នាក់នៅជាក្រុមដែលយើងបានចុះជួបសម្រាប់ការសិក្សានេះ មានចំនួនតិច វាពិបាកនឹងទាញការសន្និដ្ឋានជាទូទៅអំពីការចំណាយលើការថែទាំនៅក្នុងផ្ទះស្នាក់នៅ ជាក្រុមនៅក្នុងប្រទេសកម្ពុជាណាស់។ ទោះដូច្នេះក៏ដោយ ភស្តុតាងបែបគុណភាពដែលមានស្រាប់បង្ហាញថា ផ្ទះស្នាក់នៅជាក្រុម មានការចំណាយច្រើនជាងការចំណាយទៅលើការថែទាំតាមសហគមន៍ ដូចជា ការថែទាំដោយញាតិ ឬ ដោយឪពុកម្តាយធម៌ ដែលចំណុចនេះនាំឱ្យមានបញ្ហាទាក់ទងនឹងនិរន្តរភាព។

## បទពិសោធន៍របស់កុមារ

នៅពេលសាកសួរអំពីបទពិសោធន៍រស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម កុមារភាគច្រើនដែលបាន សម្ភាសសម្រាប់ការសិក្សានេះ បានរៀបរាប់នូវបទពិសោធន៍របស់ពួកគេក្នុងន័យវិជ្ជមាន ជាពិសេសបើ ប្រៀបធៀបទៅនឹងបទពិសោធន៍រស់នៅឯផ្ទះរបស់ពួកគេ។ ក្មេងស្រីម្នាក់ដែលបានរងការរំលោភបំពានពីឪចុង បន្ទាប់ពីម្តាយរបស់នាងរៀបការម្តងទៀតបាននិយាយថា៖ *"នៅពេលខ្ញុំរស់នៅជាមួយម្តាយរបស់ខ្ញុំ ខ្ញុំមិនសប្បាយចិត្តខ្លាំងណាស់។ បន្ទាប់មក ខ្ញុំក៏មកនៅទីនេះ ហើយឥឡូវខ្ញុំសប្បាយចិត្ត"*។[168]

164 សម្ភាសម៉ែដោះនៅផ្ទះស្នាក់នៅជាក្រុម ខេត្តបាត់ដំបង ថ្ងៃទី ១៧ខែតុលា ឆ្នាំ ២០១៦។
165 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ខែតុលា ឆ្នាំ ២០១៦។ សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
166 សម្ភាសអ្នកគ្រប់គ្រងផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
167 សម្ភាសអ្នកថែទាំនៅផ្ទះស្នាក់នៅជាក្រុម រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។
168 សម្ភាសក្មេងស្រីនៅផ្ទះស្នាក់នៅជាក្រុម រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៦។

កុមារភាគច្រើន ដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមដែលបានសម្ភាសបាននិយាយថា ស្ថានភាពសម្ភារៈរបស់ពួកគេ និង ការទទួលបានការអប់រំ មានភាពប្រសើរច្រើន ដោយសារតែពួកគេបានមករស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមនេះ។ ឧទាហរណ៍ ក្មេងស្រី ១ក្រុមដែលបានសម្ភាសនៅខេត្តសៀមរាប បានលើកឡើងថាពួកគេពេញចិត្តរស់នៅផ្ទះស្នាក់នៅជាក្រុម (ជាងរស់នៅជាមួយឪពុកម្តាយបង្កើត) ពីព្រោះ *"នៅទីនេះតែងមានអាហារជានិច្ច និងមានសាលារៀនល្អៗ ដែលយើងអាចទៅរៀនបាន"*។[169] ភាពប្រសើរឡើងនូវជីវភាពរស់នៅ និង ការទទួលបានការអប់រំ ដែលកុមារនៅផ្ទះស្នាក់នៅជាក្រុម បានទទួល អាចបង្កជាការប្រឈមខ្លាំងនៅពេលគេប៉ុនប៉ងធ្វើសមាហរណកម្មកុមារចូលទៅ ក្នុងគ្រួសារ របស់ពួកគេវិញ ដែលនៅទីនោះ គ្រួសារមិនអាចផ្តល់នូវជីវភាពប្រសើរដូចនៅផ្ទះស្នាក់នៅជាក្រុម ទន្ទឹមនោះ កុមារខ្លួនឯងត្រូវជួយទ្រទ្រង់ខ្លួនឯងនៅពេលពួកគេចាកចេញពីផ្ទះស្នាក់នៅជាក្រុម។

បើទោះជាដូច្នេះក្តី កុមារមួយចំនួនដែលបានសម្ភាសបានសំដែងនូវទស្សនៈអវិជ្ជមានអំពីការរស់នៅផ្ទះស្នាក់នៅជាក្រុមនេះ ទោះបីជាពួកគេទទួលបានលក្ខខណ្ឌជាសម្ភារៈប្រសើរយ៉ាងណាក៏ដោយ។ កង្វល់ដ៏ធំរបស់ពួកគេគឺកង្វះភាពឯកជន និងកន្លែងផ្ទាល់ខ្លួន។ កុមារមួយចំនួនដែលបានសម្ភាសនៅក្នុងផ្ទះស្នាក់នៅជាក្រុម ក៏បានប្រាប់ផងដែរថា ពួកគេនឹក ឪពុកម្តាយ របស់ពួកគេ និងមានអារម្មណ៍ខ្វះភាពកក់ក្តៅនៅពេលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមនេះ។

## កន្លែងថែទាំកុមារពាក់កណ្តាលឯករាជ្យ

កន្លែងចិញ្ចឹមកុមារពាក់កណ្តាលឯករាជ្យ គឺជាប្រភេទនៃការថែទាំជំនួសនៅសហគមន៍ដែលស្រដៀងទៅនឹងផ្ទះស្នាក់នៅជាក្រុម។ ភាពខុសគ្នាគឺ អ្នកថែទាំ/បុគ្គលិកសង្គមកិច្ចមិនរស់នៅក្នុងកន្លែងចិញ្ចឹមកុមារ ឬ ស្នាក់នៅជាមួយកុមារនៅពេលយប់ឡើយ។ ប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ មិនមានចែងអំពីកន្លែង ចិញ្ចឹមកុមារប្រភេទនេះទេ។

បើទោះជាដូច្នេះក្តី ការសិក្សាបង្ហាញថា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅក្នុងប្រទេសកម្ពុជាកំពុង ប្រើប្រាស់ការថែទាំកុមារប្រភេទនេះជាការថែទាំជំនួសតាមសហគមន៍។ កន្លែងថែទាំកុមារពាក់កណ្តាលឯករាជ្យនេះត្រូវបានប្រើប្រាស់ជាចម្បងដោយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំកុមារធំៗ (ជាធម្មតាអាយុ ១៦-១៨ឆ្នាំ) ដែលបានរស់នៅក្នុងមណ្ឌលថែទាំឬ ថែទាំជំនួស ដើម្បីឱ្យពួកគេរស់នៅដោយឯករាជ្យដោយ*គ្មានអ្នកត្រួតត្រា*។

169 សម្ភាជាក្រុមជាមួយកុមារនៅផ្ទះស្នាក់នៅជាក្រុម ខេត្តសៀមរាប ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។

*យើងមានបុគ្គលិកសង្គមកិច្ចម្នាក់ ដែលផ្តល់ប្រឹក្សា និងចុះមើលតាមកន្លែងថែទាំ ៨ម៉ោង ក្នុង១ថ្ងៃ។ កុមារវ័យជំទង់ជ្រើសរើសអ្នកដែលពួកគេចង់រស់នៅជាមួយ។  យើងផ្តល់បរិយាកាសរស់នៅប្រកបដោយសុវត្ថិភាពដល់ពួកគេ និងចុះជាប់ជាមួយពួកគេ រហូតដល់ពួកគេ អាចរស់នៅដោយឯករាជ្យបាន។ យើងនឹងធានាថាពួកគេស្គាល់អំពីការរស់នៅដោយឯករាជ្យ ដើម្បីឱ្យពួកគេអាចបោះជំហានចូលទៅក្នុងជីវិតឯករាជ្យ។*[170]

ការរៀបចំរស់នៅដោយឯករាជ្យ ត្រូវចំណាយច្រើនដូចគ្នានឹងផ្ទះស្នាក់នៅជាក្រុមដែរ បើទោះបីមិនសូវចំណាយច្រើនទៅលើបៀវត្សរ៍បុគ្គលិកក៏ដោយ។ កុមារដែលរស់នៅពាក់កណ្តាលឯករាជ្យជាច្រើនបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬចូលរៀននៅ សាកលវិទ្យាល័យ។ ឧទាហរណ៍ កុមារដែលបានរស់នៅកន្លែងថែទាំមួយនៅខេត្តបាត់ដំបង ដែលគ្រប់គ្រងដោយអង្គការបានទទួលការបណ្តុះបណ្តាលជំនាញពីគ្រូមកពីខាងក្រៅ ដែលអង្គការនោះ ជាអ្នកជួលមក បង្រៀន៖ *«ក្មេងស្រីរបស់យើងជាច្រើននាក់បានទទួលការបណ្តុះបណ្តាលជំនាញខាងផាត់មុខធ្វើសក់។ យើងជួយពួកគេ ២០០ដុល្លា ក្នុងម្នាក់ក្នុង១ខែ»។*[171]

170 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ទីក្រុងឡុងដ៍តាម skype ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។
171 សម្ភាសអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។






# មណ្ឌលថែទាំកុមារ និងអន្តេវាសិកដ្ឋាន

## គំហើញសំខាន់ៗ៖ មណ្ឌលថែទាំកុមារ និងអន្តេវាសិកដ្ឋាន

១. យោងតាមភស្តុតាងបង្ហាញថាមណ្ឌលថែទាំកុមារ និងអន្តេវាសិកដ្ឋានមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងការអនុវត្តជាក់ស្តែង ដោយប្រភេទនៃកន្លែងទាំង ២ មានភាពត្រួតគ្នាគួរឱ្យកត់សម្គាល់។

២. មានការខិតខំគួរឱ្យកត់សម្គាល់ក្នុងការធ្វើសមាហរណកម្មកុមារចេញពីការរស់នៅក្នុងមណ្ឌថែទាំ។ មួយផ្នែកប្រហែលមកពីផែនការសកម្មភាពជាតិ ដែលតម្រូវឲ្យមានការធ្វើសមាហរណកម្មកុមារចំនួន ៣០% ពីមណ្ឌលប្រកបដោយសុវត្ថិភាព មួយផ្នែកទៀតម្ចាស់ជំនួយបរទេសបានដកការគាំទ្ររបស់ពួកគេ និង មួយផ្នែកទៀតអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយបានផ្លាស់ប្តូរមុខព្រួញរបស់ពួកគេ។

៣. បើទោះបីជាការធ្វើសមាហរណកម្មកុមារឱ្យទៅរស់នៅក្រោមការថែទាំដោយគ្រួសារ គឺជាអាទិភាព ក៏ដោយប៉ុន្តែក្នុងករណីខ្លះការធ្វើសមាហរណកម្មត្រូវបានជម្រុញដោយកត្តាថវិកាជាជាង ដោយការគិតគូចំពោះឧត្តមប្រយោជន៍របស់កុមារម្នាក់ៗ។

៤. បទពិសោធន៍របស់កុមាររស់នៅក្នុងមណ្ឌលថែទាំ និងអន្តេវាសិកដ្ឋាន មានលក្ខណៈចម្រុះ។ មានកុមារមួយចំនួនបានរាយការណ៍ថា ពួកគេ «សប្បាយចិត្ត» និង «រស់នៅទីនោះបាន»។ កុមារផ្សេងទៀតនិយាយថាពួកគេនឹកគ្រួសារ និងសហគមន៍របស់ពួកគេ។

៥. កុមាររស់នៅក្នុងមណ្ឌលថែទាំ និងសាលារៀនផ្តល់កន្លែងស្នាក់នៅមានការទាក់ទងតិចតួចជាមួយគ្រួសាររបស់ខ្លួន៖ កុមារភាគច្រើនបានរាយការណ៍ថា ពួកគេកម្រ ឬ មិនដែលជួបគ្រួសាររបស់ពួកគេឡើយ។

៦. បុគ្គលិកថែទាំនៅក្នុងមណ្ឌល និង អន្តេវាសិកដ្ឋាន បានទទួលការបណ្តុះបណ្តាលពី ក្រសួង ស.អ.យ និងហាក់មាននិន្នាការនិយាយថាការបណ្តុះបណ្តាលទាំងនោះមានគុណភាពខ្ពស់ជាងអ្នកថែទាំមកពីកន្លែងថែទាំជំនួសចំពោះកុមារផ្សេងទៀត។

ប៉ុន្មានទសវត្សរ៍ថ្មីៗនេះ មានការរីកដុះដាលយ៉ាងឆាប់រហ័សនូវមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា។[172] ការមានចំណាប់អារម្មណ៍ និង ការវិនិយោគពីម្ចាស់ជំនួយបរទេស ព្រមទាំងទម្រង់នានានៃ "ការងារស្ម័គ្រចិត្ត" បានលើកទឹកចិត្តកាន់តែច្រើនឡើង ឲ្យមានការទុកដាក់ និង ថែទាំកុមារនៅក្នុងមណ្ឌល ក្នុងលក្ខណៈជាការឆ្លើយតបមួយ ឬ ជា "ដំណោះស្រាយ" មួយដោយស្វ័យប្រវត្តិ ចំពោះបញ្ហាកង្វល់ និង សេចក្តីត្រូវការដទៃទៀតទាក់ទងនឹងកិច្ចការពារកុមារ។

ការសិក្សានេះបានធ្វើការប្រមូលទិន្នន័យបែបគុណភាពពីមណ្ឌលថែទាំកុមារចំនួន ៤កន្លែង និងអន្តេវាសិកដ្ឋានចំនួន ៣ កន្លែង ដែលផ្តល់ការថែទាំជំនួសចំពោះកុមារនៅរាជធានីខេត្តចំនួន ៥។ គោលបំណងនៃការចុះទៅពិនិត្យមណ្ឌលទាំងនេះ គឺដើម្បីធ្វើការប្រៀបធៀបកន្លែងថែទាំទាំងនេះជាមួយកន្លែងថែទាំដោយគ្រួសារ និង ដើម្បីបង្កើនការយល់ដឹងអំពីការខិតខំប្រឹងប្រែងធ្វើសមាហរណកម្មកុមារពីមណ្ឌល ឱ្យទៅទទួលការថែទាំជំនួសវិញ។ បុគ្គលិកថែទាំចំនួន ១៤នាក់ នៅក្នុងមណ្ឌលថែទាំទាំងនោះត្រូវបានបញ្ចូលទៅក្នុងការសិក្សានេះ។ មានមណ្ឌល តែ ១ប៉ុណ្ណោះ ក្នុងចំណោមមណ្ឌលចំនួន ៧ បានកំណត់ខ្លួនឯងថាជា "អន្តេវាសិកដ្ឋាន" និងមានមណ្ឌល ២ទៀត ហៅខ្លួនឯងថាជាអន្តេវាសិកដ្ឋានផង និងជាមណ្ឌលថែទាំកុមារផង និង មណ្ឌល ៤ ទៀតហៅខ្លួនឯងថាជាមណ្ឌលថែទាំកុមារ។

យោងតាមភស្តុតាង បង្ហាញថាមណ្ឌលថែទាំ និងអន្តេវាសិកដ្ឋានមានលក្ខណៈស្រដៀងគ្នានៅក្នុងការអនុវត្តជាក់ស្តែង។ មណ្ឌលទាំងអស់ដែលបានបញ្ចូលនៅក្នុងការសិក្សានេះត្រូវបានរកឃើញថា បានផ្តល់ការថែទាំដល់កុមារនៅក្នុងមណ្ឌលថែទាំរបស់ខ្លួន។ មណ្ឌលខ្លះផ្តល់ការអប់រំដល់កុមារនៅនឹងកន្លែង ( ដូចជាអន្តេវាសិកដ្ឋាន ) ប៉ុន្តែកុមារនៅមណ្ឌលផ្សេងទៀតទទួលបានការអប់រំនៅសាលារៀនខាងក្រៅមណ្ឌលដោយមណ្ឌលមួយចំនួនផ្តល់ទាំងការសិក្សាខាងក្នុងមណ្ឌលផង និងទាំងខាងក្រៅមណ្ឌលផល។ លទ្ធភាពទទួលបានការអប់រំកាន់តែប្រសើរ ត្រូវបានរកឃើញថាជាកត្តាដ៏សំខាន់មួយដែលអូសទាញកុមារឲ្យចូលទៅរស់នៅមណ្ឌលថែទាំ/សាលារៀនផ្តល់កន្លែងស្នាក់នៅ ក្នុងគ្រប់មណ្ឌលទាំង អស់។ យ៉ាងណាមិញ ទោះបីជាហេតុផលចម្បងនៃការទុកដាក់កុមារគឺដើម្បី "ទទួលបានការអប់រំ" ក៏ដោយ ប៉ុន្តែចំនុចនេះ ( ដូចគ្នាទៅនឹងបញ្ហា "ភាពក្រីក្រ" ដែរ ) គ្របដណ្តប់ លើមូល ហេតុជាច្រើនសម្រាប់ការទុកដាក់កុមារ។ ពិតប្រាកដណាស់ កិច្ចការពារកុមារដើរតួនាទីដ៏សំខាន់ នៅក្នុងការទុកដាក់ក្មេងស្រីនៅក្នុងអន្តេវាសិកដ្ឋាន។

បុគ្គលិកដែលបានសម្ភាសនៅឯអន្តេវាសិកដ្ឋាន បានសង្កត់ធ្ងន់អំពីមុខងារដ៏សំខាន់នៃការអប់រំនៅក្នុងកន្លែងរបស់ពួកគេ។

*កន្លែងនេះត្រូវបានគេយល់ឃើញថាជាអន្តេវាសិកដ្ឋាន។ មានកុមារដែលមានសេចក្តីត្រូវការពិតប្រាកដ និង កុមារដែលជាជនរងគ្រោះនៃអំពើរំលោភបំពាន ប៉ុន្តែ កន្លែងនេះមានដំណើរការដូចជាអន្តេវាសិកដ្ឋានសម្រាប់កុមារដែលមានសេចក្តីត្រូវការ ( ដូចជាកុមារដែលទទួលបានអាហារូបករណ៍ ) ជាជាងមណ្ឌលកុមារកំព្រា។[173]*

172 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា "ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល" ខែមីនា ឆ្នាំ ២០១៦។
173 សម្ភាសប្រធានមណ្ឌលថែទាំ ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

កន្លែងដទៃទៀត បានកត់សម្គាល់ថា ពួកគេត្រូវបាន មន្ទីរ ស.អ.យ ចាត់ចំណាត់ថ្នាក់ថាជាអន្តេវាសិកដ្ឋាន ទោះបីជាពួកគេចាត់ទុកការបំពេញមុខងារបឋមរបស់ពួកគេទាក់ ទៅនឹងការផ្តល់នូវផ្ទះសម្រាប់កុមារដែលត្រូវការការថែទាំក៏ដោយ៖

*ខ្ញុំគិតថា ខាងសុខុមាលភាពសង្គម មិនអាចធ្វើចំណាត់ប្រភេទនៃស្ថានភាពដ៏ពិសេសរបស់យើងបាននោះទេ។ ដូច្នេះហើយបានជាយើងហៅកន្លែងរបស់យើងថាជាផ្ទះ។ តែឥឡូវនេះគេហៅយើងថាជាអន្តេវាសិកដ្ឋាន។ ដូច្នេះខ្ញុំក៏និយាយថា យើងស្នាក់នៅទីនេះដូចជាគ្រួសារមួយ យើងធ្វើការជាមួយគ្នា យើងរស់នៅជាមួយគ្នា ហើយយើងបណ្តុះបណ្តាលពួកគេឲ្យចេះឈោងចាប់ និងចេះឈរដោយខ្លួនឯង។*[174]

អន្តេវាសិកដ្ឋាននេះ គឺជាករណីលើកលែងមួយបើប្រៀបធៀបជាមួយមណ្ឌលថែទាំ/សាលារៀនផ្តល់កន្លែងស្នាក់នៅដទៃទៀតដែលយើងបានឃើញ។ វាមានកុមារចម្រុះ។ សាលារៀនមានកូនសិស្សចំនួន ១២០០នាក់ ដែលរៀននៅថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទី ១២ ដោយមានក្មេងស្រីរស់នៅចំនួន ៦៩នាក់ (មានសាលារៀនមួយទៀតសម្រាប់ក្មេងប្រុសស្នាក់នៅ)។ ចំពោះអ្នកដែលមានលទ្ធភាព ត្រូវបានស្នើសុំឱ្យបង់វិភាគទាន ឬ បង់ថ្លៃទ្រទ្រង់សាលារៀន។ មកដល់ពេលនេះ គ្មានគ្រួសារណាមួយដែលមានកុមាររស់នៅ និងរៀនសូត្រនៅទីនេះ មានលទ្ធភាពបង់វិភាគទានបែបនេះឡើយ។

## ប្រវត្តិរបស់កុមារ

កុមាររស់នៅក្នុងមណ្ឌលថែទាំ ឬសាលារៀនផ្តល់កន្លែងស្នាក់នៅមានប្រវត្តិ និងសាវតាចម្រុះ។ ស្របគ្នាទៅនឹងការស្រាវជ្រាវមុនៗដែរ  កុមារភាគតិចរស់នៅក្នុងមណ្ឌលថែទាំត្រូវបានរាយការណ៍ថាជាកុមារ "កំព្រាទាំងឪពុកនិងម្តាយ (មិនមានឪពុក ឬម្តាយនៅរស់) (យោងតាមរបាយការណ៍ស្តីពីការកំណត់ទីតាំងមណ្ឌលរបស់ ក្រសួង ស.អ.យ បានឱ្យដឹងថាប្រហែលមានកុមារម្នាក់ក្នុងចំណោមកុមារ ៥នាក់ ដែលមានស្ថានភាពបែបនេះ)។ មូលហេតុចម្បងដែលកុមារចូលមកស្នាក់នៅមណ្ឌលថែទាំ ឬ អន្តេវាសិកដ្ឋានមានលក្ខណៈដូចគ្នាច្រើនទៅនឹងទម្រង់ផ្សេងទៀតនៃការថែទាំដែរ។

យោងតាមរបាយការណ៍ស្តីពីការកំណត់ទីតាំងមណ្ឌលរបស់ ក្រសួង ស.អ.យ បានឲ្យដឹងថាកុមារដែលចូលមកស្នាក់នៅមណ្ឌលមានអាយុចម្រុះ ដែលភាគច្រើនគឺចាប់ពីវ័យទារកមកម្ល៉េះ។ ប៉ុន្តែកុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលគឺជាក្មេងជំទង់៖ ៦៧% មានអាយុចាប់ពី ១១ឆ្នាំឡើងទៅ។[175] ទិន្នន័យអង្កេតរបស់ក្រសួង ស.អ.យ ក៏បានបង្ហាញក្នុងលក្ខណៈគួរឱ្យបារម្ភផងដែរថា មណ្ឌលផ្តល់ការថែទាំចំពោះកុមារដែលមានអាយុតិច ជាពិសេសទារក និងកុមារតូច អាយុចន្លោះ ០ឆ្នាំ ទៅ ៤ឆ្នាំ ច្រើនជាងទម្រង់នៃការថែទាំផ្សេងទៀត ដូចជាការថែទាំដោយឪពុកម្តាយធម៌ ដែលទារក ឬកុមារតូចទទួលបានការថែទាំជិតដល់ជាង។ បន្ថែមពីនេះទៀត យោងតាមការសិក្សានេះបង្ហាញឲ្យឃើញថា មណ្ឌលទាំងនោះផ្តល់ជម្រកដល់កុមារជាច្រើនដែលមានសេចក្តីត្រូវការចម្រុះដូចជា កុមារមានផ្ទុកមេរោគអេដស៍ ឬកុមារពិការ។ មានមណ្ឌលច្រើនជាងពាក់កណ្តាល (៦១,៥%) កំពុងផ្តល់កន្លែងស្នាក់នៅដល់កុមារដែលមានតម្រូវការបន្ថែម ហើយស្ទើរពាក់កណ្តាល (៤៧%) នៃមណ្ឌលទាំងនោះកំពុងជួយគាំទ្រដល់កុមារពិការ។ គំហើញទាំងនេះ បង្កប់នូវអត្ថន័យគោលនយោបាយដ៏សំខាន់ទាក់ទងនឹងការឃ្លាំមើល និងបទដ្ឋាននៃការថែទាំ។

174 សម្ភាសលក្ខណៈបុគ្គល នៅឯសាលារៀនដែលផ្តល់កន្លែងស្នាក់នៅរបស់គ្រីស្តសាសនា ខេត្តព្រះសីហនុ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។

175 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា "ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល" ខែមីនា ឆ្នាំ ២០១៦។

ស្របគ្នាទៅនឹងគំហើញពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារ របស់ ក្រសួង ស.អ.យ ដែលទើបធ្វើឡើងនាពេលថ្មីៗនេះដែរ បង្ហាញថាមានក្មេងស្រីតិចជាងក្មេងប្រុសបន្តិចបន្តួចប៉ុណ្ណោះដែលស្នាក់នៅក្នុងមណ្ឌល និងសាលារៀនផ្តល់កន្លែងស្នាក់នៅ ក្នុងសំណាករបស់យើង (ទោះដូច្នេះក្តី ភាពខុសគ្នានេះមិនគួរឱ្យកត់សម្គាល់នោះទេ)។ ចំនួនខ្ពស់បំផុតនៃកុមារនៅក្នុងមណ្ឌលដែលបានបញ្ចូលនៅក្នុងការសិក្សានេះមានចំនួន ១០០នាក់ និងទាបបំផុតមានចំនួន ៤៥នាក់។ មណ្ឌលខ្លះបានលើកឡើងថា ចំនួនកុមារនៅក្នុងការថែទាំរបស់ពួកគេបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល ១ឆ្នាំកន្លងមកនេះ ដោយសារតែមានកម្មវិធីធ្វើសមាហរណកម្មកុមារ៖ អ្នកពាក់ព័ន្ធម្នាក់បានរៀបរាប់អំពីអ្វីដែលបានកើតឡើងកាលពី៣ឆ្នាំមុន ថាពួកគេមានកុមារចំនួន ៤៥នាក់ នៅក្នុងមណ្ឌលរបស់ពួកគេ៖ *«នៅពេលគេចាប់ផ្តើមដកយកកុមារចេញពីមណ្ឌល យើងនៅសល់កុមារចំនួន ១៤នាក់ ដែលគ្រោងនឹងយកចេញនៅរដូវក្តៅនៃឆ្នាំ ២០១៧ ខាងមុខនេះ»*។[176] មានការយល់ដឹងខ្លះក្នុងចំណោមអ្នកពាក់ព័ន្ធថា ការដកហូតកុមារចេញពីគ្រួសាររបស់ពួកគេ ជាទូទៅ គឺមិនល្អ បើអាចចៀសវាងបាន ហើយពួកគេយល់ទៀតថាការធ្វើសមាហរណកម្មកុមារទៅសហគមន៍វិញ គួរតែជាអាទិភាពដ៏សំខាន់មួយ។

## ការកំណត់អត្តសញ្ញាណ និងការទុកដាក់កុមារ

ការបញ្ជូន និង ទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំ អាចធ្វើឡើងតាមរយៈច្រកផ្សេងៗជាច្រើន ដូចជាតាមរយៈអាជ្ញាធរមូលដ្ឋាន មន្ត្រីអនុវត្តច្បាប់ អង្គការ(អន្តរជាតិ) ទីភ្នាក់ងារសហប្រជាជាតិ (ឧ. អង្គការ IOM និងអង្គការសាសនានានា។ ដូចដែលគេអាចរំពឹងទុកថា ការទុកដាក់កុមារនៅក្នុងមណ្ឌលត្រូវបានសម្របសម្រួលតាមរយៈការរៀបចំដែលមានលក្ខណៈផ្លូវការជាង បើធៀបទៅនឹងប្រភេទផ្សេងទៀតនៃការថែទាំជំនួស។ អ្នកពាក់ព័ន្ធរាយការណ៍ថា ការទុកដាក់កុមារពិតជាមានការប៉ាន់ប្រមាណបឋម (វិធានបឋម) ទៅលើស្ថានភាពរបស់កុមារ ហើយសេចក្តីសម្រេចិត្ត «ជាផ្លូវការ» ក្នុងការទុកដាក់កុមារនៅក្នុងមណ្ឌលត្រូវបានឯកភាពពី «អាជ្ញាធរ» មួយដែលមានការទទួលស្គាល់ ៖ ក្នុងនោះអាចមាននគរបាល គកនក បុគ្គលិកសង្គមកិច្ចមកពីមន្ទីរ ស.អ.យ និង មេឃុំ។[177] លទ្ធផលដែលបានរកឃើញបង្ហាញថា នីតិវិធីប្រកបដោយបទដ្ឋានរួមទាំងលក្ខណៈវិនិច្ឆ័យ ដែលបាន ឯកភាព សម្រាប់ធ្វើការប៉ាន់ប្រមាណកុមារ និង ការសម្រេចទុកដាក់កុមារមិនត្រូវបានអនុវត្តតាម ឡើយ។ ជាក់ស្តែង ការសម្រេចចិត្តត្រូវបានធ្វើឡើងក្រោមមូលដ្ឋាន «ចំពោះកិច្ច» និងតាមករណីនីមួយៗ។

នីតិវិធីសម្រាប់អនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ចែងថាសេចក្តីសម្រេចទុកដាក់កុមារនៅក្នុងមណ្ឌល គប្បីធ្វើឡើងដោយ គកនក ការិយាល័យ ស.អ.យ និង មន្ទីរ ស.អ.យ រួមគ្នា។ លើសពីនេះ ប្រការ ៥ នៃប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំតាមមណ្ឌល (២០០៨) ចែងថា ត្រូវមានកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សរជាមួយអ្នកថែទាំកុមារពីមុន (និងកុមារ បើអាចធ្វើបាន) នៅពេលទទួលកុមារឱ្យចូលស្នាក់នៅ។ យោងតាមក្រមរដ្ឋប្បវេណី (២០០៧) (ជំពូក ៥) និងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ (១៩៨៩) (មាត្រា ១៩៩) ប្រសិនបើពុំមានផ្តល់ការយល់ព្រមពីឪពុកម្តាយ គេត្រូវមានដីកាពីតុលាការ។

176 សម្ភាសជាមួយអ្នកផ្តល់ចម្លើយសំខាន់ អង្គការ NGO ខេត្តសៀមរាប តាម skype ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។
177 មាត្រា ១១ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៥) ចែងអំពីលក្ខខណ្ឌនៃការទទួលយកកុមារមករស់នៅក្នុងមណ្ឌល។

អ្នកផ្តល់ចម្លើយខ្លះបានសង្កត់ធ្ងន់ថា គ្មានកុមារណាម្នាក់ត្រូវបានទុកដាក់នៅក្នុងមណ្ឌលដោយគ្មានការអនុញ្ញាតជាផ្លូវការពី ក្រសួង ស.អ.យ នោះទេ។ នៅក្នុងករណីផ្សេងទៀត សេចក្តីសម្រេចទទួលកុមារអាចចេញពីអង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា និង មេភូមិ។ យើងមិនបានជួបករណីដែលកុមារត្រូវបានទុកដាក់នៅក្នុងមណ្ឌលតាមដីការបស់តុលាការនោះទេ។

ជាក់ស្តែង ឪពុកម្តាយ និងអ្នកថែទាំដែលកំពុងជួបប្រទះការលំបាក ទំនងរមែងតែងសប្បាយចិត្ត និងមានឆន្ទៈទុកដាក់កូនរបស់ខ្លួននៅក្នុងមណ្ឌល ដោយជឿថា ធ្វើបែបនេះគឺដើម្បីឧត្តមប្រយោជន៍របស់កុមារនៅពេលដែលពួកគេកំពុងជួបប្រទះភាពក្រីក្រ ជម្ងឺ និងបញ្ហាប្រឈមដទៃទៀត៖ *«យើងទទួលកុមារម្នាក់អាយុ ៣ឆ្នាំ។ ជីដូនរបស់វាបានអង្វរខ្ញុំខ្លាំងណាស់។ គាត់និយាយថា «ខ្ញុំមិនអាចចិញ្ចឹមវាបានទេព្រោះខ្ញុំមានជម្ងឺ»។*[178]

នៅក្នុងការប្រាស្រ័យទាក់ទងបែបគុណភាព បុគ្គលិក និងអ្នកគ្រប់គ្រងនៅមណ្ឌលថែទាំបានបញ្ជាក់ថា លក្ខខណ្ឌនៃការទទួលកុមារចូលមកក្នុងមណ្ឌលរបស់ពួកគេមានកម្រិតខ្ពស់ តែពួកគេក៏និយាយផងដែរថាការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំគឺជាវិធានការចុងក្រោយ។ អ្នកពាក់ព័ន្ធនានាបានពន្យល់ថា៖

*[កុមារ] ត្រូវបានទទួលឲ្យចូលមករស់នៅក្នុងមណ្ឌល ប្រសិនបើពួកគេរងអំពើរំលោភបំពានពីឪពុកម្តាយ (កុមារដែលទទួលរងអំពើហិង្សាក្នុងគ្រួសារ) កុមារមកពីគ្រួសារក្រីក្រ និងកុមារត្រូវគេបោះបង់ចោល ប៉ុន្តែមុនធ្វើការទុកដាក់កុមារនៅក្នុងមណ្ឌលកុមារកំព្រា យើងត្រូវព្យាយាមបង្រួបបង្រួមកុមារជាមួយគ្រួសារជាមុនសិន។ មណ្ឌលគឺជាជម្រើសចុងក្រោយប៉ុណ្ណោះ។*[179]

*យើងមិនលោតភ្លាមទៅរកជម្រើសមណ្ឌលនោះទេ។ ជាដំបូងយើងស្វែងរកសមាជិកគ្រួសារសាខាញាតិ ដែលអាចយកកុមារទៅរស់នៅជាមួយ ហើយយើងធ្វើការប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំដើម្បីកំណត់រកការថែទាំដោយសាច់ញាតិ។*[180]

លទ្ធផលទាំងនេះ ឆ្លុះបញ្ចាំងពីបទដ្ឋានផ្លូវច្បាប់ដែលអនុញ្ញាតឲ្យកុមាររស់នៅក្នុងមណ្ឌលថែទាំ ដែលគួរតែជាជម្រើសចុងក្រោយបំផុត (និងបណ្តោះអាសន្ន) ហើយត្រូវប្រឹងប្រែងផ្តល់ការថែទាំដោយគ្រួសារដល់កុមារ។[181]

## ការត្រួតពិនិត្យតាមដាន

ចំពោះកង្វល់ទាក់ទងនឹងការរីកដុះដាលនៃមណ្ឌលថែទាំកុមារ និងកង្វះការឃ្លាំមើល និង ការត្រួតពិនិត្យក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានការដាក់ចេញនូវគោលនយោបាយ និងកម្មវិធីជាច្រើនក្នុងគោលបំណងបង្កើត និងពង្រឹងយន្តការនានាដើម្បីធ្វើនិយ័តកម្មមណ្ឌលថែទាំកុមារ សំដៅកែលំអបទដ្ឋាន និងធានានូវកិច្ចការពារកុមារ។ ទោះដូច្នេះក្តី នៅតែមានការព្រួយបារម្ភថាមានតែមណ្ឌលដែលបានចុះបញ្ជីជាផ្លូវការ ឬមានអនុស្សរណៈស្តីពីការយោគយល់ជាមួយ ក្រសួង ស.អ.យ ប៉ុណ្ណោះដែលត្រូវបានធ្វើអធិការកិច្ច។[182] របាយការណ៍ស្តីពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារ ដែលធ្វើឡើងដោយ ក្រសួង ស.អ.យ បានប៉ាន់ប្រមាណថាមានមណ្ឌលប្រមាណ ២១% នៃមណ្ឌលក្នុងប្រទេសកម្ពុជា ពុំមានអនុស្សរណៈស្តីពីការយោគយល់ ជាមួយរដ្ឋាភិបាល និង ១២% មិនបានចុះបញ្ជីជាមួយភ្នាក់ងាររដ្ឋាភិបាលណាឡើយ។

178 សម្ភាសជាមួយប្រធាន សាលារៀនផ្តល់កន្លែងស្នាក់នៅគ្រីស្តសាសនា ខេត្តព្រះសីហនុ ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៦។
179 ជនបង្គោល មន្ទីរសអយ រាជធានីភ្នំពេញ
180 កិច្ចសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ ជាមួយតំណាង គកនក ខេត្តសៀមរាប ថ្ងៃទី ១៤ ខែ១០ ឆ្នាំ ២០១៦។
181 អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ឆ្នាំ ២០១៥។
182 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា «ការកំណត់ទីតាំងមណ្ឌលថែទាំកុមារ៖ ការចងក្រងទិន្នន័យបឋម និងលទ្ធផល» ខែមីនា ឆ្នាំ ២០១៦។

មណ្ឌលតែមួយគត់នៅក្នុងការអង្កេតដែលបានកំណត់ខ្លួនឯងថាជា "សាលារៀនផ្តល់កន្លែងស្នាក់នៅ" តែម្យ៉ាង បានរាយការណ៍ថា មណ្ឌលនោះ "មិនដែល" មានភ្នាក់ងារខាងក្រៅចុះមកត្រួតពិនិត្យនោះទេ។ ទោះបីជាសាលារៀនផ្តល់កន្លែងស្នាក់នៅ ជាផ្លូវការស្ថិតនៅក្រៅការគ្របដណ្តប់របស់គោលនយោបាយស្តីពីការថែទាំជំនួសក៏ដោយ ប៉ុន្តែ វាមានសារៈសំខាន់ដើម្បីធ្វើការកត់សម្គាល់ថាមានកុមារងាយរងគ្រោះមួយចំនួនរស់នៅក្នុងសាលារៀននោះពេញមួយឆ្នាំ ដែលបង្កើតបានជាសំណួរថាតើសាលារៀនទាំងនោះគួរជាកម្មវត្ថុនៃការចុះត្រួតពិនិត្យ ដែរឬទេ។

## ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត

យោងតាមវិធានជាផ្លូវការ ការទុកដាក់កុមារនៅក្នុងមណ្ឌល គួរធ្វើឡើងជាបណ្តោះអាសន្ន[183] ប៉ុន្តែជាង ១ភាគ៣ នៃអ្នកផ្តល់ចម្លើយនៅក្នុងការសិក្សានេះអះអាងថា កុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលថែទាំរបស់ពួកគេបានស្នាក់នៅជា "អចិន្ត្រៃយ៍"។ ការប្រាស្រ័យទាក់ទងជាមួយគ្រួសារ សម្រាប់កុមាររស់នៅក្នុងមណ្ឌល និងសាលារៀនផ្តល់កន្លែងស្នាក់នៅ មានលក្ខណៈមិនដូចគ្នាទេ។ កុមារភាគច្រើនបានរាយការណ៍ឱ្យដឹងថា ពួកគេកម្រ ឬ មិនដែលបានជួបគ្រួសាររបស់ពួកគេៈ ដូចជាការទៅលេងផ្ទះរបស់ពួកគេ ឬ មានអ្នកមកលេងពួកគេ ១ដង ឬ ២ដង ក្នុង១ឆ្នាំ។ ការមិនសូវបានទាក់ទងទៅគ្រួសារ ត្រូវបានកុមារពន្យល់ថា មណ្ឌលនៅឆ្ងាយពីផ្ទះ ហើយសាច់ញាតិគ្មានប្រាក់សម្រាប់ធ្វើដំណើរ។

*ពីមុនគ្រួសាររបស់ខ្ញុំបានមកលេងខ្ញុំ ប៉ុន្តែឥឡូវពួកគេឈប់មកហើយ។ មណ្ឌលអនុញ្ញាតឲ្យខ្ញុំទៅលេងគ្រួសារ [ប៉ុន្តែ] ខេត្តខ្ញុំនៅឆ្ងាយណាស់ ហើយការធ្វើដំណើរមានតម្លៃថ្លៃ។ ដូច្នេះហើយបានជាពួកគាត់ឈប់មកលេងខ្ញុំ។*[184]

*ខ្ញុំមិនបានជួបម្តាយខ្ញុំ ហើយខ្ញុំក៏មិនបានជួបឪពុករបស់ខ្ញុំដែរ។ ម្តាយខ្ញុំរស់នៅប្រទេសថៃ ឪពុកខ្ញុំក៏ទៅប្រទេសថៃដើម្បីរកការងារធ្វើដែរ។ ពេលខ្លះយើងនិយាយគ្នាតាមទូរស័ព្ទ។*[185]

*ខ្ញុំមិនដឹងថាតើឪពុកម្តាយរបស់ខ្ញុំសុខទុក្ខយ៉ាងណានោះទេ - នៅទីនេះខ្ញុំមិនមានដំណឹងពីពួកគាត់ទេ។ ខ្ញុំមិនបានជួបពួកគាត់ញឹកញាប់នោះទេ ពីព្រោះ... ពួកគាត់បានផ្លាស់ប្តូរកន្លែងរស់នៅ។*[186]

នៅក្នុងករណីសាលារៀនផ្តល់កន្លែងស្នាក់នៅមួយ ការទាក់ទងជាមួយឪពុកម្តាយបង្កើត អាស្រ័យលើទីកន្លែងពួកគាត់រស់នៅ និង មូលហេតុនៃការស្នាក់នៅក្នុងសាលា។ ចំពោះអ្នកដែលមានគ្រួសាររស់នៅជិតការប្រាស្រ័យទាក់ទងធ្វើឡើងរៀងរាល់ខែ និងនៅពេលឈប់ សម្រាកវិស្សមកាល។ ចំពោះអ្នករស់នៅឆ្ងាយការប្រាស្រ័យទាក់ទងធ្វើឡើង ៣ដងក្នុង១ឆ្នាំ និងនៅពេល ឈប់សម្រាកវិស្សមកាល ដោយមានផ្តល់មធ្យោបាយធ្វើដំណើរដោយឥតគិតថ្លៃ ( ក្នុងករណីខ្លះ មានការគ្រប់គ្រងគ្រប់គ្រាន់ )។ មានតែក្មេងស្រីម្នាក់ប៉ុណ្ណោះដែលមិនបានទាក់ទងទៅគ្រួសារបង្កើតរបស់នាងទាល់តែសោះ ហើយមូលហេតុដែលនាងមិនអាច ទៅលេងគ្រួសាររបស់នាងបានគឺដោយសារតែការព្រួយបារម្ភគួរ ឱ្យកត់សម្គាល់ទាក់ទងនឹងកិច្ចការពារកុមារ។ មានហេតុផលតិចតួចថាហេតុអ្វីបានជាកុមារស្នាក់នៅសាលារៀនផ្តល់កន្លែងស្នាក់នៅនេះ មិនអាចរស់នៅជាមួយឪពុកម្តាយធម៌ដែលនៅជិតសាលា ដោយពួកគេអាចទៅរៀននៅសាលារាល់ថ្ងៃ តែពិតណាស់ ការទុកដាក់ជាមួយគ្រួសារធម៌

183 អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ( ថ្ងៃទី ៨ខែធ្នូ ឆ្នាំ ២០១៥ )។
184 សម្ភាសផ្ទាល់ជាមួយកុមារា ( ១៦ ) មណ្ឌលថែទាំ ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។
185 សាលារៀនផ្តល់កន្លែងស្នាក់នៅគ្រីស្តសាសនា ខេត្តព្រះសីហនុ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦។
186 ជួបជាមួយកុមារនៅសាលារៀនផ្តល់កន្លែងស្នាក់នៅ រាជធានីភ្នំពេញ ថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦។

បែបនេះ ត្រូវការនូវការផ្ដត់ផ្គង់ថវិកា។ បច្ចុប្បន្ន ដូនជីដែលមើលថែទាំ ឬបង្រៀនកុមារនៅក្នុងសាលាមិនទទួលបានប្រាក់កម្រៃឡើយ ដូច្នេះការចំណាយផ្ដោតលើតែម្ហូបអាហារ និងសម្លៀកបំពាក់ប៉ុណ្ណោះ។ យើងមិនច្បាស់ទេថាតើសាលារៀនមានមូលនិធិគ្រប់គ្រាន់ ដែរឬទេនាពេលបច្ចុប្បន្ននេះ ឬនឹងមានមូលនិធិប្រកបដោយនិរន្តរភាពនៅពេលអនាគត ដើម្បីចំណាយលើការ ថែទាំដោយឪពុកម្ដាយធម៌ចំពោះក្មេងស្រី ឬយ៉ាងណា។

## ការធ្វើសមាហរណកម្មកុមារ

ទោះបីជាកុមារនៅក្នុងមណ្ឌលមានទំនាក់ទំនងតិចតួចជាមួយឪពុកម្ដាយ និងគ្រួសារបង្កើតរបស់ពួកគេក៏ដោយ ក៏មណ្ឌលភាគច្រើនបានរាយការណ៍ឱ្យដឹងថាមានការវាយតម្លៃជាទៀងទាត់ ( យ៉ាងហោចណាស់រៀងរាល់ ៣-៦ខែម្ដង ) ទៅលើកុមារដែលស្ថិតក្រោមការថែទាំរបស់ពួកគេ ដោយស្ថាប័ន ខាងក្រៅដើម្បីពិចារណាអំពីលទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសាររបស់កុមារ។ មានហេតុផលគួរឲ្យសង្ស័យថាលទ្ធផលនេះអាចទទួលរងប៉ះពាល់ដោយការរាយកាណ៍លំអៀង ដោយហេតុថា វាមានភាពមិនស៊ីសង្វាក់គ្នាជាមួយលទ្ធផលដែលបានរកឃើញទាក់ទងនឹងភាពទៀងទាត់នៃការចុះត្រួតពិនិត្យ។[187] បើទោះជាដូច្នេះក្ដីលទ្ធផលទាំងនេះ អាចបង្ហាញឲ្យឃើញពីកង្វល់កាន់តែច្រើនឡើង ក្នុងចំណោម អ្នកគ្រប់គ្រងមណ្ឌលដែលពួកគេគួរតែកំណត់អាទិភាព និងជម្រុញការធ្វើសមាហរណកម្មកុមារចូលទៅក្នុងទម្រង់នៃការថែទាំតាមគ្រួសារ។ រួមជាមួយលទ្ធផលផ្សេងទៀត លទ្ធផលនេះបង្ហាញ ឲ្យឃើញពីការកើនឡើងនូវការផ្លាស់ប្ដូររបត់វប្បធម៌នៅក្នុងវិស័យថែទាំជំនួស ដែលងាកចេញពីការទុកដាក់ កុមារក្នុងមណ្ឌល។

ដូចបានកត់សម្គាល់ខាងដើម ទិន្នន័យបែបគុណភាពបង្ហាញថា មានការខិតខំធ្វើសមាហរណកម្មកុមារនៅតាមមណ្ឌលនានាគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១ឆ្នាំកន្លងមកនេះ ដោយមានរបាយការណ៍ អំពីការកាត់បន្ថយគួរឱ្យកត់សម្គាល់នូវចំនួនកុមារនៅក្នុងការថែទាំតាមមណ្ឌល និងការបិទមណ្ឌល។ អ្នកពាក់ព័ន្ធសំខាន់ម្នាក់បានរៀបរាប់អំពីដំណើរការធ្វើសមាហរណកម្មថា៖

*វាមិនមែនជាការងាយស្រួលនោះទេ។ តាមរយៈការប្រើប្រាស់កម្មវិធីផ្សារភ្ជាប់ទំនាក់ទំនងគ្រួសារឡើងវិញ មានន័យថាយើងកំពុងព្យាយាមពង្រឹងចំណងគ្រួសារ មុនពេលទុកដាក់កុមារ។ កុមារត្រូវបញ្ជូនទៅផ្ទះដើម្បីទៅលេងផ្ទះជាមុន ដើម្បីធ្វើការត្រួតពិនិត្យផ្ដល់ប្រឹក្សា ការចុះសួរសុខទុក្ខមិនឲ្យដឹងមុន និង ការត្រួតពិនិត្យ ក្នុងអំឡុងពេលទុកដាក់ដំបូងដើម្បីប៉ាន់ប្រមាណអំពីទំនាក់ទំនងនិងលក្ខខណ្ឌ។*

*<u>ចំពោះករណីនីមួយៗ នៅពេលដែលអ្នកសម្រេចធ្វើសមាហរណកម្មកុមារ តើមានការប៉ាន់ប្រមាណគ្រួសារមុនធ្វើសេចក្ដីសម្រេចចិត្ត ដែរឬទេ ?</u>*

*បាទ ! យើងបានជួបជាមួយគ្រួសារ។ ជាដំបូង យើងបានពន្យល់ដល់កុមារ និងបុគ្គលិកនៅក្នុងមណ្ឌល និង ជម្រាបគ្រួសារអំពីអ្វីដែលយើងគ្រោងធ្វើ រួមទាំងពេលវេលាកំណត់។*

*<u>តើពេលវេលាកំណត់របស់អ្នកសម្រាប់ការធ្វើសមាហរណកម្មកុមារ មានរយៈពេលប៉ុន្មាន ?</u>*

*យើងមានពេលវេលាកំណត់សម្រាប់ធ្វើការប៉ាន់ប្រមាណគ្រួសារ និង ការពិនិត្យតាមដានរយៈពេល ៣ឆ្នាំ។ នៅឆ្នាំដំបូង យើងចុះត្រួតពិនិត្យប្រចាំសប្ដាហ៍ ឬពីរសប្ដាហ៍ម្ដង។ នៅក្នុងឆ្នាំទី ២ យើងចុះពិនិត្យរៀងរាល់ខែ។ នៅក្នុងឆ្នាំទី ៣ ប្រចាំខែ ហើយឆ្នាំទី ៤ តាមដានបន្ត។*[188]

187 មណ្ឌលប្រហែលជារាប់បញ្ចូលការចុះពិនិត្យមើលក្នុងគោលបំណងផ្សេងដោយស្ថាប័នខាងក្រៅ ហេតុដូច្នេះហើយទើបចំនួនការចុះត្រួតពិនិត្យមានការកើនឡើង។
188 សម្ភាសអ្នកផ្ដល់ចម្លើយសំខាន់ ដែលផ្ដល់សេវាសមាហរណកម្ម ខេត្តសៀមរាប ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។

បើទោះបីជាការខិតខំប្រឹងប្រែងទាំងនេះ គួរតែទទួលបានលើកទឹកចិត្តយ៉ាងណាក៏ដោយ ប៉ុន្តែវាមានមូលហេតុដែលធ្វើឱ្យព្រួយបារម្ភថា នៅក្នុងករណីខ្លះ ការធ្វើសមាហរណកម្មត្រូវបានជម្រុញដោយបញ្ហាខ្វះថវិកា ជាជាងការគិតគូដល់ឧត្តមប្រយោជន៍កុមារដែលស្ថិតក្រោមការថែទាំ។ នៅពេលរៀបរាប់អំពីដំណើរការធ្វើសមាហរណកម្មអ្នកផ្តល់សេវា ដូចបានដកស្រង់ខាងលើ បានកត់ សម្គាល់ថា៖ *"យើងធ្វើសមាហរណកម្មកុមារពីព្រោះយើងអស់មូលនិធិនៅក្នុងកម្មវិធីរបស់យើង"។*[189] អ្នកផ្តល់សេវាម្នាក់ទៀតបានពន្យល់អំពីការលំបាកក្នុងការធ្វើសមាហរណកម្មកុមារនៅសល់ចំនួន ១៣នាក់ នៅក្នុងមណ្ឌលរបស់ពួកគេ បន្ទាប់ពីអស់មូលនិធិថា៖

*យើងនៅមានកុមារជាង ១៣នាក់ទៀត ក្នុងនោះមានក្មេងស្រីអាយុ ១៦ឆ្នាំម្នាក់ មិនអាចត្រឡប់ទៅវិញបានដោយសារតំបន់ដែលគ្រួសារនាងរស់នៅវាគួរឲ្យញញើត ព្រោះវាពោរពេញដោយគ្រឿងញៀន និង ពេស្យាចារ… ក្មេងស្រីម្នាក់ទៀត ម្តាយរបស់នាងរស់នៅក្បែរនេះ។ គាត់ជាគ្រូបង្រៀន តែគាត់បានរៀបការម្តងទៀត ហើយប្តីរបស់គាត់រំលោភបំពានផ្លូវភេទលើកុមារ។ យើងបានយកកុមារម្នាក់នោះមករស់នៅក្នុងមណ្ឌល ប៉ុន្តែឥឡូវនេះយើងមិនទាន់បានរកកន្លែងឲ្យនាងស្នាក់នៅបាននៅឡើយទេ។ ក្មេងស្រីនោះបដិសេធមិនព្រមត្រឡប់ទៅផ្ទះវិញ ប៉ុន្តែនាងបានយល់ព្រមឲ្យផ្ទេរនាងទៅអង្គការផ្សេង។*[190]

## ការបណ្តុះបណ្តាល

អ្នកដែលបានសម្ភាសទាំងអស់សម្រាប់ការសិក្សានេះ នៅក្នុងមណ្ឌលថែទាំកុមារ និងសាលារៀនផ្តល់កន្លែងស្នាក់នៅ បានបញ្ជាក់ថា ពួកគេបានទទួលការបណ្តុះបណ្តាល និង ការផ្តល់ប្រឹក្សាអំពីកិច្ចការពារកុមារ និង ភាគច្រើនពួកគេបានទទួលការបណ្តុះបណ្តាលពីអាជ្ញាធររដ្ឋាភិបាល ច្រើនជាងអ្នកថែទាំនៅក្នុងទម្រង់នៃការថែទាំដទៃទៀត ៖ ជិតពាក់កណ្តាល (៤៣%) នៃបុគ្គលិកមណ្ឌល និងសាលារៀនផ្តល់កន្លែង ស្នាក់នៅបាននិយាយថា ពួកគេបានទទួលការបណ្តុះបណ្តាលពី ក្រសួង ស.អ.យ។[191] បុគ្គលិកថែទាំនៅក្នុងមណ្ឌល និង សាលារៀនផ្តល់កន្លែងស្នាក់នៅដែលបានបញ្ចូលនៅក្នុងការសិក្សានេះ បានផ្តល់ពិន្ទុផ្នែក គុណភាពនៃការបណ្តុះបណ្តាលរបស់ពួកគេ ខ្ពស់ជាងជាងអ្នកថែទាំនៅក្នុងទម្រង់ផ្សេងទៀតនៃការថែទាំជំនួស៖ ៧៩% នៃបុគ្គលិកថែទាំរបស់មណ្ឌល/អន្តេវាសិកដ្ឋាន បានផ្តល់ពិន្ទុ "៥" លើ "៥" ដោយឡែក ជាទូទៅ អ្នកថែទាំផ្តល់ពិន្ទុត្រឹម ៣ ឬច្រើនជាងនេះ។ បើទោះជាដូច្នេះក្តី បុគ្គលិកខ្លះកត់សម្គាល់ថា បើទោះបីជាមានការបណ្តុះបណ្តាលពេញលេញអំពីទិដ្ឋភាពជាក់ស្តែងនៃការថែទាំកុមារ (ឧ. ការធ្វើអនាម័យ និង លាងសម្អាត) ក៏ដោយ ក៏ពួកគេនៅតែត្រូវការបណ្តុះបណ្តាលបន្ថែមទៀតអំពីជំនាញផ្តល់ប្រឹក្សា និងជំនាញទំនាក់ទំនងជាមួយកុមារ។ ចំណុចនេះមានសារៈសំខាន់ដោយហេតុថាកុមារជាច្រើននៅក្នុងមណ្ឌល និងសាលារៀនផ្តល់កន្លែងស្នាក់នៅមានសេចក្តីត្រូវការផ្នែកផ្លូវចិត្តស្មុគស្មាញ។

## ការចំណាយ និងការផ្តល់មូលនិធិ

មណ្ឌលថែទាំកុមារ និង សាលារៀនផ្តល់កន្លែងស្នាក់នៅ ពិតជាមានតម្រូវការធនធានច្រើនដោយសារការថែទាំប្រភេទនេះជាទូទៅត្រូវចំណាយច្រើន ហើយមិនសូវមាននិរន្តរភាពដូចការថែទាំជំនួសប្រភេទដទៃទៀតទេ។ អ្នកពាក់ព័ន្ធម្នាក់បាននិយាយថា មណ្ឌលរបស់គាត់ត្រូវចំណាយ ៤០.០០០ដុល្លា ក្នុង១ត្រីមាស

189 សម្ភាសអ្នកផ្តល់ចម្លើយសំខាន់ ដែលផ្តល់សេវាសមាហរណកម្ម ខេត្តសៀមរាប ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៦។
190 សម្ភាសអ្នកថែទាំ រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១៦
191 Chi square, $p<0.01$

ដែលភាគច្រើនត្រូវចំណាយលើប្រាក់ខែបុគ្គលិក និងចំណីអាហារសម្រាប់កុមារ។ គេបាននិយាយថា ចំពោះបុគ្គលិកសង្គមកិច្ចប្រកបដោយគុណវុឌ្ឍិការងារម្នាក់ ត្រូវផ្តល់បៀវត្សរ៍ជូនគាត់ចន្លោះពី ៣០០-៦០០ដុល្លារអាមេរិកក្នុងមួយខែ។

មណ្ឌលថែទាំកុមារស្ទើរទាំងអស់ ទទួលមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសាសនាបរទេស និង មិនមានអ្នកថែទាំនៅក្នុងមណ្ឌលណាម្នាក់ នៅក្នុងការសិក្សានេះរាយការណ៍ថាពួកគេបានទទួលមូលនិធិពីរដ្ឋាភិបាលនោះទេ។ អ្នកពាក់ព័ន្ធជាច្រើនបានកត់សម្គាល់ថា ការទទួលបានមូលនិធិកាន់តែមានការពិបាកខ្លាំងឡើងៗនៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ដោយសារម្ចាស់ជំនួយអន្តរជាតិកំពុងចាប់ផ្តើមដកជំនួយ។ នេះគឺជាការឆ្លុះបញ្ចាំងមួយផ្នែកទៅលើវិបត្តិជនភៀសខ្លួននៅស៊ីរី និងនៅប្រទេសជុំវិញ និងខ្លះទៀតដោយសារមានការកើនឡើងនូវការចង់បានគម្រូថែទាំតាមគ្រួសារ និងសហគមន៍។

## បទពិសោធន៍របស់កុមារ

ទិន្នន័យអំពីបទពិសោធន៍របស់កុមារនៅក្នុងមណ្ឌលមានលក្ខណៈចម្រុះ។ កុមារមួយចំនួនបាននិយាយថាពួកគេ «សប្បាយរីករាយ» និង «រស់នៅស្រួល» ហើយបានកត់សម្គាល់ថាជីវិត «កាន់តែមានផាសុកភាព» ឬ «មិនសូវតឹងតែង» ដូចនៅផ្ទះ។ កុមារបាននិយាយថាពួកគេសប្បាយចិត្តដោយមានឱកាសទទួលបានការអប់រំ និងនិយាយថាពួកគេសប្បាយដោយមានមិត្តភក្តិនៅជុំវិញ។ ពួកគេក៏បង្ហាញនូវការពេញចិត្តចំពោះរបស់សម្ភារៈផ្សេងទៀត ដែលពួកគេមាននៅក្នុងមណ្ឌលផងដែរ បើធៀបទៅនឹងជីវិតរបស់ពួកគេនៅឯផ្ទះ។

*នៅផ្ទះមិនមានរបស់របរប្រើប្រាស់ទំនើប ឬមានសួនដូចនៅទីនេះទេ។ នៅទីនេះយើងគឺជាកសិករ យើងមានវាលស្រែ និងរស់នៅជាគ្រួសារមួយ។*[192]

*ទីកន្លែងនេះផ្តល់ការអប់រំ កន្លែងស្នាក់នៅ ការស្វាគមន៍ និងចំណេះដឹង ដើម្បីកែលំអ និងផ្លាស់ប្តូរអាកប្បកិរិយារបស់យើង។ យើងមានអាហារ និង ការស្រឡាញ់។*[193]

វាបង្ហាញយ៉ាងច្បាស់តាមរយៈការចុះដល់មណ្ឌលថា កុមារនៅទីនោះរស់នៅក្នុងស្ថានភាពសម្ភារៈដ៏មានផាសុកភាពជាងកុមាររស់នៅក្នុងការថែទាំជំនួសប្រភេទដទៃទៀត។ នៅគ្រប់មណ្ឌលទាំងអស់ដែល យើងបានចុះទៅដល់ កុមារមានសម្ភារៈងូតទឹក មានបន្ទប់ទឹក មានបង្គន់ ដែលមានដំណើរការ មានកន្លែងគេង មានបន្ទប់លេង និង មានកន្លែងសម្រាប់ហាត់ប្រាណ។ កន្លែងថែទាំកុមារចំនួនពាក់កណ្តាល មានសម្ភារៈថែទាំសុខភាព និង សម្ភារៈវេជ្ជសាស្ត្របឋម។ តាមពិត លក្ខខណ្ឌវិនិច្ឆ័យដែលមាននៅក្នុងបញ្ជីផ្ទៀងផ្ទាត់មណ្ឌលថែទាំ និងសាលារៀនផ្តល់កន្លែងស្នាក់នៅ មានពិន្ទុខ្ពស់ជាងប្រភេទនៃការថែទាំផ្សេងទៀត នេះបើនិយាយអំពីគុណភាពនៃកន្លែងថែទាំ សុវត្ថិភាព និង អនាម័យ។

192 បានជួបជាមួយកុមារនៅឯសាលារៀនផ្តល់កន្លែងស្នាក់នៅ រាជធានីភ្នំពេញ ថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦។
193 ការពិភាក្សាជាក្រុមជាមួយកុមារនៅមណ្ឌល ខេត្តកណ្តាល ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦។

ទោះបីជាកន្លែងថែទាំមានផាសុខភាពល្អក៏ដោយ មិនមែនកុមារគ្រប់រូបសុទ្ធសឹងតែរាយការណ៍ថា ពួកគេសប្បាយចិត្តដោយបានស្នាក់នៅក្នុងមណ្ឌល និងអន្តេវាសិកដ្ឋាននោះទេ។ កុមារបាននិយាយអំពីការនឹកឪពុកម្ដាយរបស់ពួកគេ ហើយទោះបីជាពួកគេបានចំណាយពេលនៅជាមួយមិត្តភក្តិក៏ដោយ ក៏ពេលខ្លះពួកគេនិយាយថាមណ្ឌល និងសាលារៀនដែលពួកគេរស់នៅនោះមានមនុស្សច្រើនពេកដែល «ពិបាក» និង «គួរឲ្យធុញទ្រាន់»។ កុមារជាមធ្យមដែលគេងនៅក្នុងបន្ទប់តែមួយនៅក្នុងមណ្ឌល មានចំនួន ៩នាក់។ នៅក្នុងអន្តេវាសិកដ្ឋានមួយ ដែលយើងបានចុះទៅមើល មានក្មេងស្រីចំនួន២០នាក់ ស្នាក់នៅក្នុងសយនដ្ឋានមួយ។ ក្មេងស្រីម្នាក់រៀបរាប់អំពីស្ថានភាពរបស់នាងដល់អ្នកស្រាវជ្រាវយើងថា៖

*ខ្ញុំចង់ចាកចេញ។ ខ្ញុំធុញថប់។ ខ្ញុំបានចំណាយពេលជាច្រើនដើម្បីរៀនសូត្រ និងបោសសម្អាត។ ការអប់រំមានសារៈសំខាន់សម្រាប់ខ្ញុំ ហើយនេះគឺជាកន្លែងតែមួយគត់ដែលខ្ញុំអាចទទួលបានការអប់រំ។ វាជាការសប្បាយរីករាយក្នុងការចែករំលែកបន្ទប់ជាមួយគ្នា តែពេលខ្លះវារំខានដោយសារកន្លែងគេង និងកន្លែងសិក្សានៅក្នុងបន្ទប់តែមួយ។*[194]

ការរស់នៅឆ្ងាយពីផ្ទះ គឺជាមូលហេតុចម្បងដែលធ្វើឱ្យកុមាររាយការណ៍ថាពួកគេមិនសប្បាយចិត្តនៅក្នុងមណ្ឌល និង អន្តេវាសិកដ្ឋាន។ កុមារខ្លះកត់សម្គាល់ថា ទោះបីជាពួកគេទទួលបានប្រយោជន៍ ផ្នែកសម្ភារៈនៅក្នុងមណ្ឌលក៏ដោយ ប៉ុន្តែជីវិតរបស់ពួកគេនៅឯផ្ទះ «សប្បាយជាង» ដោយសារពួកគេអាចនៅជួបជុំគ្រួសារ៖ *«ខ្ញុំមានអារម្មណ៍ក្រៀមក្រំដោយមិនបានឃើញម្ដាយរបស់ខ្ញុំ» «ពេលខ្លះខ្ញុំនឹកគ្រួសាររបស់ខ្ញុំ។ ខ្ញុំចង់ជួយពួកគាត់ពីព្រោះពួកគាត់កាន់តែចាស់ណាស់ទៅហើយ»។*

194 បានជួបកុមារនៅឯសាលារៀនផ្ដល់កន្លែងស្នាក់នៅ រាជធានីភ្នំពេញ ថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០១៦។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៩

ក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលបានកំណត់នូវបញ្ហាប្រឈមមួយចំនួនដែលអាចប៉ះពាល់ការអនុវត្តឯកសារគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ( សូមអានទំព័រទី ២០ ខាងលើ )។ គោលនយោបាយនេះត្រូវបានផ្សព្វផ្សាយអស់រយៈពេល ១០ឆ្នាំមកហើយ ដោយក្នុងរយៈពេលនេះយើងឃើញមានវឌ្ឍនភាពដោយមានការកែសម្រួលច្បាប់ និង កម្មវិធីរួមទាំងការផ្លាស់ប្តូរនូវវប្បធម៌នៃការអនុវត្តមួយចំនួន។ បើទោះជាដូច្នេះក្តី ក៏នៅមានបញ្ហាប្រឈមជាច្រើន ដោយសារមានចំនួនកុមារច្រើនពេកស្ថិតនៅក្នុងប្រព័ន្ធថែទាំ និងមានកុមារជាច្រើនទៀតដែលបន្តស្នាក់នៅក្នុងមណ្ឌល។

លើសពីនេះ មានបញ្ហាប្រឈមមួយចំនួនបន្ថែមទៀតដែលប៉ះពាល់ដល់ការបំបែកកុមារពីគ្រួសារ ការផ្តល់ការថែទាំជំនួស និង ចំនួនកុមារចូលទៅក្នុងប្រព័ន្ធថែទាំ។ ការប្រឈមទី ១ គឺកង្វះ "សំណាញ់សុវត្ថិភាព" ផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល សម្រាប់ឪពុកម្តាយ ដែលមិនមានមធ្យោបាយគ្រប់គ្រាន់ក្នុងការឧបត្ថម្ភគាំទ្រកូន។ រដ្ឋមិនបានផ្តល់ប្រាក់ឧបត្ថម្ភ ឬ ប្រាក់ឧបត្ថម្ភដល់ឪពុកម្តាយ និង អ្នកថែទាំជាសាច់ញាតិឡើយ សូម្បីតែក្នុងករណីដែលគ្រួសារមានតែឪពុក ឬ មានតែម្តាយក៏ដោយ ដែលធ្វើឲ្យកុមារ ប្រឈមទៅនឹងការបំបែកពីគ្រួសារ ដោយសារតែភាពក្រីក្រ។ ទី ២ គឺកង្វះសេវាគាំទ្រគ្រួសារនៅក្នុងសហគមន៍ ដើម្បីបង្ការការបំបែកកុមារពីគ្រួសារ និង ទី ៣ ការចំណាយពាក់ព័ន្ធនឹងការអប់រំរបស់កុមារ។ ការប្រឈមបន្ថែមទៀតដែលបានលើកឡើងនៅក្នុងឯកសារគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ គឺការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិជាធរមាននៅមានកម្រិតទាប ក្នុងនោះរួមមាន "ប្រកាស" ដែលបានចូលជាធរមានចាប់តាំងពីឯកសារគោលនយោបាយនេះត្រូវបានផ្សព្វផ្សាយ ដែលប្រកាសនេះ ត្រូវបានរចនាឡើងដើម្បីធានាការអនុវត្តគោលនយោបាយ។ គួរកត់សម្គាល់ថា មានតែបុគ្គលម្នាក់ប៉ុណ្ណោះ ដែលយើងបានសម្ភាសសម្រាប់ការសិក្សានេះ បាននិយាយយោងដល់អំណាចរបស់តុលាការ ឬ សេចក្តីត្រូវការឱ្យប្រើប្រាស់បញ្ញត្តិច្បាប់ដើម្បីការពារកុមារ និងដើម្បីធានាឲ្យមានការបង្កើតផែនការទុកដាក់ កុមារជាអចិន្ត្រៃយ៍ដ៏សមស្រប។

មានបញ្ហាដទៃផ្សេងទៀត ដែលគួរតែរំលេចផងដែរ។ បើទោះបីជាបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ស្តីពីសុវត្ថិភាពកុមារ ផ្តល់នូវដំបូន្មាន និងព័ត៌មានអំពីបញ្ហាកុមារតាមទូរស័ព្ទ និងអាចផ្តល់សេវាឈោងដល់តាមមូលដ្ឋាន ក្នុងករណីមួយចំនួនក៏ដោយ ក៏បច្ចុប្បន្ននេះមិនទាន់មានយន្តការត្រួតពិនិត្យតាមដានសិទ្ធិរបស់កុមារជាផ្លូវការ ដែលអាចជួយដោះស្រាយ ឬ ធ្វើការស៊ើបអង្កេតពាក្យបណ្តឹង អំពីការថែទាំ ឬ កង្វះការថែទាំកុមារនៅឡើយ។[195] លើសពីនេះ ការយល់ដឹងរបស់សាធារណជននៅមាន កម្រិតទាប ចំពោះបញ្ហាការពារកុមារ ការមាក់ងាយកុមារដែលរងការរំលោភបំពាន ត្រូវគេបោះបង់ចោល ឬត្រូវបានយកចេញពីគ្រួសាររបស់ពួកគេ ដោយសារហេតុផលការពារកុមារ។ ជាលទ្ធផល ចំណុចនេះនាំ ឱ្យមានការពន្យល់ថា កុមារស្ថិតនៅក្នុងការថែទាំជំនួស ដោយសារតែគ្រួសាររបស់ពួកគេ "ក្រីក្រ" ហើយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល មាននិន្នាការមើលរំលងមូលហេតុពិតប្រាកដ ដែលបណ្តាលឱ្យកុមារចូលមកទទួលការថែទាំ និងការចាត់វិធានការសមស្របដើម្បីដោះស្រាយបញ្ហាទាំងនោះ។

195 ChildSafe គ្រប់គ្រងដោយដៃគូ 3PC។ នៅក្នុងឆ្នាំ ២០១៦ គេបានទទួលការហៅចូលចំនួន ២២៧១ដង។ នៅក្នុងត្រីមាសទី១ នៃឆ្នាំ ២០១៦ មានការហៅចូលសរុបចំនួន ៦៧៧ដង និង មានកុមារអាយុ ១២-១៨ឆ្នាំ ហៅចូលចំនួន ២៥១ដង។

បញ្ហាឫសគល់ទាំងនេះ ត្រូវតែធ្វើការដោះស្រាយជាបន្ទាន់ប្រសិនបើគេចង់កាត់បន្ថយចំនួនកុមារនៅក្នុងការថែទាំតាមមណ្ឌល និង ការថែទាំជំនួសតាមសហគមន៍ប្រកបដោយប្រសិទ្ធិភាព និង ប្រកបដោយអត្ថន័យ និង បង្កលក្ខណៈឱ្យកុមារអាចរស់នៅជាមួយគ្រួសាររបស់ពួកគេ ក្នុងករណីដែលទង្វើបែបនេះគឺជាឧត្តមប្រយោជន៍របស់កុមារ។

## អនុសាសន៍

ជាទូទៅ ក្រសួង ស.អ.យ និង ដៃគូរដ្ឋាភិបាលរបស់ខ្លួន ចាំបាច់ត្រូវពង្រឹងសមត្ថភាពគ្រប់គ្រងករណីរបស់ខ្លួន និង ការផ្តល់សេវានៅតាមស្រុក។ មានការផ្តល់អនុសាសន៍ថា បន្ថែមពីលើផែនការសកម្មភាពជាតិបច្ចុប្បន្នរបស់ក្រសួងសម្រាប់កែលម្អការថែទាំកុមារ ក្រសួង ស.អ.យ គួររៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ និងផ្តល់សេវាគ្រប់គ្រងករណីការពារកុមារនៅក្នុងស្រុក ក្នុងរយៈពេល ៥ឆ្នាំខាងមុខ។ យុទ្ធសាស្ត្រនេះគួរបញ្ចូលការរៀបចំច្បាប់ និងការណែនាំសម្រាប់គ្រប់គ្រង និង រៀបចំឱ្យមានលក្ខណៈផ្លូវការនូវទម្រង់ថែទាំជំនួសផ្សេងៗគ្នា រាប់បញ្ចូលការកំណត់តួនាទី និង ការទទួលខុសត្រូវ ព្រមទាំងបទដ្ឋាននៃការថែទាំ ការគ្រប់គ្រងការធានាគុណភាព និង ការត្រួតពិនិត្យគុណភាព សេវាថែទាំតាមសហគមន៍។ ការពិចារណា មិនគួរផ្តោតចំពោះតែការអភិវឌ្ឍន៍សេវារដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែ ក៏គួរផ្តោតលើតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការសហការផ្តល់សេវាទាំងនោះនៅក្នុងស្រុក និងឃុំផងដែរ។ ធាតុផ្សំដ៏សំខាន់មួយនៃយុទ្ធសាស្ត្រគឺត្រូវពិនិត្យកែសម្រួលឡើងវិញឲ្យបានល្អិតល្អន់ទៅលើជំពូកទី ៧ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួស ដើម្បីធានានូវការធ្វើផែនការទុកដាក់កុមារជាអចិន្ត្រៃយ៍ប្រកបដោយសុវត្ថិភាព និងមានយន្តការថ្មីៗសម្រាប់ផ្តល់សេវាថែទាំដោយឪពុកម្តាយធម៌ និងសេវាសុំកូនប្រកបដោយប្រសិទ្ធិភាពនៅក្នុងស្រុក។

វាមានភាពចាំបាច់ដ៏ពិតប្រាកដ និង បន្ទាន់ ដែលត្រូវមានភ្នាក់ងារសង្គមកិច្ចកាន់តែច្រើននៅថ្នាក់ស្រុក។ បច្ចុប្បន្ន ចំនួនភ្នាក់ងារសង្គមកិច្ចដែលផ្តល់សេវាការពារកុមារមានចំនួនតិចខ្លាំងណាស់។ បណ្តារដ្ឋដែលមានការអភិវឌ្ឍន៍នៅអឺរ៉ុប មានអត្រាភ្នាក់ងារសង្គមកិច្ចម្នាក់សម្រាប់ប្រជាជនចន្លោះពី ៣០០-១៥០០នាក់។ នៅក្នុងប្រទេសកម្ពុជា អត្រាផលធៀបនេះមានចំនួន ១ ទល់នឹង ២៧.០០០នាក់។[196] អត្រាផលធៀបនេះមានកម្រិតខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ ៖ ប្រទេសឥណ្ឌូនេស៊ី និង មីយ៉ាន់ម៉ា មានកម្រិតផលធៀបខ្ពស់ជាង។ ទោះដូច្នេះក្តី ប្រទេសមានប្រាក់ចំណូលមធ្យមចំនួន២ គឺប្រទេសអាហ្វ្រិកខាងត្បូង និង ប្រទេសយូហ្គាន់ដា មានអត្រាផលធៀបប្រហែល ១ លើ ៦០០០ ដែលនេះជាអត្រាមួយដែលរដ្ឋាភិបាលកម្ពុជាគួរប្រឹងប្រែងឈានឱ្យដល់កម្រិតនេះ។ ក្នុងរយៈពេលខ្លី និងមធ្យម ក្រសួង ស.អ.យ ត្រូវគិតគូរអំពីរបៀបបង្កើននិងកែលម្អសមត្ថភាពធនធានមនុស្ស និង ហិរញ្ញវត្ថុ។ ប្រាកដណាស់ គេនឹងត្រូវចំណាយពេលវេលាប៉ុន្មានឆ្នាំដើម្បីបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ចថ្មីៗ និង ដើម្បីឱ្យពួកគេអភិវឌ្ឍជំនាញ និង បទពិសោធន៍ចាំបាច់នានា។ បើទោះជាដូច្នេះក្តី គេមិនច្បាស់ថាប្រព័ន្ធនេះអាចរង់ចាំបាន ឬយ៉ាងណាឡើយ។

គេបានផ្តល់អនុសាសន៍ថាគប្បីពិចារណាជ្រើសរើស និងបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ចពាក់កណ្តាលវិជ្ជាជីវៈនៅក្នុងរយៈពេលខ្លី ដើម្បីជួយធ្វើការងារជាមួយបុគ្គលិកសង្គមកិច្ចរបស់មន្ទីរ ស.អ.យ និង គ.ក.ន.ក នៅថ្នាក់ស្រុក និង ដើម្បីប្រើប្រាស់ធនធានដ៏គួរឱ្យកត់សម្គាល់របស់អង្គការមិនមែនរដ្ឋាភិបាល សំដៅផ្តល់សេវាគាំទ្រគ្រួសារ និងសេវាថែទាំជំនួស។ គំរូនៃការគ្រប់គ្រងករណីរួមគ្នារវាងរដ្ឋាភិបាល/អង្គការមិនមែនរដ្ឋាភិបាល ដែលបានរៀបចំនៅក្នុងប្រទេសមីយ៉ាន់ម៉ាអាចប្រើប្រាស់ជាគំរូដ៏មាន សារៈប្រយោជន៍សម្រាប់រដ្ឋាភិបាលកម្ពុជា។

196 The State of the Social Service Workforce, Global Social Service Workforce Alliance, 2015 អាចរកបានតាមគេហទំព័រ៖ www.cpcnnetwork.org. នៅក្នុងប្រទេសស៊ុយអែដ ផលធៀបគឺបុគ្គលិកសង្គមកិច្ចម្នាក់សម្រាប់ប្រជាពលរដ្ឋ ៣០០នាក់។ នៅក្នុងចក្រភពអង់គ្លេសបុគ្គលិកសង្គមកិច្ចម្នាក់សម្រាប់ប្រជាពលរដ្ឋ ៦០០នាក់។ នៅក្នុងប្រទេសអ៊ីតាលី បុគ្គលិកសង្គមកិច្ចម្នាក់សម្រាប់ប្រជាពលរដ្ឋ ១៦០០នាក់។ នៅក្នុងប្រទេសយូហ្គាន់ដា បុគ្គលិកសង្គមកិច្ចម្នាក់សម្រាប់ប្រជាពលរដ្ឋ ៦៥០០នាក់ និងនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង បុគ្គលិកសង្គមកិច្ចម្នាក់សម្រាប់ប្រជាពលរដ្ឋ ៦០៩៦នាក់។

## ការថែទាំដោយសាច់ញាតិ

ការថែទាំដោយសច់ញាតិ គឺជាការអនុវត្តជាប្រពៃណី និងជាទូទៅនៅក្នុងប្រទេសកម្ពុជាសម្រាប់កុមារដែលត្រូវការការថែទាំជំនួសមូលហេតុជាច្រើនផ្សេងៗ។ ការថែទាំដោយសាច់ញាតិមានអត្ថប្រយោជន៍មួយចំនួន៖ កុមារនៅតែស្ថិតនៅក្នុងគ្រួសារដើមរបស់ពួកគេ ពួកគេនៅរក្សាទំនាក់ទំនង និងបណ្ដាញសាច់ញាតិ ហើយពួកគេត្រូវបានថែទាំ ដោយមនុស្សពេញវ័យ ដែលភាគច្រើនជាមនុស្សដែលពួកគេបានបង្កើតទំនាក់ទំនងជាមួយរួចហើយ។

ជាញឹកញាប់ ការថែទាំដោយសាច់ញាតិអាចធ្វើទៅបាន តែមិនត្រូវបានគេប្រើឲ្យអស់ លទ្ធភាពនៅឡើយ ដែលភាគច្រើនដោយសារសមាជិកគ្រួសារគ្មានសមត្ថភាពក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កុមារ។ នេះគឺជាបញ្ហាដែលភាគច្រើនកើតឡើងនៅពេលជីដូនជីតា និងជាពិសេសគឺជីដូនទោល ដែលជាញឹកញាប់ពុំមានប្រភពប្រាក់ចំណូលជាក់លាក់ និង ពឹងផ្អែកតែលើការជួយគាំទ្រពីកូនៗរបស់គាត់ប៉ុណ្ណោះ។ ក្នុងករណីទាំងនេះ ការថែទាំដោយសាច់ញាតិអាចជាជម្រើសដ៏ល្អ ប្រសិនបើមានការផ្ដល់ប្រាក់ឧបត្ថម្ភ និង មានការគ្របដណ្ដប់លើថ្លៃចំណាយអប់រំ។

ករណីសិក្សាអំពីការថែទាំដោយសាច់ញាតិជាច្រើន ដែលបានបញ្ចូលនៅក្នុងការ ស្រាវជ្រាវនេះ បង្ហាញថាការថែទាំដោយសាច់ញាតិពិតជាមានប្រសិទ្ធិភាព ដែលមានលទ្ធផលវិជ្ជមានសម្រាប់កុមារ។ បើទោះជាដូច្នេះក្ដី នៅក្នុងករណីសិក្សាដទៃទៀត ក៏មានការរាយការណ៍ថាកុមារបានរងការរំលោភបំពាន ការមិនអើពើ និង កេងប្រវ័ញ្ចផងដែរ។ ដូច្នេះ ការត្រួតពិនិត្យតាមដាន មានសារៈសំខាន់ខ្លាំងណាស់។

អ្នកទទួលខុសត្រូវចំពោះការទុកដាក់កុមារនៅក្នុងការថែទាំដោយសាច់ញាតិ ដែលយើងបានសម្ភាសសម្រាប់របាយការណ៍នេះ បានផ្ដោតជាចម្បងថាតើសមាជិកគ្រួសារមាន "ឆន្ទៈ" ក្នុងការយកកុមារ ទៅចិញ្ចឹមដែរឬទេ។ ប្រសិនបើមាននរណាម្នាក់នៅក្នុងគ្រួសារមានឆន្ទៈយកកុមារទៅចិញ្ចឹម ភាគច្រើននេះ ហាក់បីដូចជាកត្តាដែលធ្វើការសម្រេចចិត្តសម្រាប់ការទុកដាក់កុមារ ដោយមានការប៉ាន់ប្រមាណបន្ថែម ទៀតបន្តិចបន្តួចប៉ុណ្ណោះ។ នៅពេលដែលកុមារត្រូវបានគេទុកដាក់ជាមួយគ្រួសារសាច់ញាតិរួចហើយ អ្នកថែទាំជាសាច់ញាតិរមែងតែងជួបការលំបាកក្នុងការបំពេញការចំណាយ និងសេចក្ដីត្រូវការថែទាំរបស់កុមារ។

### អនុសាសន៍

- នៅពេលដែលកុមារត្រូវបានទុកដាក់ជាមួយសាច់ញាតិ ដោយមន្ទីរ ស.អ.យ គកនក ឬអង្គការមិនមែនរដ្ឋាភិបាល គេគួរធ្វើការប៉ាន់ប្រមាណទៅលើសាច់ញាតិជាអ្នកថែទាំនោះ ដើម្បីឲ្យដឹងថាតើពួកគេអាចបំពេញសេចក្ដីត្រូវការរបស់កុមារបាន ឬយ៉ាងណា។
- ការទុកដាក់កុមារនៅក្នុងការថែទាំដោយសាច់ញាតិ ដោយមន្ទីរ ស.អ.យ គកនក ឬ អង្គការមិនមែនរដ្ឋាភិបាល គួរត្រូវបានកត់ត្រាជាផ្លូវការដោយមន្ទីរ ស.អ.យ។
- ក្រសួង និង មន្ទីរ ស.អ.យ គួរធ្វើការពិនិត្យឡើងវិញទៅលើការផ្ដល់មូលនិធិដល់ការថែទាំដោយសាច់ញាតិ ដើម្បីកំណត់ថាតើការថែទាំបែបនេះ អាចទទួលបានការគាំទ្រដោយថវិកា ដោយរបៀបណា ក្នុងករណីចាំបាច់ និង យន្តការដែលអាចរៀបចំឱ្យមាន (ដោយក្រុមប្រឹក្សាឃុំ) ដើម្បីធានាថាកុមារដែលត្រូវបានទុកដាក់ឱ្យរស់នៅក្រោមការថែទាំដោយសាច់ញាតិ នឹងមិនត្រូវបានតម្រូវឲ្យបង់ប្រាក់ជូនគ្រូបង្រៀន នៅពេលដែលកុមារចូល រៀននៅសាលារដ្ឋ។
- មន្ទីរ ស.អ.យ គប្បីពិនិត្យឡើងវិញទៅលើកម្រិតនៃការត្រួតពិនិត្យតាមដាន និង ការជួយគាំទ្ររបស់ខ្លួននាពេលបច្ចុប្បន្ន សម្រាប់អ្នកថែទាំជាសាច់ញាតិ។

ពុំមានកម្មវិធីថែទាំដោយឱពុកម្ដាយធម៌ដែលគ្រប់គ្រងដោយរដ្ឋាភិបាលទ្បើយ ដោយបច្ចុប្បន្នអ្នកថែទាំជាឱពុកម្ដាយធម៌ ត្រូវបានជ្រើសរើស គាំទ្រ និងគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ វិធីសាស្ត្រខុសៗគ្នាដែលអង្គការមិនមែនរដ្ឋាភិបាលប្រើប្រាស់ដើម្បីធ្វើការជ្រើសរើស បណ្ដុះបណ្ដាលទទួលស្គាល់ និង ត្រួតពិនិត្យទៅលើអ្នកថែទាំដែលជាឱពុកម្ដាយធម៌ មានន័យថា បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា ពុំមានសេវាថែទាំដោយឱពុកម្ដាយធម៌ថ្នាក់ជាតិមួយដែលមានការឯកភាពគ្នានោះទេ។ លើសពីនេះរាល់ការចំណាយលើអ្នកថែទាំជាឱពុកម្ដាយធម៌បច្ចុប្បន្ន ត្រូវបានផ្ដល់ដោយអង្គការ មិនមែន រដ្ឋាភិបាល។ ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលផ្ដល់សេវាថែទាំមួយជួបវិបត្តិថវិកា ហើយអ្នកថែទាំ ជាឱពុកម្ដាយធម៌មិនទទួលបានបៀវត្សរ៍ នោះកុមារដែលពួកគេមើលថែទាំទាំងនោះ ទំនងមិនអាចមាន ផ្ទះស្នាក់នៅ។ ប្រព័ន្ធថែទាំដោយឱពុកម្ដាយធម៌ ដែលពឹងផ្អែកទាំងស្រុងឬជាសំខាន់លើការផ្ដល់ មូលនិធិរបស់អង្គការ មិនមាននិរន្តរភាពរយៈពេលវែងទ្បើយ ឬក្នុងរយៈពេលខ្លីក៏ថាបាន។ សេវាថែទាំដោយ ឱពុកម្ដាយធម៌មួយដែលមាននិរន្តរភាព តម្រូវឲ្យរដ្ឋាភិបាលជាអ្នកទទួលយក និងផ្ដល់ថវិកាគាំទ្រ។

លក្ខណៈ និង គុណភាពនៃសេវាថែទាំដោយឱពុកម្ដាយធម៌នៅក្នុងការសិក្សានេះ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ ដោយវាអាស្រ័យលើការប្ដេជ្ញាចិត្ត ធនធាន ជំនាញ និងបទពិសោធន៍ របស់អ្នកថែទាំជាឱពុកម្ដាយធម៌។

មានការកត់សម្គាល់ថា អ្នកថែទាំជាឱពុកម្ដាយធម៌ភាគច្រើនទទួលខុសត្រូវចំពោះកូនធម៌មួយចំនួនធំក្នុងពេលតែមួយ បន្ថែមពីលើការមើលថែទាំកូនបង្កើតរបស់ខ្លួន ដោយពេលខ្លះគ្រួសារធម៌មើល ថែទាំកូនធម៌ និងកូនបង្កើតរបស់ខ្លួនរហូតដល់ ៩នាក់ ក្នុងពេលតែមួយ។ ប្រការនេះពិតជា នាំឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការផ្ដល់ពេលវេលា និង ការយកចិត្តទុកដាក់គ្រប់គ្រាន់ដល់កូនធម៌ ហើយវាក៏អាចដាក់សម្ពាធយ៉ាងខ្លាំងទៅលើអ្នកថែទាំជាឱពុកម្ដាយធម៌មួយចំនួនផងដែរ។

បច្ចុប្បន្នពុំមានការបែងចែករវាងឱពុកម្ដាយធម៌ដែលផ្ដល់ការថែទាំរយៈពេលខ្លី និងរយៈពេលវែងនោះទេ ហើយអ្នកថែទាំជាឱពុកម្ដាយធម៌ មិនបានចូលរួមពេញលេញ នៅក្នុងការធ្វើ ផែនការទុកដាក់កុមារជាអចិន្ត្រៃយ៍ ឬធ្វើផែនការ សម្រាប់អ្វីដែលនឹងកើតទ្បើងនៅពេល កុមារឈាន ចូលអាយុ ១៨ឆ្នាំទ្បើយ។ កុមារខ្លះដែលស្ថិតក្រោមការថែទាំរបស់ ឱពុកម្ដាយធម៌ដែលបាន សម្ភាសនៅ ក្នុងការសិក្សានេះ ច្បាស់ជាត្រូវការឱពុកម្ដាយធម៌រយៈពេលវែង៖ ពួកគេនៅក្មេង ពួកគេបានមករស់នៅជាមួយឱពុកម្ដាយធម៌ជាច្រើនឆ្នាំ ហើយពួកគេទំនងមិនអាចវិលត្រឡប់ទៅរស់នៅជាមួយឱពុកម្ដាយបង្កើត ឬ គ្រួសាររបស់ពួកគេវិញបាន ដោយសារស្ថានភាពគ្រួសារ។ ការសិក្សានេះបានរកឃើញថា មានឱពុកម្ដាយធម៌ដែលចង់ចិញ្ចឹមកុមារតូចៗជាអចិន្ត្រៃយ៍ប្រសិនបើត្រូវការឱ្យមានការថែទាំបែបនេះ សម្រាប់កុមារ។ក្នុងករណីនេះ មន្ទីរ ស.អ.យ គួរពិចារណាថាតើការយកជាកូនចិញ្ចឹមក្នុងស្រុកគឺ ជាឧត្តម ប្រយោជន៍របស់កុមារដែរឬទេ។ ប្រសិនបើគ្មានការប៉ាន់ប្រមាណដោយប្រុងប្រយ័ត្នពីកុមារ និងអ្នកថែទាំជាឱពុកម្ដាយធម៌នោះទេកុមារអាចត្រូវបានគេប្ដូរពីការថែទាំដោយឱពុកម្ដាយធម៌មួយទៅឱពុកម្ដាយធម៌ មួយទៀត។ ក្មេងស្រីម្នាក់នៅក្នុងរបាយការណ៍នេះត្រូវបានគេធ្វើការផ្លាស់ប្ដូរចំនួន ៧ដងក្នុងរយៈពេល ៣ឆ្នាំដំបូង។

### អនុសាសន៍

- រដ្ឋាភិបាលគួរពិនិត្យឡើងវិញទៅលើប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ ទាក់ទងនឹងការធ្វើផែនការទុកដាក់កុមារជាអចិន្ត្រៃយ៍ ក្នុងគោលបំណងផ្តល់សេវាថែទាំដោយឪពុកម្តាយធម៌ និងសេវាសុំកូនក្នុងប្រទេសនៅថ្នាក់ស្រុក ក្នុងលក្ខណៈជាផ្នែកមួយនៃសេវាការពារកុមារ។ ក្រសួង ស.អ.យ អាចធ្វើការងារជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់សេវានៅថ្នាក់ស្រុក ប៉ុន្តែរដ្ឋគួរទទួលខុសត្រូវចំពោះការធានាឲ្យមានសេវាថែទាំដោយឪពុកម្តាយធម៌ និង សេវាសុំកូនក្នុងប្រទេសនៅតាមស្រុកនីមួយៗ និងមានការអនុវត្តស្របតាមបទដ្ឋានអប្បបរមា។
- មិនគួរទុកដាក់កូនធម៌លើស ៣នាក់ ទៅក្នុងគ្រួសារមួយឡើយ លើកលែងតែកុមារដែលត្រូវជាបងប្អូនបង្កើតនឹងគ្នា ដែលក្នុងករណីនេះ ឪពុកម្តាយធម៌គួរត្រូវបានអនុញ្ញាតឲ្យទទួលយកកុមារដែលជាបងប្អូនបង្កើតទាំងអស់។
- គួរពង្រឹងដំណើរការវាយតម្លៃ ជាពិសេស ទាក់ទងនឹងភាពសមស្របរបស់ឪពុកម្តាយធម៌។
- ត្រូវពង្រឹងការបន្តត្រួតពិនិត្យតាមដាន និងការគាំទ្រជាប្រចាំ (ការងារករណី)។

### ការថែទាំតាមវត្តអារាម

វត្តអារាម ផ្តល់ការថែទាំដល់ក្រុមកុមារខុសៗគ្នាដែលមានប្រវត្តិ និងសេចក្តីត្រូវការផ្សេងគ្នា។ បើទោះបីជាកុមារខ្លះចូលទៅស្នាក់នៅក្នុងវត្តដើម្បីតែរៀនព្រះធម៌ក៏ដោយ ប៉ុន្តែកុមារដទៃទៀតត្រូវការការថែទាំ និងកិច្ចការពារ។ បច្ចុប្បន្នការថែទាំតាមវត្តអារាមផ្តល់ដល់កុមារនូវសេចក្តីត្រូវការមូលដ្ឋាន ដូចជា អាហារ និងជម្រក និង ផ្តល់ការគាំទ្រកុមារក្នុងការអប់រំថែមទៀត។ បើទោះជាដូច្នេះក្តី គោលបំណងចម្បងនៃវត្តគឺជាទីកន្លែងសក្ការៈសម្រាប់សាសនា មិនមែនជាអ្នកផ្តល់ការថែទាំកុមារឡើយ។ ព្រះសង្ឃអង្គខ្លះបានទទួលការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ ប៉ុន្តែភារកិច្ចផ្នែកសាសនារបស់ព្រះអង្គមិនអនុញ្ញាតឲ្យព្រះអង្គក្លាយជាអ្នកថែទាំកុមារពេញម៉ោងឡើយ។

បច្ចុប្បន្ន លក្ខខណ្ឌនៅក្នុងវត្តមិនសូវល្អនោះទេ និង មិនស្របតាមប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ឡើយ។ លើសពីនេះ ការផ្តល់អាហារដល់កុមារពឹងផ្អែកយ៉ាងខ្លាំងលើការបរិច្ចាគពីសប្បុរសជន និង មិនមែនមានអាហារគ្រប់គ្រាន់សម្រាប់កុមារគ្រប់រូបឡើយ។

មានការខ្វះខាតក្នុងការឃ្លាំមើល និង ការធ្វើផែនការសម្រាប់កុមារ។ វត្តអារាមមិនបានតាមដានកុមារដែលបានចាកចេញពីវត្ត និង មិនច្បាស់អំពីអ្វីដែលកើតឡើងចំពោះកុមារឡើយបន្ទាប់ពីកុមារចាកចេញពីវត្ត។

### អនុសាសន៍

- ក្រសួងធម្មការ និង សាសនា គួររៀបចំគោលនយោបាយស្តីពីការទទួលកុមារឱ្យចូលស្នាក់នៅក្នុងវត្តអារាម។
- ក្រសួងធម្មការ និង សាសនា គួរធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីកំណត់អំពីកម្រិតវិសាលភាពដែលវត្តផ្តល់ការថែទាំកុមារបានអនុវត្តស្របតាមប្រកាសស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ និង គួររៀបចំផែនការសកម្មភាពដើម្បីឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់ដើម្បីបំពេញតាមបទដ្ឋានថែទាំកុមារឲ្យបានពេញលេញ ដោយបញ្ចូលបញ្ញត្តិស្តីពី "បរិយាកាសថែទាំដែលផ្តល់ការយកចិត្តទុកដាក់ និង គាំទ្រ"។

- វត្តអារាមគប្បីតម្រូវឱ្យជូនដំណឹងទៅមន្ទីរ ស.អ.យ អំពីការទទួលយកកុមារឱ្យចូលស្នាក់នៅក្នុងករណីដែលបញ្ហាកិច្ចការពារកុមារ គឺជាហេតុផលមួយផ្នែក ឬ ទាំងស្រុងនៃការទទួលកុមារឱ្យស្នាក់នៅ ក្នុងនោះរួមមានដូចជាការដែលឪពុក ឬ ម្តាយកុមារធ្វើចំណាកស្រុក ស្លាប់ រៀបការជាថ្មី និងបដិសេធមិនមើលថែទាំកុមារ ឬ ទម្រង់ណាមួយនៃការរំលោភបំពាន ការមិនអើពើអំពើហិង្សា ឬអំពើកេងប្រវ័ញ្ចលើកុមារ។
- ក្រសួងធម្មការ និងសាសនា រួមជាមួយ ក្រសួង ស.អ.យ គួរពិចារណាផ្តល់ជូន[197] អ្នកទទួលខុសត្រូវពេញម៉ោងម្នាក់សម្រាប់ធ្វើការត្រួតពិនិត្យលើការថែទាំកុមារ ក្នុងករណីដែលវត្តមួយមានកុមារច្រើនជាង១០នាក់រស់នៅ។
- ក្រសួងធម្មការ និងសាសនា គួររៀបចំឲ្យមានគោលនយោបាយការពារកុមារគំរូមួយសម្រាប់វត្តអារាម។
- ក្រសួងធម្មការ និងសាសនា គួររៀបចំប្រព័ន្ធប្រមូលទិន្នន័យមួយអំពីកុមារទាំងអស់ដែលរស់នៅក្នុងវត្តអារាម។
- ក្រសួងធម្មការ និងសាសនា និង ក្រសួង ស.អ.យ គួររៀបចំពិធីសារការងាររួមគ្នាមួយស្តីពីការទទួលខុសត្រូវចំពោះកុមារស្នាក់នៅក្នុងវត្តអារាម។

## ផ្ទះស្នាក់នៅជាក្រុម

ដូចទម្រង់ផ្សេងទៀតនៃការថែទាំជំនួសដែរ ផ្ទះស្នាក់នៅជាក្រុមមានទម្រង់ និងលក្ខណៈខុសៗគ្នា។ ផ្ទះស្នាក់នៅជាក្រុមខ្លះស្ថិតនៅក្នុងសហគមន៍ ហើយកុមារមានទំនាក់ទំនងសកម្មនៅក្នុងជីវិតរស់នៅជាលក្ខណៈសហគមន៍ ចំណែកផ្ទះស្នាក់នៅជាក្រុមខ្លះផ្សេងទៀតមានលក្ខណៈជាស្ថាប័នដែលបិទជិត។ ផ្ទះស្នាក់នៅជាក្រុមខ្លះស្រដៀងទៅនឹងមណ្ឌលខ្នាតតូច ហើយផ្ទះស្នាក់នៅជាក្រុមផ្សេងទៀតស្រដៀង ទៅនឹងផ្ទះចិញ្ចឹមកូនធម៌។

ភាគច្រើនផ្ទះស្នាក់នៅជាក្រុមដែលយើងបានចុះជួប មានបទដ្ឋានខ្ពស់ មានបុគ្គលិកគ្រប់គ្រាន់ និងមានដំណើរការល្អ។ ទន្ទឹមនោះ មានសំនួរចោទសួរដែលទាក់ទងនឹងបញ្ហានិរន្តរភាពរបស់វា អាស្រ័យដោយសារផ្ទះស្នាក់នៅទាំងនេះទទួលមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាល ដែលអាចនឹងជួបប្រទះវិបត្តិថវិកានៅពេលណាមួយ។ ផ្ទះស្នាក់នៅជាក្រុម ក៏ជាទម្រង់ថែទាំជំនួសដែលត្រូវចំណាយច្រើនផងដែរ បើប្រៀបធៀបទៅនឹងការថែទាំដោយឪពុកម្តាយធម៌ និងការថែទាំដោយសាច់ញាតិ និង មានគោលបំណងផ្តល់ "ការថែទាំបណ្តោះអាសន្ន" ប៉ុណ្ណោះ។

ជានិច្ចកាល គេរមែងតែងមានតម្រូវការនូវទម្រង់ផ្សេងៗនៃការថែទាំតាមមណ្ឌលសម្រាប់ កុមារដែលមានវ័យច្រើន ដែលមិនអាចចុះសម្រុងការរស់នៅក្នុងគ្រួសារធម៌បាន និង ដែលគ្មានសាច់ញាតិថែទាំ ប៉ុន្តែយ៉ាងណាក្តី បើនិយាយអំពីលំដាប់លំដោយ គេគួរជ្រើសរើសយកផ្ទះស្នាក់នៅជាក្រុមតូចៗ ប្រសើរជាងការ ជ្រើសរើសយកមណ្ឌលទ្រង់ទ្រាយធំ។ យ៉ាងណាមិញ វាមានគ្រោះថ្នាក់ត្រង់ថាផ្ទះស្នាក់ នៅជាក្រុមខ្លះនឹងបន្ត ប្រតិបត្តិដូចជាមណ្ឌលថែទាំកុមារ ដោយកុមាររស់នៅក្នុងនោះមានទំនាក់ទំនងបន្តិច បន្តួចប៉ុណ្ណោះជាមួយសហគមន៍។ បញ្ហានេះអាចដោះស្រាយបាន តាមរយៈការធានាថាកុមារ ត្រូវបានអនុញ្ញាតឱ្យចូលស្នាក់នៅ ក្នុងផ្ទះស្នាក់នៅជាក្រុម លុះត្រាតែបានឆ្លងកាត់ការវាយតម្លៃពេញលេញ និង ចំពោះតែក្នុងករណីដែលការទទួលកុមារឱ្យចូលស្នាក់នៅ មានភាពចាំបាច់ដើម្បីបំពេញសេចក្តីត្រូវការ របស់កុមារ និង ធានាថាកុមារមានផែនការថែទាំមួយនៅពេលដែលត្រូវបានទទួលឱ្យស្នាក់នៅ ដែលផែនការនោះដោះស្រាយបាននូវបញ្ហាការថែទាំរបស់ពួកគេនៅពេលអនាគត។

197 នេះអាចជាព្រះសង្ឃ។ ការងារមិនចាំបាច់ត្រូវមានន័យថាត្រូវផ្តល់បៀវត្សរ៍នោះទេ ប៉ុន្តែមានន័យថាបុគ្គលនោះមានតួនាទីធ្វើការថែទាំកុមារពេញម៉ោង។

## អនុសាសន៍

- ក្រសួង ស.អ.យ គួរធ្វើការពិនិត្យឡើងវិញលើការចំណាយនាពេលបច្ចុប្បន្ន ការផ្ដល់ហិរញ្ញប្បទាន និង ទម្រង់ដែលចំណាយតិចបំផុតសម្រាប់ផ្គត់ផ្គង់ដល់ផ្ទះស្នាក់នៅជាក្រុម។
- ក្រសួង ស.អ.យ គួរធានាថាស្រុកនីមួយៗមានផ្ទះស្នាក់នៅជាក្រុមក្នុងចំនួនគ្រប់គ្រាន់ ដើម្បីផ្ដល់ការថែទាំដល់កុមារដែលត្រូវការការថែទាំតាមផ្ទះបែបនេះ និង ដែលមិនអាចរស់នៅក្រោមការថែទាំដោយសាច់ញាតិ ឬឪពុកម្ដាយធម៌។
- គប្បីពិនិត្យ និង កែសម្រួលនិយមន័យនៃផ្ទះស្នាក់នៅជាក្រុម នៅក្នុងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ ដើម្បីឲ្យស្របទៅនឹងគោលការណ៍ណែនាំស្ដីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ។

## អន្តេវាសិកដ្ឋាន

យោងតាមផែនការសកម្មភាពជាតិដើម្បីកែលម្អការថែទាំកុមារ ក្នុងគោលដៅបញ្ជូនកុមារចំនួន ៣០% ដោយសុវត្ថិភាព ពីមណ្ឌលទៅគ្រួសាររបស់ពួកគេវិញ ត្រឹមឆ្នាំ ២០១៨[198] មណ្ឌលថែទាំកុមារកំពុងចាប់ផ្ដើមធ្វើសមាហរណកម្មកុមារទៅគ្រួសាររបស់ពួកគេវិញ។ បើទោះជាដូច្នេះក្ដី គេត្រូវអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារតាមសហគមន៍ ទាក់ទងនឹងការងារត្រួត ពិនិត្យឱ្យបានទាំងស្រុង ដើម្បីធានាថាពុំមានការទទួលយកកុមារបន្ថែមទៀតឱ្យចូលស្នាក់នៅក្នុងមណ្ឌលលើកលែងតែក្នុងករណីចាំបាច់បំផុត។

អន្តេវាសិកដ្ឋានមានតួនាទីមួយនៅក្នុងប្រព័ន្ធអប់រំ ក៏ប៉ុន្តែការសិក្សាបានបង្ហាញថា មូលហេតុ នៃការទុកដាក់កុមារខ្លះនៅក្នុងសាលារៀននេះ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងបញ្ហាការពារកុមារនៅក្នុងគ្រួសារ។ប្រសិនបើកុមារត្រូវបានទុកដាក់នៅក្នុងអន្តេវាសិកដ្ឋា និងលក្ខណៈជាទម្រង់នៃការថែទាំជំនួស ជាពិសេសសម្រាប់កុមារធំៗ ដូច្នេះ រាល់នីតិវិធីទាំងអស់ដែលមានចែងនៅក្នុងច្បាប់បច្ចុប្បន្នគប្បីយកមកអនុវត្ត។

## អនុសាសន៍

- គប្បីតម្រូវឲ្យអន្តេវាសិកដ្ឋានផ្ដល់ព័ត៌មានដល់មន្ទីរ ស.អ.យ អំពីចំនួនកុមារស្នាក់នៅទីនោះ។
- ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួង ស.អ.យ គួររៀបចំបទដ្ឋានអប្បបរមានៃការថែទាំសម្រាប់កុមារដែលស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន។
- ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំគោលនយោបាយការពារកុមារគំរូមួយ សម្រាប់អន្តេវាសិកដ្ឋានដោយសំដៅទាំងគោលនយោបាយពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងសាលារៀន និង ការបញ្ជូនករណីដែលមានការព្រួយបារម្ភទាក់ទងនឹងកិច្ចការពារកុមារពីគ្រួសារ។
- ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួង ស.អ.យ គួររៀបចំពិធីសារការងាររួមគ្នាមួយស្ដីពីការទទួលខុសត្រូវគាំទ្រដល់កុមារស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន។
- ក្រសួង ស.អ.យ គួរទទួលខុសត្រូវចំពោះការពិនិត្យតាមដាន និងការចុះធ្វើអធិការកិច្ចលើការថែទាំកុមារនៅក្នុងអន្តេវាសិកដ្ឋាន។

198 ខែកញ្ញា ឆ្នាំ ២០១៦។

# ឯកសារយោង

# ១០

## ច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ ២០០៦

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស ឆ្នាំ ២០០៨

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ ២០១១

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ឆ្នាំ ២០១៥

សេចក្តីសម្រេចលេខ ៦៤/១៤២ ២០១០ នៃមហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ

## ប្រភពឯកសារបន្ថែម


Brake-Smith, Julia, ‘Community-Based Alternative Care Options in Cambodia’, Child Protection Unit: Trauma Recovery Project, World Vision Cambodia, March 2014.

Brickell, K. (2012). ‘The ‘Stubborn Stain’ on Development: Gendered Meanings of Housework (Non)-Participation in Cambodia’. Journal of Development Studies, Taylor & Francis (Routledge), 2011, pp.1

Brickell, K., & Chant, S. (April 12, 2010). ‘The unbearable heaviness of being’: Reflections on female altruism in Cambodia, Philippines, The Gambia and Costa Rica. Progress in Development Studies, 10, 2, 145-159.

Friends International, ‘Knowledge, Attitudes and Practices (KAP) Survey on Foster Care,’ 2015.

Holt International, *‘Cambodia Orphanage Survey,’ United States Agency for International Development*, 2005

Jordanwood, M, ‘Protecting Cambodia’s Children?’, Phnom Penh: World Vision Cambodia, 2016.

Kent, A. (2003). Recovery of the collective spirit: The role of the revival of Buddhism in Cambodia. Working Paper.

Kent, A. (June 01, 2007). Purchasing Power and Pagodas: The Sīma Monastic Boundary and Consumer Politics in Cambodia. Journal of Southeast Asian Studies, 38, 2, 335-354.

Ledgerwood, J. L. (January 01, 1995). Khmer kinship: The matriliny/matriarchy myth. Journal of Anthropological Research, 247-261.

Ministry of Social Affairs, Veterans and Youth Rehabilitation, Alternative Care Database, 2010

Ministry of Social Affairs, Veterans and Youth Rehabilitation and UNICEF, 'A Study of Attitudes Towards Residential Care in Cambodia', 2011.

Ministry of Social Affairs, Veterans and Youth Rehabilitation, 'Final National Report: Mapping of Residential Care Institutions in 25 Provinces', Awaiting Publication, 2016.

Ministry of Social Affairs, Veterans and Youth Rehabilitation, 'Mapping of Residential Care Institutions: Preliminary data compilation and findings', March 2016.

Rany, S et al. (2012). Cambodia's Higher Education Development in Historical Perspectives (1863-2012). International Journal of Learning & Development. Vol. 2, No. 2.

Survey of the Level and Quality of Child Care in the Temples of Kandal Province Cambodia. ICC-HOSEA Project, 2004.

UNICEF Cambodia, 'Strengthening Child Protection Systems in Cambodia', UNICEF Cambodia Quarterly Progress Report to the United States Agency for International Development (USAID), January to March 2016.

Westering, J. (2010). Changing Social Norms on Alternative Care for Children in Cambodia. UNICEF Final Paper.

# ឧបសម្ព័ន្ធ ១ ៖ សំណាកសម្រាប់ការសិក្សា

## តារាងទី ១៖ ការថែទាំដោយសាច់ញាតិ

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | ការគាំទ្រក្រោយទុកដាក់កុមារ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| ថែទាំដោយសាច់ញាតិ ខេត្តកណ្តាល | ថែទាំដោយជីដូន ជីតា | ឪពុកម្តាយធ្វើចំណាកស្រុក | ក្រៅផ្លូវការត្រូវបានសម្រេចនៅក្នុងគ្រួសារ | មាន! ផ្ទះកសាងដោយអង្គការមិនមែនរដ្ឋាភិបាល និងមានការផ្តល់នូវថ្នាក់បំប៉ន កង់ | មិនធ្លាប់ |
| ថែទាំដោយញាតិ ខេត្តកណ្តាល | ឪពុកមាផ្តល់ការថែទាំដល់កុមារដែលបានធ្វើសមាហរណកម្ម | ម្តាយធ្វើចំណាកស្រុក ជីដូនស្លាប់ | ក្រៅផ្លូវការត្រូវបានសម្រេចនៅក្នុងគ្រួសារ | មានចំណីអាហារ | ធ្លាប់តែត្រូវបានធ្វើសមាហរណកម្មទៅរស់នៅជាមួយជីដូនមុនការទុកដាក់កុមារទៅរស់នៅជាមួយឪពុកម្តាយ |
| ថែទាំដោយញាតិ ខេត្តព្រះសីហនុ | ជីដូនជីតាផ្តល់ការថែទាំ | ម្តាយត្រូវខ្សែភ្លើងឆក់ ឪពុកញៀនគ្រឿងស្រវឹង និងថ្នាំញៀន ភាពក្រីក្រការមិនអើពើ | ក្រៅផ្លូវការត្រូវបានសម្រេចនៅក្នុងគ្រួសារ | មាន! មានរថយន្តដឹកទៅសាលារៀន មានផ្តល់អាហារ | ធ្លាប់! កុមារ ២នាក់រស់នៅក្នុងមណ្ឌលថែទាំតែត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារអ្នកដទៃមុនធ្វើការទុកដាក់ជាមួយជីដូនជីតា |
| ថែទាំដោយញាតិ ខេត្តសៀមរាប | មីង និងជីដូនផ្តល់ការថែទាំ | កុមារ ២នាក់ត្រូវបោះបង់ចោល និងរើសយកមកចិញ្ចឹមដោយអង្គការមិនមែនរដ្ឋាភិបាល។ កុមារម្នាក់ត្រូវបានវាយដំ និងមិនយកចិត្តទុកដាក់ដោយម្តាយចុងក្រោយពីឪពុករៀបការម្តងទៀត។ | កុមារ ២នាក់ត្រូវបានបញ្ជូនបន្តដោយអង្គការមិនមែនរដ្ឋាភិបាល។ ម្នាក់ត្រូវបានទុកដាក់ក្រៅផ្លូវការបន្ទាប់ពីមីងបានធ្វើអន្តរាគមន៍។ | មាន! អង្គការមិនមែនរដ្ឋាភិបាលផ្តល់អង្ករ ១៥ kg ក្នុង ១ខែតាមរយៈគកនក | ធ្លាប់! កុមារ ២នាក់ពីមុនរស់នៅមណ្ឌលថែទាំបន្ទាប់ពីម្តាយបានទុកពួកគេ នៅខាងមុខ អង្គការមិនមែនរដ្ឋាភិបាល ហើយគេចខ្លួនបាត់ទៅ។ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | ការគាំទ្រក្រោយទុកដាក់កុមារ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| ថែទាំដោយញាតិ ខេត្តសៀមរាប | មីង និងក្មេងស្រី អាយុ ២១ឆ្នាំ ផ្តល់ការថែទាំ | ឪពុកម្តាយស្លាប់ ដោយសារជម្ងឺអេដស៍ | ក្រៅផ្លូវការត្រូវបាន សម្រេចនៅក្នុង គ្រួសារ | មិនមាន! មានតែការ គាំទ្រអាហារបន្ទាន់ ពីអង្គការមិនមែន រដ្ឋាភិបាល ប្រសិន បើចាំបាច់ក្មេងស្រី អាយុ ២១ឆ្នាំគាំទ្រ ប្អូនៗទាំង៣របស់ នាង។ | មិនធ្លាប់ |
| ថែទាំដោយញាតិ ខេត្តបាត់ដំបង | មីង និងពូ ផ្តល់ការថែទាំ | ម្តាយស្លាប់ដោយ ជម្ងឺបេង ឪពុក រៀបការម្តងទៀត ម្តាយចុងវាយធ្វើ បាបកុមារ | ផ្លូវការ តែមិនមាន ការប៉ាន់ប្រមាណ ជាមុន | មាន! ប្រាក់ ២០ដុល្លាក្នុង១ខែ អង្ករ ៥០ kg រាល់ ២ខែ ផលិតផល អនាម័យ | ធ្លាប់! ក្មេងប្រុសរស់ នៅក្នុងមណ្ឌលថែទាំ រយៈពេល ៣ឆ្នាំមុនធ្វើ សមាហរណកម្ម |
| ថែទាំដោយញាតិ ខេត្តបាត់ដំបង | ឪពុកម្តាយផ្តល់ការ ថែទាំដល់ក្មេង ស្រីមានផ្ទុក មេរោគអេដស៍ | ម្តាយស្លាប់ដោយសារ មេរោគអេដស៍/ ជម្ងឺអេដស៍ ឪពុក រៀបការម្តងទៀត | ផ្លូវការ អង្គការ មិនមែនរដ្ឋាភិបាល ធ្វើការប៉ាន់ប្រមាណ មុនពេលទុកដាក់ កុមារចំនួន ២លើក រួមជាមួយ គកនក និងមន្ទីរសង្គមកិច្ច | មានការផ្តល់ប្រាក់ ៣៥ដុល្លាក្នុង១ខែ អង្ករ ៥០kg រាល់ ២ខែម្តង ផលិតផល អនាម័យ ការដឹក ជញ្ជូនទៅមន្ទីរពេទ្យ (ព្យាបាលមេរោគ អេដស៍ដោយ ឥតគិតថ្លៃ) | ក្មេងស្រីធ្លាប់រស់ នៅក្នុងមណ្ឌលថែទាំ រយៈពេល៤ឆ្នាំមុន ធ្វើសមាហរណកម្ម |
| ថែទាំដោយញាតិ រាជធានីភ្នំពេញ | ជីដូនជីតាផ្តល់ ការថែទាំ | ឪពុកម្តាយទុកកូន ចោលជាមួយជីដូន ជីតាហើយធ្វើចំណាក ស្រុកទៅរកការងារ ធ្វើ៖ វិលត្រឡប់មក វិញ តែរស់នៅតាមព្រំ ដែនថៃ មិនធ្វើទំនាក់ ទំនង/មកលេង/ផ្តល់ ការគាំទ្រដល់កុមារ (បោះបង់ចោល) | បុគ្គលិកមន្ទីរសង្គម កិច្ចចុះពិនិត្យមើល មុនការទុកដាក់ កុមារតែមិនបាន ធ្វើការប៉ាន់ប្រមាណ | មិនមាន | ក្មេងប្រុសធ្លាប់រស់នៅ ក្នុងមណ្ឌលតែ មណ្ឌលអស់លុយ ដូច្នេះកុមារក៏បាន ធ្វើសមាហរណកម្ម |

## តារាងទី ២៖ ការថែទាំដោយឪពុកម្តាយធម៌

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | ការគាំទ្រក្រោយការទុកដាក់កុមារ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តកណ្តាល | ការថែទាំផ្តល់ដោយឪពុកម្តាយធម៌ក្មេងប្រុសគឺជាកូនធម៌ទី ១៥។ | ត្រូវបានបោះបង់ចោល រស់នៅតាមចញ្ចើមថ្នល់ ជីដូនបដិសេធមិនមើលថែទាំ | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាលទុកដាក់កុមារទៅគ្រួសារធម៌ | មានការផ្តល់ប្រាក់ ២៥ដុល្លាក្នុង១ខែសម្រាប់កុមារម្នាក់ មានផ្តល់ថ្នាំដុសធ្មេញ ច្រាសដុះធ្មេញ សាប៊ូបោក ខោអាវ មុង ភួយ ខ្នើយ កន្ទេល ការចំណាយថែទាំសុខភាព | ធ្លាប់ទុកដាក់នៅក្នុងការថែទាំដោយគ្រួសារធម៌តែមណ្ឌលត្រូវបានបិទទ្វារដោយមន្ទីរសង្គមកិច្ច |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តកណ្តាល | ម្តាយធម៌ផ្តល់ការថែទាំដល់កូនធម៌ ៩នាក់ | កូនធម៌ ៤នាក់ត្រូវបានបោះបង់ចោលដោយម្តាយបង្កើត | ក្រៅផ្លូវការ ម្តាយធម៌រើសកុមារនៅតាមផ្លូវ ក្រោយមកបានទាក់ទងទៅមន្ទីរសង្គមកិច្ច | អង្គការមិនមែនរដ្ឋាភិបាលផ្តល់ ៧០០ដុល្លាដើម្បីសាងសង់បន្ទប់គេងមួយ | មិនមាន |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តព្រះសីហនុ | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់កុមារអាយុ៨ឆ្នាំម្នាក់ | កុមារត្រូវបានបោះបង់ដោយម្តាយ | ពាក់កណ្តាលផ្លូវការ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដើរតួនាទីជាម្តាយធម៌ គកនក ត្រូវបានជូនដំណឹង | បន្ទាប់ពីកុមារអាយុបាន ៦ឆ្នាំ មិនមានការគាំទ្របន្ថែមផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល | មិនមាន |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តព្រះសីហនុ | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់កុមារអាយុ ៥ឆ្នាំម្នាក់ | កុមារត្រូវបានបោះបង់ដោយម្តាយ | ក្រៅផ្លូវការម្តាយបង្កើតជាដំបូងសុំឲ្យម្តាយធម៌មើលការថែទាំកុមារជាបណ្តោះអាសន្ន | ៥០ដុល្លា ១ខែ អង្ករ២០ 20kg ត្រីខកំប៉ុង ២០-៣០ កំប៉ុង អង្គការមិនមែនរដ្ឋាភិបាលក៏ផ្តល់នូវការចំណាយថែទាំសុខភាព | មិនមាន |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តសៀមរាប | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់កូនធម៌ ៣នាក់ជាបងប្អូនបង្កើត | ម្តាយស្លាប់ដោយជម្ងឺអេដស៍ ឪពុកក៏មានផ្ទុកមេរោគអេដស៍ មិនអាចថែទាំកូន | ពាក់កណ្តាលផ្លូវការកូនស្រីបង្កើតរបស់គ្រួសារធម៌ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលហើយរៀបចំការទុកដាក់ | អង្ករ ៣០ kg ១ខែ ប្រាក់១១០ដុល្លា១ខែ សម្រាប់កុមារ ៣នាក់ (យោងតាមឪពុកការចំណាយជាក់ស្តែងគឺ ៣០០ដុល្លា១ខែ | មិនធ្លាប់។ កុមារបានមកលេងមណ្ឌលថែទាំដែលគ្រប់គ្រងដោយ អង្គការមិនមែនរដ្ឋាភិបាល |

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | ការគាំទ្រក្រោយការទុកដាក់កុមារ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តសៀមរាប | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់កុមារក្រិនអាយុ ៤ឆ្នាំម្នាក់ | ឪពុកម្តាយបង្កើតមិនអើពើជាមួយកុមារ ហើយញៀនគ្រឿងស្រវឹង | ផ្លូវការ ប្រធានភូមិបញ្ជូនករណីទៅអង្គការមិនមែនរដ្ឋាភិបាល ដែលបន្ទាប់មកទុកដាក់កុមារទៅគ្រួសារធម៌មួយចំនួន | គាំទ្រសម្ភារៈមានទឹកប្រាក់១៥០ដុល្លា ១ខែ (មានទឹកដោះគោ សាប៊ូខោ ទឹកនោម) | មិនធ្លាប់។ កូនធម៌ស្នាក់នៅខ្លីនៅក្នុងមន្ទីរពេទ្យមុនត្រូវបានទុកដាក់ជាមួយគ្រួសារធម៌ |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តបាត់ដំបង | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់ក្មេងស្រីអាយុ ៥ឆ្នាំម្នាក់ | កុមារត្រូវគេបោះបង់ចោលនៅក្បែរផ្ទះសម្រាមតាមផ្លូវ | ក្រៅផ្លូវការម្តាយធម៌រើសកុមារយកមកចិញ្ចឹម។ ក្រោយមកជូនដំណឹងទៅអាជ្ញាធរដើម្បីកុំឲ្យមានការចោទប្រកាន់ថា"លួចក្មេង"។ | ឈប់ទទួលការគាំទ្រហើយ។ ក្នុងរយៈពេល ២ឆ្នាំកន្លះអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់ប្រាក់ ៥០ដុល្លា១ខែ | ទេ |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តបាត់ដំបង | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់ក្មេងប្រុសអាយុ ១៤ឆ្នាំម្នាក់ | កុមារត្រូវបោះបង់ចោលនៅមុខមណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាលបានធ្វើការប៉ាន់ប្រមាណមុនទុកដាក់កុមារចំនួន ៥ដង ប្រធានឃុំបានចុះហត្ថលេខលើទម្រង់ធ្វើសមាហរណកម្ម | ទេ! អង្គការមិនមែនរដ្ឋាភិបាលគាំទ្រគ្រួសារបានកន្លះឆ្នាំបន្ទាប់ពីទុកដាក់ ដោយមានអង្ករ 50 kg រាល់ ២ខែ និងប្រាក់ ២០ដុល្លា ១ខែ | កុមារធ្លាប់រស់នៅក្នុងមណ្ឌលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលមុនទុកដាក់ |
| ការថែទាំដោយឪពុកម្តាយធម៌ ខេត្តបាត់ដំបង | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់ក្មេងប្រុសជាបងប្អូនបង្កើត ៣នាក់។ "ផ្ទះស្នាក់នៅជាក្រុម" មានអង្គការមិនមែនរដ្ឋាភិបាលចូលរួមនៅក្នុងការទុកដាក់ | កុមារត្រូវបានជួញដូរ (ដោយម្តាយបង្កើត) ទៅប្រទេសថៃធ្វើជាអ្នកសុំទាន។ កុមារត្រូវបានបញ្ជូនមកមណ្ឌលសំចតនៅព្រំដែនថៃ។ ឪពុកបង្កើតប្រើហិង្សា។ | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរសង្គមកិច្ចចុះត្រួតពិនិត្យមុនការទុកដាក់ | ម្តាយធម៌ទទួលបាន "ប្រាក់ខែ" ២៥ដុល្លា ១ខែពី អង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលឧបត្ថម្ភកុមារម្នាក់៤៥ដុល្លា ១ខែ និងផលិតផលអនាម័យនិងការថែទាំសុខភាព។ ម្តាយធម៌ជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិ | កុមារធ្លាប់រស់នៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលមុនការទុកដាក់ទៅគ្រួសារធម៌ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | ការគាំទ្រក្រោយការទុកដាក់កុមារ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| ការថែទាំដោយឪពុកម្តាយធម៌នៅរាជធានីភ្នំពេញ | ឪពុកម្តាយធម៌ផ្តល់ការថែទាំដល់កូនធម៌ចំនួន ៦នាក់ | កុមារម្នាក់មានម្តាយមានផ្ទុកមេរោគអេដស៍ និងឈឺជាទម្ងន់មិនអាចមើលថែទាំម្តាយ។បងប្អូន ២នាក់មានឪពុកម្តាយធ្វើចំណាកស្រុក ហើយម្តាយមិនអាចថែទាំពួកគេបាន។ កុមារ ២នាក់ត្រូវបានបដិសេធនៅពេលម្តាយរៀបការម្តងទៀត ម្នាក់ទៀតមិនច្បាស់ធ្លាប់ទទួលរងការបំពានផ្លូវភេទនៅក្នុងការទុកដាក់ដំបូង | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាលទុកដាក់កុមារនៅក្នុងគ្រួសារធម៌ | ឪពុកម្តាយធម៌បានទទួល «ប្រាក់ខែ» ៧៥ដុល្លា ១ខែសម្រាប់កុមារម្នាក់ | កុមាររស់នៅមណ្ឌលមុនការទុកដាក់ទៅក្នុងគ្រួសារធម៌ (ក្មេងប្រុសម្នាក់ទទួលរងការបំពានផ្លូវភេទនៅក្នុងមណ្ឌល) |

## តារាងទី ៣៖ ការថែទាំតាមវត្តអារាម

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងវត្ត | ដំណើរការទុកដាក់ | ការគាំទ្រ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| វត្តនៅខេត្តសៀមរាប | ក្មេងប្រុសអាយុ ១៤-២២ឆ្នាំរស់នៅក្នុងវត្ត។ ក្មេងប្រុស ១០នាក់មកដើម្បីរៀនភ្លេងបុរាណនៅពេលថ្ងៃ។ ព្រះសង្ឃមួយអង្គត្រូវបានចាត់តាំងជាអ្នកទទួលបន្ទុកលើការថែទាំកុមារ។ មិនមានក្មេងស្រី។ | នៅផ្ទះមិនអាចរៀនដល់ថ្នាក់មធ្យមសិក្សា។ ឪពុកម្តាយមិនអាចផ្គត់ផ្គង់បានគ្រប់គ្រាន់។ | ក្រៅផ្លូវការ ម្តាយឬជីដូនមកជួបចៅអធិការ (កុមារខ្លះមកម្នាក់ឯង)វត្តអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកុមារពីជនបទ និងការខិតខំសង្វាតរៀនសូត្រ | វត្តទទួលការបរិច្ចាគ។ កុមារទទួលបានកន្លែងស្នាក់នៅនិងអាហារឪពុកម្តាយខ្លះបានជួយកុមារចន្លោះពី៥-២៥ដុល្លាក្នុង១ខែ | មិនធ្លាប់ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុរស់នៅក្នុងវត្ត | ដំណើរការទុកដាក់ | ការគាំទ្រ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| វត្តនៅខេត្តបាត់ដំបង | ក្មេងប្រុស ៦នាក់ អាយុពី ៩-១៧ឆ្នាំ។ គ្មានក្មេងស្រី។ ព្រះសង្ឃ៧អង្គជាអ្នកថែទាំ | ទទួលបានការសិក្សារៀនសូត្រ (យកវត្តជាផ្ទះស្នាក់នៅ) ជីដូនមិនអាចផ្តល់ការថែទាំគ្រប់គ្រាន់។ កុមារកំព្រាឬកុមារត្រូវគេបោះបង់ | ក្រៅផ្លូវការ អ្នកជិតខាងឬសាច់ញាតិបញ្ជូនកុមារកំព្រា ឬកុមារដែលគេបោះបង់ចោល | វត្តទទួលបានការបរិច្ចាគ។ កុមារទទួលបានកន្លែងស្នាក់នៅ និងចំណីអាហារការចំណាយប៉ាន់ស្មាន ៥០ដុល្លាសម្រាប់កុមារម្នាក់ក្នុង១ខែ។ | មិនធ្លាប់ |
| វត្តនៅខេត្តបាត់ដំបង | សិស្ស ៣០នាក់ (៧នាក់ជាកុមារ)។ ចៅអធិការវត្តចាត់តាំងសិស្សធំ២នាក់ឲ្យមើលកុមារ។ | ឲ្យរស់នៅជិតសាលារៀន កាត់បន្ថយការចំណាយលើអាហាររបស់គ្រួសារទទួលបានកន្លែងស្នាក់នៅដោយឥតគិតថ្លៃកុមារខ្លះជាកុមារកំព្រា | ពាក់កណ្តាលផ្លូវការ ឪពុកម្តាយ ឬសាច់ញាតិមកជួបវត្តៗសាកសួរអ្នកអាណាព្យាបាលតម្រូវឲ្យមានការចុះហត្ថលេខាពីឃុំ ឬប្រធានភូមិ | សិស្សធំៗមើលកុមារមិនទទួលប្រាក់ខែ។ វត្តទទួលបានការបរិច្ចាគ។ កុមារទទួលបានកន្លែងស្នាក់នៅឥតគិតថ្លៃពីព្រះសង្ឃ។ ភាគច្រើនចម្អិនហូបខ្លួនឯង។ កុមារខ្លះទទួលប្រាក់ពី ឪពុកម្តាយ (ជាមធ្យមប្រហែល ៧ដុល្លាក្នុង១ខែ)។ | មិនធ្លាប់ |
| វត្តនៅខេត្តកណ្តាល | មានកុមារ ២០០នាក់រស់នៅក្នុងវត្តមានកុមារជាង៥៦នាក់នឹងបួសជាព្រះសង្ឃមានព្រះសង្ឃ១៧អង្គមើលខុសត្រូវ។ គ្មានក្មេងស្រី។ វត្តផ្តល់ការសិក្សានៅក្នុងបរិវេណវត្ត។ គ្រូមកពីក្រសួងអប់រំ។ កុមារ ៧០០នាក់ចូលរៀននៅក្នុងសាលា។ | ដើម្បីបានរៀនសូត្រ កុមារខ្លះជាកុមារកំព្រាឪពុក ឬកំព្រាម្តាយ ឬឪពុកម្តាយធ្វើចំណាកស្រុក | ក្រៅផ្លូវការជីដូន ឬសាច់ញាតិផ្សេងនាំកុមារមករស់នៅក្នុងវត្ត | វត្តទទួលការបរិច្ចាគ។ គ្រូបង្រៀនទទួលប្រាក់ខែពីក្រសួងកុមារទទួលការសិក្សា កន្លែងស្នាក់នៅ និងអាហារដោយឥតគិតថ្លៃការចំណាយលើអាហារចំនួន ៣០០០ដុល្លាក្នុង១ខែ | មិនធ្លាប់ |
| វត្តនៅខេត្តព្រះសីហនុ | មានព្រះសង្ឃ ១៧២អង្គ (៧០អង្គអាយុក្រោម ១៨ឆ្នាំ) មិនមានការរៀបចំថែទាំច្បាស់លាស់ | ទទួលបាននូវអាហារកន្លែងស្នាក់នៅឥតគិតថ្លៃកុមារមានបញ្ហាខាងអាកប្បកិរិយាកុមារកំព្រា បំពានដោយឪពុក ឬម្តាយ | ក្រៅផ្លូវការ ឪពុកម្តាយ ឬសាច់ញាតិជូនកុមារមកស្នាក់នៅក្នុងវត្ត | វត្តទទួលបានការបរិច្ចាគ។ កុមារទទួលបានកន្លែងស្នាក់នៅ និងអាហារ។ ព្រះសង្ឃ១អង្គ ត្រូវបិណ្ឌបាតឲ្យបាន ៧៧ដុល្លាក្នុង១ខែ | មិនធ្លាប់ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុ រស់នៅក្នុងវត្ត | ដំណើរការទុកដាក់ | ការគាំទ្រ | កុមារធ្លាប់រស់នៅក្នុងការថែទាំតាមមណ្ឌលពីមុន |
|---|---|---|---|---|---|
| វត្តនៅរាជធានីភ្នំពេញ | កុមារ ៤០នាក់រស់នៅក្នុងវត្ត អាយុ ១០-១៨ឆ្នាំ មានព្រះសង្ឃ ១៤១អង្គ រស់នៅក្នុង»បន្ទប់ខណ្ឌៗ» ចំនួន ១១ បន្ទប់ខណ្ឌមានក្មេងប្រុសរហូត៨នាក់ រស់នៅក្នុង ១បន្ទប់ខណ្ឌ គ្មានក្មេងស្រី។ | កុមារកំព្រាឪពុកម្តាយមិនអាចផ្តល់ការថែទាំ ទទួលបានអាហារកន្លែងស្នាក់នៅឥតគិតថ្លៃ ឪពុកម្តាយធ្វើចំណាកស្រុក | ក្រៅផ្លូវការ ឪពុកម្តាយ ឬសាច់ញាតិនាំកុមារមកស្នាក់នៅក្នុងវត្ត | កុមារទទួលបានអាហារសល់ពីព្រះសង្ឃឆាន់ និងកន្លែងស្នាក់នៅឥតគិតថ្លៃ មិនមានសាច់ញាតិគាំទ្រ ព្រះសង្ឃចំណាយលើ សម្លៀកបំពាក់ ស្បែកជើងសម្ភារៈរៀនសូត្រ | មិនធ្លាប់ |
| វត្តនៅរាជធានីភ្នំពេញ | កុមារ ៥០នាក់រស់នៅជាមួយជីដូន (ដូនជី) ១០នាក់រស់នៅជាមួយព្រះសង្ឃ | ឪពុកម្តាយមិនអាចផ្តល់ការគាំទ្រគ្រប់គ្រាន់ ទទួលបានការសិក្សា បួសធ្វើជាសង្ឃកុមារកំព្រាឪពុកម្តាយធ្វើចំណាកស្រុក | ពាក់កណ្តាលផ្លូវការ កុមារខ្លះត្រូវបានបញ្ជូនដោយ អង្គការមិនមែនរដ្ឋាភិបាល ខ្លះត្រូវបាននាំដោយសាច់ញាតិ | វត្តទទួលការបរិច្ចាគ កុមារទទួលបានអាហារ កន្លែងស្នាក់នៅឥតគិតថ្លៃពីដូនជី | មិនធ្លាប់ |

## តារាងទី ៤៖ ផ្ទះស្នាក់នៅជាក្រុម និងការរស់នៅដោយឯករាជ្យ

| ករណី | ការរៀបចំការថែទាំ | មូលហេតុនៃការរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | កន្លែងស្នាក់នៅ | កុមារធ្លាបរស់នៅមណ្ឌលថែទាំពីមុន |
|---|---|---|---|---|---|
| ផ្ទះស្នាក់នៅជាក្រុមនៅខេត្តសៀមរាប | ក្មេងស្រី ១២នាក់(និងក្មេងប្រុសម្នាក់) អាយុ៤-១៦ឆ្នាំ ទទួលការថែទាំពី ម៉ែដោះ ៣នាក់ (មាន ២នាក់ស្នាក់នៅទីនោះ) | ឪពុកម្តាយមិនអាចផ្តល់ការថែទាំពេញលេញដល់កូន ដោយសារគ្រឿងស្រវឹងគ្រឿងញៀន ល្បែងស៊ីសង។ មានខ្លះត្រូវបានកេងប្រវ័ញ្ចពលកម្ម | ពាក់កណ្តាលផ្លូវការ អ្នកគ្រប់គ្រងចុះទៅភូមិនៅជនបទដើម្បីកំណត់អត្តសញ្ញាណក្មេងស្រីងាយរងគ្រោះ គកនក និងមន្ទីរសង្គមកិច្ចចុះហត្ថលេខាលើ ការទុកដាក់ | អង្គការមិនមែនរដ្ឋាភិបាលជួលបុគ្គលិកមានប្រាក់ខែ | ជាទូទៅមិនធ្លាប់ ក្មេងស្រីម្នាក់រស់នៅមណ្ឌលបណ្តោះអាសន្ន ដោយសារមានការបំពាន និងជួញដូរ មុនការទុកដាក់ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុនៃការរស់នៅក្នុងការថែទាំជំនួស | ដំណើរការទុកដាក់កុមារ | កន្លែងស្នាក់នៅ | កុមារធ្លាប់រស់នៅមណ្ឌលថែទាំពីមុន |
|---|---|---|---|---|---|
| ផ្ទះស្នាក់នៅជាក្រុម/គ្រួសារធម៌បណ្ដោះអាសន្ននៅខេត្តបាត់ដំបង | ម៉ែដោះផ្ទះស្នាក់នៅជាក្រុមម្នាក់មើលថែទាំក្មេងប្រុស ៣នាក់ អាយុ ៨-១៤ឆ្នាំ។ | ក្មេងប្រុសត្រូវបានម្ដាយជួញដូរទៅប្រទេសថៃដើម្បីធ្វើជាអ្នកសុំទាន | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរសង្គមកិច្ចធ្វើការប៉ាន់ប្រមាណមុនទុកដាក់ | ផ្ទះឯកជន ម៉ែដោះទទួលបានប្រាក់ខែ | មានកុមារធ្លាប់ស្នាក់នៅក្នុងមណ្ឌលព្រោះជាជនរងគ្រោះពីការជួញដូរមុនមានការទុកដាក់ |
| ផ្ទះស្នាក់នៅជាក្រុមនៅក្នុងរាជធានីភ្នំពេញ | អ្នកថែទាំម្នាក់មើលថែទាំកុមារ ៧នាក់ (អាយុ ៦-២២ឆ្នាំ) | ម្ដាយរៀបការម្ដងទៀត ហើយក្មេងស្រីត្រូវបំពានដោយឪពុកចុង ម្ដាយមានផ្ទុកមេរោគអេដស៍ មិនអាចថែទាំកូនម្ដាយសេពគ្រឿងស្រវឹង និងហិង្សា | ការទុកដាក់ធ្វើជាផ្លូវការ គកនកចុះហត្ថលេខាលើការទុកដាក់ ការកំណត់អត្តសញ្ញាណក្មេងជូនធ្វើ ជូនមិនធ្វើ | ជួលផ្ទះបុគ្គលិកទទួលប្រាក់ខែ | ម្ដងកុមាររស់នៅក្នុងមណ្ឌលតែត្រូវបានបណ្ដេញចេញដោយសង្ស័យថាបានសម្លាប់មនុស្ស |
| ការរស់នៅដោយឯករាជ្យនៅក្នុងខេត្តព្រះសីហនុ | ក្មេងប្រុស ២នាក់ (អាយុ ១៥ និង១៧ឆ្នាំ) រស់នៅដោយឯករាជ្យ បុគ្គលិកសង្គមកិច្ច ២នាក់ចុះត្រួតពិនិត្យក្រោយបញ្ចប់ការងារ | ត្រូវបានកេងប្រវ័ញ្ចពលកម្មនៅក្នុងប្រទេសថៃ ឪពុកប្រើហិង្សាមិនអាចរៀនសូត្រ | ពាក់កណ្ដាលផ្លូវការ អង្គការមិនមែនរដ្ឋាភិបាលចូលរួមនៅក្នុងការទុកដាក់ | អង្គការមិនមែនរដ្ឋាភិបាលបង់ថ្លៃបន្ទប់ជួលក្មេងប្រុសទទួលប្រាក់ ៥-១៥ដុល្លាក្នុង១សប្ដាហ៍ | ក្មេងប្រុសធ្លាប់រស់នៅក្នុងមណ្ឌលមុនការទុកដាក់នៅក្នុងកន្លែងរស់នៅដោយឯករាជ្យ |

## តារាងទី ៥៖ មណ្ឌលថែទាំ និងសាលារៀនផ្ដល់កន្លែងស្នាក់នៅ

| ករណី | ការរៀបចំការថែទាំ | មូលហេតុនៃការរស់នៅក្នុងវត្តអារ៉ាម | ដំណើរការទុកដាក់កុមារ | ការគាំទ្រ |
|---|---|---|---|---|
| មណ្ឌលថែទាំ (អង្គការគ្រីស្ដសាសនា) ខេត្តកណ្ដាល | មានកុមារចំនួន១០០នាក់ អាយុ ៦-១៦ឆ្នាំ (៥០% ជាក្មេងស្រី)កុមារ១៥នាក់នៅក្នុងបន្ទប់នីមួយៗ មានបុគ្គលិក ១៨នាក់ | ឪពុក ឬម្ដាយឬជីដូនជីតាមិនអាចមើលថែទាំពេញលេញឪពុកម្ដាយជាប់ពន្ធនាគារឪពុកម្ដាយមានផ្ទុកមេរោគអេដស៍ | ផ្លូវការប្រធានភូមិនគរបាលអាចារ្យបញ្ជូនករណី មាន MoU ជាមួយ ក្រសួង ស.អ.យ | អាហារ កន្លែងស្នាក់នៅ រៀនបន្ថែម មណ្ឌលទទួលបាន ៤០.០០០ដុល្លាពីម្ចាស់ជំនួយបរទេសដែលត្រូវចំណាយលើប្រាក់ខែបុគ្គលិក និងអាហារ |

| ករណី | ការរៀបចំការថែទាំ | មូលហេតុនៃការរស់នៅក្នុងវត្តអារ៉ាម | ដំណើរការទុកដាក់កុមារ | ការគាំទ្រ |
|---|---|---|---|---|
| សាលាផ្តល់កន្លែងស្នាក់នៅខេត្តព្រះសីហនុ | មានកុមារ ៣៨នាក់រស់នៅក្នុងសាលាក្នុងបន្ទប់ចំនួន ២ (បែងចែកតាមភេទ) ២០នាក់មករៀននៅពេលរសៀល អាយុ៥-១៨ឆ្នាំមានបុគ្គលិក ៥នាក់ | ឪពុកម្តាយធ្វើចំណាកស្រុកទៅប្រទេសថៃ ជីដូនមិនអាចមើលថែទាំ គ្រួសារប្រើហិង្សាទទួលបានការសិក្សារៀនសូត្រ | ក្រៅផ្លូវការ ឪពុកម្តាយ និងសាច់ញាតិ បញ្ជូនកុមារ។ សាលាអនុវត្តតាមលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលកុមារ។ ក្រសួង ស.អ.យ ធ្វើអធិការកិច្ច | បុគ្គលិកមិនទទួលប្រាក់ខែ មានតែអ្នកស្ម័គ្រចិត្ត ៦៥ដុល្លាសម្រាប់កុមារម្នាក់ក្នុង១ខែ (កន្លែងស្នាក់នៅអាហាររៀនសូត្រ)។ មូលនិធិពីអង្គការគ្រីស្តសាសនានៅសហរដ្ឋអាមេរិក និងហ្វីលីពីន |
| មណ្ឌលថែទាំ/មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប | កុមារ ៤៦នាក់រស់នៅក្នុងមណ្ឌល អាយុ ៣-១៨ឆ្នាំ (៥០%ជាក្មេងស្រី) មានម៉ែដោះ ៩នាក់ បុគ្គលិកសង្គមកិច្ច ២នាក់ធ្វើការនៅទីនោះ | កុមារកំព្រា កុមារត្រូវគេបោះបង់ និងកុមាររងគ្រោះពីការជួញដូរ | ផ្លូវការ ការបញ្ជូនភាគច្រើនមកពីមន្ទីរសង្គមកិច្ច គកនកប្រធានភូមិ | ទទួលមូលនិធិពីម្ចាស់ជំនួយអូស្ត្រាលីបុគ្គលិកទទួលបាន១២៥ដុល្លា ១ខែ ផ្តល់កន្លែងស្នាក់នៅអាហារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់កុមារ ថ្នាក់រៀនបន្ថែមប្រាក់ហោប៉ៅ ៤ដុល្លា ក្នុង១ខែ |
| មណ្ឌលថែទាំខេត្តសៀមរាប | ក្មេងស្រី ១៤នាក់ ៨នាក់ក្នុងផ្ទះមួយ មានម៉ែដោះ ៧នាក់ បុគ្គលិកសង្គមកិច្ច ២នាក់ អ្នកផ្តល់ប្រឹក្សា ២នាក់ | រងគ្រោះពីការបំពានផ្លូវភេទជួញដូរ កេងប្រវ័ញ្ចពលកម្ម | ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរសង្គមកិច្ច បញ្ជូនករណីទៅមណ្ឌល | អាហារ កន្លែងស្នាក់នៅការពិនិត្យសុខភាព ចាក់ថ្នាំបង្កា ផ្តល់ប្រឹក្សា ការបណ្តុះបណ្តាលជំនាញ គាំទ្រផ្លូវច្បាប់ទទួលប្រាក់ទៅរៀនៅសាលាឯកជន |
| មណ្ឌលថែទាំខេត្តបាត់ដំបង | កុមារ ៣៤នាក់រស់នៅក្នុងមណ្ឌល (២០នាក់ជាក្មេងស្រី) បុគ្គលិក៧នាក់ បុគ្គលិកសង្គមកិច្ច២នាក់ | កុមារបោះបង់ចោល កុមារជួញដូរ | ផ្លូវការ នគរបាល បញ្ជូនកុមារ | ផ្តល់មូលនិធិដោយអង្គការយូនីសេហ្វ និងម្ចាស់ជំនួយ អន្តរជាតិ ផ្តល់កន្លែងស្នាក់នៅអាហារប្រឹក្សាយោបល់ថវិកា ប្រតិបត្តិ១ឆ្នាំ ២៨០០០ដុល្លា (រួមបញ្ចូលទាំងការធ្វើសមាហរណកម្ម |

| ករណី | ការរៀបចំការថែទាំ | មូលហេតុនៃការរស់នៅក្នុងវត្តអារ៉ាម | ដំណើរការទុកដាក់កុមារ | ការគាំទ្រ |
|---|---|---|---|---|
| មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តបាត់ដំបង | កុមារ ៣៨នាក់ (៣០%ជាក្មេងស្រី) អាយុ ១៥-១៩ឆ្នាំ ស្នាក់នៅក្នុងផ្ទះផ្សេងគ្នា មានបុគ្គលិក ១៥នាក់ មានបុគ្គលិកសង្គមកិច្ច១នាក់ | កុមារគេបោះបង់ចោល កុមារកំព្រា ជួញដូរ បំពានកេងប្រវ័ញ្ចពលកម្ម | ផ្លូវការបញ្ជូនដោយអង្គការមិនមែនរដ្ឋាភិបាល នគរបាលមន្ទីរសង្គមកិច្ច | ផ្ដល់កន្លែងស្នាក់នៅ អាហារបណ្ដុះបណ្ដាលវិជ្ជាជីវៈ ថ្លៃសិក្សា ប្រសិនបើចាំបាច់ ទទួលមូលនិធិពីម្ចាស់ជំនួយជប៉ុន ផ្ដល់ប្រាក់សម្រាប់រស់នៅដោយឯករាជ្យ (រហូតដល់ ៣ខែ) |
| សាលារៀនផ្ដល់កន្លែងស្នាក់នៅ រាជធានីភ្នំពេញ | ក្មេងស្រី ៦៩នាក់ បុគ្គលិក ១នាក់ គ្រូ១នាក់ គិលានុបដ្ឋាយិការនី១នាក់ មានបន្ទប់ដេក ២៖ មានបន្ទប់ទឹកស្អាតនិងមានកន្លែងទុកដាក់សម្ភារៈ | ឪពុកម្ដាយធ្វើចំណាកស្រុកទៅប្រទេសថៃកុមារត្រូវគេបោះបង់ មិនអើពើ ឪពុកម្ដាយលេងល្បែង ឬគ្រឿងស្រវឹង | ក្រៅផ្លូវការ តាមរយៈព្រះវិហារកាតូលិក (សង្ឃ) និងបុគ្គល | ១០៥ដុល្លា ក្នុង១ខែ សម្រាប់កុមារម្នាក់ ឪពុកម្ដាយខ្លះផ្ដល់វិភាគទានរហូតដល់២០ដុល្លា ផ្ដល់កន្លែងស្នាក់នៅ រៀនសូត្រ និងអាហារ |

# ឧបសម្ព័ន្ធទី ២ ៖ ឧបករណ៍ប្រមូលទិន្នន័យ

## សេចក្តីណែនាំសម្រាប់ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ ៖ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អ្នកជំនាញខាងការងារថែទាំជំនួស បុគ្គលិកអង្គការយូនីសេហ្វ

[កំណត់សម្គាល់សម្រាប់អ្នកសម្ភាស៖ ឧបករណ៍នេះមានរួមមានសំណួរបញ្ជាក់លំអិត ដែលមិនទាក់ទងជាមួយគ្រប់អ្នកពាក់ព័ន្ធនោះទេ។ សំណួរទាំងនេះត្រូវបានបញ្ចូលដើម្បីសម្រួលដល់ការសម្ភាស ក្នុងករណីដែលអ្នកពាក់ព័ន្ធមានការយល់ដឹងច្រើនអំពីទិដ្ឋភាពជាក់លាក់នៃការថែទាំជំនួស។ ដោយសារការសម្ភាសទាំងនេះមានគោលបំណងស្វែងយល់ដឹងស៊ីជម្រៅអំពីការអនុវត្តការថែទាំជំនួសនៅក្នុងសហគមន៍ ក្នុងប្រទេសកម្ពុជា វាជាការល្អដែលត្រូវលើកជាសំណួរទូលំទូលាយខ្លះ]។

### ណែនាំអំពីការសិក្សាដោយយោងតាមសេចក្តីថ្លែងខាងក្រោម៖

យើងកំពុងធ្វើការសិក្សាអំពីការអនុវត្តការថែទាំកុមារនៅក្នុងប្រទេសកម្ពុជា គឺកុមារដែលមិនស្ថិតនៅក្រោមការថែទាំពីឪពុកម្តាយ។ ការសិក្សានេះទទួលមូលនិធិពីអង្គការយូនីសេហ្វ។ គោលបំណងនៃការសិក្សាគឺដើម្បីរៀនសូត្រអំពីប្រភេទនៃការថែទាំ ( ជំនួស ) ដែលមាន ជាពិសេស នៅក្នុងសហគមន៍ និងដើម្បីកំណត់មើលថាតើការថែទាំងប្រភេទទាំងនេះដំណើរការល្អកម្រិតណា និង តើត្រូវកែលំអរដូចម្តេចខ្លះទៀត។ យើងមានសំណួរខ្លះសម្រាប់សួរអ្នក ទាក់ទងនឹងការយល់ដឹង និងបទពិសោធន៍របស់អ្នកជាមួយទម្រង់ថែទាំ( ជំនួស ) ផ្សេងៗនៅក្នុងប្រទេសកម្ពុជា រួមទាំងទស្សនៈរបស់អ្នកអំពីជម្រើសដែលកំពុងប្រើប្រាស់ និង អនុវត្ត រួមទាំងគំនិតផ្សេងៗអំពីវិធីសាស្ត្រដែលអាចជួយកែលំអសេវាថែទាំជំនួសនាពេលអនាគត។

ចូរពន្យល់ថា ការចូលរួមក្នុងការសិក្សានេះជាលក្ខណៈស្ម័គ្រចិត្ត និងប្រាប់ទៅអ្នកចូលរួមឱ្យបានដឹងអំពីការរក្សាការសម្ងាត់ និងភាពអនាមិក ។

### តើអ្នករីករាយក្នុងការចូលរួមសម្ភាស ដែរឬទេ ?

( ប្រសិនបើអ្នកផ្តល់ចម្លើយឯកភាពចូលរួម ) យើងសូមអរគុណចំពោះការយល់ព្រមចូលរួមនៅក្នុងកិច្ចសម្ភាសនេះ។ សំខាន់បំផុត ការស្រាវជ្រាវនេះគឺអង្គការយូនីសេហ្វធ្វើការសិក្សារៀនសូត្រ ដូច្នេះសូមអ្នកមេត្តាឆ្លើយដោយមិនលាក់លៀម និងបើកចំហតាមដែលអាចធ្វើបាន។ នៅពេលដែលយើងបញ្ចូលការរួមវិភាគទានរបស់អ្នកទៅក្នុងរបាយការណ៍របស់យើង យើងរមែងតែងរក្សាយោបល់របស់អ្នកជាអនាមិក។ អ្នកអាចមិនមានចម្លើយចំពោះគ្រប់សំណួររបស់យើង ដូច្នេះសូមកុំព្យាយាមឆ្លើយសំណួរណាដែលអ្នកមិនដឹងចម្លើយ។ យើងចង់ដឹងអំពីការយល់ឃើញទស្សនៈ និងបទពិសោធន៍របស់អ្នក។

## សំណួរដំបូង

១. សូមអ្នកពន្យល់សង្ខេបអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នក ជាពិសេស តើការងាររបស់អ្នកមានទំនាក់ទំនងដូចម្តេចខ្លះជាមួយការថែទាំជំនួស?

២. តើអ្នកអាចពន្យល់បន្តិចអំពីប្រវត្តិ/បរិបទទាក់ទងនឹងការថែទាំជំនួសនៅក្នុងប្រទេសកម្ពុជា (នៅក្នុងខេត្ត/ ស្រុក/ឃុំរបស់អ្នក) បានឬទេ?

## បរិបទ និងតម្រូវការ

៣. តើនរណាជាក្រុមកុមារចម្បងៗនៅក្នុងប្រទេសកម្ពុជា (នៅក្នុងខេត្ត/ ស្រុក/ឃុំរបស់អ្នក) ដែលត្រូវការការថែទាំ/រស់នៅដោយគ្មានការថែទាំពីឪពុកម្តាយ?

៤. តើដោយសារមូលហេតុអ្វីខ្លះ និង ហេតុអ្វីបានជាកុមារទាំងនេះត្រូវការការថែទាំ (ជំនួស)? តើពួកគេធ្លាក់ខ្លួនទៅជាត្រូវការថែទាំជំនួសដោយរបៀបណា?

៥. តើជាទូទៅ មានអ្វីកើតឡើងខ្លះចំពោះកុមារទាំងនេះ? តើនៅទីបំផុតពួកគេរស់នៅដោយមាន ឬគ្មានការថែទាំ? តើការថែទាំប្រភេទណាខ្លះ?

## ទម្រង់នៃការថែទាំជំនួស

៦. តើជម្រើសនៃថែទាំជំនួសមានអ្វីខ្លះ? (ប្រសិនបើចាំបាច់សូមកំណត់និយមន័យនៃការថែទាំ) (ចូរផ្តល់តម្រុយប្រសិនបើចាំបាច់) ចុះចំណែកឯការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ផ្ទះស្នាក់នៅជាក្រុម និងការថែទាំតាមវត្តអារាម?

៧. ក្នុងការអនុវត្តជាក់ស្តែង តើទម្រង់នៃការថែទាំនីមួយៗត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច? តើទម្រង់ទូទៅនៃការថែទាំកុមារមានលក្ខណៈដូចម្តេច?

៨. តើអ្នកគិតថាជម្រើសថែទាំជំនួសណាល្អបំផុតសម្រាប់កុមារនៅក្នុងប្រទេសកម្ពុជា (នៅក្នុងខេត្ត/ ស្រុក/ឃុំរបស់អ្នក)? តើណាខ្លះជាជម្រើសអាក្រក់បំផុត? ហេតុអ្វី?

*ចំពោះទម្រង់នៃការថែទាំនីមួយៗដែលអ្នកផ្តល់ចម្លើយបានដឹង យើងព្យាយាមស្វែងយល់ព័ត៌មានដូចខាងក្រោម៖*

## ការកំណត់អត្តសញ្ញាណ និងការបញ្ជូន

៩. តើកុមារទំនងនឹងធ្លាក់ចូលទៅក្នុងទម្រង់នៃការថែទាំ X ដោយរបៀបណា? តើពួកគេត្រូវបានកំណត់អត្តសញ្ញាណយ៉ាងដូចម្តេច/តើនរណាជាអ្នកបញ្ជូនពួកគេ? តើមានដំណើរការប៉ាន់ប្រមាណ/បញ្ជូនកុមារជាផ្លូវការដែរឬទេ? (ប្រសិនបើអ្នកបានដឹងអំពីដំណើរការនេះ) តើដំណើរការនេះប្រព្រឹត្តទៅដូចម្តេចខ្លះ/នរណាខ្លះចូលរួម? តើមានការជូនដំណឹង ឬ ចូលរួមពីអាជ្ញាធររដ្ឋាភិបាល (ឬអ្នកដទៃទៀត) ដែរឬទេ? តើតួនាទី/ការចូលរួមរបស់ឪពុកម្តាយ និង គ្រួសារសាខាញាតិរបស់កុមារមានអ្វីខ្លះ?

## លក្ខណៈនៃការថែទាំជំនួស

១០. តើនរណាជាអ្នកធ្វើប្រតិបត្តិការសេវា X នេះ? តើមានកុមារប៉ុន្មាននាក់ដែលសេវា X នេះអាចផ្តល់កន្លែងស្នាក់នៅជូន? តើមានកុមារប៉ុន្មាននាក់កំពុងស្នាក់នៅជាក់ស្តែងនៅទីនោះ? តើអ្នកស្គាល់កន្លែងនោះច្បាស់ដែរឬទេ? តើអ្នកចាត់ទុកកន្លែងទាំងនោះថាមានបរិយាកាសល្អសម្រាប់កុមារដែរឬទេ? ហេតុអ្វីល្អ ឬហេតុអ្វីមិនល្អ?

១១. តើកុមារទំនងនឹងស្នាក់នៅក្នុងការថែទាំ X រយៈពេលប៉ុន្មាន? តើមានការខិតខំប្រឹងប្រែងដើម្បីបង្រួបបង្រួមជាមួយគ្រួសាររបស់ពួកគេដែរឬទេ? តើមានយន្តការពិនិត្យឡើងវិញទៅលើករណីរបស់កុមារដែរឬទេ? តើយន្តការនេះដំណើរការដូចម្តេចដែរ? តើកុមារចាកចេញពីទម្រង់ថែទាំ X នៅពេលណា? តើពួកគេនឹងទៅកន្លែងណា?

១២. តើអ្នកដឹងអំពីសេវាថែទាំដែលផ្តល់ដល់កុមារនៅក្នុងមណ្ឌលដែរឬទេ? តើមានសេវាអ្វីខ្លះ? ផ្តល់គម្រុយខ្លះៗ ដើម្បីស្វែងយល់ថាតើកុមារមានលទ្ធភាពទទួលបានសេវាខាងក្រោមដែរឬទេ៖

- ទទួលសេវាសង្គមកិច្ច រាប់បញ្ចូលការផ្តល់ប្រឹក្សាយោបល់ ការធ្វើផែនការថែទាំ ។ល។
- សេចក្តីត្រូវការមូលដ្ឋាន ដូចជា អាហារ សេវាសុខភាព ។ល។
- ការអប់រំ ឬសេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពដទៃទៀត។
- ដំបូន្មាន និងការគាំទ្រផ្លូវច្បាប់។
- សេវាផ្សេងទៀតដែលកន្លែងថែទាំផ្តល់ឲ្យ។

*ចូរផ្តល់គម្រុយដើម្បីស្វែងយល់ព័ត៌មានលំអិតតាមដែលអាចធ្វើបាន។*

១៣. តើមានបញ្ហាអ្វីដែរឬទេ ចំពោះសេវាដែលបានផ្តល់ដល់កុមារនៅក្នុងមណ្ឌល? តើមានកង្វះខាតអ្វីដែរឬទេ? តើសេវាថែទាំជំនួសនេះ អាចធ្វើការកែលំអដូចម្តេចខ្លះ?

## ការគ្រប់គ្រង ការផ្តល់មូលនិធិ និង រដ្ឋបាល

១៤. តើនរណាជាអ្នកគ្រប់គ្រងទម្រង់ថែទាំ X នេះ? តើសេវានេះបានចុះបញ្ជីជាផ្លូវការជាមួយរដ្ឋាភិបាលដែរឬទេ?

១៥. តើការរៀបចំបុគ្គលិកមានលក្ខណៈដូចម្តេចដែរ (មានបុគ្គលិកប៉ុន្មាននាក់ តើបុគ្គលិកទាំងនោះមានសាវតាដូចម្តេចខ្លះ។ល។?) តើបុគ្គលិកទទួលបានការបណ្តុះបណ្តាល ឬការកសាងសមត្ថភាពដែរឬទេ? តើមានចន្លោះប្រហោងផ្នែកសមត្ថភាពដែរឬទេ? តើចន្លោះប្រហោងទាំងនោះមានអ្វីខ្លះ?

១៦. តើទម្រង់នៃការថែទាំ X ទទួលបានការផ្តល់ហិរញ្ញប្បទានដូចម្តេច? តើអ្នកបានដឹងអំពីថវិកាសម្រាប់ប្រតិបត្តិទម្រង់ថែទាំ X នេះដែរទេ? តើមានការចំណាយដូចម្តេចខ្លះ?

## ការត្រួតពិនិត្យតាមដាន

១៧. តើមាននរណាទទួលខុសត្រូវត្រួតពិនិត្យតាមដានទម្រង់ថៃទាំ X ដែរឬទេ ? តើអ្វីខ្លះជាគោលបំណង នៃការត្រួតពិនិត្យតាមដាននោះ ? តើការត្រួតពិនិត្យតាមដាន ពាក់ព័ន្ធការងារអ្វីខ្លះ ? តើការត្រួតពិនិត្យ នេះធ្វើញឹកញាប់កម្រិតណា ? តើគេប្រើប្រាស់លទ្ធផលយ៉ាងដូចម្តេច ?

## អនុសាសន៍ និងសេចក្តីសន្និដ្ឋាន

១៨. តើអ្នកគិតថាអ្វីជាចន្លោះប្រហោងធំបំផុតនៅក្នុងការថៃទាំជំនួសចំពោះកុមារក្នុងប្រទេសកម្ពុជា ? តើចន្លោះប្រហោងទាំងនេះអាចចំពេញយ៉ាងដូចម្តេច ?

១៩. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីកែលម្អសេវាថៃទាំជំនួសដែលមានស្រាប់ដែរឬទេ ?

# សេចក្តីណែនាំសម្រាប់កិច្ចសម្ភាសបុគ្គល ជាមួយអ្នកថែទាំ និងអ្នកគ្រប់គ្រង

## ណែនាំអំពីការសិក្សាដោយយោងតាមសេចក្តីថ្លែងខាងក្រោម៖

យើងកំពុងធ្វើការសិក្សាអំពីការអនុវត្តការថែទាំកុមារនៅក្នុងប្រទេសកម្ពុជា គឺកុមារដែលមិនស្ថិតនៅក្រោមការថែទាំពីឪពុកម្តាយ។ ការសិក្សានេះទទួលមូលនិធិពីអង្គការយូនីសេហ្វ។ គោលបំណងនៃការសិក្សាគឺដើម្បីរៀនសូត្រអំពីប្រភេទនៃការថែទាំ (ជំនួស) ដែលមាន ជាពិសេស នៅក្នុងប្រទេសកម្ពុជា និងដើម្បីកំណត់មើលថាតើការថែទាំងប្រភេទទាំងនេះដំណើរការល្អប៉ុណ្ណា ហើយតើត្រូវកែលំអរបៀបយ៉ាងដូចម្តេចខ្លះ។ យើងមានសំណួរខ្លះសម្រាប់សួរអ្នកទាក់ទងនឹងចំណេះដឹង និងបទពិសោធន៍របស់អ្នកក្នុងការផ្តល់ការថែទាំដល់កុមារ។

> ចូរពន្យល់ថា ការចូលរួមក្នុងការសិក្សានេះជាលក្ខណៈស្ម័គ្រចិត្ត និងប្រាប់ទៅអ្នកចូលរួមឱ្យបានដឹងអំពីការរក្សាការសម្ងាត់ និងភាពអនាមិក ។

## តើអ្នករីករាយក្នុងការចូលរួមសម្ភាស ដែរឬទេ?

(ប្រសិនបើអ្នកផ្តល់ចម្លើយឯកភាពចូលរួម) យើងសូមអរគុណចំពោះការយល់ព្រមចូលរួមនៅក្នុងកិច្ចសម្ភាសនេះ។ សំខាន់បំផុត ការស្រាវជ្រាវនេះគឺអង្គការយូនីសេហ្វធ្វើការសិក្សារៀនសូត្រ ដូច្នេះសូមអ្នកមេត្តាឆ្លើយដោយមិនលាក់លៀម និងបើកចំហតាមដែលអាចធ្វើបាន។ នៅពេលដែលយើងបញ្ចូលការរួមវិភាគទានរបស់អ្នកទៅក្នុងរបាយការណ៍របស់យើង យើងរមែងតែងរក្សាយោបល់របស់អ្នកជាអនាមិក។ អ្នកអាចមិនមានចម្លើយចំពោះគ្រប់សំណួររបស់យើង ដូច្នេះសូមកុំព្យាយាមឆ្លើយសំណួរណាដែលអ្នកមិនដឹងចម្លើយ។ យើងចង់ដឹងអំពីការយល់ឃើញ ទស្សនៈ និងបទពិសោធន៍របស់អ្នក។

## សំណួរដំបូង

១. សូមអ្នកពន្យល់សង្ខេបអំពីតួនាទីផ្តល់/គ្រប់គ្រងការថែទាំជំនួសចំពោះកុមារ [ប្រសិនបើពាក់ព័ន្ធ សូមបញ្ជាក់អំពីការថែទាំដោយឪពុកម្តាយធម៌ ថែទាំដោយសាច់ញាតិ ផ្ទះស្នាក់នៅជាក្រុម ការថែទាំតាមវត្តអារាម មណ្ឌលថែទាំ ។ល។]

២. (ប្រសិនបើអ្នកផ្តល់ចម្លើយជាអ្នកគ្រប់គ្រង/ជាបុគ្គលិកនៅក្នុងមណ្ឌល/អង្គការ) តើអ្នកអាចពន្យល់បន្តិចអំពីប្រវត្តិ/បរិបទទាក់ទងនឹងមណ្ឌល/អង្គការរបស់អ្នក និង សេវាដែលមណ្ឌល/អង្គការរបស់អ្នកផ្តល់ដល់កុមារ បានដែរឬទេ? តើគោលដៅទូទៅជារួមមានអ្វីខ្លះ/តើមណ្ឌលរបស់អ្នកមានអាណត្តិកាងារធ្វើអ្វីខ្លះ?

៣. (ប្រសិនបើអ្នកផ្តល់ចម្លើយគឺជាអ្នកថែទាំដោយសាច់ញាតិ ឬឪពុកម្តាយធម៌) តើអ្នកបានចូលរួមនៅក្នុងការផ្តល់ការថែទាំដោយឪពុកម្តាយធម៌ ឬដោយសាច់ញាតិអស់រយៈពេលប៉ុន្មាន? តើអ្នកចូលរួមយ៉ាងដូចម្តេច? ហេតុអ្វីបានជាអ្នកសម្រេចចិត្តធ្វើការងារនេះ?

## សំណួរទូទៅ

៤. តើមានកុមារប៉ុន្មាននាក់នៅក្នុងមណ្ឌលថែទាំរបស់អ្នក នាពេលនេះ? តើអ្នក/មណ្ឌល របស់អ្នកមាន សមត្ថភាពផ្តល់ការថែទាំដល់កុមារប៉ុន្មាននាក់?

៥. សូមប្រាប់ខ្ញុំបន្តិចអំពីកុមារដែលស្ថិតក្រោមការថែទាំរបស់អ្នក- តើពួកគេមានអាយុប៉ុន្មាន/ភេទអ្វីខ្លះ? តើសាវតាសង្គម សាសនា និងជាតិពន្ធុរបស់ពួកគេ មានលក្ខណៈដូចម្តេចដែរ? មូលហេតុអ្វីបាន ជាពួកគេត្រូវការការថែទាំ? តើពួកគេមានឪពុកម្តាយ ឬអ្នកអាណាព្យាបាល ដែរឬទេ?

*(សំណួរទូទៅសម្រាប់អ្នកផ្តល់សេវាថែទាំជាឪពុកម្តាយធម៌/អ្នកថែទាំជាសាច់ញាតិ)*

៦. តើមាននរណាខ្លះរស់នៅផ្ទះរបស់អ្នក? តើអ្នកមានកូនបង្កើតដែរឬទេ?

៧. តើអ្នក (ឬអ្នកផ្សេងទៀតក្នុងគ្រួសាររបស់អ្នក) ជានិយោជិត មែនដែរឬទេ? តើប្រភពចំណូលរបស់ អ្នកគឺជាអ្វី?

៨. តើកុមារដែលស្ថិតក្រោមការថែទាំរបស់អ្នក មានបុគ្គលិកសង្គមកិច្ចដែលត្រូវបានចាត់តាំងឱ្យទទួល បន្ទុក ដែរឬទេ? ប្រសិនបើមាន តើបុគ្គលិកសង្គមកិច្ចនោះមកពីណា?

*(សំណួរទូទៅសម្រាប់អ្នកផ្តល់សេវាថែទាំនៅតាម ផ្ទះស្នាក់នៅជាក្រុម/វត្តអារាម/មណ្ឌលថែទាំ)*

៩. តើអ្នកមានអ្នកថែទាំប៉ុន្មាននាក់នៅក្នុងមណ្ឌលរបស់អ្នក? តើមាននិយោជិត/បុគ្គលិកណាផ្សេង ដែលចូលរួមក្នុងការផ្តល់ការថែទាំដល់កុមារ ដែរឬទេ?

១០. តើកុមារដែលស្ថិតក្រោមការថែទាំរបស់អ្នក មានបុគ្គលិកសង្គមកិច្ចដែលត្រូវបានចាត់តាំងឱ្យទទួល បន្ទុក ពីក្នុងកន្លែងរបស់អ្នក ឬ ពីខាងក្រៅ ដែរឬទេ?

## ការកំណត់អត្តសញ្ញាណ និងការបញ្ជូនកុមារ

១១. តើកុមារទំនងនឹងធ្លាក់ចូលទៅក្នុងទម្រង់នៃការថែទាំរបស់អ្នក ដោយរបៀបណា? តើពួកគេត្រូវបាន កំណត់អត្តសញ្ញាណយ៉ាងដូចម្តេច/តើនរណាជាអ្នកបញ្ជូនពួកគេ? តើមានដំណើរការប៉ាន់ប្រមាណ/ បញ្ជូនកុមារជាផ្លូវការដែរឬទេ? (ប្រសិនបើអ្នកបានដឹងអំពីដំណើរការនេះ) តើដំណើរការនេះប្រព្រឹត្ត ទៅដូចម្តេចខ្លះ/នរណាខ្លះចូលរួម? តើមានការជូនដំណឹង ឬ ចូលរួមពីអាជ្ញាធររដ្ឋាភិបាល (ឬអ្នក ដទៃទៀត) ដែរឬទេ? តើតួនាទី/ការចូលរួមរបស់ឪពុកម្តាយ និង គ្រួសារសាខាញាតិរបស់កុមារ មានអ្វីខ្លះ?

*(សំណួរសម្រាប់អ្នកផ្តល់សេវាថែទាំដោយឪពុកម្តាយធម៌/សាច់ញាតិ)*

១២. តើអ្នកផ្តល់ការថែទាំក្នុងនាមជាឪពុកម្តាយធម៌ដល់កុមារនេះ/ទាំងនេះ ដោយសារមូលហេតុអ្វី/ ដោយរបៀបណា? តើនរណាជាអ្នកបញ្ជូនកុមារទាំងនេះមកឱ្យអ្នក និង តើកត្តាអ្វីខ្លះដែលធ្វើឱ្យអ្នក សម្រេចចិត្តថែទាំពួកគេ?

[កំណត់សម្គាល់សម្រាប់អ្នកសម្ភាសៈ ប្រសិនបើអ្នកសម្ភាសអ្នកថែទាំជាឪពុកម្តាយធម៌/សាច់ញាតិ វាកាន់តែសមស្របប្រសិនបើអ្នកសួរសំណួរអំពីករណីជាក់លាក់]

១៣. តើកុមារទំនងនឹងស្នាក់នៅក្នុងការថែទាំរបស់អ្នករយៈពេលប៉ុន្មាន? តើមានការប្រឹងប្រែងបង្រួបបង្រួមកុមារជាមួយគ្រួសាររបស់ពួកគេ ដែរឬទេ? តើមានយន្តការពិនិត្យឡើងវិញទៅលើករណីរបស់កុមារដែរឬទេ? តើយន្តការនេះមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច? នៅពេលណា/ក្រោមកាលៈទេសៈអ្វីខ្លះដែលកុមារនឹងចាកចេញពីការថែទាំរបស់អ្នក? តើពួកគេទៅកន្លែងណា?

១៤. សូមប្រាប់ខ្ញុំបន្តិចអំពីសេវាចាំបាច់ជាមូលដ្ឋាន ដែលបានផ្តល់ដល់កុមារនៅក្នុងការថែទាំរបស់អ្នក? តើកុមារបានទទួលអាហារ កន្លែងស្នាក់នៅ សេវាសុខភាព ។ល។ ដែរឬទេ? តើពួកគេទទួលបានដោយរបៀបណា? (ផ្តល់តម្រុយខ្លះៗ ដើម្បីស្វែងយល់ថាតើកុមារមានលទ្ធភាពទទួលបានសេវាអ្វីខ្លះ)

១៥. តើកុមារដែលអ្នកថែទាំ បានចូលសាលារៀន ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬប្រភេទនៃសកម្មភាពអប់រំដទៃទៀត ដែរឬទេ? តើនរណាជាអ្នកផ្តល់ការអប់រំនេះ? តើអ្នកគិតថាវាគ្រប់គ្រាន់/សមស្របដែរឬទេ? ហេតុអ្វីគ្រប់គ្រាន់/សមស្រប ហេតុអ្វីមិនគ្រប់គ្រាន់/មិនសមស្រប?

១៦. តើកុមារមានសកម្មភាព/ភារកិច្ច/ការទទួលខុសត្រូវជាក់លាក់ប្រចាំថ្ងៃ ដែរឬទេ? តើការងារទាំងនោះមានអ្វីខ្លះ? (ផ្តល់តម្រុយដើម្បីស្វែងយល់ព័ត៌មានលំអិតអំពីរយៈពេលដែលចំណាយធ្វើសកម្មភាពដែលបានលើកឡើង និងលក្ខណៈនៃសកម្មភាពទាំងនេះ)

១៧. តើកុមារដែលអ្នកថែទាំ បានទទួលសេវាសង្គមកិច្ច ដែរឬទេ? តើនរណាជាអ្នកផ្តល់សេវាទាំងនេះ? តើសេវាទាំងនេះមានអ្វីខ្លះ? តាមទស្សនៈរបស់អ្នក តើសេវានោះមានប្រសិទ្ធិភាព/មានសារៈប្រយោជន៍ចំពោះកុមារ ដែរឬទេ? ហេតុអ្វី?

១៨. តើកុមារនៅក្នុងការថែទាំរបស់អ្នកបានទទួលដំបូន្មាន/ការគាំទ្រផ្លូវច្បាប់ដែរឬទេ? តើមានអ្នកខាងក្រៅ ឬគ្រួសារ/អង្គការរបស់អ្នក ដែលកុមារអាចទាក់ទងបានដែរឬទេ ប្រសិនបើកុមារមានបញ្ហា? តើអ្នកទាំងនោះជាអ្នកណា?

១៩. តើមានបញ្ហា ឬ ចន្លោះប្រហោងនៅក្នុងសេវាដែលអ្នកផ្តល់ជូនកុមារដែលស្ថិតក្រោមការថែទាំរបស់អ្នកដែរឬទេ? តើមានខ្វះខាតអ្វីដែរឬទេ? តើសេវាដែលអ្នកផ្តល់អាចធ្វើការកែលំអយ៉ាងដូចម្តេច?

២០. ជាទូទៅ តើការប្រឈម និងការលំបាកចម្បងៗដែលអ្នកជួបប្រទះក្នុងនាមជាអ្នកថែទាំមានអ្វីខ្លះ? (ផ្តល់តម្រុយដើម្បីចង់ដឹងថាតើពួកគេមានអារម្មណ៍ដូចម្តេចចំពោះកុមារនៅក្នុងការថែទាំរបស់ពួកគេ?

## ការផ្តល់មូលនិធិ ការគ្រប់គ្រង និងការកសាងសមត្ថភាព

២១. តើនរណាជាអ្នកគ្រប់គ្រង/ត្រួតពិនិត្យតាមដានការថែទាំដែលអ្នកផ្តល់ឲ្យ? តើសេវាថែទាំរបស់អ្នកមានចុះបញ្ជីជាផ្លូវការជាមួយរដ្ឋាភិបាលដែរឬទេ? ប្រសិនបើមានជាមួយស្ថាប័នរដ្ឋាភិបាលមួយណា?

២២. តើការថែទាំរបស់អ្នក ត្រូវអនុវត្តតាមវិធាន ឬលិខិតបទដ្ឋានគតិយុត្តិណាមួយដែរឬទេ? ប្រសិនបើមាន តើអ្នកត្រូវអនុវត្តតាមវិធាន ឬលិខិតបទដ្ឋានគតិយុត្តិណាខ្លះ? តើមានលក្ខខណ្ឌតម្រូវដែលអ្នកត្រូវបំពេញដើម្បីចុះបញ្ជី/សុំការអនុម័តយល់ព្រមជាផ្លូវការ ក្នុងនាមជាអ្នកថែទាំ ដែរឬទេ?

២៣. តើការរៀបចំបុគ្គលិកយ៉ាងដូចម្តេចដែរ (មានប៉ុន្មាននាក់ មានសាវតាអ្វីខ្លះ ។ល។) (ចូរផ្តល់តម្រុយដើម្បីសាកសួរចង់ដឹងអំពីចំនួនបុគ្គលិកអចិន្រ្តៃយ៍ដែលមានវត្តមានគ្រប់ពេលវេលា។ល។)

២៤. តើអ្នក (បុគ្គលិករបស់អ្នក) បានទទួលការបណ្តុះបណ្តាល ឬការកសាងសមត្ថភាពដែរឬទេ? តើនរណាជាអ្នកផ្តល់ការបណ្តុះបណ្តាល? តើបណ្តុះបណ្តាលអំពីអ្វីខ្លះ? តើមានបញ្ហាកង្វះសមត្ថភាពដែរឬទេ/ តើអ្នកនឹងទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលបន្ថែមនេះដែរឬទេ? សូមរៀបរាប់បញ្ជាក់លម្អិត។

២៥. តើអ្នកបានទទួលមូលនិធិពីខាងក្រៅ សម្រាប់ផ្គត់ផ្គង់សេវាថែទាំរបស់អ្នកដែរឬទេ? តើអ្នកបានទទួលចំនួនប៉ុន្មាន និង តើមូលនិធិទាំងនោះមានប្រភពមកពីណា?

២៦. តើអ្នកត្រូវការចំណាយប៉ុន្មានសម្រាប់ការផ្តល់សេវានេះ? តើមានការចំណាយជាក់លាក់អ្វីខ្លះទាក់ទងនឹងការផ្តល់ការថែទាំដល់កុមារ?

២៧. តើអ្នកមានថវិកាគ្រប់គ្រាន់សម្រាប់រាល់ការចំណាយដែរឬទេ? ប្រសិនបើអ្នកមានមូលនិធិបន្ថែមដើម្បីផ្តល់ដល់ការថែទាំឲ្យកាន់តែប្រសើរ តើអ្នកនឹងចំណាយវាដូចម្តេចខ្លះ?

## ការពិនិត្យតាមដាន និងការឃ្លាំមើល

២៨. តើមាននរណាទទួលខុសត្រូវពិនិត្យតាមដានសេវាថែទាំរបស់អ្នកដែរឬទេ? ប្រសិនបើមាន តើជានរណា? តើគោលបំណងនៃការត្រួតពិនិត្យតាមដាននេះគឺជាអ្វី? តើការពិនិត្យតាមដាននេះមានពាក់ព័ន្ធការងារអ្វីខ្លះ? តើការត្រួតពិនិត្យនេះកើតឡើងញឹកញាប់ប៉ុណ្ណា? តើលទ្ធផលរបស់វាត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?

## អនុសាសន៍ និងសេចក្តីសន្និដ្ឋាន

២៩. តើអ្នកមានអនុសាសន៍អ្វីខ្លះសម្រាប់កែលម្អសេវាថែទាំជំនួសរបស់អ្នក?

៣០. តើអ្នកគិតថាអ្វីខ្លះជាចន្លោះប្រហោងធំបំផុតនៅក្នុងការថែទាំជំនួសចំពោះកុមារក្នុងប្រទេសកម្ពុជា? (នៅក្នុងខេត្ត ស្រុក ឃុំរបស់អ្នក?) តើចន្លោះប្រហោងទាំងនោះអាចបំពេញដោយរបៀបណា?

# សេចក្តីណែនាំសម្រាប់កិច្ចសម្ភាសលក្ខណៈបុគ្គល ៖ កុមារនៅក្នុងការថែទាំជំនួស

ប្រសើរបំផុត ការសម្ភាសត្រូវធ្វើមួយទល់នឹងមួយ (ពីរទល់មួយ រួមទាំងអ្នកបកប្រែ)។ ប្រសិនបើវាធ្វើឱ្យកុមារដែលត្រូវសម្ភាសមានអារម្មណ៍កាន់តែងាយស្រួល ពួកគេអាចនាំអ្នកដែលគេជឿទុកចិត្តមកកន្លែងសម្ភាសបាន។ ការសម្ភាសត្រូវធ្វើនៅកន្លែងមានសុវត្ថិភាព និងស្ងៀមស្ងាត់។

ណែនាំអំពីខ្លួនអ្នក និងគោលបំណងនៃការសិក្សា៖ នេះជាការសិក្សាអំពីការថែទាំចំពោះកុមារនៅក្នុងប្រទេសកម្ពុជា ជាពិសេស កុមារដែលមិនរស់នៅឯផ្ទះ ឬមិនត្រូវបានមើលថែទាំដោយឪពុកម្ដាយរបស់ពួកគេ។ យើងកំពុងស្វែងយល់អំពីបទពិសោធន៍របស់អ្នក ដើម្បីយើងអាចដឹងថាមានអ្វីកំពុងកើតឡើងជាក់ស្ដែង ហើយត្រូវធ្វើអ្វីបន្ថែមទៀតដើម្បីការពារកុមារនៅពេលអនាគត។ សូមពន្យល់ថា ការសម្ភាសនេះគឺជាការស្ម័គ្រចិត្ត ដូច្នេះត្រូវសុំការយល់ព្រមជាមុន និងប្រាប់អ្នកចូលរួមផ្ដល់សម្ភាសអំពីភាពអនាមិក។

## សំណួរដំបូង

១. ជាដំបូង សូមអ្នកប្រាប់ខ្ញុំបន្តិចអំពីខ្លួនអ្នក៖ តើអ្នកអាយុប៉ុន្មាន?

២. តើបច្ចុប្បន្នអ្នករស់នៅឯណា ហើយរស់នៅជាមួយអ្នកណា? តើនរណាថែទាំអ្នក?

៣. ពីមុនអ្នករស់នៅឯណា? តើមាននរណាមើលខុសត្រូវលើអ្នកដែរឬទេ? តើអ្នកនោះជានរណា?

៤. (ប្រសិនបើកុមាររស់នៅក្នុងការថែទាំជំនួស) តើអ្នករស់នៅទីនេះរយៈពេលប៉ុន្មានហើយ?

៥. (ប្រសិនបើកុមាររស់នៅក្នុងការថែទាំជំនួស) តើបងប្អូនប្រុស ស្រីរបស់អ្នកកំពុងរស់នៅឯណានៅពេលនេះ?

៦. សូមប្រាប់ខ្ញុំបន្តិចអំពីគ្រួសាររបស់អ្នក តើឪពុកម្ដាយរបស់អ្នកធ្វើការដែរឬទេ? តើប្រភពចំណូលចម្បងរបស់អ្នកបានមកពីណា?

៧. តើអ្នកទៅសាលារៀនដែរឬទេ? តើអ្នកទៅរៀននៅឯណា? តើអ្នកដែលខានទៅរៀនដោយសារហេតុផលណាមួយ ដែរឬទេ? ហេតុអ្វី?

   ក. ប្រសិនបើកុមារមិនបានទៅរៀននៅសាលា ត្រូវសួរកុមារថាតើពួកគេបានចូលរៀនវគ្គបណ្ដុះបណ្ដាលណាមួយ ឬពួកគេធ្វើការ ប្រសិនបើពួកគេធ្វើការ តើជាប្រភេទការងារអ្វីនិងធ្វើការងារប៉ុន្មានម៉ោង។

៨. តើអ្នកចូលចិត្តរស់នៅទីនេះឬទេ? ហេតុអ្វីចូលចិត្ត ហេតុអ្វីមិនចូលចិត្ត? តើអ្វីខ្លះជាមូលហេតុចម្បងដែលអ្នកមករស់នៅទីកន្លែងនេះ?

៩. នៅពេលអ្នកមិននៅទីនេះ តើអ្នកចូលចិត្តចំណាយពេលវេលារបស់នៅកន្លែងណាច្រើនជាងគេ? តើអ្នកទៅធ្វើអ្វីនៅទីនោះ? តើអ្នកចំណាយពេលវេលាជាមួយនរណា?

១០. តើមានបញ្ហាណាមួយដែលអ្នកកំពុងដោះស្រាយនៅទីនេះ នៅឯសាលារៀន ឬ នៅក្នុងសហគមន៍ដែរឬទេ? តើមានអ្វីខ្លះដែលធ្វើឲ្យអ្នកមានអារម្មណ៍មិនមានសុវត្ថិភាព ឬ ប្រឈមនឹងគ្រោះថ្នាក់ដែរឬទេ?

## ប្រវត្តិករណី

១១. ផ្តល់តម្រុយដើម្បីស្វែងយល់ទស្សនៈរបស់កុមារអំពីការទុកដាក់របស់ពួកគេនៅក្នុងការថែទាំជំនួស/ការបញ្ជូនទៅកន្លែងថែទាំជំនួស៖ តើអ្វីខ្លះជាមូលហេតុដែលអ្នកមករស់នៅទីកន្លែងនេះនៅពេលដំបូង ? តើមានអ្វីកើតឡើងនៅពេលនោះ ? តើអ្នកមានបញ្ហានៅឯផ្ទះ ឬ នៅឯសាលារៀន ឬកន្លែងដទៃទៀតដែរឬទេ ? តើអ្នកបានទទួលរងនូវប្រភេទណាមួយនៃការរំលោភបំពាននៅឯផ្ទះ ឬនៅកន្លែងផ្សេងទៀត ដែរឬទេ ? តើអ្នកធ្លាប់ប្រាប់អ្នកណាម្នាក់អំពីបញ្ហារបស់អ្នក ដែរឬទេ ?

១២. តើមានអ្វីបានកើតឡើង ? តើមានអ្នកណាខ្លះពាក់ព័ន្ធនឹងករណីរបស់អ្នក ? តើនរណាសម្រេចចិត្តថាអ្នកគួរមករស់នៅទីនេះ ? តើអ្នកមានអារម្មណ៍ដូចម្តេចខ្លះនៅពេលនោះ ? តើឥឡូវនេះអ្នកមានអារម្មណ៍ដូចម្តេចដែរ ? *(សួរសំណួរផ្តល់តម្រុយដើម្បីស្វែងយល់អំពីព័ត៌មានលំអិតឱ្យបានច្រើនទៅតាមដែលអាចធ្វើបានអំពីព្រឹត្តិការណ៍ ដែលធ្វើឲ្យកុមារត្រូវគេបញ្ជូន របៀបដែលករណីត្រូវបានកំណត់អត្តសញ្ញាណនិង រាយការណ៍ និងតើដំណើរការ ឆ្លើយតប និង ធ្វើសេចក្តីសម្រេចចិត្ត មានអ្វីខ្លះ)។*

១៣. *សួរសំណួរផ្តល់តម្រុយដើម្បីយល់ដឹងអំពីរបៀបដែលករណីត្រូវបានដោះស្រាយ/នរណាជាអ្នកដោះស្រាយ និងមានអ្វីបានកើតឡើង។ ព្យាយាមស្វែងយល់ថាតើនរណាបានចូលរួមនៅក្នុងដំណាក់កាលនីមួយៗ ថាតើមានពាក់ព័ន្ធដំណើរការផ្លូវច្បាប់ ដែរឬទេ ? តើពួកគេមានតួនាទីអ្វីខ្លះ តើកុមារត្រូវបានដកហូតពីផ្ទះរបស់ពួកគេនៅពេលណាមួយដែរឬទេ តើកុមារ ឬគ្រួសាររបស់គេបានទទួលសេវា/ការគាំទ្រណាមួយ ដែរឬទេ ? ព្យាយាមស្វែងយល់អំពីពេលវេលាដែលហេតុការណ៍ទាំងនេះបានកើតឡើងផងដែរ។*

## បទពិសោធន៍នៅក្នុងការថែទាំ

១៤. តើមានកុមារប៉ុន្មាននាក់កំពុងរស់នៅទីនេះ ? តើពួកគេមានរឿងរ៉ាវដូចម្តេចខ្លះ/ហេតុអ្វីបានជាពួកគេមកនៅទីនេះ ? តើពួកគេមកពីកន្លែងជិតៗនេះ ឬ មកពីគ្រប់ទីកន្លែង ? តើអ្នកចុះសម្រុងជាមួយពួកគេដែរឬទេ ?

១៥. សូមប្រាប់ខ្ញុំបន្តិចថាតើនៅទីនេះយ៉ាងម៉េចដែរសម្រាប់អ្នក ? តើក្នុងថ្ងៃនីមួយអ្នកធ្វើអ្វីខ្លះ ? ( ផ្តល់តម្រុយដើម្បីស្វែងយល់អំពីចំណុចខាងក្រោម )

ក. តើអាហារយ៉ាងម៉េចដែរនៅទីនេះ ? តើអ្នកហូបប៉ុន្មានដង ? តើអាហាររបស់អ្នកមានអ្វីខ្លះ ?

ខ. តើអ្នកមានធ្លាក់ខ្លួនឈឺឬទេតាំងពីចូលមកនៅទីនេះ ? តើអ្នកអាចទទួលបានជំនួយដែលអ្នកត្រូវការដែរឬទេ ? (ប្រសិនបើឆ្លើយថាទេ) តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកឈឺ ? តើអ្នកអាចប្រាប់នរណាបាន ?

គ. តើអ្នកគេងនៅឯណា ? តើអ្នកមានពូក ខ្នើយ ភួយ ។ល។ ឬទេ ?

ឃ. តើអ្នកមានកន្លែងទុកដាក់របស់របររបស់អ្នក ដែរឬទេ ?

ង. តើបង្គន់ និងបន្ទប់ងូតទឹកមានលក្ខណៈដូចម្តេច ? តើវាមានស្អាត ឬ កខ្វក់ ?

ច. តើអ្នកអាចងូតទឹកមួយថ្ងៃប៉ុន្មានដង ? តើអ្នកមានកន្លែងឯកជនសម្រាប់ងូតទឹកដែរឬទេ ឬអ្នកត្រូវងូតទឹកនៅចំពោះមុខអ្នកដទៃ ? តើអ្នកនោះជានរណា ?

១៦. តើអ្នកមាន«បុគ្គលិកសង្គមកិច្ច» ឬនរណាម្នាក់ដែលត្រូវបានចាត់តាំងឲ្យជួយអ្នកឬទេ ? តើអ្នកនោះជាអ្នកណា ? តើអ្នកដឹងថាពួកគេមកពីកន្លែងណាទេ ? តើអ្នកជួបពួកគេញឹកញាប់ប៉ុណ្ណា ? តើអ្នកពិភាក្សា អំពីបញ្ហាអ្វី ? តើអ្នកយល់ថាវាមានសារៈប្រយោជន៍ដែរឬទេ ?

១៧. (ប្រសិនបើកុមារបានទៅរៀន) តើអ្នកយល់យ៉ាងណាដែរចំពោះសាលារៀន? តើវាពិបាកពេក ឬវាងាយស្រួលពេក? ចុះលោកគ្រូ-អ្នកគ្រូវិញយ៉ាងម៉េចដែរ? ចុះសិស្សផ្សេងទៀត? តើអ្នកមានការលំបាកអ្វីដែរឬទេនៅឯសាលារៀន?

១៨. (ក្រៅពីទៅរៀន) តើអ្នកមានភារកិច្ច ឬការងារផ្សេងដែលអ្នកត្រូវទទួលខុសត្រូវនៅកន្លែងនេះដែរឬទេ? តើជាការងារអ្វី? តើអ្នកចំណាយពេលប៉ុន្មានដើម្បីធ្វើការងារនេះ ក្នុង១ថ្ងៃ? តើការងារនេះពិបាកប៉ុណ្ណា?

១៩. តើអ្នកយល់យ៉ាងម៉េចដែរចំពោះបុគ្គលិក/អ្នកថែទាំនៅក្នុងកន្លែងនេះ? តើពួកគេធ្វើចំពោះអ្នកដូចម្ដេចខ្លះ? តើឥរិយាបថរបស់ពួកគេចំពោះអ្នក និងចំពោះកុមារផ្សេងទៀតដូចម្ដេចដែរ? តើពួកគេធ្វើចំពោះអ្នកខុសគ្នាពីការធ្វើចំពោះកុមារដទៃ ដែរឬទេ? តើខុសគ្នាដូចម្ដេចខ្លះ? ហេតុអ្វី?

២០. តើនៅកន្លែងនេះមានបទបញ្ជាដូចម្ដេចខ្លះ? តើនឹងមានអ្វីកើតឡើងប្រសិនបើអ្នកមិនគោរពតាមបទបញ្ជា? តើមានការដាក់ទោសដូចម្ដេចខ្លះបើអ្នករំលោភបំពានបទបញ្ជា? (ផ្ដល់តម្រុយដើម្បីសាកសួរស្វែងយល់អំពីទណ្ឌកម្មលើរាងកាយ ភាពញឹកញាប់ និងកម្រិតនៃភាពធ្ងន់ធ្ងរ)។

២១. នៅក្នុងមណ្ឌលនេះ តើអ្នកធ្លាប់មានបញ្ហាជាមួយកុមារផ្សេង ឬជាមួយបុគ្គលិកដែរឬទេ? តើបញ្ហានោះមានប្រភេទអ្វីខ្លះ? តើមានអ្នកណាដែលបង្គ្រោះថ្នាក់ដល់អ្នកដែរឬទេ? តើជានរណា? តើអ្នកមានប្រាប់នរណាដែរឬទេ? ហេតុអ្វីប្រាប់/ហេតុអ្វីមិនប្រាប់? (ប្រសិនបើប្រាប់ ព្យាយាមប្រមូលព័ត៌មានលំអិតឲ្យបានច្រើនអំពីហេតុការណ៍ បរិបទ កម្រិតភាពធ្ងន់ធ្ងរ ការឆ្លើយតប និងលទ្ធផលទៅតាមដែលអាចធ្វើបាន)

២២. ប្រសិនបើអ្នកមានបញ្ហាជាក់លាក់ (ឧ. ប្រសិនបើមាននរណាម្នាក់បង្គ្រោះថ្នាក់ដល់អ្នក) តើមាននរណាម្នាក់ដែលអ្នកអាចប្រាប់រឿងនោះទៅគាត់បាន ដែរឬទេ? តើរឿងនេះធ្លាប់កើតឡើងដែរឬទេ?

២៣. តើមាននរណាម្នាក់នៅក្នុងមណ្ឌលនេះធ្លាប់និយាយអំពីបញ្ហាផ្លូវភេទ ប្រើប្រាស់ពាក្យសំដីផ្លូវភេទ ឬស្ទាបអ្នកក្នុងន័យផ្លូវភេទ ដែលធ្វើឲ្យអ្នកមានអារម្មណ៍មិនងាយស្រួល ឬមិនសប្បាយចិត្តដែរឬទេ? តើគាត់នរណា? តើធ្លាប់មាននរណាម្នាក់បានសុំអ្នក ឬបង្ខំអ្នកឱ្យរួមភេទជាមួយពួកគេដោយអ្នកមិនចង់ដែរឬទេ? តើអ្នកមានប្រាប់នរណា ដែរឬទេ? ហេតុអ្វីប្រាប់/ហេតុអ្វីមិនប្រាប់? (ប្រសិនបើមានចូរព្យាយាមប្រមូលព័ត៌មានលំអិតឲ្យបានច្រើនអំពីហេតុការណ៍ បរិបទ កម្រិតភាពធ្ងន់ធ្ងរ ការឆ្លើយតប និងលទ្ធផល ទៅតាមដែលអាចធ្វើបាន)

២៤. ជាទូទៅអ្នកមានអារម្មណ៍ដូចម្ដេចចំពោះទីកន្លែងនេះ? តើមានអ្វីខ្លះដែលអ្នកចូលចិត្ត និងអ្វីខ្លះដែលអ្នកមិនចូលចិត្ត? តើឥឡូវនេះអ្នកមានបញ្ហាថ្មីដែលកំពុងដោះស្រាយឬទេ? តើមានអ្វីនៅក្នុងជីវិតរបស់អ្នកដែលអ្នកចង់ធ្វើការផ្លាស់ប្ដូរ ដែរឬទេ?

២៥. តើអ្នកដឹងទេថាតើអ្នកនឹងស្នាក់នៅទីនេះរយៈពេលប៉ុន្មាន? តើអ្នកចង់ស្នាក់នៅរយៈពេលប៉ុន្មាន?

២៦. តើអ្វីៗមានភាពប្រសើរឡើងដែរឬទេ ចាប់តាំងពីអ្នកបានមកស្នាក់នៅទីនេះ? តើវាមានភាពប្រសើរឡើងដូចម្ដេចខ្លះ?

២៧. តើគោលដៅ និងសេចក្ដីសង្ឃឹមរបស់អ្នកមានអ្វីខ្លះសម្រាប់ពេលអនាគត?

## អនុសាសន៍

២៨. បើក្រឡេកមើលទៅក្រោយវិញ តើអ្នកសប្បាយរីករាយក្នុងការមករស់នៅទីនេះឬទេ ? បើក្រឡេកមើលទៅក្រោយវិញ តើអ្នកប្រាថ្នាឱ្យអ្វីៗត្រូវបានដោះស្រាយក្នុងលក្ខណៈខុសប្លែកពីនេះ ដែរឬទេ ?

២៩. តើអ្នកគិតថាអ្វីខ្លះ នឹងធ្វើឲ្យកន្លែងនេះកាន់តែល្អប្រសើរជាងមុនសម្រាប់អ្នក និងកុមារដទៃទៀត ? ប្រសិនបើអ្នកអាចផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលវត្តអារាម ឬអង្គការដទៃទៀតអំពីរបៀបដែលគេអាចធ្វើឲ្យប្រសើរឡើងនូវជីវិតរបស់កុមារ តើអ្នកនឹងផ្តល់អនុសាសន៍អ្វីខ្លះ ?

ថ្លែងអំណរគុណដល់អ្នកផ្តល់ចម្លើយចំពោះការចំណាយពេលរបស់ពួកគេ។

ពន្យល់ម្តងទៀតថា ការសិក្សានេះនឹងជួយឲ្យមានការយល់ដឹងអំពីហានិភ័យណាខ្លះដែលកុមារបានជួបប្រទះនៅក្នុងសហគមន៍ និងមានការចាត់វិធានការណាខ្លះដើម្បីកែលំអស្ថានភាពទាំងនោះសម្រាប់កុមារនៅពេលអនាគត។

# សេចក្តីណែនាំសម្រាប់ការពិភាក្សាជាក្រុម - កុមារក្រោមការថែទាំជំនួស

ប្រសើរបំផុត ការពិភាក្សាជាក្រុមគួរត្រូវធ្វើជាមួយកុមារដែលមានគ្នា ៦ទៅ ៨នាក់ និងជាមួយយុវជនដែលមានភេទដូចគ្នា អាយុចាប់ពី ១២ឆ្នាំ ឡើងទៅ។ ការពិភាក្សានេះគួរធ្វើនៅកន្លែងឯកជនមួយដែលគ្មានអ្នកផ្សេងអាចស្តាប់ឮអ្នកផ្តល់ចម្លើយ។

ជាដំបូង ធ្វើការណែនាំខ្លួនអ្នក និងគោលបំណងនៃការសិក្សា៖
ការសិក្សានេះផ្តោតលើការថែទាំកុមារនៅក្នុងប្រទេសកម្ពុជា ជាពិសេស កុមារដែលមិនរស់នៅឯផ្ទះ ឬកុមារមិនទទួលបានការថែទាំពីឪពុកម្តាយរបស់ពួកគេ។ យើងកំពុងព្យាយាមស្វែងយល់ពីបទពិសោធន៍របស់អ្នក ដើម្បីយើងអាចដឹងថាតើមានអ្វីកំពុងកើតឡើងជាក់ស្តែង និងគួរធ្វើអ្វីបន្ថែមទៀតដើម្បីការពារកុមារនៅពេលអនាគត។ សូមពន្យល់ថាការសម្ភាសនេះធ្វើជាលក្ខណៈស្ម័គ្រចិត្ត ទទួលបានការព្រមព្រៀង និងប្រាប់អ្នកចូលរួមអំពីភាពអនាមិក។ ការពិភាក្សានេះ ត្រូវធ្វើឡើងលុះត្រាណាតែឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារអាយុក្រោម ១៨ឆ្នាំទាំងអស់បានយល់ព្រមឲ្យកុមារចូលរួម។

## សំណួរទាក់ទងនឹងប្រវត្តិ

១. ជាដំបូង តើអ្នកអាចប្រាប់អំពីខ្លួនអ្នកបន្តិចបានឬទេ៖ តើអ្នកអាយុប៉ុន្មាន?

២. តើអ្នកបានមករស់នៅទីនេះអស់រយៈពេលប៉ុន្មាន?

៣. តើអ្នកមកពីណា? តើអ្នកមកពីតំបន់ជិតនេះ ឬមកពីកន្លែងឆ្ងាយ?

## តើកុមារមករស់នៅក្នុងការថែទាំជំនួសយ៉ាងដូចម្តេច?

៤. សូមប្រាប់ខ្ញុំបន្តិចអំពីទីកន្លែងនេះ *(គឺសំដៅលើមណ្ឌលថែទាំវត្ត ផ្ទះស្នាក់នៅជាក្រុម ។ល។)* តើកន្លែងនេះគេបង្កើតមកមានគោលដៅអ្វីខ្លះ? តើមានកុមារប៉ុន្មាននាក់រស់នៅទីនេះ?

៥. តើកុមារប្រភេទណាខ្លះរស់នៅទីនេះ? តើកុមារមកស្នាក់នៅទីនេះមានអាយុប៉ុន្មាន? តើពួកគេជាមនុស្សមកពីតំបន់ជាក់លាក់ ឬ មានប្រវត្តិជាក់លាក់ ដែរឬទេ?

៦. តើអ្នកអាចផ្តល់ឱ្យខ្ញុំនូវឧទាហរណ៍ខ្លះបានដែរឬទេ ថាហេតុអ្វីបានជាកុមារមកស្នាក់នៅទីនេះ? តើពួកគេមានរឿងអ្វីខ្លះ? តើអ្នកអាចផ្តល់ឱ្យខ្ញុំនូវឧទាហរណ៍ខ្លះបានដែរឬទេ ថាហេតុអ្វីបានជាកុមារចាកចេញពីផ្ទះរបស់ពួកគេ ទៅរស់នៅកន្លែងផ្សេង? *(ប្រសិនបើកុមារនិយាយអំពីបទពិសោធន៍របស់ពួកគេ ឬលើកឧទាហរណ៍ពាក់ព័ន្ធជាមួយបទពិសោធន៍របស់មិត្តភក្តិរបស់ពួកគេ ត្រូវផ្តល់តម្រុយដើម្បីជជីកស្វែងយល់ថាវាមានហេតុការណ៍ ឬ ស្ថានភាពអ្វីដែលជម្រុញកុមារឲ្យមករស់នៅក្នុងមណ្ឌល)*។

៧. តើកុមារមកស្នាក់នៅទីនេះបានដោយរបៀបណា? តើនរណាសម្រេចថាកុមារត្រូវស្នាក់នៅទីនេះ? តើកុមារដែលមកសុំកន្លែងស្នាក់នៅដោយខ្លួនឯងដែរឬទេ? តើពួកគេត្រូវបានបញ្ជូនដោយមនុស្សធំពេញវ័យ ឬដោយអាជ្ញាធរ? ប្រើសិនបើដូច្នេះ តើនរណាជាអ្នកបញ្ជូនពួកគេ?

៨. *(សួរបន្ត ប្រសិនបើកុមារលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ)*។ តើនរណាខ្លះ បានចូលរួមធ្វើសេចក្ដីសម្រេចចិត្តបញ្ជូនអ្នកមកទីនេះ? តើឪពុកម្ដាយរបស់អ្នកបានចូលរួមឬទេ/តើពួកគាត់យល់ព្រមឬទេ? ចុះអ្នកវិញ តើអ្នកមានបានចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តដែរឬទេ?

៩. តើមានកុមារណាដែលគេមិនស្វាគមន៍ឲ្យមករស់នៅកន្លែងនេះដែរឬទេ? ហេតុអ្វី?

## តើនៅក្នុងកន្លែងថែទាំជំនួស កុមារជួបប្រទះបទពិសោធន៍អ្វីខ្លះ?

១០. ជាធម្មតា តើកុមារស្នាក់នៅកន្លែងនេះរយៈពេលប៉ុន្មាន? តើកុមារចាកចេញដោយមូលហេតុអ្វីខ្លះ? តើពួកគេទៅណាបន្ទាប់ពីពួកគេចាកចេញ? តើអ្នកដឹងថាអ្នកនឹងស្នាក់នៅទីនេះរយៈពេលប៉ុន្មាន? តើអ្នកចង់ស្នាក់នៅយូរប៉ុណ្ណា?

១១. សូមប្រាប់ខ្ញុំបន្តិចថាតើនៅទីនេះយ៉ាងម៉េចដែរសម្រាប់អ្នក? តើក្នុងថ្ងៃនីមួយៗអ្នកធ្វើអ្វីខ្លះ? (ផ្ដល់តម្រុយដើម្បីស្វែងយល់អំពីចំណុចខាងក្រោម)

ក. តើអាហារយ៉ាងម៉េចដែរនៅទីនេះ? តើអ្នកហូបប៉ុន្មានដង? តើអាហាររបស់អ្នកមានអ្វីខ្លះ?
ខ. តើអ្នកមានធ្លាក់ខ្លួនឈឺឬទេតាំងពីចូលមកនៅទីនេះ? តើអ្នកអាចទទួលបានជំនួយដែលអ្នកត្រូវការដែរឬទេ? (ប្រសិនបើឆ្លើយថាទេ) តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកឈឺ? តើអ្នកអាចប្រាប់នរណាបាន?
គ. តើអ្នកគេងនៅឯណា? តើអ្នកមានពូក ខ្នើយ ភួយ ។ល។ ឬទេ?
ឃ. តើអ្នកមានកន្លែងទុកដាក់របស់របររបស់អ្នក ដែរឬទេ?
ង. តើបង្គន់ និងបន្ទប់ងូតទឹកមានលក្ខណៈដូចម្ដេច? តើវាមានស្អាត ឬ កខ្វក់?
ច. តើអ្នកអាចងូតទឹកមួយថ្ងៃប៉ុន្មានដង? តើអ្នកមានកន្លែងឯកជនសម្រាប់ងូតទឹកដែរឬទេ ឬអ្នកត្រូវងូតទឹកនៅចំពោះមុខអ្នកដទៃ? តើអ្នកនោះជានរណា?

១២. តើកុមារនៅទីនេះទៅសាលារៀន ដែរឬទេ? តើអ្នកទៅសាលារៀនដែរឬទេ? (ប្រសិនបើអ្នកចូលរួមឆ្លើយថាបាទ/ចាស) តើអ្នកយល់យ៉ាងណាចំពោះសាលារៀន? តើវាពិបាកពេក ឬងាយស្រួលពេក? ចុះលោកគ្រូ-អ្នកគ្រូវិញយ៉ាងម៉េចដែរ? ចុះសិស្សផ្សេងទៀត? តើអ្នកមានការលំបាកអ្វីដែរឬទេនៅឯសាលារៀន?

១៣. (ក្រៅពីទៅរៀន) តើអ្នកមានភារកិច្ច ឬការងារផ្សេងដែលអ្នកត្រូវទទួលខុសត្រូវនៅកន្លែងនេះដែរឬទេ? តើជាការងារអ្វី? តើអ្នកចំណាយពេលប៉ុន្មានដើម្បីធ្វើការងារនេះ ក្នុង១ថ្ងៃ? តើការងារនេះពិបាកប៉ុណ្ណា?

១៤. តើអ្នកមាន«បុគ្គលិកសង្គមកិច្ច» ឬនរណាម្នាក់ដែលត្រូវបានចាត់តាំងឲ្យជួយអ្នកឬទេ? តើអ្នកនោះជាអ្នកណា? តើអ្នកដឹងថាពួកគេមកពីកន្លែងណាទេ? តើអ្នកជួបពួកគេញឹកញាប់ប៉ុណ្ណា? តើអ្នកពិភាក្សាអំពីបញ្ហាអ្វី? តើអ្នកយល់ថាវាមានសារៈប្រយោជន៍ដែរឬទេ?

១៥. តើអ្នកយល់យ៉ាងម៉េចដែរចំពោះបុគ្គលិក/អ្នកថែទាំនៅក្នុងកន្លែងនេះ? តើពួកគេធ្វើចំពោះអ្នកដូចម្ដេចខ្លះ? តើឥរិយាបថរបស់ពួកគេចំពោះអ្នក និងចំពោះកុមារផ្សេងទៀតដូចម្ដេចដែរ? តើពួកគេធ្វើចំពោះអ្នកខុសគ្នាពីការធ្វើចំពោះកុមារដទៃ ដែរឬទេ? តើខុសគ្នាដូចម្ដេចខ្លះ? ហេតុអ្វី?

១៦. តើអ្នកអាចផ្តល់ឧទាហរណ៍អំពីបទបញ្ជាមួយចំនួននៅកន្លែងនេះបានដែរឬទេ ? តើនឹងមានអ្វីកើតឡើងប្រសិនបើអ្នកមិនគោរពតាមបទបញ្ជា ? តើមានការដាក់ទោសដូចម្តេចខ្លះបើអ្នករំលោភបំពានបទបញ្ជា ? ( ផ្តល់តម្រុយដើម្បីសាកសួរស្វែងយល់អំពីទណ្ឌកម្មលើរាងកាយ ភាពញឹកញាប់ និងកម្រិតនៃភាពធ្ងន់ធ្ងរ )។

១៧. ប្រសិនបើកុមារម្នាក់មានបញ្ហាជាក់លាក់ ( ឧ. ប្រសិនបើមាននរណាម្នាក់បង្កគ្រោះថ្នាក់ដល់អ្នក ) តើមាននរណាម្នាក់ដែលកុមារអាចប្រាប់រឿងនោះទៅគាត់បាន ដែរឬទេ ? តើអ្នកបាន ដឹងថាករណីនេះធ្លាប់កើតឡើងដែរឬទេ ?

១៨. តើមាននរណាម្នាក់នៅក្នុងមណ្ឌលនេះធ្លាប់និយាយអំពីបញ្ហាផ្លូវភេទ ប្រើប្រាស់ពាក្យសំដីផ្លូវភេទ ឬស្ទាបកុមារនៅទីនេះក្នុងន័យផ្លូវភេទ ដែរឬទេ ? តើគាត់ជានរណា ? តើមាននរណាដែលអ្នកអាចប្រាប់បានដែរឬទេ ? ហេតុអ្វីប្រាប់/ហេតុអ្វីមិនប្រាប់ ? ( ប្រសិនបើមាន ចូរព្យាយាមប្រមូលព័ត៌មានលំអិតឲ្យបានច្រើនអំពីហេតុការណ៍ បរិបទ ការឆ្លើយតប និងលទ្ធផល ទៅតាមដែលអាចធ្វើបាន ដរាបណាកុមារមានអារម្មណ៍ងាយស្រួល )។

១៩. ជាទូទៅអ្នកមានអារម្មណ៍ដូចម្តេចចំពោះទីកន្លែងនេះ ? តើមានអ្វីខ្លះដែលអ្នកចូលចិត្ត និងអ្វីខ្លះដែលអ្នកមិនចូលចិត្ត ? តើឥឡូវនេះអ្នកមានបញ្ហាថ្មីដែលកំពុងដោះស្រាយឬទេ ? តើមានអ្វីនៅក្នុងជីវិតរបស់អ្នកដែលអ្នកចង់ធ្វើការផ្លាស់ប្តូរ ដែរឬទេ ?

## ស៊ីណារីយ៉ូ

២០. វិន័យនៅឯផ្ទះ/មណ្ឌល/វត្តៈ ចិន្តា ពេលខ្លះធ្វើខុសបទបញ្ជានៅឯផ្ទះ ហើយរំខានដល់បុគ្គលិក/ព្រះសង្ឃ។ នៅពេលនាងរំខានដល់គេឯង អ្នកថែទាំឲ្យនាងអង្គុយបែរមុខទៅរកជញ្ជាំងនៅជ្រុងម្ខាងនៃបន្ទប់។ ពេលខ្លះ អ្នកថែទាំស្រែកដាក់ចិន្តា និងប្រើសំដីអាក្រក់។ ថ្ងៃមួយ ចិន្តាបានស្រែកដាក់អ្នកថែទាំវិញ។ អ្នកថែទាំបានតបតដោយហៅចិន្តាចេញក្រៅនិងវាយនាងជាការដាក់ទណ្ឌកម្ម។ ចិន្តាឈឺយ៉ាងខ្លាំង ហើយនាងត្រូវទៅមន្ទីរពេទ្យ។

សំណួរពិភាក្សាៈ តើអ្នកគិតយ៉ាងដូចម្តេចចំពោះសាច់រឿងនេះ ? តើអ្នកគិតថាអ្វីដែលអ្នកថែទាំធ្វើជារឿងធម្មតា ដែរឬទេ ? ហេតុអ្វីធម្មតា ឬហេតុអ្វីមិនធម្មតា ? តើចិន្តាគួរធ្វើដូចម្តេច ? តើនាងនឹងប្រាប់នរណាដែរឬទេ ? ហេតុអ្វី ?តើនាងអាចប្រាប់នរណាបាន ? តើបុគ្គលដែលនាងរាយការណ៍ប្រាប់អាចធ្វើអ្វីបានខ្លះ ? បើអ្នកថែទាំវាយចិន្តាតើអាចផ្លាស់ប្តូរអ្វីបានខ្លះ ? តើវាបានធ្វើឲ្យប្រសើរអ្វីខ្លះ ? ហេតុអ្វី ?

តើអ្វីដែលបានរៀបរាប់ក្នុងសាច់រឿងនេះ ពេលខ្លះវាកើតឡើងដែរឬទេ ? តើអ្នកអាចប្រាប់ខ្ញុំអំពីករណីណាមួយបានដែរឬទេ ?

២១. ការបំពានផ្លូវភេទៈ វណ្ណាកា គឺជាក្មេងប្រុសម្នាក់ដែលរស់នៅទីនេះ។ ថ្ងៃ១ វណ្ណាកា បានមកជួបអ្នកដោយមានទឹកមុខក្រៀមក្រំ។ គាត់ប្រាប់អ្នកថាព្រះសង្ឃ/អ្នកថែទាំតែងលេងសើចជាមួយគាត់។ ព្រះសង្ឃ/អ្នកថែទាំបានសួរវណ្ណាកាថាតើគាត់ចូលចិត្តស្រីឬទេ ហើយប្រាប់វណ្ណាកាថាគាត់មិនគួរមានក្តីស្រម៉ៃអំពីស្រីៗនោះទេ។ ព្រះសង្ឃ/អ្នកថែទាំបានសុំឲ្យវណ្ណាកាបង្ហាញលិង្គរបស់គាត់។

ព្រះសង្ឃ/អ្នកថែទាំបានចាប់ផ្ដើមចាប់ទាញ និងលេងលិង្គរបស់វណ្ណា។ ព្រះសង្ឃប្រាប់វណ្ណាកា មិនឲ្យគិតពីរឿងទាំងនោះតទៅទៀត។

សំណួរសម្រាប់ពិភាក្សា៖ តើអ្នកគិតយ៉ាងដូចម្ដេចចំពោះសាច់រឿងនេះ? តើសាច់រឿងបែបនេះ អាចកើតឡើងនៅទីនេះឬទេ? តើមានអ្វីបានកើតឡើងខ្លះ? ប្រសិនបើមានរឿងដូច្នេះមែន តើអ្នកនឹងធ្វើអ្វីខ្លះ? តើគាត់នឹងប្រាប់អ្នកដទៃដែរឬទេ? ហេតុអ្វីត្រូវប្រាប់ ឬហេតុអ្វីមិនត្រូវប្រាប់? តើគាត់អាចប្រាប់នរណាបាន? តើបុគ្គលនេះនឹងដោះស្រាយដូចម្ដេច?

## អនុសាសន៍

២២. បើក្រឡេកមើលទៅក្រោយវិញ តើអ្នកសប្បាយរីករាយក្នុងការមករស់នៅទីនេះឬទេ? បើក្រឡេកមើលទៅក្រោយវិញ តើអ្នកប្រាថ្នាឱ្យអ្វីៗត្រូវបានដោះស្រាយក្នុងលក្ខណៈខុសប្លែកពីនេះ ដែរឬទេ?

២៣. តើអ្នកគិតថាអ្វីខ្លះ នឹងធ្វើឲ្យកន្លែងនេះកាន់តែល្អប្រសើរជាងមុនសម្រាប់អ្នក និងកុមារដទៃទៀត? ប្រសិនបើអ្នកអាចផ្ដល់អនុសាសន៍ជូនរដ្ឋាភិបាល វត្តអារាម ឬអង្គការដទៃទៀត អំពីរបៀបដែលគេអាចធ្វើឲ្យប្រសើរឡើងនូវជីវិតរបស់កុមារ តើអ្នកនឹងផ្ដល់អនុសាសន៍អ្វីខ្លះ?

ថ្លែងអំណរគុណដល់អ្នកផ្ដល់ចម្លើយចំពោះការចំណាយពេលរបស់ពួកគេ។

ពន្យល់ម្ដងទៀតថា ការសិក្សានេះនឹងជួយឲ្យមានការយល់ដឹងអំពីហានិភ័យណាខ្លះដែលកុមារបានជួបប្រទះនៅក្នុងសហគមន៍ និងមានការចាត់វិធានការណាខ្លះដើម្បីកែលំអស្ថានភាពទាំងនោះសម្រាប់កុមារនៅពេលអនាគត។

# បញ្ជីផ្ទៀងផ្ទាត់តាមរយៈការសង្កេត

សូមឲ្យបុគ្គលដែលទទួលខុសត្រូវនៅក្នុងមណ្ឌលថែទាំជំនួស ផ្តល់ការយល់ព្រមមុននឹងយកបញ្ជីផ្ទៀងផ្ទាត់នេះមកប្រើ។ ជាធម្មតាបុគ្គលទទួលខុសត្រូវនោះគឺជាអ្នកគ្រប់គ្រង/អ្នកតាមដាននៅក្នុងផ្ទះស្នាក់នៅជាក្រុម ឬមណ្ឌលថែទាំ ឬជាព្រះសង្ឃជាន់ខ្ពស់ ឬជាមេគ្រួសារធម៌ ឬមេគ្រួសារនៃសាច់ញាតិដែលចិញ្ចឹមកុមារនោះ។

ការបំពេញបញ្ជីនេះ គួរចំណាយពេលប្រហែល ៥ ទៅ ១០នាទី។ សូមបង្ហាញការគោរព និងមិនត្រូវទន្ទ្រានតាមចិត្តនោះទេ នៅពេលដែលអ្នកចូលទៅកាន់កន្លែងទាំងនេះដើម្បីធ្វើការសង្កេតមើល។ លើសពីនេះ ដើម្បីទទួលបានការយល់ព្រមពីបុគ្គលទទួលខុសត្រូវ សូមជម្រាបគាត់ថារាល់ព័ត៌មានដែលប្រមូលបាននៅក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ នឹងរក្សាជាអនាមិកបំផុត ហើយអ្នកនឹងមិនសរសេរឈ្មោះរបស់គាត់ ឬឈ្មោះរបស់ទីកន្លែងនោះទេ។

| ព័ត៌មានអំពីសាវតា | | |
|---|---|---|
| រាជធានីខេត្ត ( សូមគូសសញ្ញា ✓ ជ្រើសរើស ) | ☐ ភ្នំពេញ<br>☐ កណ្តាល<br>☐ ព្រះសីហនុ | ☐ សៀមរាប<br>☐ បាត់ដំបង |
| **ឃុំ** ( សូមសរសេរឈ្មោះឃុំ ) | ........................................................................................................................ | |
| **ឈ្មោះ** ( សូមសរសេរឈ្មោះមណ្ឌល ) | ........................................................................................................................ | |
| **កាលបរិច្ឆេទ** ( សូមសរសេរកាលបរិច្ឆេទថ្ងៃដែលអ្នកបានចុះទៅដល់ ) | ................../................./...២០១៦ | |
| **ប្រភេទនៃការថែទាំជំនួស** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើសចម្លើយលើសពីមួយ ) | ☐ ថែទាំដោយឪពុកម្តាយធម៌<br>☐ ថែទាំដោយសាច់ញាតិ<br>☐ ផ្ទះស្នាក់នៅជាក្រុម<br>☐ វត្ត<br>☐ មណ្ឌលសាសនាដទៃទៀត | ☐ មណ្ឌលថែទាំ<br>☐ អន្តេវាសិកដ្ឋាន<br>☐ ផ្សេងៗ ( សូមបញ្ជាក់ខាងក្រោម )<br>......................... |

| បញ្ជីផ្ទៀងផ្ទាត់ | | |
|---|---|---|
| តើកន្លែងនេះមានប្រព័ន្ធលូទឹកដែលមានដំណើការ ដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើកុមារមានទឹកសុវត្ថិភាពសម្រាប់បរិភោគដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើមានសម្ភារៈបន្ទប់ទឹកដែរឬទេ ? (ដូចជាសាប៊ូ កន្សែង និងច្រាសដុសធ្មេញ) | ☐ បាទ/ចាស | ☐ ទេ |
| តើមានកន្លែងទុកដាក់សម្រាមដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើមានការសម្រួលដល់ការចូលបន្ទប់ទឹកដែរឬទេ ? (រាប់បញ្ចូលទាំងសម្រាប់កុមារពិការ) | ☐ បាទ/ចាស | ☐ ទេ |
| តើកុមារទាំងអស់មានពូកសម្រាប់គេងឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើគ្រប់គ្រែទាំងអស់មានមុងដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើមានកន្លែងសម្រាប់កុមារលេងដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| **សម្រាប់តែផ្ទះស្នាក់នៅជាក្រុម** | | |
| តើកុមារអាយុលើសពី ៦ឆ្នាំត្រូវបានបំបែកតាមភេទឬទេ ? (សម្រាប់ការគេង និងបន្ទប់ទឹក) | ☐ បាទ/ចាស | ☐ ទេ |
| តើមានសត្វ (មាន់ ទា ជ្រូក ។ល។) នៅក្នុងបរិវេណ ឬនៅក្បែរបរិវេណរស់នៅដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |
| តើត្រពាំង ឬបឹងនៅក្នុងបរិវេណមានរបងព័ទ្ធជុំវិញដែរឬទេ ? | ☐ បាទ/ចាស | ☐ ទេ |

| សម្រាប់មណ្ឌល/ផ្ទះស្នាក់នៅទាំងអស់ | | | | | |
|---|---|---|---|---|---|
| តើអ្នកដាក់ពិន្ទុឲ្យប៉ុន្មានចំពោះលក្ខខណ្ឌជារូបវ័ន្តដែលកុមាររស់នៅ ? (សូមគូសយកចម្លើយដែលប្រសើរជាងគេបំផុត)<br>១ = មិនល្អ; ៥ = ល្អណាស់ | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៤ | ☐ ៥ |

# ឧបករណ៍អង្កេតសម្រាប់អ្នកថែទាំកុមារ/អ្នកគ្រប់គ្រង

ដោយមានកិច្ចគាំទ្រពីអង្គការយូនីសេហ្វ អង្គការរបស់យើងដែលមានឈ្មោះថាក្វាំមអន្តរជាតិ កំពុងធ្វើការសិក្សាស្រាវជ្រាវមួយអំពីទម្រង់ផ្សេងៗគ្នានៃការរៀបចំផ្តល់ការថែទាំជំនួសតាមសហគមន៍ក្នុងប្រទេសកម្ពុជា។ យើងកំពុងពិនិត្យមើលទៅលើការថែទាំតាមផ្ទះរស់នៅជាក្រុមវត្តអារាម និងកន្លែងសាសនាដទៃទៀត ការថែទាំដោយសាច់ញាតិនិង ការថែទាំដោយឪពុកម្តាយចិញ្ចឹម។ យើងមានបំណងចង់រៀនសូត្រពីអ្នកអំពីការងាររបស់អ្នកក្នុងការផ្តល់ការថែទាំជំនួសចំពោះកុមារ ដើម្បីជួយឱ្យយើងយល់ថាតើការថែទាំជំនួសមាន ដំណើរការដូចម្តេចនៅក្នុងការអនុវត្តន៍ជាក់ស្តែង។ យើងបានរៀបចំសំនួរមួយចំនួន ដែលអ្នកអាចត្រូវចំណាយពេលប្រមាណ ១០ ទៅ ១៥នាទីប៉ុណ្ណោះ ដើម្បីឆ្លើយ។ សូមអ្នកឆ្លើយដោយស្មោះត្រង់បំផុតទៅតាមដែលអាចធ្វើទៅបាន អាស្រ័យដោយយើងចង់រៀនសូត្រពីចំណេះដឹង និងបទពិសោធន៍របស់អ្នក។ រាល់ព័ត៌មានដែលអ្នកផ្តល់ឱ្យយើង នឹងត្រូវរក្សាជាអនាមិកហើយយើងនឹងមិនសរសេរបញ្ជាក់ឈ្មោះរបស់អ្នក ឬ កន្លែងថែទាំកុមាររបស់អ្នកឡើយ។

អ្នកមិនចាំបាច់បំពេញទម្រង់អង្កេតនោះទេ ប្រសិនបើអ្នកមិនចង់ ហើយអ្នកអាចជ្រើសរើសមិនឆ្លើយសំនួរណាមួយ ឬ សំនួរទាំងអស់បាន។ តើអ្នកចង់ធ្វើការអង្កេតនេះ ដែរឬទេ ? ( សូមគូររង្វង់ជ្រើសរើសចម្លើយ )

បាទ-ចាស / ទេ

យើងចង់ប្រើប្រាស់ព័ត៌មានមួយចំនួនដែលអ្នកប្រាប់យើង នៅក្នុងរបាយការណ៍របស់យើង ប៉ុន្តែ យើងនឹងមិនបង្ហាញឈ្មោះរបស់អ្នកឡើយ។ តើបានដែរឬទេ ? ( សូមគូររង្វង់ជ្រើសរើសចម្លើយ )

បាទ-ចាស / ទេ

| ព័ត៌មានអំពីសារពើ | | |
|---|---|---|
| **ខេត្ត** ( សូមគូសសញ្ញា ✓ ជ្រើសរើស ) | ☐ ភ្នំពេញ<br>☐ កណ្តាល<br>☐ ព្រះសីហនុ | ☐ សៀមរាប<br>☐ បាត់ដំបង |
| **ឃុំ** ( សូមសរសេរឈ្មោះឃុំរបស់អ្នក ) | ............................................................................................ | |
| **ឈ្មោះកន្លែងថែទាំកុមារ** ( សូមសរសេរ ឈ្មោះកន្លែងថែទាំកុមាររបស់អ្នក ) | ឈ្មោះ:............................................................./ មិនមែនកន្លែងថែទាំកុមារ | |

| | | |
|---|---|---|
| **ប្រភេទការថែទាំជំនួសដែលអ្នកផ្ដល់ជូន** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើស ចម្លើយលើសពីមួយ) | ☐ ការថែទាំដោយឪពុកម្ដាយចិញ្ចឹម<br>☐ ការថែទាំដោយសាច់ញាតិ<br>☐ ផ្ទះស្នាក់នៅជាក្រុម<br>☐ វត្តអារាម<br>☐ កន្លែងសាសនាដទៃទៀត | ☐ មណ្ឌលថែទាំកុមារ<br>☐ សាលារៀនដែលផ្ដល់កន្លែងស្នាក់នៅ<br>☐ ផ្សេងៗ (សូមបញ្ជាក់ខាងក្រោម)<br>......................... |
| **តើអ្នកមានតួនាទីអ្វីនៅក្នុងកន្លែងថែទាំ កុមារ/ផ្ទះស្នាក់នៅនេះ?** (សូមជ្រើសរើស ចម្លើយដែលប្រសើរបំផុត) | ☐ អ្នកគ្រប់គ្រង/អ្នកមើលការខុសត្រូវ<br>☐ អ្នកផ្ដល់ការថែទាំ<br>☐ គ្រូបង្រៀន<br>☐ អ្នកផ្ដល់មគ្គុទ្ទេសក៍ណែនាំខាងសាសនា | ☐ ម្ដាយ<br>☐ ឪពុក<br>☐ (សូមបញ្ជាក់ខាងក្រោម)<br>......................... |
| **តើអ្នកបានដើរតួនាទីនេះរយៈពេល ប៉ុន្មាន?** (សូមជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ តិចជាង ១ឆ្នាំ<br>☐ ១ឆ្នាំ<br>☐ ២ឆ្នាំ | ☐ ៣ឆ្នាំ<br>☐ ៤ឆ្នាំ ឬ ច្រើនជាងនេះ |
| **តើអ្នកមានភេទអ្វី?** (សូមគូសសញ្ញា ✓ ជ្រើសរើស) | ☐ ប្រុស | ☐ ស្រី |
| **តើអ្នកមានអាយុប៉ុន្មាន** (សូមបញ្ជាក់) | ..................................... ឆ្នាំ | |
| **តើអ្នកបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា ដែរឬទេ?** (សូមគូសសញ្ញា ✓ ជ្រើសរើស) | ☐ បាទ-ចាស | ☐ ទេ |
| **នៅក្នុងកន្លែងថែទាំ/ផ្ទះស្នាក់នៅរបស់អ្នក តើមានអ្នកផ្ដល់ការថែទាំចំនួនប៉ុន្មាន នាក់?** (សូមបញ្ជាក់) | មានអ្នកថែទាំចំនួន........................... នាក់ | |
| **នៅក្នុងកន្លែងថែទាំ/ផ្ទះស្នាក់នៅរបស់អ្នក តើមានកុមារចំនួនប៉ុន្មានអ្នក?** (សូមបញ្ជាក់) | កុមារាចំនួន......................... នាក់ / កុមារីចំនួន.......................... នាក់ | |
| **តើកុមារដែលរស់នៅក្នុងកន្លែងថែទាំ/ ផ្ទះស្នាក់នៅរបស់អ្នក មានអាយុប៉ុន្មាន?** (សូមគូសសញ្ញា ✓ ជ្រើសរើសរាល់ប្រអប់ដែលសមស្រប) | ☐ អាយុក្រោម១ឆ្នាំ<br>☐ 1-3 ឆ្នាំ<br>☐ 3-6 ឆ្នាំ<br>☐ 6-10 ឆ្នាំ | ☐ 10-14 ឆ្នាំ<br>☐ 14-18 ឆ្នាំ<br>☐ ១៨ឆ្នាំឡើងទៅ |
| **តើមានកុមារដែលមានសេចក្ដីត្រូវការ ពិសេស រស់នៅក្នុងកន្លែងថែទាំ/ ផ្ទះស្នាក់នៅរបស់អ្នក ដែរឬទេ?** (សូមគូសសញ្ញា ✓ ជ្រើសរើសរាល់ប្រអប់ដែលសមស្រប) | ☐ ទេ | ☐ បាទ/ចាស ផ្ទុកមេរោគអេដស៍<br>☐ បាទ/ចាស កុមារពិការ |

| | | |
|---|---|---|
| **ជាទូទៅ តើកុមាររស់នៅក្រោមការថែទាំរបស់អ្នក រយៈពេលប៉ុន្មាន?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ តិចជាង១សប្តាហ៍<br>☐ ១សប្តាហ៍ ទៅ ១ខែ | ☐ ១ខែ ទៅ ១ឆ្នាំ<br>☐ អចិន្ត្រៃយ៍ |
| **ការអប់រំ** | | |
| **តើកុមារដែលស្ថិតក្រោមការថែទាំរបស់អ្នកទទួលបានការអប់រំប្រភេទណា?** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើស ចម្លើយលើសពីមួយ) | ☐ សាលាបឋមសិក្សារដ្ឋ<br>☐ សាលាមធ្យមសិក្សារដ្ឋ<br>☐ រៀនសូត្រនៅតាមវត្តអារាម ឬតាមកន្លែងសាសនា | ☐ រៀនសូត្រនៅតាមអង្គការមិនមែនរដ្ឋាភិបាល<br>☐ ការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>☐ គ្មានទទួលបានការអប់រំ<br>☐ ផ្សេងៗ (សូមបញ្ជាក់)<br>............................................. |
| **ការត្រួតពិនិត្យ** | | |
| **តើកន្លែងថែទាំ/ផ្ទះស្នាក់នៅរបស់អ្នក បានផ្តល់ការថែទាំជំនួសចំពោះកុមារ រយៈពេលប៉ុន្មាន?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ តិចជាង១ឆ្នាំ<br>☐ 1 - 2 ឆ្នាំ | ☐ លើសពី ២ឆ្នាំ |
| **តើមន្ត្រីពីខាងក្រៅចុះមកពិនិត្យមើលកន្លែងថែទាំ/ផ្ទះស្នាក់នៅរបស់អ្នកញឹកញាប់កម្រិតណា ដើម្បីធានាថាកុមារមានសុវត្ថិភាព?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ យ៉ាងហោចណាស់១ខែ ម្តង<br>☐ យ៉ាងហោចណាស់រៀងរាល់៣ខែម្តង<br>☐ យ៉ាងហោចណាស់រៀងរាល់៤ខែម្តង | ☐ យ៉ាងហោចណាស់រៀងរាល់៦ខែម្តង<br>☐ យ៉ាងហោចណាស់រៀងរាល់១ឆ្នាំម្តង<br>☐ តិចជាង១ឆ្នាំម្តង<br>☐ មិនដែល |
| **តើនរណាជាអ្នកចុះធ្វើការត្រួតពិនិត្យ សុវត្ថិភាពទាំងនេះ?** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើសចម្លើយលើសពីមួយ) | ☐ មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា<br>☐ អង្គការមិនមែនរដ្ឋាភិបាល<br>☐ គ្មានការចុះពិនិត្យ | ☐ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ<br>☐ ផ្សេងៗ (សូមបញ្ជាក់ខាងក្រោម)<br>.................................. |

| | | |
|---|---|---|
| **តើមន្ត្រីពីខាងក្រៅចុះមកពិនិត្យមើលកុមារ ដែលស្ថិតនៅក្រោមការថែទាំរបស់អ្នក ញឹកញាប់កម្រិតណា ដើម្បីវាយតម្លៃទៅលើ លទ្ធភាពក្នុងការធ្វើសមាហរណកម្មទៅក្នុង គ្រួសារស៊ាំ/គ្រួសារបង្កើត?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ យ៉ាងហោចណាស់រៀងរាល់៤ខែម្តង<br>☐ យ៉ាងហោចណាស់រៀងរាល់៦ខែម្តង<br>☐ យ៉ាងហោចណាស់រៀងរាល់១ឆ្នាំម្តង | ☐ តិចជាង១ឆ្នាំម្តង<br>☐ មិនដែល<br>☐ មិនត្រឹមត្រូវ (ដោយសារតែកុមារស្ថិតនៅក្រោមការថែទាំដោយឪពុកម្តាយចិញ្ចឹម ឬការថែទាំដោយសាច់ញាតិរួចទៅហើយ) |
| **តើនរណាជាអ្នកចុះពិនិត្យដើម្បីវាយតម្លៃ ទៅលើលទ្ធភាពក្នុងការធ្វើសមាហរណកម្ម ទាំងនេះ?** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើស <u>ចម្លើយលើសពីមួយ</u>) | ☐ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>☐ អង្គការមិនមែនរដ្ឋាភិបាល<br>☐ គ្មានការចុះពិនិត្យ | ☐ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ<br>☐ ផ្សេងៗ (សូមបញ្ជាក់ខាងក្រោម)<br>................................. |
| **តើអ្នករក្សាកំណត់ហេតុលាយលក្ខណ៍អក្សរ អំពីកុមារដែលស្ថិតនៅក្រោមការថែទាំ របស់អ្នក ដែរឬទេ?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត) | ☐ បាទ/ចាស ចំពោះកុមារគ្រប់រូប<br>☐ បាទ/ចាស ចំពោះកុមារមួយចំនួនប៉ុណ្ណោះ<br><br>បើទោះបីជាចំពោះតែកុមារ មួយចំនួនក៏ដោយ សូមបញ្ជាក់ថាតើមានការរក្សាកំណត់ហេតុចំពោះកុមារ ចំនួនប៉ុន្មាននាក់៖ | ☐ គ្មាន<br><br>កុមារចំនួន.................នាក់ |
| **ការបណ្តុះបណ្តាល** | | |
| **តើអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលណាមួយ អំពីការផ្តល់ប្រឹក្សា និង របៀបកំណត់អំពីអំពើរំលោភបំពានកុមារ ដែរឬទេ?** (សូមគូសសញ្ញា ✓ ជ្រើសរើស) | ☐ បាទ/ចាស | ☐ ទេ |
| **ប្រសិនបើធ្លាប់ តើនរណាជាអ្នកផ្តល់ការបណ្តុះបណ្តាលនេះ?** (សូមគូសសញ្ញា ✓ ជ្រើសរើស) | ☐ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ☐ អង្គការមិនមែនរដ្ឋាភិបាល<br>☐ ផ្សេងៗ (សូមបញ្ជាក់)<br>.................................... |

| | | | | | |
|---|---|---|---|---|---|
| **តើអ្នកយល់ថាការបណ្តុះបណ្តាលនេះមានសារៈប្រយោជន៍ដល់កម្រិតណា ក្នុងការរៀបចំត្រៀមលក្ខណៈខ្លួនអ្នកសម្រាប់ការងារ ថែទាំជាក់ស្តែងដែលអ្នកធ្វើ?** (សូមគូសសញ្ញា ✓ ជ្រើសរើសចម្លើយដែលប្រសើរបំផុត)<br>1 = មិនសូវមានប្រយោជន៍<br>5 = មានប្រយោជន៍ខ្លាំងណាស់ | ☐ 1 | ☐ 2 | ☐ 3 | ☐ 4 | ☐ 5 |

## មូលនិធិ
## (សម្រាប់តែអ្នកគ្រប់គ្រង និង អ្នកមើលការខុសត្រូវប៉ុណ្ណោះ)

| | | |
|---|---|---|
| តើអ្នកបានទទួលមូលនិធិពីខាងក្រៅសម្រាប់ផ្តល់ការថែទាំជំនួស ដែរឬទេ? | ☐ បាទ/ចាស | ☐ ទេ |
| **ប្រសិនបើអ្នកបានទទួល សូមបញ្ជាក់ថាតើអ្នកបានទទួលមូលនិធិពីខាងក្រៅ ពីប្រភពណា** (អ្នកអាចគូសសញ្ញា ✓ ជ្រើសរើសចម្លើយលើសពីមួយ) | ☐ រដ្ឋាភិបាល<br>☐ មូលនិធិសុខុមាលភាពកុមារ<br>☐ ស្ថាប័នសាសនាអន្តរជាតិ<br>☐ ស្ថាប័នសាសនាក្នុងស្រុក | ☐ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ<br>☐ អង្គការមិនមែនរដ្ឋាភិបាលជាតិ<br>☐ បុគ្គលឯកជន<br>☐ ផ្សេងៗ (សូមបញ្ជាក់)<br>................................. |

unicef
for every child

USAID
FROM THE AMERICAN PEOPLE

coram international